# ថ្ងៃទី 01 ខែសីហា ឆ្នាំ២០១៩

## សកម្មជនរិះរកវិធីបញ្ចៀសការកេងប្រវ័ញ្ចពលករនៅជប៉ុន

https://khmer.voanews.com/ 01 សីហា 2019 ម៉ែន គឹមសេង

ប្រទេសជប៉ុនមានគម្រោងជ្រើសរើសកម្មករជំនាញចំនួន៣៤៥.០០០នាក់ក្នុងរយៈពេល៥ឆ្នាំខាងមុខដើម្បីធ្វើការងារនៅផ្នែកភោជនីយដ្ឋាន សំណង់ កសិកម្ម និងថែរក្សាមនុស្សចាស់។ ពលករនឹងមកពីបណ្តាប្រទេសមួយចំនួនដែលមានដូចជាចិន ភូមា វៀតណាម ហ្វីលីពីន និងកម្ពុជាជាដើម។

វ៉ាស៊ីនតោន៖ ក្នុងពេលដែលប្រទេសជប៉ុនកំពុងតែត្រៀមលក្ខណៈទទួលយកពលករពីបណ្តាប្រទេសនៅតំបន់អាស៊ីដើម្បីបំពេញកង្វះខាតកម្លាំងពលកម្មដោយសារតែពលរដ្ឋជប៉ុនមានវ័យចំណាស់ ក្រុមសកម្មជនការពារសិទ្ធិពលករបានស្នើឡើងនូវវិធានការសុវត្ថិភាព និងសន្តិសុខការងារដើម្បីជៀសវាងបញ្ហាប្រឈមនានាដែលបានកើតមានឡើងចំពោះពលករដូចក្នុងពេលកន្លងមក។

សកម្មជនសិទ្ធិពលករដែលមកពីប្រទេសជប៉ុន កម្ពុជា វៀតណាម និងភូមា បានពិភាក្សាគ្នានៅទីក្រុងតូក្យូកាលពីដើមខែកក្កដា ដោយផ្តោតលើបញ្ហាដែលអាចជួយសម្រួលការងារដល់ពលករដែលមានដូចជាក្រមប្រតិបត្តិសម្រាប់ក្រុមហ៊ុនជ្រើសរើសពលករ ការកំណត់កម្រៃជើងសារទាបបំផុត ប្រព័ន្ធផ្តល់ព័ត៌មានត្រឹមត្រូវ និងសារៈសំខាន់នៃការចងក្រងជាបណ្តាញជាដើម។ ពួកគេទាមទារឱ្យរដ្ឋាភិបាលជប៉ុនរៀបចំគោលការណ៍ជាក់លាក់សម្រាប់ការអនុវត្តដើម្បីជៀសវាងបញ្ហានានា។ នេះបើតាមការបញ្ជាក់របស់បណ្តាញជនចំណាកស្រុកតំបន់មេគង្គ។

អ្នកស្រី រីកូ ហារីម៉ា អ្នកសម្របសម្រួលថ្នាក់តំបន់នៃបណ្តាញជនចំណាកស្រុកតំបន់មេគង្គយល់ថាការកំណត់តម្លៃកម្រៃជើងសារច្បាស់លាស់នឹងជួយទប់ស្កាត់ក្រុមហ៊ុនជ្រើសរើសបុគ្គលិកទុច្ចរិតមួយចំនួនដែលគំរាមទារប្រាក់ពីពលករច្រើនហួសហេតុដែលធ្វើឱ្យពួកគេជំពាក់បំណុលច្រើន។ អ្នកស្រីរីកូ ហារីម៉ាបានបន្ថែមប្រាប់វីអូអេថា៖ «នៅពេលដែលកម្មករជំពាក់បំណុលគឺពួកគេពិបាកមកដាក់ពាក្យបណ្តឹងនៅការិយាល័យរបស់រដ្ឋាភិបាល អំពីការកេងប្រវ័ញ្ចកម្លាំងពលកម្ម ប្រាក់កម្រៃការងារនិងបញ្ហាការងារដទៃទៀតដែលពួកគេទទួលរងពីថៅកែជប៉ុន»។ ក្នុងពេលកន្លងមកមានការយកថ្លៃសេវាជ្រើសរើសខ្ពស់ដូចជានៅប្រទេសវៀតណាមច្បាប់តម្រូវឱ្យយកតែ ៣៦០០ដុល្លារប៉ុន្តែក្រុមហ៊ុនទាររហូតដល់ ៧០០០ ឬ ១០០០០ដុល្លារ។ រីឯនៅកម្ពុជាមិនមានការកំណត់តម្លៃទេប៉ុន្តែពលករខ្លះបានចំណាយប្រាក់ចន្លោះពី៥០០០ទៅ៧០០០ដុល្លារដើម្បីបានទៅធ្វើការ។ អ្នកស្រីរីកូ ហារីម៉ា បានបន្ថែមថាដោយសារតែហេតុនេះមានពលករមួយចំនួនបានរត់ចោលក្រុមហ៊ុនចាស់ទៅធ្វើការនៅកន្លែងដែលទទួលបានប្រាក់ខែច្រើន៖ « ជារឿយៗរដ្ឋាភិបាលនៅប្រទេសទាំងសងខាង និងក្រុមហ៊ុនជ្រើសរើសពលករនិយាយអំពីពលកររត់ចោលការងារថាជាបញ្ហាមួយ ប៉ុន្តែយើងមើលឃើញថាប្រសិនបើបញ្ហាប្រាក់បំណុលរបស់ពលករត្រូវបានដោះស្រាយដោយការមិនយកកម្រៃជើងសារច្រើន គឺពួកគេនឹងមានសម្ពាធតិចតួច ក្នុងការខិតខំស្វែងរកការងារដែលបានប្រាក់ឈ្នួលខ្ពស់ ហើយយើងជឿថាការរត់ចោលការងារនឹងថយចុះដែរ»។

ប្រទេសជប៉ុនមានគម្រោងជ្រើសរើសកម្មករជំនាញចំនួន៣៤៥.០០០នាក់ក្នុងរយៈពេល៥ឆ្នាំខាងមុខដើម្បីធ្វើការងារនៅផ្នែកភោជនីយដ្ឋាន សំណង់ កសិកម្ម និងថែរក្សាមនុស្សចាស់។ ពលករនឹងមកពីបណ្តាប្រទេសមួយចំនួនដែលមានដូចជាចិន ភូមា វៀតណាម ហ្វីលីពីន និងកម្ពុជាជាដើម។ ការណ៍នេះដោយសារតែប្រទេសជប៉ុនបានធ្វើវិសោធនកម្មច្បាប់អន្តោប្រវេសន៍របស់ខ្លួន ដែលមានលក្ខណៈតឹងរ៉ឹងដោយបន្ថែមឱ្យមានទិដ្ឋាការប្រភេទកម្មករជំនាញពិសេស។

ពលករខ្មែរដែលកំពុងបំពេញការងារនៅប្រទេសជប៉ុនគឺធ្វើឡើងក្រោមកម្មវិធីកម្មសិក្សាហើយ បច្ចុប្បន្នមានចំនួន៣.៣២៨នាក់។ កញ្ញា ឆែម ស្រីពៅ កម្មសិក្សាការីខ្មែរម្នាក់បានបញ្ជាក់ប្រាប់វីអូអេថា នាងបានចំណាយប្រាក់ចំនួន៥០០០ដុល្លារដើម្បីបានទៅធ្វើការនៅប្រទេសជប៉ុន។ កញ្ញាបានបន្ថែមទៀតថានៅមានបញ្ហាប្រឈមមួយចំនួន

ទៀតដែលពលករជួបប្រទះគឺពេលធ្វើការថែមម៉ោងគឺថៅកែបង់ប្រាក់ តែពាក់កណ្តាលនៃតម្លៃឈ្នួលនៅម៉ោងធម្មតាប៉ុណ្ណោះ៖ «ភាគច្រើនបើតាមខ្ញុំឮថៅកែគេធ្វើបាបគេកាត់ប្រាក់ខែយើង។ ដូចជាម៉ោងថែមគេកំណត់ឱ្យតែ៣០ទៅ៤០ម៉ោង ប៉ុន្តែបើយើងធ្វើលើសហ្នឹងគេគិតឱ្យត្រឹមតែមួយម៉ោង៤ដុល្លារទេ។ គេអត់បន្ថែមគេទៅជាបន្ថយ ដល់អីចឹងយើងធ្វើការច្រើនប្រាក់ខែបើកមកបានតិច»។

សកម្មជនសិទ្ធិពលករក៏បានស្នើឱ្យផ្តល់សិទ្ធិដល់កម្មសិក្សាការី ដូចជាពលករដទៃទៀតដែរគឺពួកគេមិនមែនជាអ្នកដែលធ្វើកម្មសិក្សាទេ។ ដូច្នេះពួកគេមានសិទ្ធិផ្លាស់ប្តូរការងារដូចជាពលរដ្ឋជប៉ុនដទៃទៀតដែរដោយមិនត្រូវរងពាក្យរិះគន់ថាពួកគេរត់ចោលការងារឡើយ។

ពលការិនីម្នាក់ទៀតគឺអ្នកស្រី សៀ ណែគួយ បានរត់ចោលការងារដោយសារតែស្ថានភាពការងារនិងសកម្មភាពនយោបាយ ដែលបានចូលរួមក្នុងប្រទេសជប៉ុនហើយបច្ចុប្បន្នកំពុងរស់នៅជាជនភៀសខ្លួននយោបាយ។ កាលពីខ្ញុំបញ្ចប់ការងារគឺជិតដល់អាណត្តិខ្ញុំត្រឡប់ទៅខ្មែរវិញ។ ពេលយើងមកជាកម្មសិក្សាការី គឺយើងមានរយៈពេលមួយឆ្នាំ។ បន្ទាប់ពីមួយឆ្នាំបើសិនជាយើងប្រឡងជាប់ គឺបន្ត៣ឆ្នាំបានប៉ុន្តែបើប្រឡងមិនជាប់ទេគឺថៅកែបញ្ជូនយើងទៅផ្ទះវិញហើយដោយសារខ្ញុំទៅវិញអត់បាន។ ទីមួយមកដល់ប្រទេសជប៉ុនការងារច្រើន។ មួយថ្ងៃខ្ញុំធ្វើការ១៣ឬ១៤ម៉ោងហើយគ្មានពេលរៀនទេ ថ្ងៃសៅរ៍អាទិត្យក៏អត់ពេលសម្រាកទេ។ មួយខែហ្នឹងសម្រាកតែមួយថ្ងៃទេ។ អីចឹងហើយខ្ញុំនឹកឃើញថាប្រឡងអត់ជាប់គឺថៅកែបញ្ជូនទៅវិញហើយ។ ខ្ញុំគិតថាខ្ញុំមិនអាចប្រឡងបានទេព្រោះខ្ញុំអត់ចេះអីសោះ។ អីចឹងហើយពេលដល់៧ខែតាមរយៈមិត្តភក្តិគេប្រាប់ថាបើសិនជាអត់ទៅ ស្រុកបានអីចឹងទៅសុំសិទ្ធិនយោបាយទៅព្រោះអីនៅជប៉ុនគេឱ្យសិទ្ធិនយោបាយ»។ បញ្ហាប្រឈមដទៃទៀតពាក់ព័ន្ធនឹងកិច្ចសន្យាដែលមានខុសគ្នារវាងភាសាជប៉ុននិងភាសាដើមរបស់ពលករចំណាកស្រុក។ ឧទាហរណ៍ពលករខ្លះបានចុះលើកិច្ចសន្យាថានឹងត្រូវបញ្ជូនត្រឡប់មកប្រទេសដើមវិញ ក្នុងពេលដែលមានផ្ទៃពោះក្នុងខណៈពេលដែលកិច្ចសន្យាជាភាសាជប៉ុនមិនមានចែងពីចំណុចនោះទេ។

លោក Kazuomi Aoyagi នៃសម្ព័ន្ធសមាគមសម្រាប់ការជំរុញការចូលរួមនិងចម្រុះជាតិសាសន៍(The Alliance of Associations for Diversity and Inclusion Acceleration) នៅប្រទេសជប៉ុនបានថ្លែងថា៖ «ពលករចំណាកស្រុកក៏ជាមនុស្សដែរ។ គេមិនត្រូវបដិសេធសិទ្ធិមិនឱ្យពួកគេស្រឡាញ់គ្នា បង្កើតកូននិងកសាងក្រុមគ្រួសារបានទេ»។

លោកសាស្ត្រាចារ្យ រ៉ាកូ អាសាតូ នៃសាកលវិទ្យាល័យក្យូតូបានបញ្ជាក់ថាការអនុវត្តនឹងនៅតែខុសគ្នានៅក្នុងប្រទេសនីមួយៗ។ លើសពីនោះទៀតរដ្ឋាភិបាលជប៉ុនបានបង្ហាញចេតនាមិនចូលរួមពាក់ព័ន្ធនឹងការងារលម្អិតក្នុងការអនុវត្តទេ។

លោក ហៃ វណ្ណា សកម្មជនខ្មែរនៅប្រទេសជប៉ុននៅតែព្រួយបារម្ភពីអំពើពុករលួយនៅក្នុងប្រទេសកម្ពុជាហើយលោកស្នើឱ្យគោរពនូវអ្វីដែលបានចែង។ «ជាការពិតណាស់ប្រសិនបើមានការគោរពច្បាប់ខ្ជាប់ខ្ជួន មានការកំណត់ការយកកម្រៃវាជាការល្អ ប៉ុន្តែបើសិនជាមានអំពើពុករលួយនៅក្នុងប្រទេសកម្ពុជាទោះបីជាយើងកំណត់តម្លៃដើងសារហ្នឹងយ៉ាងណាក៏វានៅតែមានឈ្មួញទុច្ចរិតមួយចំនួននៅតែបន្តយកលើសពីអ្វីដែលគេបានចែង។ អីចឹងជាសរុបមក ចង់ឱ្យអ្វីៗវាប្រសើរទាល់តែយើងហ្នឹងគោរពច្បាប់សិន»។ ប្រទេសខ្លះក្នុងតំបន់ដូចជាប្រទេសវៀតណាមបានប្រើវិធីដាក់ពិន្ទុក្រុមហ៊ុនជ្រើសរើសបុគ្គលិកតាមការអនុវត្តការងាររបស់ពួកគេ ដែលបានជួយសម្រួលដល់ពលករយល់ដឹងច្រើនហើយជ្រើសរើសក្រុមហ៊ុនណាដែលពួកគេចង់បាន។ វិធីសាស្ត្រនេះបាននាំឱ្យមានភាពល្អប្រសើរខ្លះ។ នេះបើតាមការបញ្ជាក់របស់បណ្តាញជនចំណាកស្រុកតំបន់មេគង្គ៕

# ថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៩

## កម្ពុជា-តួកគីសន្យារួមគ្នាប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងឧក្រិដ្ឋកម្មមានអង្គការចាត់តាំងនិងភេរវកម្ម

http://bayontv.com.kh/ 01/08/2019

ភ្នំពេញ៖ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណៈរដ្ឋតួកគី បានសន្យារួមគ្នាទប់ស្កាត់និងប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ជាពិសេសការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ការជួញដូរគ្រឿងញៀនតែម្តង។

យោងតាមសេចក្តីប្រកាសព័ត៌មាននៃលទ្ធផលដំណើរទស្សនកិច្ចរបស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃទៅកាន់ប្រទេសតួកគីរយៈពេល ប្រាំថ្ងៃគឺចាប់ពីថ្ងៃទី២៨ ខែកក្កដា ដល់ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ បានឲ្យដឹងថា នៅក្នុងកិច្ចប្រជុំទ្វេភាគីជាមួយ ឯកឧត្តម ស៊ូឡីម៉ាន សុយលូរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃសាធារណរដ្ឋតួកគី ភាគីទាំងពីរបានបានពិភាក្សា និងផ្លាស់ប្តូរយោបល់ទៅវិញទៅមកពាក់ព័ន្ធនឹងបម្រែបម្រួលជាសកលក្នុងបរិបទនៃវិស័យសន្តិសុខអន្តរជាតិ ជាពិសេសបានផ្តោតការយកចិត្តទុកដាក់លើសណ្ឋាន និងទម្រង់ថ្មីៗនៃបទល្មើសដែលអាចបង្កផលប៉ះពាល់ និងហានិភ័យ ដល់សន្តិភាព ស្ថិរភាពសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនៃប្រទេសទាំងពីរ។

សេចក្តីប្រកាសបានឲ្យដឹងទៀតថា ភាគីទាំងពីរបានចុះហត្ថលេខាលើ «កិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការសន្តិសុខ រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋតួកគី» ដែលកិច្ចព្រមព្រៀងនេះដើរតួនាទីជាមូលដ្ឋានយ៉ាងសំខាន់ ក្នុងការបង្កើតនូវក្របខ័ណ្ឌរួម សម្រាប់ពង្រីកកិច្ចសហប្រតិបត្តិការសន្តិសុខរវាងប្រទេសទាំងពីរ ដោយផ្តោតលើ«ឧក្រិដ្ឋកម្មឆ្លងដែន និងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ជាពិសេសការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស ការជួញដូរអាវុធខុសច្បាប់បទល្មើសបច្ចេកវិទ្យា បទល្មើសសម្អាតប្រាក់ ការរត់ពន្ធទំនិញខុសច្បាប់ ការរត់ពន្ធទេសន្តប្រវេសន៍ទេសន្តប្រវេសន៍ខុសច្បាប់ ព្រមទាំងការផ្លាស់ប្តូរទស្សនកិច្ចដកពិសោធន៍ការងារ និងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីលើកកម្ពស់សមត្ថភាពនៅក្នុងជួរកងកម្លាំងអនុវត្តច្បាប់របស់កម្ពុជាជាដើម»។

សេចក្តីប្រកាសព័ត៌មានបានឲ្យដឹងទៀតថា ក្រៅពីចំណុចពិភាក្សា និងកិច្ចការសំខាន់ៗ ដែលស្ថិតក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសន្តិសុខ ភាគីទាំងពីរក៏បានឯកភាពកំណត់យកកិច្ចសហប្រតិបត្តិការលើការងារចំនួនទៀតរួមមានការផ្លាស់ប្តូរបទពិសោធន៍លើការងារគ្រប់គ្រង និងត្រួតពិនិត្យសុវត្ថិភាពចរាចរណ៍នៅតាមទីប្រជុំជន។ ការផ្លាស់ប្តូរបទពិសោធន៍លើការពង្រឹង និងពង្រីកភាពជាដៃគូរវាងរដ្ឋាភិបាល ជាមួយសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការចូលរួមអភិវឌ្ឍសង្គមជាតិ។ កិច្ចសហប្រតិបត្តិការបណ្តុះបណ្តាល និងលើកកម្ពស់សមត្ថភាពកងកម្លាំងនគរបាលព្រំដែនទឹកនិងការផ្លាស់ប្តូរ និងចែករំលែកបទពិសោធន៍លើការងារដឹកនាំ និងគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិជាដើម។

សូមបញ្ជាក់ថាក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់សម្តេចក្រឡាហោម ស ខេង សម្តេចក៏បានអញ្ជើញធ្វើទស្សនកិច្ចទៅកាន់អង្គភាពមួយចំនួនចំណុះក្រសួងមហាផ្ទៃ នៃសាធារណរដ្ឋតួកគី រួមមាន នាយកដ្ឋានប្រឆាំងការរត់ពន្ធនិងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង មជ្ឈមណ្ឌលកាមេរ៉ាសុវត្ថិភាពត្រួតពិនិត្យបទល្មើស នាយកដ្ឋានគាំទ្រ និងផែនការចរាចរណ៍ និងអង្គភាពកម្លាំងប្រតិបត្តិការពិសេសផងដែរ៕

## កិច្ចប្រជុំផ្សព្វផ្សាយផែនការ និងការណែនាំ ស្តីពីការគ្រប់គ្រងមុខសញ្ញាបទល្មើស

https://gdlf-kh.com/ 01/08/2019 Kim Sopha កំពង់ចាម

ខេត្តកំពង់ចាម ៖ រសៀលថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ នៅសាលប្រជុំធំ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម លោកឧត្តមសេនីយ៍ទោ ឯម កុសល ស្នងការនគរបាលខេត្ត បានដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយផែនការ និងការណែនាំ ស្តីពីការគ្រប់គ្រងមុខសញ្ញាបទល្មើសដល់មន្ត្រី នៃផែនការងារនគរបាលព្រហ្មទណ្ឌ, ផែនការងារនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច និងផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។

ដោយមានការអញ្ជើញចូលរួមពី លោកស្នងការរង លោកអនុប្រធានផែន លោក លោកស្រី នាយ-នាយរងការិយាល័យ លោក លោកស្រី នាយ-នាយរងផ្នែក រហូតដល់មន្ត្រី ចំណុះផែនការងារនគរបាលព្រហ្មទណ្ឌ ផែនការងារនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច និងផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន លោកអធិការ-អធិការរង និងមន្ត្រីជំនាញ ទទួលការងារផ្នែកនគរបាលយុត្តិធម៌ និងផ្នែកពិនិត្យកន្លែងកើតហេតុ នៃអធិការដ្ឋាននគរបាលស្រុក ក្រុង ទាំង១០ សរុបចំនួន២១០នាក់៕

## អាជ្ញាធរថៃ បញ្ជូនពលរដ្ឋខ្មែរម្នាក់ មកឲ្យកម្ពុជាវិញ ករណីឆ្លងដែនខុសច្បាប់កាប់ឈើគ្រញូង

http://kampucheathmey.com/ 2/8/2019 9:16 Am

ឧត្តរមានជ័យ ៖ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ នៅវេលាម៉ោង១១និង៣០នាទី អាជ្ញាធរថៃ បានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន១នាក់ តាមច្រកអន្តរជាតិជាំ មកកាន់កម្ពុជាវិញ។ សមត្ថកិច្ចបានឲ្យដឹងថា ពលរដ្ឋខ្មែរដែលអាជ្ញាធរបញ្ជូនមកឲ្យកម្ពុជាវិញនោះ មានឈ្មោះ ស៊ុយ ណាង ភេទប្រុស អាយុ៥១ឆ្នាំ រស់នៅភូមិទួលពង្រ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

សមត្ថកិច្ចបានឲ្យដឹងទៀតថា ពលរដ្ឋខ្មែរចូលក្នុងទឹកដីថៃ កាប់ឈើគ្រញូង ត្រូវទាហានចាប់ខ្លួននោះនៅថ្ងៃទី១២,០៣,២០១៦ ពីបទឆ្លងដែនកាប់ឈើ ជាប់គុកនៅខេត្តស៊ីសាកេតប្រទេសថៃ ចូលតាមច្រកអូរស្មាច ស្ថិតក្នុងភូមិសាស្ត្រខ្មែរភូមិអូរស្មាច ឃុំអូរស្មាច ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ឈមខាងថៃភូមិស្ទឹងចាន់ ឃុំស្ទឹងចាន់ ស្រុកឃុនហាន ខេត្តស៊ីសាកេត ប្រទេសថៃ។ បច្ចុប្បន្ន ក្រោយពីសមត្ថកិច្ចធ្វើការអប់រំរួច បានឲ្យវិលទៅលំនៅដ្ឋានវិញហើយ៕ **ដោយ ៖ ចាន់ ធី**

## អាជ្ញាធរចិន ចាប់មេអណ្តើកដែលនាំនារីខ្មែរទៅយកប្តីចិនបញ្ជូនមកស្រុកកំណើតវិញ

http://kampucheathmey.com/ 1/8/2019 3:07 Pm

ភ្នំពេញ ៖ សមត្ថកិច្ចនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩នេះ បានបញ្ជូនខ្លួនមេអណ្តើកម្នាក់ មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការសាកសួររឿងពាក់ព័ន្ធករណីនាំនារីខ្មែរ៣នាក់ ទៅយកប្តីនៅប្រទេសចិន ក្រោយពីអាជ្ញាធរចិន ចាប់បញ្ជូនឲ្យមកកម្ពុជាវិញ។

ជនសង្ស័យមានឈ្មោះ ហាក់ ណៃហូ ភេទស្រី អាយុ២៧ឆ្នាំ មានទីលំនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ សព្វថ្ងៃមានប្តីជាជនជាតិចិនឈ្មោះ ផាញ់ ជឹងធី អាយុ៣៥ រស់នៅខេត្តជើជាំង ប្រទេសចិន។ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងណាននីង ប្រទេសចិន បានបញ្ជូនស្ត្រីខ្មែរចំនួន៤នាក់ឲ្យមកកម្ពុជាវិញ មូលហេតុត្រូវបានសមត្ថកិច្ចចិនឃាត់ខ្លួន ពីបទចូលប្រទេសចិនដោយខុសច្បាប់។ ស្ត្រី៤នាក់នោះ ១.

ឈ្មោះ ហាក់ ណៃហូ អាយុ២៧ឆ្នាំ ,២.ឈ្មោះ រុន ស្រីមុំ អាយុ២៩ឆ្នាំ ,៣.ឈ្មោះ លុន ភក្តី អាយុ១៩ឆ្នាំ ,និង៤.ឈ្មោះ ហេង លីលី អាយុ៣៥ឆ្នាំ ពួកគេមានស្រុកកំណើតនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

អង្គហេតុបណ្តាលឲ្យអាជ្ញាធរចិនចាប់បញ្ជូនស្ត្រីខ្មែរ៤នាក់មកស្រុកវិញនោះ កាលពីខែមិថុនា ឆ្នាំ២០១៩ ឈ្មោះ ហាក់ ណៃហូ បានមកលេងស្រុកកំណើតក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ហើយបាននិយាយបញ្ចុះបញ្ចូលអូសទាញនារីនៅក្នុងភូមិជាមួយគ្នាចំនួន៣នាក់ មានឈ្មោះ រុន ស្រីមុំ ឈ្មោះ លុន ភក្តី និងឈ្មោះ ហេង លីលី ថាឲ្យទៅយកប្តីចិន និងរស់នៅប្រទេសចិន ដោយបានថ្លៃទឹកដោះម្នាក់៣.០០០ដុល្លារអាមេរិក ហើយការចំណាយគ្រប់បែបយ៉ាងគេ(ហាក់ ណៃហូ)ចេញឲ្យទាំងអស់។ ក្រោយមកនារី៣នាក់នោះ ក៏បានយល់ព្រមតាមការអូសទាញរបស់មេអណ្តើក ហើយមេអណ្តើក ក៏បានឲ្យប្រាក់ទៅពួកនាងម្នាក់ពី១៥០ ទៅ២០០ដុល្លារអាមេរិក ដើម្បីឲ្យយកទៅធ្វើលិខិតឆ្លងដែន(ប៉ាសស្ព័រ)លិខិតពិនិត្យសុខភាព និងលិខិតបញ្ជាក់ពីភាពនៅលីវ។

លុះថ្ងៃទី២៤ ខែមិថុនា ក្រោយពេលធ្វើលិខិតស្នាមរួចរាល់ហើយ ឈ្មោះ ហាក់ ណៃហូ និងប្តីជាជនជាតិចិន បាននាំស្ត្រីទាំង៣នាក់ទៅប្រទេសចិន ដោយឆ្លងកាត់តាមច្រករបៀនក្នុងខេត្តស្វាយរៀង ចូលដល់ប្រទេសវៀតណាម រួចជិះរថយន្តបន្តដំណើរទៅដល់ព្រំដែនចិន។ លុះពេលដល់ព្រំដែនចិន.វៀតណាមហើយពួកគេបានឆ្លងតាមច្រករបៀនចូលទៅប្រទេសចិនទៀត និងនៅពេលចូលដល់ទឹកដីចិនហើយ ក៏មានបុរសម្នាក់ជាជនជាតិចិនត្រូវជាមិត្តភ័ក្តិប្តី ហាក់ ណៃហូ បើករថយន្តតូច១គ្រឿងទៅទទួលយកពួកគេ។

ការស្នាក់នៅប្រទេសចិនដោយខុសច្បាប់មួយរយៈនោះ ត្រូវបានអាជ្ញាធររកឃើញ និងចាប់បញ្ជូនឲ្យមកស្រុកខ្មែរវិញនេះ មិនតែប៉ុណ្ណោះសមត្ថកិច្ចនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្រសួងមហាផ្ទៃ បានស្រាវជ្រាវដឹងថា ស្ត្រីឈ្មោះ ហាក់ ណៃហូ ជាអ្នកផ្តើមគំនិតប្រព្រឹត្តអំពើជួញដូរមនុស្សដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន ទើបត្រូវបានឃាត់ខ្លួនកសាងសំណុំរឿងបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញសម្រេចតាមនីតិវិធី៕ **ដោយ ៖ មករា**

## សាច់ញាតិអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធឱ្យជួយពលករខ្មែរ ៨០នាក់ជាប់ពន្ធនាគារនៅស្រុកអារញ្ញប្រទេសថៃ

https://www.rfa.org/khmer/ ដោយ ថន ថារ៉ូ 2019-08-01

សាច់ញាតិពលករខ្មែរឆ្លងដែនទៅប្រទេសថៃខុសច្បាប់ អំពាវនាវឱ្យស្ថាប័នពាក់ព័ន្ធជួយអន្តរាគមន៍ទៅភាគីថៃដោះលែងពលករខ្មែរប្រមាណ ៨០នាក់កំពុងជាប់ពន្ធនាគារនៅស្រុកអារញ្ញ ខេត្តស្រះកែវ ឱ្យមានសេរីភាពឡើងវិញ។ សាច់ញាតិអះអាងថា សមត្ថកិច្ចថៃចាប់ពួកគេដាក់គុកជាង ៣ខែហើយមិនទាន់បញ្ជូនត្រឡប់មកកម្ពុជានៅឡើយទេ។ សាច់ញាតិពលករដែលកំពុងជាប់ឃុំនៅស្រុកអារញ្ញ លើកឡើងថា ពួកគេសុទ្ធតែជាអ្នកចាញ់បោកមេខ្យល់នាំទៅធ្វើការនៅប្រទេសថៃខុសច្បាប់ ហើយត្រូវសមត្ថកិច្ចថៃចាប់ខ្លួន ដោយមិនទាន់បានធ្វើការនៅឡើយទេ។

ឪពុកជនរងគ្រោះនៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ លោក គង់ សុផាត ប្រាប់អាស៊ីសេរីនៅព្រឹកថ្ងៃទី៣០ កក្កដាថា កូនរបស់លោក ២នាក់ និងអ្នកជិតខាង ៣នាក់ទៀត កំពុងជាប់គុកនៅស្រុកអារញ្ញ (Aranyaprathet) ខេត្តស្រះកែវ (Srakaeo) ប្រទេសថៃ មិនទាន់ត្រឡប់មកកម្ពុជាវិញនៅឡើយទេ។ លោកបញ្ជាក់ថា ពលករខ្មែរទាំងនោះប្រមាណ ៨០នាក់ បានចាញ់បោកមេខ្យល់នាំទៅធ្វើការរោងចក្រនៅខេត្តជាប់ទីក្រុងបាងកក តាំងពីថ្ងៃទី២៥ ខែមេសា ប៉ុន្តែមិនចាំឈ្មោះមេខ្យល់ទាំងនោះទេ។នៅថ្ងៃទី២៦ ខែមេសា ក៏ប៉ូលិសថៃព័ទ្ធចាប់បានទាំងអស់គ្នា រួចបញ្ជូនទៅដាក់នៅទីក្រុងបាងកកចំនួន ២ខែ។ ក្រោយមកថៃក៏បានបញ្ជូនពួកគេទៅដាក់គុកនៅស្រុកអារញ្ញបន្តទៀតរហូតមកទល់សព្វថ្ងៃ៖ «បាទ! គ្នាលំបាកការហូបចុកបាយក៏លាយឱ្យគ្នាស៊ីបបរមិនសមនិងបបរ គ្នាយំមកតែឱ្យខ្ញុំផ្តល់លុយឱ្យចាយការដេកនៅក៏លំបាកទឹកមុជក៏លំបាក គាត់ប្រាប់មកខ្ញុំថា បាយលាយដាក់សំរូបដូចបបរអីចឹងឱ្យគ្នាហូប ហូបឆ្អែតក៏

ដោយមិនឆ្អែតក៏ដោយ ខ្លះគ្នាមិនហ៊ានស៊ី គ្រាន់តែឃើញគាត់ក្អួត ដែលគាត់ជាប់គុកថ្មីៗគាត់អត់ហ៊ានហូប»។ លោកបន្តថា កូនរបស់លោកទូរស័ព្ទមកប្រាប់ក្រុមគ្រួសារទាំងទឹកភ្នែកជារៀងរាល់ថ្ងៃ ក្នុងចំណោមពលករទាំង ៨០នាក់ ក៏មានទាំងកុមារតូចៗ ជាច្រើននាក់ជាប់ឃុំជាមួយឪពុកម្តាយរបស់ពួកគេដែរ ក្នុងនោះមានពលករខ្លះបានដួលសន្លប់ក្នុងពន្ធនាគារ ដោយសារហូបអាហារក្នុងពន្ធនាគារបានបណ្តាលឱ្យធ្លាក់ខ្លួនឈឺជាច្រើននាក់ទៀតផង។

អាស៊ីសេរីមិនអាចទាក់ទងអគ្គកុងស៊ុលខ្មែរប្រចាំនៅស្រុកអារញ្ញ លោក ហ៊ុន សារឿន ដើម្បីសុំអត្ថាធិប្បាយជុំវិញការស្នើសុំនេះបានទេ នៅរសៀលថ្ងៃទី៣០ កក្កដា ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។

ចំណែកប្រធានក្រុមការងារទំនាក់ទំនងព្រំដែនកម្ពុជាថៃ ប្រចាំនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត លោក ហេង ហុកម៉េង ប្រាប់អាស៊ីសេរីថា ខាងលោកមិនទាន់បានទទួលដំណឹងនេះនៅឡើយទេ។ ទោះជាយ៉ាងណា អះអាងថា សមត្ថកិច្ចថៃតែងតែបញ្ជូនពលករខ្មែរតាមច្រកព្រំដែននេះជារៀងរាល់ថ្ងៃ ជាពិសេសពលករឆ្លងដែនខុសច្បាប់ដោយខាងថៃមិនចាប់ដាក់ពន្ធនាគារនោះទេ ព្រោះខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ បានឯកភាពគ្នាបញ្ជូនពលករធ្វើការខុសច្បាប់មកស្រុកកំណើតវិញ ដោយមិនមានការដាក់គុកដូចពេលមុននោះទេ៖ «ដូចមិនមែនអីចឹងទេបងសាច់រឿងមិនអីចឹងផង ព្រោះអីយើងបានចុះកិច្ចព្រមព្រៀងគ្នាចំពោះពលករខុសច្បាប់នឹងគឺបញ្ជូនមកខ្មែរអូតូម៉ាទិចតែម្តង។ មានទាំងអ្នកត្រូវច្បាប់ទៀត ដល់ពេលអត់លុយមកផ្ទះប្រាប់គេថាខុសច្បាប់បញ្ជូនមកតាមនឹងបណ្តោយដែលវាអត់អស់សោហ៊ុយអត់អស់អី មានអីចឹងទៀត មិនដាក់គុកដាក់អីទេ ខុសច្បាប់អីចឹង លើកលែងតែគាត់ប្រព្រឹត្តបទល្មើសនៅថៃអត់ដឹងទេ»។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្ស អាដហុក (Adhoc)ប្រចាំនៅខេត្តបន្ទាយមានជ័យលោក ស៊ុំ ច័ន្ទគា លើកឡើងថា ថ្វីបើមានការព្រមព្រៀងយោគយល់គ្នារវាងខេត្តជាប់ព្រំដែនប្រទេសទាំង២ក៏ដោយ ក៏ពលករខ្មែរជាច្រើននាក់តែងតែសមត្ថកិច្ចថៃចាប់ដាក់គុកជាប្រចាំ។ មន្ត្រីសង្គមស៊ីវិលរូបនេះ ស្នើដល់អាជ្ញាធរពាក់ព័ន្ធត្រូវតែពិនិត្យរឿងនេះឡើងវិញ ជាមួយភាគីថៃ ដើម្បីជួយដល់ពលករខ្មែរ ឱ្យឆាប់បានត្រឡប់មកស្រុកកំណើតវិញ៖ «យើងឃើញគ្រាន់តែបើកច្រកភ្លាមពួកគាត់ចេញទៅតាមច្រកនឹង ត្រូវបង់លុយឱ្យសមត្ថកិច្ចការពារព្រំដែនប៉ុន្មាន ហើយមេខ្យល់នាំទៅថៃចេញដូចម្រាមដៃ ប៉ុន្តែបែរទៅជាមិនទាន់ចាត់ការមេខ្យល់ឱ្យបានច្រើននៅឡើយទេ អីចឹងទុកបណ្តែតបណ្តោយអ៊ីចឹង ហើយអ្នករងគ្រោះពលរដ្ឋរងគ្រោះដដែលៗ ចាប់ដាក់គុកដដែលអត់មានអីច្រើនទេ ចុះបើមេខ្យល់មានទប់ស្កាត់ឯណា»។

ឪពុកពលករនៅស្រុកម៉ាឡៃលោក គង់ សុផាត អះអាងថា មូលហេតុដែលកូនធ្វើចំណាកស្រុកដោយសារពួកគេគ្មានការងារធ្វើនៅស្រុកកំណើត ស្របពេលដែលគ្រួសារបានខ្ចីប្រាក់ពីធនាគារ ដើម្បីដាំដុះហើយខាតដើមទុន ក៏នាំគ្នាទៅថៃ ដើម្បីរកប្រាក់សងធនាគារវិញ ក៏ស្រាប់តែប្រាក់ក៏បង់ថង់ក៏ដាច់ ដោយត្រូវជាប់គុកនៅប្រទេសថៃទៅវិញ។

លោក ស៊ុំ ច័ន្ទគារ លើកឡើងថា អាជ្ញាធរក៏ត្រូវតែស្វែងរកចាប់មេខ្យល់ដែលនាំពលករឆ្លងដែនខុសច្បាប់ ទៅដាក់ទោសតាមច្បាប់ និងរឹតបន្តឹងតាមព្រំដែនឱ្យបានតឹងរ៉ឹង ដើម្បីកុំឱ្យពួកគេបោកប្រាស់ពលរដ្ឋនាំទៅធ្វើការប្រទេសថៃខុសច្បាប់ទៀត៕

## មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន សរុបចំនួន ៩៧នាក់

https://www.facebook.com/ អគ្គនាយកដ្ឋានការងារ-General Department of Labour

នាថ្ងៃព្រហស្បតិ៍ ១កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩ នៅសាលប្រជុំB នៃទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំ

តម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន សរុបចំនួន ៩៧នាក់ (ស្រី ២០នាក់) និងក្រុមគ្រួសារកម្មសិក្សាការីសរុបចំនួន៤០នាក់។

**វគ្គសិក្សានេះរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងដល់កម្មសិក្សាការី ឱ្យមានការយល់ដឹងអំពី៖**

១-ការរៀបចំខ្លួន ដើម្បីធ្វើការនៅបរទេស
២-ភូមិសាស្ត្រ បរិស្ថាន និងវប្បធម៌នៅបរទេស
៣-ការធ្វើដំណើរតាមផ្លូវ និងការមកដល់បរទេស
៤-ការធ្វើការងារ និងការរស់នៅក្នុងបរទេស
៥-ការគ្រប់គ្រងប្រាក់
៦-សុខភាព និងអនាម័យ
៧-ការធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ
៨-សុវត្ថិភាព និងសេវាគាំទ្រ។

**ក្រុមហ៊ុនដែលបានបញ្ជូនកម្មសិក្សាការី ទទួលការបណ្តុះបណ្តាលក្នុងវគ្គនេះមានចំនួន៩ គឺ**

១. Asia Recruit Staffing ( A.R.S ) Co., LTD
២. Asian Human Support ( Cambodia ) Co., LTD
៣. Axel Asia Human Resources Co., LTD
៤. CATM Asia Manpower Cooperation Co., LTD
៥. C-Pro Co., LTD
៦. Dream Manpower ( Cambodia ) Co., LTD
៧. Gala Tokyo Manpower Co., LTD
៨. Takayama Labour Supply Co., LTD
៩. Yota Manpower Supply Co., LTD

## ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៩

## ស្ថានទូតកម្ពុជា ស្នើឲ្យថៃដោះលែងពលរដ្ឋ ៨៥ នាក់

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 06 August 2019 | 16:00 ICT

**ភ្នំពេញ៖** ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃបានធ្វើលិខិតជាផ្លូវការស្នើឲ្យអាជ្ញាធរថៃដោះលែងពលរដ្ឋខ្មែរ ៨៥ នាក់ ដែលកំពុងជាប់ពន្ធនាគារនៅខេត្តស្រះកែវ ខណៈពួកគេត្រូវបានចាប់ឃុំខ្លួនអស់ជាង ៣ ខែ។នេះបើតាមមន្ត្រីអ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា។ ការស្នើសុំនេះធ្វើឡើងបន្ទាប់ពីសាច់ញាតិរបស់ពួកគេអំពាវនាវឱ្យស្ថាប័នពាក់ព័ន្ធជួយអន្តរាគមន៍ទៅភាគីថៃដោយអះអាងថាសមត្ថកិច្ចថៃចាប់អ្នកទាំងនោះដាក់គុកជាង ៣ ខែមកហើយ។

អ្នកនាំពាក្យក្រសួងការបរទេស លោក កេត សោផាន់ បានប្រាប់កាលពីម្សិលមិញថា ស្ថានទូតកម្ពុជាកាលពីថ្ងៃទី ៥ ខែ សីហា បានធ្វើលិខិតជាផ្លូវការស្នើសុំឲ្យអាជ្ញាធរថៃដោះលែងពលករខ្មែរ ទាំង ៨៥ នាក់នោះជាបន្ទាន់។ លោកថា៖ «ស្ថានទូត (កម្ពុជា) បានធ្វើលិខិតជាផ្លូវការស្នើសុំឲ្យមានការដោះលែងជាបន្ទាន់តាមដែលអាចធ្វើទៅបាន ហើយខាងពន្ធនាគារសន្យាថា នឹងជួយធ្វើរឿងនេះឲ្យបានឆាប់»។ លោកបានបន្តថា ក្រោយពីទទួលព័ត៌មានពីការចាប់ខ្លួននេះមន្ត្រីស្ថានទូតបានទាក់ទងជាមួយប្រធានពន្ធនាគារស្នួនភ្លូដើម្បីសួររកមូលហេតុ ហើយបន្ទាប់មកប្រធានពន្ធនាគារថៃបានឲ្យមន្ត្រីស្ថានទូតជួប ហើយប្រាប់ថាជាករណីសង្ស័យរឿងជួញដូរមនុស្ស។ លោកបានបន្ថែមថា៖ «ដោយពិនិត្យឃើញថា ការឃុំខ្លួនលើស ៨៥ ថ្ងៃ ទើបនៅថ្ងៃ ៣០ កក្កដា ឆ្នាំ ២០១៩ ស្ថានទូតកម្ពុជាបានជួបប្រធានពន្ធនាគារម្តងទៀត។ គាត់ (ប្រធានពន្ធនាគារ) ប្រាប់ថា រឿងនេះគាត់បានយកចិត្តទុកដាក់បំផុត ហើយបានរាយការណ៍ជាបន្តបន្ទាប់ទៅថ្នាក់លើ ហើយក្រោយជំនួបលើកនេះគាត់នឹងរាយការណ៍ជាបន្ទាន់ទៅថ្នាក់លើដោយបញ្ជាក់ពីការយកចិត្តទុកដាក់របស់ស្ថានទូតកម្ពុជាហើយ នឹងផ្តល់លទ្ធផលមកស្ថានទូត (កម្ពុជា) វិញ»។

លោក ស៊ុំ ចន្ទគា មន្ត្រីសម្របសម្រួលសមាគមសិទ្ធិមនុស្ស អាដហុកប្រចាំខេត្តបន្ទាយមានជ័យបានថ្លែងថា នៅតែមានអ្នកធ្វើចំណាកស្រុកខុសច្បាប់ទៅថៃ បើទោះជាពួកគេប្រឈមមុខនឹងការបាញ់សម្លាប់ ធ្វើទារុណកម្មឬការចាប់ដាក់ពន្ធនាគារក្តី។ លោកថា៖ «វាមិនមានអ្វីថ្មីទេ វាកើតឡើងដដែលៗចំពោះប្រជាជនកម្ពុជា។ យើងពុំមានយន្ត

ការច្បាស់លាស់ដើម្បីជួយធ្វើឲ្យពលករឲ្យរួចផុតពីការធ្វើទុកបុកម្នេញពីអាជ្ញាធរថៃ។ រាជរដ្ឋាភិបាលត្រូវមានយន្តការបេ
ង្កភាពងាយស្រួលដល់ពលករខ្មែរឲ្យធ្វើការនៅស្រុកគេ»។ លោកបន្តថា អាជ្ញាធរកម្ពុជាក៏ត្រូវស្វែងរកចាប់ខ្លួនមេខ្យល់
ដែលនាំពលករខ្មែរឆ្លងដែនខុសច្បាប់ផងដែរ៕

## ចំណាកស្រុករកចំណូលមិនគ្រប់គ្រាន់ក៏ខាកមកចិញ្ចឹមមាន់បានចំណូលជិតពាន់ដុល្លា!

http://aspirekh.org/k-chhnang_chicken/ by Linna Chim | Aug 6, 2019

ដោយសារតែជីវភាពខ្វះខាត ជីវិតប្តីប្រពន្ធគ្រួសារថ្មីថ្មោងដែលមានកូនតូចនៅឡើយនោះបានបង្ខំចិត្តអោយប្តី
ធ្វើចំណាកស្រុកស្វែងរកការងារធ្វើនៅឯប្រទេសថៃដោយសង្ឃឹមថា អាចនឹងរកចំណូលបានគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់
គ្រួសារ។ ផ្ទុយទៅវិញក្តីរំពឹងគឺមិនដូចអ្វីដែលជួបផ្ទាល់នោះទេ។

អ្នកស្រី ជា គឹមសួ មានអាយុ៣៥ឆ្នាំ រស់នៅភូមិជារៅ ឃុំរលាប្អៀរ ស្រុក រលាប្អៀរខេត្តកំពង់ឆ្នាំងហើយក៏ជា
សមាជិក បណ្តុំអាជីវកម្មមាន់របស់កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
ហៅកាត់ថាASPIREចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៨មក។មុនពេលចូលកម្មវិធីASPIRE អ្នកស្រី គឹមសួ បានរៀបរាប់ពី
ផលលំបាករបស់ខ្លួនថា៖ «ដោយសារតែជីវភាពលំបាកគឺត្រូវអោយប្តីធ្វើចំណាកស្រុកទៅប្រទេសថៃប៉ុន្តែនៅទីហ្នឹងរក
កំរៃអត់សូវបានទេហើយខ្ញុំនៅទីនេះកូនតូចក៏រកអត់សូវបានដែរ។តែដោយមានការជួយពីកម្មវិធីASPIRE ជួយបណ្តុះប
ណ្តាលនិងធ្វើទ្រង់មាន់២០% ហើយនេះអាចជាការលើកចិត្តខ្ញុំហើយក៏ពិចារណាទៅថាការអញ្ចឹមមាន់គឺលើកស្ទួយ
ជីវភាពគ្រួសារខ្ញុំហើយម្យ៉ាងទៀតខ្ញុំអាចនៅជុំគ្នា ប្តីខ្ញុំប្រពន្ធខ្ញុំក្រុមគ្រួសារខ្ញុំនៅជុំគ្នា។អត់បាច់ចំណាកស្រុកទៅធ្វើការ
នៅប្រទេសក្រៅដែរ។» គ្រួសាររបស់អ្នកស្រីគឹមសួ ក្រៅពីការចិញ្ចឹមមាន់លក្ខណៈគ្រួសារតិចតួចពួកគាត់ក៏មានទាំងដាំ
បន្លែនិងធ្វើស្រែផងដែរ។ប៉ុន្តែដោយសារតែការដាំដុះនិងការចិញ្ចឹមគ្មានបច្ចេកទេសត្រឹមត្រូវ ធ្វើអោយផលដែលទទួល
បានគឺមិនគ្រប់គ្រាន់សម្រាប់បង្កើនកំរៃជួយដល់ជីវភាពគ្រួសារទាំងមូលបាននោះទេ។ រូបគាត់បានបញ្ជាក់យ៉ាងដូច
នេះថា«ខ្ញុំចិញ្ចឹមមាន់និយាយទៅគឺយូរហើយគ្រាន់តែជាលក្ខណៈគ្រួសារ។ កាលហ្នឹងមានមេ៤ទៅ១០ក្បាលនោះទេ
ហើយអាចផលិតកូនបានតែ១០០ក្បាលទេ។អញ្ចឹង១០០ក្បាលលក់មួយតំលៃបានតែ១ដុល្លារស្មើ១០០ដុល្លាក្នុង១ខែ
តែគ្រួសារខ្ញុំត្រូវការចំណាយច្រើនអញ្ចឹង១០០ដុល្លារមិនអាចចំណាយគ្រប់គ្រាន់នោះទេ។»

ដោយសារតែចំណូលបានតិចតួចពីការចិញ្ចឹមមាន់ ដាំបន្លែ និងធ្វើស្រែសម្រាប់តែហូបក្នុងគ្រួសារទើបធ្វើ
ឲ្យគ្រួសាររបស់អ្នកស្រីគឹមសួនៅតែមិនមានពេលគ្រប់គ្រាន់រស់នៅជុំគ្នា ព្រោះទាំងប្តីទាំងប្រពន្ធគឺត្រូវខិតខំធ្វើការច្រើន
ទៀតដើម្បីអាចរកចំណូលបានបន្ថែមសម្រាប់ដោះស្រាយជីវភាពដែលត្រូវការការចំណាយជាប្រចាំនោះ។ អ្នកស្រី គឹម
សួ បានរៀបរាប់បន្ថែមពីជីវិតរបស់គាត់ថា«កាលពីខ្ញុំមិនទាន់បានចូលកម្មវិធីASPIREមក គ្រួសារខ្ញុំរវល់ច្រើនប្តីគាត់
រវល់ច្រើន ងាកទៅរកការងារខាងក្រៅធ្វើ ដូចជាត្រូវធ្វើសំណង់ជាដើម។តែដល់ពេលបានការជួយពីកម្មវិធីមកប្តីរបស់ខ្ញុំ
មិនបាច់ទៅណាហើយមុខរបរប៉ុណ្ណឹងគឺអាចផ្គត់ផ្គង់គ្រួសាខ្ញុំបាន។ហូបហ្នឹងចាយហ្នឹងកូនរៀនក៏ហ្នឹង។» សព្វថ្ងៃនេះ
ការចិញ្ចឹមមាន់របស់គ្រួសារអ្នកស្រីជា គឹមសួមានការរីកចំរើនគួរឲ្យកត់សម្គាល់ ដោយលើផ្ទៃដីប្រមាណជា២៥០០
ម៉ែត្រការ៉េ ចំនួនមាន់ដែលធ្លាប់តែមានត្រឹមតែ៤ទៅ១០ក្បាលគឺបានកើនឡើងរហូតដល់ទៅ២០០ក្បាលហើយចំណូ
លវិញក៏កើនឡើងលើសមុនៗចំនួន៥ទៅ៧ដងឯណោះ។ «មានការផ្លាស់ប្តូរគឺមួយខែរកប្រាក់ចំណូលបានដល់ទៅ
៧០០ដុល្លារ ដោយកាលពីមុនក្នុង១ថ្ងៃពេលខ្លះមិនអាចរកបានសូម្បីតែមួយរយរៀលហើយមួយខែបាន១០០ដុល្លារ
មិនទាំងអាចទូទាត់ការចាយវាយគ្រប់ផង។ ៧០០ដុល្លារហ្នឹងខ្ញុំផាត់ចំណាយតែ២៥០លើចំណី លើវ៉ាក់សាំងក្រៅពី
ហ្នឹងគឺចំណេញតែម្តងដែលអាចជួយផ្គត់ផ្គង់គ្រួសារបានមួយចំណែកធំ។» ការចូលរួមជាមួយកម្មវិធីផ្សព្វផ្សាយបច្ចេក
ទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុហៅកាត់ថាASPIRE អ្នកស្រី ជា គឹមសួ បានទទួលការប
ណ្តុះបណ្តាលលើបច្ចេកទេសនៃការចិញ្ចឹមមាន់ជាច្រើនផ្នែកដែលរួមមានទាំងការផ្សំចំណី ការចាក់វ៉ាក់សាំងការរៀបចំ
ទ្រង់ និងការមើលថែផ្សេងៗដែលអាចជួយអោយមាន់របស់គាត់ធន់នឹងជំងឺក៏ដូចជាការដោះស្រាយបញ្ហានៃការប្រែ

ប្រែប្រួលអាកាសធាតុជាដើម។ តាមសំដីរបស់អ្នកស្រីគីម សួ បានឲ្យដឹងពីការជួយរបស់កម្មវិធីថា«កម្មវិធីបានជួយ២០% លើទ្រង់ ហើយសល់ខ្លះបានលើសំណាញ់និងយកទៅទិញមាន់បន្ថែម។ពីហ្នឹងមកទៀតគឺគាត់ជួយរកទីផ្សារអោយខ្ញុំ និងបង្ហាត់ពីការធ្វើចំណីនិងប្រើប្រាស់ចំណី។» ហើយសម្រាប់មេរៀនដែលទាក់ទិននឹងការប្រែប្រួលអាកាសធាតុ អ្នកស្រីបានអះអាងថា«អានេះអី ការប្រប្រួលអាកាសធាតុហ្នឹង ផ្ទះខ្ញុំរាងទំនាបបន្តិច ពេលរដូវវស្សាមានទឹកហូរកាត់គឺត្រូវដឹកដីដាក់និងបាញ់ថ្នាំសំលាប់មេរោគហើយដល់ពេលមេឃក្តៅគឺត្រូវប្រើថ្នាំត្រជាក់អីចឹងហ្នឹងណា។»

កញ្ញា ហេង គឹមស្រៀង អនុប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្តកំពង់ឆ្នាំងបានបញ្ជាក់បន្ថែមពីការបណ្តុះបណ្តាលនិងភាពជោគជ័យនៃអាជីវកម្មមាន់នៅក្នុងខេត្តកំពង់ឆ្នាំងយ៉ាងដូចនេះថា៖ «កម្មវិធីASPIRE គឺបានជួយដល់ប្រជាជន ដោយទី១ផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ហើយនឹងការធ្វើបង្ហាញទៅលើកសិករ។បន្ទាប់ពីបានផ្សព្វផ្សាយហើយបង្រៀន ហើយគឺយើងធ្វើការប្រមូលផ្តុំក្រុមផលិតដើម្បីឈ្មោះទៅរកទីផ្សារតែម្តង។» គាត់បានបន្ថែមទៀតថា«គឺយើងបានបង្រៀនខាងបណ្តុំអាជីវកម្មទី១ឲ្យគាត់ចេះធ្វើផែនការសិន។ចំណុចទី២គឺឲ្យគាត់រកអាជីវករដើម្បីជួបគ្នាហើយចរចារ។អញ្ចឹងយើងមានការប្រជុំជួបគ្នារវាងអាជីវករអ្នកផលិតនិងអ្នកទិញ។ អ្នកលក់អ្នកទិញអោយជួបគ្នាយ៉ាងហោចណាស់បីដងហើយធ្វើកិច្ចសន្យាជាមួយគ្នាដែរ។» ខេត្តកំពង់ឆ្នាំងដែលមានចំងាយ ៩១គីឡូម៉ែត្រពីរាជធានីភ្នំពេញគឺមានប្រជាជនប្រមាណជាជាង៥២ម៉ឺននាក់ហើយប្រមាណ៧៧%គឺប្រកបរបរកសិកម្ម។

កម្មវិធីASPIRE ធ្វើការលើស្រុកចំនួន៧ដោយមានឃុំចំនួន៦៦ក្នុងខេត្តកំពង់ឆ្នាំងហើយគិតពីឆ្នាំ២០១៦រហូតមកដល់ឆ្នាំ២០១៩នេះកម្មវិធីគឺបានជ្រើសរើសកសិករ អោយចូលរួមជាមួយបានចំនួនជាង១ម៉ឺននាក់ហើយពួកគាត់ក៏ជាសមាជិកសហគមន៏កសិកម្មផងដែរ។ នៅក្នុងខេត្តកំពង់ឆ្នាំងនេះកម្មវិធីSPIRE បានផ្តល់សេវាផ្សព្វផ្សាយនិងបណ្តុះបណ្តាលទៅដល់កសិករនូវបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការធ្វើបង្ហាញតាមរយៈការអនុវត្តផ្ទាល់ផ្នែកកសិកម្មដល់កសិករ ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មជាដែលមានទាំងការចិញ្ចឹមសត្វការដាំបន្លែនិងការធ្វើស្រែហើយនឹងមានការចងក្រងក្រុមផលិតដើម្បីឈ្មោះទៅរកទីផ្សារជាដើម។

## ថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១៩

## អាណិតណាស់! ស្ត្រីកម្ពុជាម្នាក់នាំកូនៗដើររកប្តីដែលកំពុងធ្វើការនៅបាងកក តែត្រូវមន្ត្រីថៃឃាត់ខ្លួន

---

https://mediakhmer.club/ August 8, 2019 khmer media News

ថៃ៖ ស្ត្រីក្រីក្រជនជាតិខ្មែរម្នាក់បាននាំកូនៗរបស់គាត់ទៅទីក្រុងបាងកកដោយថ្មើរជើង ដើម្បីទៅរកស្វាមី ប៉ុន្តែត្រូវបានមន្ត្រីថៃហៅមកសួរនាំភ្លាមៗ នៅពេលដែលពួកគេដើរនៅតាមដងផ្លូវ ក្នុងខេត្ត Krabin Buri កាលពីព្រឹកថ្ងៃពុធ។ ប៉ូលិសថៃបាននិយាយថា ស្ត្រីម្នាក់នេះមានអាយុ ៤០ឆ្នាំ ហើយកូនទាំង ៣នាក់ របស់គាត់ គឺក្មេងស្រី ២នាក់ និងក្មេងប្រុសម្នាក់ ពួកគេបានដើរកាត់ស្ពានីយ៍ប្រេងឥន្ធនៈមួយនៅលើផ្លូវ Suwannasorn ក្នុងភូមិ Ban Sradoo នៅប្រហែលម៉ោង ១ និង ៣០នាទី យប់។

លោក Sa-nguanprasit នាយវរសេនីយ៍ប៉ូលិស Krabin Buri បានឱ្យដឹងថា ស្ត្រីជាជនជាតិខ្មែរម្នាក់នេះមានឈ្មោះ Tuenles បានប្រាប់ប៉ូលិសថា គាត់បាននាំកូនៗដែលមានអាយុ ១២, ៩ និង ៨ឆ្នាំ ទៅជួបឪពុករបស់ពួកគេដែលមានការងារជាអ្នកលក់កម្រងផ្កា នៅទីក្រុងបាងកក។ គាត់ក៏មានគម្រោងស្វែងរកការងារធ្វើនៅទីនេះដែរ ដើម្បីជួយចិញ្ចឹមគ្រួសារ។ គាត់មានប្រាក់តិចតួចប៉ុណ្ណោះ ពោលគឺបន្ទាប់ពីឆ្លងកាត់ព្រំដែនរួច គាត់មានប្រាក់ល្មមសម្រាប់

ឡានក្រុងឆ្លងពី Sa Kaeo ទៅស្រុក Kabin Buri បន្ទាប់មកទៀតគាត់ក៏បានសម្រេចចិត្តថា នឹងដើរហូតឱ្យដល់ទីក្រុងបាងកក។

ពួកគេបានចាប់ផ្តើមដំណើរនៅយប់ថ្ងៃអង្គារ ដើម្បីចៀសវាងកម្តៅថ្ងៃនៅលើផ្លូវនាពេលថ្ងៃ។ Tuenles បាននិយាយថា គាត់នៅសល់លុយ ១០០បាត ដែលគាត់គ្រោងចំណាយលើទឹក និងស្បៀងអាហារសម្រាប់កូនៗក្នុងដំណើរទៅកាន់ទីក្រុងបាងកកនេះ។ យ៉ាងណាក៏ដោយប៉ូលីសបាននិយាយថា ពួកគេមិនមានលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរអ្វីទាំងអស់ ដូច្នេះពួកគេនឹងត្រូវបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ៕ ប្រភព៖ Khmer Note

## អាជ្ញាធរថៃ បញ្ជូនពលរដ្ឋខ្មែរ៥នាក់ មកឲ្យអាជ្ញាធរកម្ពុជាវិញ ពាក់ព័ន្ធករណីឆ្លងដែនខុសច្បាប់ កាប់ឈើគ្រញូងក្នុងទឹកដីថៃ

http://nokorwatnews.com/archives/ 08-08-2019

ខេត្តឧត្តរមានជ័យ ៖ អាជ្ញាធរថៃ បានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន៥នាក់ តាមច្រកអន្តរជាតិជាំ កាលពីវេលាម៉ោង១៧និង៥០នាទីល្ងាច ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ ស្ថិតនៅភូមិ/ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានឲ្យដឹងថា ពលរដ្ឋខ្មែរចំនួន៥នាក់ ដែលអាជ្ញាធរថៃ បានបញ្ជូនមកឲ្យអាជ្ញាធរកម្ពុជាវិញនោះមានឈ្មោះដូចខាងក្រោម ៖

១,ឈ្មោះ វិច សុផាត ភេទប្រុស អាយុ៥៣ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

២,ឈ្មោះ កាន ហន ភេទប្រុស អាយុ៣២ឆ្នាំ រស់នៅឈើទាល ឃុំជំពូលវ័ន្ត ស្រុកជំគិរី ខេត្តកំពត។អ្នកទាំង២ ចាប់ខ្លួនថ្ងៃទី០៦,០១,២០១៧ ពីបទឆ្លងដែនដែនកាប់ឈើ។

៣,ឈ្មោះ យ៉ាត ភារម្យ ភេទប្រុស អាយុ២៤ឆ្នាំ រស់នៅភូមិរុណ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ចាប់ខ្លួនថ្ងៃទី០៩,០៦,២០១៦។ អ្នកទាំង០៣ ជាប់គុកនៅខេត្តស៊ីសាកេត ចូលតាមច្រកអូរស្វាយ។

៤,ឈ្មោះ ខែម តារា ភេទប្រុស អាយុ២៥ឆ្នាំ រស់នៅភូមិអូរឫស្សី ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ចាប់ខ្លួនថ្ងៃទី០៦,០២,២០១៧ ពីបទឆ្លងដែនកាប់ឈើ។

៥,ឈ្មោះ អឹម រិន ភេទប្រុស អាយុ២៣ឆ្នាំ រស់នៅភូមិស្រែល្អ ឃុំបាក់អន្លូង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ចាប់ខ្លួនថ្ងៃទីដូចនាក់ទី៤។ អ្នកទាំង០២ ជាប់គុកនៅខេត្តស៊ីសាកេត ចូលតាមច្រកព្រលានដូនពោធិ៍, តាមច្រកអូរស្វាយ ក្នុងភូមិសាស្ត្រខាងខ្មែរភូមិ/ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ឈមចាងថៃភូមិ/ឃុំទឹងចាន់ ស្រុកឃុនហានខេត្តស៊ីសាកេត, តាមច្រកព្រលានដូនពោធិ៍ ភូមិសាស្ត្រខ្មែរភូមិទួលគ្រោះ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ឈមខាងថៃភូមិ/ឃុំបាក់ដង ស្រុកឃុនហាន ខេត្តស៊ីសាកេត ប្រទេសថៃ។

បច្ចុប្បន្ន សមត្ថកិច្ចនៅនឹងមាត់ច្រកអន្តរជាតិជាំ បានធ្វើការអប់រំ រួចបានឲ្យវិលទៅលំនៅដ្ឋានរៀងៗខ្លួនវិញ៕ ប៉ែន នួន

## សិក្ខាសាលាសម្ពោធគម្រោង ធ្វើការជាមួយគ្នាដើម្បីកុមារកម្ពុជា

https://gdlf-kh.com/ 09/08/2019 Him Uykeang ខេត្តសៀមរាប

សៀមរាប៖ នៅព្រឹកថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៩នេះ នៅសណ្ឋាគារអង្គរប៉ារ៉ាឌី ខេត្តសៀមរាប មានបើកអង្គសិក្ខាសាលាសម្ពោធ ធ្វើការជាមួយគ្នា ដើម្បីកុមារកម្ពុជា ដែលរៀបចំឡើងដោយអង្គការដែនដីមនុស្ស-ហូឡង់ដ៍ប្រចាំកម្ពុជា ក្រោមអធិបតីភាពរបស់ លោកជំទាវ យូ សុភា អភិបាលរងនៃគណៈអភិបាលខេត្ត និង ជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត លោកជំទាវ ស៊ិន ណម សមាជិកាក្រុមប្រឹក្សាខេត្ត ជាប្រធានគណៈកម្មាកិច្ចការស្ត្រីនិងកុមារខេត្ត និងលោក អេរីកវ៉ាន់ឌ័រលើ នាយកប្រចាំប្រទេសអង្គការដែនដីមនុស្ស-ហូឡង់ដ៍ប្រចាំកម្ពុជា

ដោយ មានការចូលរួម ពីសំណាក់អស់លោក លោកស្រីជា គណៈអភិបាលក្រុង ចៅសង្កាត់ ប្រធានកម្រង មេភូមិ និង នាយកសាលា នៅក្នុងតំបន់គោលដៅដែលបានជ្រើសរើស ប្រមានចំនួន៦០នាក់ចូលរួមជាសិក្ខាកាម ។

មានចំណាប់អារម្មណ៍នោះលោក អេរីកវ៉ាន់ឌ័រលី ក៏បានធ្វើការបញ្ជាក់អំពីគោលបំណងនៃគម្រោងនេះគឺដើម្បី ទប់ស្កាត់ការពារ និងការឆ្លើយតបចំពោះការកេងប្រវញ្ចផ្លូវភេទកុមារ ក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍ (SECTT)នៅខេត្តសៀមរាប រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ។ អង្គសិក្ខាសាលាសម្ពោធ គម្រោងធ្វើការជាមួយគ្នា ដើម្បីកុមារកម្ពុជា របស់អង្គការដែនដីមនុស្ស-ហូឡង់ដ៏ បង្កើតគម្រោងរបស់ខ្លួន ក្នុងក្របខណ្ឌកម្មវិធីសកលចំនួន៥ គឺ .ការកេងប្រវ័ញ្ចផ្លូវភេទកុមារ ,ពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និង អំពើជួញដូរ និងទេសន្តរប្រវេសន៍កុមារ រួមនឹង សុខភាពផ្លូវភេទ និង កិច្ចការពារកុមារ ពេលមានវិបត្តិមនុស្សធម៌ ។ លោកបានបន្តទៀតថា សិក្ខាសាលាដែលមានរយៈ ពេលកន្លះថ្ងៃនេះ ពិតជាមានសារៈសំខាន់ និង អត្ថប្រយោជន៍ខ្លាំងណាស់ នៅក្នុងចក្ខុវិស័យនៃសេចក្ដីប៉ងប្រាថ្នា របស់ អង្គការដែនដីមនុស្ស-ហូឡង់ដ៏ ដើម្បីលើកស្ទួយ សិទ្ធិកុមារ តាមរយៈការអនុវត្តន៍គម្រោង ធ្វើការជាមួយគ្នាដើម្បីកុមារ កម្ពុជា (WATCH កម្ពុជា) នៅលើទឹកដីនៃខេត្តសៀមរាបនេះ ។ លោកជឿជាក់យ៉ាងមុតមាំថា សិក្ខាសាលានឹង តំណាងឲ្យកាលានុវត្តភាពដ៏ត្រចះត្រចង់មួយសម្រាប់ឲ្យយើងគ្រប់គ្នា ត្រូវស្ថិតនៅក្នុងទំព័រតែមួយជាមួយគ្នា ធ្វើការងារ សំដៅឆ្ពោះទៅរកទិសដៅតែមួយ ក្នុងការលើកស្ទួយសិទ្ធិកុមារនៅកម្ពុជា ជាសំខាន់នៅលើទឹកដីនៃខេត្តសៀមរាបនេះ តែម្តង។

មានប្រសាសន៍នោះដែរលោកជំទាវ យូ សុភា ក៏បានលើកឡើងថា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់សម្តេច តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចដាក់ចេញនូវកម្មវិធី នយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា ដើម្បី កំណើនការងារ សមធម៌ និងប្រសិទ្ធភាព ( កសាងមូល ដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០) ដោយបាន ដាក់ចេញនូវគោលនយោបាយសំខាន់ៗជាច្រើន ដែលបានកំណត់ជាអាទិភាពក្នុងការសម្រេចបាននូវកំណើនប្រកប ដោយចីរភាព និងបរិយាប័ន្ន ការអភិវឌ្ឍធនធានមនុស្ស លើផ្នែកអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ការ បង្កើនឱកាសការងារសមរម្យ និងប្រកបដោយផលិតភាពជូនប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ដោយសមធម៌ ដើម្បីលើក កម្ពស់ជីវភាពភាពថ្លៃថ្នូររបស់ប្រជាពលរដ្ឋ និងភាពសុខដុមរមនាសង្គម។ លោកជំទាវបានបញ្ជាក់ថា ការរៀបចំអង្គ សិក្ខាសាលាសម្ពោធគម្រោងនេះឡើង ក្នុងគោលបំណង ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទកុមារ នៅក្នុងវិស័យធ្វើ ដំណើរនិងទេសចរណ៍ និង ដើម្បីធានាឲ្យបាននូវការឆ្លើយតប ក្នុងការជួយដោះស្រាយបញ្ហា របស់ស្ត្រី និង កុមារ និង អន្តរាគមន៍ទាន់ពេលវេលាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលមានការសម្របសម្រួលជាពហុវិស័យ ។

ម្យ៉ាងទៀត ដើម្បីឲ្យការអនុវត្តការងារកាន់តែមានប្រសិទ្ធភាព ក្រុមការងារដឹកនាំដោយកុមារជាច្រើន ត្រូវបាន បង្កើតឡើងដូចជា ចលនាយុវជនកាយរឹទ្ធិជាតិកម្ពុជា យុវជនកាកបាទក្រហមកម្ពុជា ក្លឹបកុមារនៅតាមសាលារៀន បណ្តាញកុមារអ្នកតស៊ូមតិនិងចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ ដែលពួកគេក្លាយជាចលនាយុវជន ឬកុមារ ឈានមុខក្នុងការកសាង និងអភិវឌ្ឍន៍សង្គម ។ សមិទ្ធផលដ៏ធំធេងទាំងនេះ សបញ្ជាក់ពី ការប្តេជ្ញាចិត្តដ៏មុតមាំរបស់រដ្ឋាភិបាល ក្នុងការលើកស្ទួយវិស័យសុខុមាលភាពកុមារ ដែលធានាឱ្យកុមារគ្រប់រូបទទួលបាននូវការគាំទ្រ សម្រាប់ការ ចាប់ផ្តើមជីវិតដ៏ល្អ និងអភិវឌ្ឍពោរពេញទៅដោយសក្តានុពល ក្លាយជាពលរដ្ឋកម្ពុជា ដែលមានការទទួលការខុសត្រូវ ក្នុងគ្រួសារនិងសង្គម និងមានភាពផលិតភាពពេញលេញមួយជីវិត ។ ហើយសិក្ខាសាលានេះ ″ មានសារៈសំខាន់ ហើយយើងអាចធ្វើអន្តរាគមយ៉ាងទូលំទូលាយ និង មានប្រសិទ្ធភាពជាមួយគ្នា តាមរយៈកិច្ចសហការគ្នាយ៉ាង ខ្លាំងក្លា ក្នុងគោលបំណងឆ្ពោះទៅរកទិសដៅដ៏ធំបំផុតរួមមួយ ហើយជាមួយគោលដៅធំបំផុត គឺដើម្បីទប់ស្កាត់និងដោះ ស្រាយបញ្ហាការកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមប្រព័ន្ធអ៊ីនធឺណេត នៅក្នុងប្រទេសកម្ពុជា ។

លោកជំទាវ យូ សុភា ក៏បានលើកផងដែរថា ដើម្បីឆ្លើយតបទៅនឹងកម្មវិធីគោលនយបាយ របស់រាជរដ្ឋាភិបាលកម្ពុជា និង អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ លោកជំទាវក៏បានអំពាវនាវចំពោះអាជ្ញាធរដែនដី លោកគ្រូ អ្នកគ្រូ ឪពុកម្តាយ អាណាព្យាបាល អង្គការដៃគូជាតិ អន្តរជាតិ និងសង្គមទាំងមូល សូមបន្តការពង្រឹង នូវកិច្ចសហការឲ្យជិតស្និទ្ធជាមួយសាលារៀន ដើម្បីជានាបានកាន់តែល្អប្រសើរទៀត លើការបង្កលក្ខណៈសម្បត្តិ ដល់កុមារឲ្យទទួលបានការអប់រំ និងរៀនសូត្រ ពិសេសចូលរួមនិងសហការអនុវត្តនូវគម្រោងស្តីពី "ធ្វើការជាមួយគ្នាដើម្បីកុមារកម្ពុជា" ដែលមានអង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំនៅប្រទេសកម្ពុជា ជាអ្នកអនុវត្តគម្រោងផ្ទាល់ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវលើកុមារនៅក្នុងវិស័យធ្វើដំណើរនិងទេសចរណ៍នេះ៕

## ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៩

## អន្តរសាសនា នឹងប្រារព្ធទិវាប្រយុទ្ធប្រឆាំងការជួញដូរមនុស្សរួមគ្នានៅសប្តាហ៍ក្រោយ

http://bayontv.com.kh/ 10/08/2019

ភ្នំពេញ ៖ រាជរដ្ឋាភិបាល និងអន្តរសាសនា មានដូចជា សាសនាព្រះពុទ្ធ សាសនាឥស្លាម និងសាសនាគ្រឹះ នឹងធ្វើការដង្ហែក្បួន មួយនៅសប្តាហ៍ក្រោយ ដើម្បីប្រារព្ធទិវាប្រយុទ្ធប្រឆាំង និងការជួញដូរ មនុស្សដោយក្បួនដង្ហែនេះ នឹងមានសារជាច្រើនបង្ហាញដល់ប្រជាជនកម្ពុជា ឲ្យកាន់តែយល់ ច្បាស់បន្ថែមទៀតទាក់ទង នឹងការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ។

ថ្លែងប្រាប់អ្នកសារព័ត៌មានក្រោយពីប្រជុំជាមួយភាគីពាក់ព័ន្ធ និងតំណាងសាសនា នានា នៅប្រទេសកម្ពុជា នារសៀល ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩នេះ លោកជំទាវ ជូ ប៊ុនអេង រដ្ឋ លេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការ ជួញដូរមនុស្សបានឲ្យដឹងថា ក្បួនព្យុហយាត្រា ដែលមានពុទ្ធបរិស័ទ សាសនា នានាចូលរួមនេះនឹង ធ្វើឡើងនៅព្រឹកថ្ងៃទី១៤ ខែសីហា ខាងមុខនេះ ដោយក្បួននឹងចាប់ផ្តើមពីមុខវត្តបទុមបតី ឆ្ពោះ ទៅកាន់មជ្ឈមណ្ឌលកំសាន្ត កោះពេជ្រ ហើយអាចនឹងមានមនុស្សចូលរួមជិតពីរពាន់នាក់។ លោកជំទាវបានលើកឡើងទៀតថា រាជរដ្ឋាភិបាលបានខិតខំយ៉ាងខ្លាំងនិងបានជំរុញដល់ភាគីពាក់ព័ន្ធទាំងអស់ត្រូវខិតខំសកម្មបន្ថែមទៀត ក្នុងការស៊ើបអង្កេត ការពារទប់ស្កាត់ជួញដូរមនុស្សនេះ ឲ្យបានល្អប្រសើរខណៈក្នុងឆមាសទី១ ឆ្នាំ ២០១៩នេះ អាជ្ញាធរបានបង្ក្រាប ការជួញដូរមនុស្សនិងផ្លូវភេទ បានកើនឡើង ជាងឆ្នាំ កន្លងទៅ រហូតដល់ជិត២០ ភាគរយនោះ។ លោកជំទាវ បានឲ្យដឹងថា ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ សម្រាប់ឆមាសទី១ ឆ្នាំ២០១៩នេះ បានបង្ហាញថា អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត១៩ បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន៧៨ករណី លើ ៦២ករណី (កើនឡើង១៦ករណី ស្មើនឹង២៥%)។បានឃាត់ខ្លួនជនសង្ស័យ បញ្ជូនទៅសាលាដំបូងចំនួន៩៧នាក់ និងសង្គ្រោះជនរងគ្រោះចំនួន២៦៣នាក់ (លើ១០៦នាក់) កើន១៥៧នាក់ ស្មើនឹង១៤៨%៕

## បុរសជនជាតិអង់គ្លេសម្នាក់ជាប់ពន្ធនាគារ១៥ខែ ពីបទប្រព្រឹត្តអំពើអាសលើកុមារខ្មែរ

https://www.rfa.org/khmer/ ដោយ ហេង រស្មី 2019-08-10

បុរសជនជាតិអង់គ្លេសម្នាក់ ត្រូវបានតុលាការកាត់ឱ្យជាប់ពន្ធនាគារ ១៥ខែ ពីបទប្រព្រឹត្តអំពើអាសលើកុមារខ្មែរ។ សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី៩ ខែសីហា ឆ្នាំនេះបានប្រកាសសាលក្រមប្រឆាំងលោក ស៊ីហ្វិន ចន ល័រីម៉ែន (Stephen John Loryman) ក្រោយពីតុលាការរកឃើញថា មានពិរុទ្ធភាពពីបទ" ប្រព្រឹត្តអំពើអាស លើអនីតិជនអាយុក្រោម ១៥ ឆ្នាំ" ក្រោមច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ។ នៅក្នុងសេចក្តីប្រកាសព័ត៌មាន របស់អង្គការសកម្មភាពដើម្បីកុមារ (APLE) នៅថ្ងៃទី៩ ខែ សីហា បានបញ្ជាក់ថា ក្នុងចំណោម

ទោសជាប់ពន្ធនាគារទាំង ១៥ ខែនោះ តុលាការសម្រេចព្យួរទោសបីខែ បង្គាប់ឱ្យលោក ស្ទីហ្វិន ចន ល័រីម៉ែន បង់ប្រាក់សំណងប្រមាណជាង ១៥០០ ដុល្លារដល់កុមាររងគ្រោះ ២ នាក់ និងពិន័យជាប្រាក់ ៧៥០ដុល្លារ។

តាមសេចក្ដីសម្រេចនេះ លោក ស្ទីហ្វិន ចន ល័រីម៉ែន នឹងត្រូវជាប់ពន្ធនាគារតែបីខែទៀតប៉ុណ្ណោះ ព្រោះតុលាការបានឃុំខ្លួនលោក តាំងពីចុងខែវិច្ឆិកា ឆ្នាំ២០១៨។ ទោះជាយ៉ាងនេះក្ដី ក្រោយចេញពីពន្ធនាគារ លោកត្រូវតុលាការហាមចូលប្រទេសកម្ពុជាវិញ រយៈពេលបីឆ្នាំ។ អ្នកឯកទេសការពារកុមារ នៃអង្គការសកម្មភាពដើម្បីកុមារ (APLE) លោក ខឹម រ៉ាន់ដូ សាទរសេចក្ដីសម្រេចរបស់តុលាការកម្ពុជា ដែលហាមលោក ស្ទីហ្វិន ចន ល័រីម៉ែន មិនឱ្យចូលស្រុកខ្មែរវិញនេះ។ លោកថា ការហាមឃាត់នេះ ជួយកាត់បន្ថយហានិភ័យដល់កុមារខ្មែរ៕

## ស្ត្រីពលករកម្ពុជា ម្នាក់ដែរជាតំណាងអោយពលករកម្ពុជា ដ៏ទៃទៀតដែលធ្វើការនៅក្នុងប្រទេសថៃ សូមស្នើរដល់រាជរដ្ឋាភិបាលថៃ អនុញ្ញាតឱ្យពលករបរទេស បង្កើតសហជីពកម្មករក្នុងប្រទេសថៃ

https://www.facebook.com Pheak Tra 11-08-2019

ស្ត្រីពលករកម្ពុជា ម្នាក់ដែរជាតំណាងអោយពលករកម្ពុជាដ៏ទៃទៀតដែរធ្វើការនៅក្នុងប្រទេសថៃ សូមស្នើរដល់រាជរដ្ឋាភិបាលថៃ អនុញ្ញាតឱ្យពលករបរទេស បង្កើតសហជីពកម្មករក្នុងប្រទេសថៃ ដើម្បីជួយសម្រួលនៅពេលពួកគាត់ជួបបញ្ហាត្រូវថៅកែឬក្រុមហ៊ុនរំលោភបំពានសិទ្ធិការងារក្នុងប្រទេសថៃ។ ការស្នើសុំដូច្នេះបន្ទាប់ពីស្ត្រីពលករកម្ពុជាដែលធ្វើការនៅក្នុងប្រទេសថៃ ភាគច្រើនមិនទទួលបានសិទ្ធិការងារពេញលេញដូចពលករបុរស ជាទូទៅស្ត្រីជាពលករដែលធ្វើលើវិស័យសំណង់និងការងារផ្សេងទៀត ទទួលបានប្រាក់ឈ្នួលត្រឹមតែ 160បាត ទៅ265បាត នេះបើយោងតាមរបាយការណ៍របស់ស្ត្រីពលករកម្ពុជាដែលធ្វើសំណង់និងធ្វើការនៅតាមផែត្រីក្នុងតំន់នេសាទនៃប្រទេសថៃ។

## ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ និងមន្ត្រីការទូតទាំងអស់ បានអញ្ជើញចុះសួរសុខទុក្ខនិងសំណេះសំណាល ជាមួយបងប្អូនពលករខ្មែរចំនួនជាង ៦០០នាក់ ដែលកំពុងបម្រើការងារនៅលើកោះឆាង ខេត្តត្រាត ប្រទេសថៃ

https://www.facebook.com Royal Embassy of Cambodia in Bangkok 12-08-2019

នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩ ឯកឧត្តម អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ និងមន្ត្រីការទូតទាំងអស់ បានអញ្ជើញចុះសួរសុខទុក្ខនិងសំណេះសំណាល ជាមួយបងប្អូនពលករខ្មែរចំនួនជាង ៦០០នាក់ ដែលកំពុងបម្រើការងារនៅលើកោះឆាង ខេត្តត្រាត ប្រទេសថៃ ដែលកម្មវិធីប្រព្រឹត្តទៅប្រកបដោយភាពស្និតស្នាលនិងរីករាយ។ ជាមួយគ្នានេះដែរ ឯកឧត្តមឯកអគ្គរាជទូតក៏បានពាំនាំមកនូវការផ្តាំផ្ញើរសាកសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ជូនដល់បងប្អូនពលករខ្មែរដែលកំពុងស្នាក់នៅនិងធ្វើការក្នុងប្រទេសថៃ ដែលជានិច្ចកាលសម្តេចទាំងទ្វេតែងតែយកចិត្តទុកដាក់ពីសុខទុក្ខរបស់បងប្អូនជាប់ជានិច្ច។

ឯកឧត្តមឯកអគ្គរាជទូតក៏បានបញ្ជាក់ថា បច្ចុប្បន្ននេះក្នុងគោលបំណងដើម្បីបង្និតសេវាកម្មឱ្យកៀកជិតបងប្អូនប្រជាពលរដ្ឋ ក៏ដូចជារួមចំណែកកាត់បន្ថយចំណាយ និងពេលវេលាធ្វើដំណើររបស់ពលរដ្ឋដែលរស់នៅឆ្ងាយពីទីក្រុងបាងកក ស្ថានទូតបានរៀបចំកម្មវិធីសំណេះសំណាល និងសួរសុខទុក្ខបងប្អូនពលកររៀងរាល់ចុងសប្តាហ៍ ដោយនៅក្នុងកម្មវិធីនោះក៏មានក្រុមការងារចល័តផ្តល់សេវាកម្មប្រឹក្សាយោបល់លើបញ្ហាការងារ និងសេវាកុងស៊ុលដូចជា ការពន្យាសុពលភាពលិខិតឆ្លងដែន និងបញ្ជាក់ឯកសារផ្សេងៗ។ល។ ក្រុមការងារស្ថានទូតបានចេញឯកសារចំនួន ១០០ ដល់បងប្អូន ដោយឥតគិតលុយដល់ទីកន្លែង។

ជាចុងក្រោយឯកឧត្តមឯកអគ្គរាជទូត ក៏បានផ្ដាំផ្ញើឱ្យបងប្អូនពលករទាំងអស់ខិតខំធ្វើការងារ សន្សំប្រាក់ផ្ញើទៅស្រុក ខំរៀនជំនាញដើម្បីអនាគតពេលត្រឡប់ទៅធ្វើការនៅប្រទេសកម្ពុជាវិញ ព្រមទាំងមើលថែរក្សាសុខភាពរបស់ខ្លួនឱ្យបានល្អ។

# ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៩

## ស្អែកនេះ កម្ពុជានឹងរៀបចំវេទិកាជាតិ អន្តរសាសនា លើកទី៣ «ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប»

http://www.freshnewsasia.com/ 2019-08-13

**(ភ្នំពេញ)៖** រាជរដ្ឋាភិបាលកម្ពុជា នឹងរៀបចំវេទិកាជាតិ អន្តរសាសនា លើកទី៣ «ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប» នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌល និងពិពណ៌កោះពេជ្រ ក្រោមអធិបតីភាព សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)។

វេទិកាជាតិអន្តរសាសនានេះ រៀបចំដោយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, ក្រសួងធម្មការ និងសាសនា និងអង្គការការីតាសកម្ពុជា ដោយមានការចូលរួមគាំទ្រពីថ្នាក់ដឹកនាំសាសនារួមមាន ព្រះពុទ្ធសាសនា ឥស្លាមសាសនា កាតូលិក និង គ្រីស្ទបរិស័ទដំណឹងល្អ និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។

**គោលបំណង៣សំខាន់ នៃវេទិកានេះគឺ៖**

***ទី១៖** ដើម្បីលើកកម្ពស់សារសំខាន់ នៃវេទិកាអន្តរសាសនានៅកម្ពុជា ដែលបង្ហាញពីភាពសុខដុមនៃសាសនានៅក្នុងកម្ពុជានាំមកនូវសន្តិភាពជាតិ ការគោរពសិទ្ធិមនុស្ស សេចក្ដីថ្លៃថ្នូរ និងភាពរីកចម្រើនរបស់មនុស្សជាតិ។

***ទី២៖** ដើម្បីបង្ហាញពីតួនាទីដ៏សំខាន់របស់ថ្នាក់ដឹកនាំសាសនាទាំងឡាយ ក្នុងការផ្សព្វផ្សាយអប់រំ និងផ្ដល់ចំណេះ ដឹងដល់ប្រជាពលរដ្ឋ អំពីសីលធម៌ក្នុងការរស់នៅ ជៀសវាងការរំលោភបំពាន អំពើជួញដូរ កេងប្រវ័ញ្ចគ្រប់រូបភាពលើមនុស្សផងគ្នា និងជួយណែនាំឲ្យចូលរួមបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស ដែលជាទាសភាពសម័យទំនើបគួរឲ្យស្អប់ខ្ពើម ។

***ទី៣៖** សកម្មភាពជាច្រើន ដែលត្រូវបានរៀបចំក្នុងឱកាសនោះគឺ មានធម្មយាត្រាដង្ហែរសារ និងចែកផ្សាយសារ ដែលដែលមានខ្លឹមសារអប់រំ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់ផ្សព្វផ្សាយដល់សាធារណជន ទស្សនាពិពរណ៌សកម្មភាពចូលរួមប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស សុន្ទរកថា និងអនុសាសន៍ដឹកនាំ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគ.ជ.ប.ជ ពិធីសូត្រធម៌ និងអធិដ្ឋានបង្ហោះសាររួមគ្នា៕

## ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំកិច្ចប្រជុំគណៈកម្មាការអន្តរៈក្រសួង ត្រៀមកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រី លើកទី៥ និងកិច្ចប្រជុំ ថ្នាក់រដ្ឋមន្ត្រីលើកទី៣ នៃប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម និង ថៃ

https://www.facebook.com/ithsamheg/ អ៊ិត សំហេង - Ith Samheng 13-08-2019

ព្រឹកថ្ងៃទី១៣ សីហា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបាន ដឹកនាំកិច្ចប្រជុំគណៈកម្មាការអន្តរៈក្រសួង ត្រៀម កិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រី លើកទី៥ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៣ នៃប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម និង

ថៃ CLMVT នាសប្ដាហ៍ទី៣ខែ កញ្ញា នៅខេត្តសៀមរាប។ ពិធីបើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី នឹងប្រព្រឹត្តទៅ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ប្រធានបទ នៃកិច្ចប្រជុំការតភ្ជាប់ប្រព័ន្ធសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសន៍ ដែលមានសារៈសំខាន់ខ្លាំងណាស់ចំពោះ បណ្ដាប្រទេសក្នុងតំបន់ និងសម្រាប់កម្ពុជាយើង។ អង្គប្រជុំបានឯកភាពខ្ពស់ផែនការរៀបចំដើម្បីកម្ពុជាជាម្ចាស់ផ្ទះដ៏ល្អក្នុងកិច្ចប្រជុំនេះ។

## ក្រសួងការងារ ព្រមានម្ចាស់សិប្បកម្មឥដ្ឋទាំងឡាយណា ដែលប្រើកុមារឱ្យធ្វើការ នឹងចាត់វិធានការតាមក្រមព្រហ្មទណ្ឌភ្លាម

http://www.freshnewsasia.com/ 2019-08-12

**(ភ្នំពេញ)៖** មន្ត្រីជាន់ខ្ពស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានព្រមានជាថ្មីថា បើមានករណីណាមួយប្រើប្រាស់ពលកម្មកុមារ ក្រសួងនឹងធ្វើការដាក់កំហិត បើសិនជាកម្រិតធ្ងន់ធ្ងរ ក្រសួងនឹងធ្វើការពិន័យយកតែម្តង បើករណីគ្រោះថ្នាក់អាចបាត់បង់សារពាង្គកាយ ឬឈានដល់ការបាត់បង់អាយុជីវិតណាមួយ ក្រសួងនឹងធ្វើកិច្ចសហការជាមួយអាជ្ញាធរដែលពាក់ព័ន្ធ អនុវត្តក្រមព្រហ្មទណ្ឌភ្លាម។

នេះជាការបញ្ជាក់របស់លោក វ៉េង ហៀង អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ និងជាប្រធាននាយកដ្ឋានកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងឱកាសដែលលោកដឹកនាំក្រុមអធិការរបស់ក្រសួងការងារ ចុះទៅដល់កន្លែងសិប្បកម្មផលិតឥដ្ឋដោយផ្ទាល់ ស្ថិតនៅតាមបណ្តាយផ្លូវជាតិលេខ៦អា សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វា នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩។ លោកបានលើកឡើងថា យុទ្ធនាការចុះផ្សព្វផ្សាយការលុបបំបាត់ពលកម្មកុមារនៅក្នុងវិស័យផលិតឥដ្ឋនេះ គឺជាប្រសិទ្ធភាពធំធេងមួយនៅក្នុងវិធានការណ៍ទប់ស្កាត់ និងការផ្លាស់ប្តូរឥរិយាបថ របស់កម្មករនិយោជិត និយោជក ព្រមទាំងសហគមន៍ ដើម្បីធានាថាកុមារទាំងអស់បានទទួលការការពារ ហើយកុមារដែលមានអាយុពេញវ័យទទួលបានការងារសមរម្យ មិនប្រកបដោយគ្រោះថ្នាក់។

លោកថា «**អ្វីដែលយើងរំពឹងទុកក្នុងកម្រិតប្រសិទ្ធភាពបែបនេះ គឺកម្មករនិយោជិត និយោជកទាំងអស់គ្នាមានការយល់ដឹងពីការប្រើប្រាស់ពលកម្មកុមារ ការទប់ស្កាត់កុមារមិនឱ្យចូលទៅក្នុងសិប្បកម្ម ផលិតឥដ្ឋ និងការសហការល្អជាមួយស្ថាប័ន ដើម្បីឱ្យកុមារទទួលបានការរៀនសូត្រ និងទទួលបានការបណ្តុះបណ្តាលជំនាញដែលជាអនាគត ក្នុងការចូលរួមចំណែកនៅក្នុងការប្រកួត ប្រជែងសេដ្ឋកិច្ចនៅកម្ពុជា**»។

លោក វ៉េង ហៀង បានបញ្ជាក់ថា យុទ្ធនាការនេះគឺក្រុមអធិការកិច្ចចុះជាច្រើនលើកច្រើនសារមកហើយ ប៉ុន្តែបើនៅក្នុងកម្រិតថ្នាក់ជាតិ ក្រុមការងារចុះបានចំនួន ៤លើក លើកទីមួយ នៅឆ្នាំ២០០៨ លើកពីរ នៅក្នុងឆ្នាំ ២០១៦ លើកទីបី នៅឆ្នាំ២០១៩ និងយុទ្ធនាការនេះនឹងបន្ត នៅឆ្នាំ២០២០ទៀត ដើម្បីជំរុញការធានា និងការទប់ស្កាត់ពលកម្មកុមារនេះក្នុងកម្រិតមួយនៅក្នុងគ្រោះថ្នាក់សឹងតែគ្មាន ឬអាចនិយាយបានថា គ្មានពលកម្មកុមារនៅក្នុងសិប្បកម្មផលិតឥដ្ឋនោះឡើយ។ លោកលើកឡើងបន្តថា យុទ្ធនាការការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនេះ ធ្វើឡើងក្នុងគោលបំណង ទី១.អនុវត្តអធិការកិច្ចនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ដើម្បីធានាបាននូវលក្ខខណ្ឌការងារល្អប្រសើរលើផលិតកម្ម នៃការប្រើប្រាស់ផលិតផលធ្វើពីឥដ្ឋ ដែលជាគម្រោងមួយដ៏សំខាន់ក្នុងការគាំទ្រដល់វិស័យសំណង់នៅកម្ពុជា ទី២. ផ្សព្វផ្សាយ និងលើកកម្ពស់ឱ្យមានការប្រឆាំងពលកម្មកុមារ តាមរយៈនិយោជក កម្មករនិយោជិត និងក្រុមគ្រួសារសហគមន៍ ដែលនៅជុំវិញបរិវេណសិប្បកម្មផលិតឥដ្ឋ ដើម្បីឱ្យពួកគាត់មានការយល់ដឹងអំពីវិធានការណ៍ និងការហាមប្រាមនៃការប្រើប្រាស់ពលកម្មកុមារ ទី៣.ជួយសង្គ្រោះកុមារដែលមានករណីមានការប្រើប្រាស់ពលកម្មកុមារ គឺយើងនឹងផ្តល់ការស្តារនីតិសម្បទា និងផ្តល់ឱកាសនូវកិច្ចអន្តរាគមន៍ស្មុល ដើម្បីជំរុញឱ្យកុមារទាំងនេះទទួលបានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ទន្ទឹមនឹងនេះដែរ លោកអគ្គលេខាធិការ ក៏បានជម្រាបទៅដល់ និយោជក កម្មករនិយោជិតថា ការហាមប្រាមពលកម្មកុមារ និងការពង្រឹងលក្ខខណ្ឌការងារល្អ និងពង្រឹងសមត្ថភាពកម្មករនិយោជិតវ័យក្មេងនេះ គឺជាការពង្រីកនូវកាលានុវត្តភាពនៃពាណិជ្ជកម្ម ក៏ដូចជាសេដ្ឋកិច្ចនៅកម្ពុជា និងទីផ្សារការងារដ៏ល្អប្រសើរនៅកម្ពុជា ការប្រើប្រាស់ពលកម្មកុមារមិនត្រឹមតែបង្កប៉ះពាល់ដល់អាជីវកម្មទេ ថែមទាំងសង្គមទាំងមូល សូមអាណាព្យាបាលទាំងអស់បញ្ជូនកូនឱ្យបានទៅរៀនគ្រប់ៗគ្នា ហើយរំពឹងទុកថា កុមារទាំងអស់នេះនឹងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈត្រឹមត្រូវដែលជាទីផ្សារកម្លាំងពលកម្មដ៏ល្អបំផុតសម្រាប់កម្ពុជានាពេលអនាគត៕

## ជប៉ុនសន្យានៅតែបន្តជួយបណ្តុះបណ្តាលធនធានមនុស្សលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់កម្ពុជា

http://www.rasmeinews.com/ August 13, 2019, 11:32 AM

*ដោយៈដេប៉ូ/ភ្នំពេញ ៖* ឯកអគ្គរាជទូតជប៉ុន ប្រចាំកម្ពុជាដែលបញ្ចប់អាណត្តិបាន បង្ហាញនូវកិច្ចសហប្រតិបត្តិការល្អជាមួយកម្ពុជា ក្នុងនេះថា នៅតែបន្តក្នុងការជួយបណ្តុះបណ្តាលផ្នែកជំនាញវិជ្ជាជីវៈដល់ពលរដ្ឋកម្ពុជាបន្ថែមទៀត។ ការលើកឡើងបែបនេះធ្វើឡើងដោយលោក HORINOUCHI ឯក អគ្គរាជទូតជប៉ុន ប្រចាំកម្ពុជាចប់អាណត្តិដែលបានជួបសំណេះសំណាលនិងជម្រាបលា លោកអ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនាទីស្តីការក្រសួងការងារ កាលពីរសៀលថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩កន្លងមក។ បញ្ជាក់ប្រាប់ លោករដ្ឋមន្ត្រីក្រសួងការងារក្នុងពិធីនេះ លោក HORINOUCHI បាន ឲ្យដឹងថា ប្រទេសជប៉ុននៅតែរីករាយក្នុងការផ្តល់នូវការបណ្តុះបណ្តាលធនធានមនុស្សដល់កម្ពុជាបន្ថែមទៀត។ ព្រមជាមួយគ្នានេះលោកអគ្គរាជទូតបានរំលឹកដែរថា កន្លងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា បានចុះអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការជាមួយប្រទេសជប៉ុនលើការបញ្ជូនកម្មសិក្សាការី-ពលករជំនាញទៅធ្វើការនៅប្រទេសជប៉ុនចំនួន ២ រួមមានៈ ទី១. អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ (MOC) ស្តីពីកម្មវិធីបណ្តុះបណ្តាលកម្មសិក្សាការីជំនាញបច្ចេកទេស បានចុះនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ និងទី២. អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ (MOC) ស្តីពីក្របខណ្ឌសម្រាប់ភាពជាដៃគូព័ត៌មានសម្រាប់ប្រតិបត្តិការសមស្របនៃប្រព័ន្ធទទួលយកធនធានមនុស្សបរទេស ដោយមានឋានៈនៃការស្នាក់នៅនៃពលករជំនាញ បានចុះនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។

បញ្ជាក់ក្នុងពិធីនេះដែរ លោក អ៊ិតសំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈថ្លែងអំណរគុណចំពោះរដ្ឋាភិបាលជប៉ុន ដែលបានទទួល និងបណ្តុះបណ្តាលកម្មសិក្សាការីកម្ពុជា ឲ្យទទួលបានប្រាក់បៀវត្សខ្ពស់ និងចំណេះជំនាញយ៉ាងល្អប្រសើរ ដែលបានរួមចំណែកជួយជំរុញជីវភាពរបស់ពួកគេឱ្យមានភាពរីកចម្រើនបានមួយកម្រិត។ សម្រាប់កិច្ចប្រតិបត្តិការក្នុងប្រទេស ជប៉ុនបានបញ្ជូនគ្រូជំនាញមកបណ្តុះបណ្តាលដល់សិក្ខាកាមកម្ពុជានិងក្រៅពីនេះ ក្រុមហ៊ុនវិនិយោគជប៉ុនដែលបាននិងកំពុងវិនិយោគនៅកម្ពុជា ក៏មានការយកចិត្តទុកដាក់ចំពោះកម្មករនិយោជិតផងដែរ ដូចជាបញ្ហាអនាម័យ និងសុវត្ថិភាពការងារ ពិសេសជប៉ុនក៏បានជួយជំរុញការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ (TVET) ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA)ជាដើម។ លោក រដ្ឋមន្ត្រីបានលើកឡើងផងថា កម្ពុជានៅតែបន្តកិច្ចសហប្រតិបត្តិការល្អជាមួយស្ថានទូតជប៉ុន រដ្ឋាភិបាល និងប្រជាជនជប៉ុនជានិច្ច ដើម្បីធ្វើឱ្យទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរកាន់តែល្អប្រសើរ និងមានភាពយូរអង្វែងទៅថ្ងៃខាងមុខ។ គួរបញ្ជាក់ ទៀត ថា លោក HORINOUCHI ដែលបញ្ចប់តំណែងជាអគ្គរាជទូតជប៉ុន ប្រចាំកម្ពុជានឹងត្រូវចេញពីប្រទេសកម្ពុជាត្រលប់ទៅប្រទេសជប៉ុនវិញ៕B/

## ចាប់ និងឃុំខ្លួនលោក អះម៉ាត់ យ៉ះយ៉ា និងក្មួយប្រុស ពាក់ព័ន្ធការជួញដូរមនុស្សទៅប្រទេសអារ៉ាប់, តុលាការប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ១៥ឆ្នាំ និងពិន័យទឹកប្រាក់២០០លានរៀល

https://mediakhmer.club/media/ August 13, 2019 khmer media News

(ភ្នំពេញ)៖ លោក អះម៉ាត់ យ៉ះយ៉ា អតីតរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានតុលាការចេញដីកាឃុំខ្លួនដាក់ពន្ធនាគារ ជាមួយនឹងក្មួយប្រុសរបស់ខ្លួនម្នាក់ទៀត ពាក់ព័ន្ធករណីជួញដូរមនុស្សទៅប្រទេសអារ៉ាប់។ នេះបើយោងតាមការសម្រេចរបស់លោក គួរ សៅ អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជាប្រធានក្រុមប្រឹក្សាជំនុំជម្រះនៅរសៀលថ្ងៃនេះ។ សម្រាប់ជនជាប់ចោទទាំងពីរនាក់ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ចំនួន១៥ឆ្នាំ និងពិន័យជាទឹកប្រាក់ ចំនួន២០០លានរៀល ដោយត្រូវសងទៅជនរងគ្រោះម្នាក់ ១២០ លានរៀល និងម្នាក់ទៀត ៨០លានរៀល។

យោងតាមសេចក្តីរាយការណ៍របស់លោក ជួន សុជាតិ ភ្នាក់ងារព័ត៌មាន Fresh News ប្រចាំតុលាការបានឲ្យដឹងថា កាលពីព្រឹកមិញ តុលាការបានបើកការជំនុំជម្រះទៅលើជនជាប់ចោទ អ៊ីស្មាអែល ពិនឧស្មន ដែលជាក្មួយប្រុសរបស់លោក អះម៉ាត់ យ៉ះយ៉ា ហើយពេលនោះ លោក អះម៉ាត់ យ៉ះយ៉ា ក៏បានចូលរួមស្តាប់សវនាការ លុះពេលចប់សវនាការ និងក្រោយពេលតុលាការប្រកាស ផ្តន្ទាទោសនោះ លោក អះម៉ាត់ យ៉ះយ៉ា ក៏ត្រូវបានចាប់ខ្លួនតែម្តង បញ្ជូនទៅកាន់ពន្ធនាគារ។ សូមបញ្ជាក់ថា ក្មួយបង្កើតលោក អះម៉ាត់ យ៉ះយ៉ា គឺលោក អ៊ីស្មាអែល ពិនឧស្មន ត្រូវបានកម្លាំងនគរបាល នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចាប់ខ្លួន ពាក់ព័ន្ធករណីនាំពលករទៅធ្វើការខុសច្បាប់ នៅប្រទេសអារ៉ាប់ប៊ីសាអូឌីត កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨។

មន្ត្រីនគរបាលបញ្ជាក់ថា កាលពីអំឡុងឆ្នាំ២០០៤ ជនសង្ស័យខាងលើបានឃោសនាក្នុងភូមិថា ឈ្មោះ អះម៉ាត់ យ៉ះយ៉ា ត្រូវជាពូរបស់ខ្លួន ត្រូវការជ្រើសរើសពលការិនីបញ្ជូន ទៅធ្វើការជាជំនួយការមេផ្ទះ នៅប្រទេសអារ៉ាប់ប៊ីសាអូឌីត ប្រាក់ឈ្នួល២២០ដុល្លារអាមេរិច កិច្ចសន្យាការងាររយៈពេល២ឆ្នាំ ចំពោះឯកសារបែបបទ លិខិតឆ្លងដែន និងសោហ៊ុយធ្វើដំណើរ ឈ្មោះ អះម៉ាត់ យ៉ះយ៉ា ជាអ្នកចំណាយ។ បន្ទាប់មកបានអូសទាញពលរដ្ឋក្នុងភូមិ២នាក់ ក្រោយមកបានចំនួន២០នាក់ទៀត ហើយនាំទៅប្រគល់ឲ្យលោក អះម៉ាត់ យ៉ះយ៉ា ស្នាក់នៅផ្ទះលេខ៣៤ ផ្លូវលេខ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ ពេលនោះជនរងគ្រោះត្រូវបានលោក អះម៉ាត់ យ៉ះយ៉ា ក្លែងអត្តសញ្ញាណដោយប្រើឯកសារ ហើយបានបញ្ជូនទៅធ្វើជាស្រ្តីបម្រើតាមផ្ទះ នៅប្រទេសអារ៉ាប់ប៊ីសាអូឌីត ។

នៅប្រទេសអារ៉ាប់ប៊ីសាអូឌីត ជនរងគ្រោះត្រូវបានថៅកែកេងប្រវ័ញ្ចកម្លាំងពលកម្ម បិទសិទ្ធសេរីភាព ហើយត្រូវបានគេលក់ទៅថៅកែជាម្ចាស់ទី១ ទៅថៅកែទី២ ក្នុងតម្លៃ២០,០០០ដុល្លារ ឲ្យធ្វើការងារផ្ទះ ហើយរងការរំលោភផ្លូវភេទ និងមិនទទួលបានប្រាក់ឈ្នួលតាំងពីពេលបញ្ជូនទៅ រហូតដល់អំឡុងខែសីហា ឆ្នាំ២០១៧។ មន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស បន្ថែមថា ជនរងគ្រោះចំនួន ២នាក់ត្រូវបានជួយសង្គ្រោះពីពីលោក អូស្មាន ហាស្សាន់ ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស សង្គ្រោះមកកម្ពុជាវិញ៕ ប្រភព៖ freshnews

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៣នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI **12-08-2019**

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៣នាក់ នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ ពីបទឆ្លងដែនស្នាក់នៅ និងធ្វើការខុសច្បាប់ នៅប្រទេសថៃ ដែលចេញតាមច្រកទ្វារព្រំដែនអន្តរជាតិជាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ៕

## ពលករខ្មែរម្នាក់មានឈ្មោះ សូធី បានដើរអិលជើងធ្លាក់ទឹកអូរបណ្តាលអោយរងរបួសធ្ងន់

https://www.facebook.com/ **ទឹកចិត្ត ពលករ ឆ្លងដែន** 13-8-2019

មានហេតុការណ៍មួយបានកើតឡើងមកលើពលករខ្មែរយើងម្នាក់មានឈ្មោះ សូធី បានដើរអិលជើងធ្លាក់ទឹកអូរបណ្តាលអោយរងរបួសធ្ងន់ បានក្រុមជួយសង្គ្រោះថៃបាននាំបញ្ជូនទៅកាន់មន្ទីរពេទ្យដោយសុវត្ថិភាព។ ហេតុកាណ៍នេះបានកើតឡើងនៅឃុំខ្លងយ៉ៃ ស្រុកខ្លងយ៉ៃ ខេត្តត្រាត ប្រទេសថៃ។

## ពលករខ្មែរប្រមាណ ១០០នាក់ចូលរួមបូជាសពពលករម្នាក់ស្លាប់នៅប្រទេសថៃ

https://www.rfa.org/khmer/ ដោយ មួង ណារ៉េត 2019-08-12

ពលករខ្មែរធ្វើការនៅប្រទេសថៃប្រមាណ ១០០នាក់ នៅរសៀលថ្ងៃទី១១ សីហា នាំគ្នាចូលរួមបូជាសពពលករខ្មែរម្នាក់ ដែលស្លាប់នៅខេត្តប្រាក់ធុមថានី (Phrathumthani) ជាប់ទីក្រុងបាងកក។

ពលករម្នាក់ឈ្មោះ ជឹម ផាត ដែលបានចូលរួមបូជាសព ប្រាប់អាស៊ីសេរីនៅរសៀលថ្ងៃទី១១ សីហាថា ពលករដែលស្លាប់នោះមានឈ្មោះ វ៉ែង សំណាង អាយុ ៣៦ឆ្នាំ ស្លាប់ដោយជំងឺគាំងបេះដូង កាលពីយប់ម៉ោង ១២យប់ថ្ងៃទ១០ សីហា។ សព លោកវ៉ែង សំណាង មានស្រុកកំណើតនៅភូមិបុស្សស្បូវឃុំភ្នំដីស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យជាពលករធ្វើការនៅក្រុមហ៊ុនប្រមូលទិញអេតចាយនៅខេត្តប្រាក់ធុមថានី (Phrathumthani)។សពរបស់លោកត្រូវបានបូជានៅរសៀលថ្ងៃទី១១ សីហា៖ «បងប្អូនពលករថ្ងៃណេះគាត់សម្រាកធ្វើការងារទាំងអស់គ្នា សូម្បីតែជាថ្ងៃដែលធ្វើការក៏ដោយ ព្រោះទាំងខ្ញុំទាំងគេពេលដឹងបងណាងដេកស្លាប់ធ្វើឱ្យខ្ញុំស្លុតចិត្ត ព្រោះលោកធ្លាប់រួមការងារជាមួយគ្នាទើបពួកគាត់សម្រាកពីការហើយនាំគ្នាជិះឡានទៅចូលរួមបូជាសពនៅក្នុងវត្តនៅខេត្តប្រ៉ាក់ធុមធានីនេះតែម្តង»។

ពលកររូបនេះបន្តថា មូលហេតុដែលប្រញាប់បូជាសពដោយសារសាច់ញាតិក្រីក្រ ហើយមិនមានប្រាក់ ដើម្បីដឹកសពយកទៅធ្វើទៅបុណ្យនៅស្រុកកំណើតបានទេ ទើបបូជាសពនៅប្រទេសថៃ រួចយកធាតុទៅធ្វើបុណ្យនៅកម្ពុជាតាមក្រោយ៕

# ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០១៩

## លោក ស ខេង ស្នើឲ្យបង្កកទ្រព្យសម្បត្តិរបស់ឧក្រិដ្ឋជនជួញដូរមនុស្ស

https://khmer.voanews.com/ 14 សីហា 2019 ហ៊ុល រស្មី

នៅចំពោះមុខអ្នកតំណាងសាសនាព្រះពុទ្ធ សាសនាកាតូលិក និងសាសនាអ៊ីស្លាម ជាច្រើនរយនាក់ លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានស្នើឲ្យមានការបង្កកទ្រព្យសម្បត្តិឧក្រិដ្ឋជនដែលបានប្រព្រឹត្តអំពើជួញដូរមនុស្ស។

ភ្នំពេញ៖ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង នៅថ្ងៃពុធនេះ បានស្នើឲ្យមានការបង្កកទ្រព្យសម្បត្តិរបស់ឧក្រិដ្ឋជនដែលសង្ស័យថាជាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស ការលាងលុយកខ្វក់ និងការកាប់ឈើខុសច្បាប់។

ថ្លែងនៅក្នុងវេទិកាជាតិ អន្តរសាសនានៅកម្ពុជាលើកទី៣ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សធ្វើឡើងនៅរាជធានីភ្នំពេញ លោក ស ខេង ដែលជាឧបនាយករដ្ឋមន្ត្រីមួយរូបផងនោះ មានប្រសាសន៍ថា ក្រុមឧក្រិដ្ឋជនជួញដូរមនុស្សគឺជាក្រុមអ្នកដែលមានទ្រព្យសម្បត្តិច្រើន ដូច្នេះគ្រាន់តែចាប់ខ្លួនពួកគេមកផ្តន្ទាទោសនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ពោលគឺគប្បីរឹបអូសទ្រព្យសម្បត្តិពួកគេបន្ថែមទៀត។ «បើយើងគ្រាន់តែចាប់បានមក យកមនុស្សហ្នឹងទៅកាត់ទោស ប៉ុន្តែអាចចរាចរលុយនោះ ដែលលុយវាខ្មៅស្រាប់នោះ យើងអត់មានបង្កកទុក វាអត់មានប្រយោជន៍ទេ»។

ក្នុងរបាយការណ៍ឆ្នាំ២០១៩នេះ ក្រសួងការបរទេសអាមេរិកបានទម្លាក់ចំណាត់ថ្នាក់នៃប្រសិទ្ធភាពនៃការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សរបស់ប្រទេសកម្ពុជាពីកម្រិត២ (ធម្មតា) ទៅកម្រិត២ស្ថិតក្រោមការឃ្លាំមើល ឬ

(Tier 2 Watch list)។ កម្រិតដែលស្ថិតក្រោមការឃ្លាំមើលនេះមានន័យថា កម្រិតប្រសិទ្ធភាពនៃការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សរបស់ប្រទេសកម្ពុជាស្ថិតក្នុងចំណុចអាក្រក់ដែលងាយនឹងរអិលទៅរកកម្រិតកាន់តែអាក្រក់ជាងនេះ គឺកម្រិត៣ ឬ Tier 3។

នៅថ្ងៃនេះលោក ស ខេង មានប្រសាសន៍ថា កម្ពុជានឹងបង្កើនការខិតខំរបស់ខ្លួនបន្ថែមទៀត លើការអប់រំនិងការផ្សព្វផ្សាយពីល្បិចកលនៃការជួញដូរមនុស្សទៅដល់ប្រជាពលរដ្ឋខ្មែរនៅទូទាំងប្រទេសនិងការអនុវត្តច្បាប់ឲ្យបានតឹងរ៉ឹងដើម្បីលុបបំបាត់ចោលរាល់ទម្រង់នៃការជួញដូរមនុស្សនេះ។

យោងតាមអ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងរយៈពេលប្រាំមួយខែដើមឆ្នាំ២០១៩នេះ អាជ្ញាធរមានសមត្ថកិច្ច បង្ក្រាបសកម្មភាពជួញដូរមនុស្សបាន ចំនួន៧៨ករណី គឺកើនឡើង ១៦ករណី បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។ អ្នកស្រីបន្ថែមថា ជនសង្ស័យចំនួន៩៧នាក់ត្រូវបានឃាត់ខ្លួននិងបញ្ជូនទៅសាលាដំបូងរាជធានីខេត្ត។ ក្នុងនោះមានស្ត្រី២២នាក់ ជនបរទេស១៤នាក់គឺជនជាតិចិន១២នាក់ និងជនជាតិអាមេរិកចំនួនពីរនាក់។ ជនរងគ្រោះចំនួន២៦៣នាក់ត្រូវបានសង្គ្រោះ។

គួរបញ្ជាក់ថាស្របពេលដែលរដ្ឋាភិបាលប្រារព្ធវេទិកាជាតិ អន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរកាលពីម្សិលមិញអតីតអ្នកនយោបាយជាន់ខ្ពស់មួយរូបគឺលោក អះម៉ាត់ យ៉ះយ៉ា ត្រូវបានតុលាការរាជធានីភ្នំពេញផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល១៥ឆ្នាំ ពីបទជាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទៅកាន់ប្រទេសអារ៉ាប់ប៊ីសាអ៊ូឌីត។ ក៏ប៉ុន្តែក្រុមគ្រួសារអតីតរដ្ឋលេខាធិការក្រសួងសង្គមកិច្ចរូបនេះលើកឡើងថា ការផ្តន្ទាទោសនេះទាក់ទងទៅនឹងទំនាស់បុគ្គលជាមួយមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាល។

លោក អះម៉ាត់ យ៉ះយ៉ា ជាអតីតអ្នកនយោបាយរបស់គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច និងគណបក្ស សមរង្ស៊ី ហើយចុងក្រោយនេះលោកបានចូលរួមជីវភាពនយោបាយជាមួយគណបក្សប្រជាជនកម្ពុជា របស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែន៕

## រដ្ឋមន្ត្រីមហាផ្ទៃប្តេជ្ញា លុបបំបាត់អំពើ ជួញដូរមនុស្សនៅ កម្ពុជា

https://www.dap-news.com/ ByID:030  Posted on 14 August 2019 | 18:49

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានប្តេជ្ញាចិត្ត ធ្វើសកម្មភាពរួមគ្នា ដើម្បីឲ្យយល់ដឹង អំពើជួញដូរមនុស្ស ផលប៉ះពាល់ ល្បិចកលជនល្មើស និងនាំគ្នាលុបបំបាត់ ទាសភាពសម័យទំនើបនេះ ឲ្យអស់ពីប្រទេសកម្ពុជា។ ក្នុងវេទិកាជាតិ អន្តរសាសនានៅកម្ពុជាលើកទី៣ ដើម្បីប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នៅរសៀលថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ សម្តេច ស ខេង បានថ្លែងឲ្យដឹងថា ជនល្មើសបានប្រព្រឹត្តទៅលើ ជនរងគ្រោះជាមនុស្សគ្រប់វ័យ ឥតរើសមុខ ដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ បាត់បង់សិទ្ធិជាមនុស្ស បាត់បង់សេចក្តីសុខ ក្នុងគ្រួសារ ខូចខាតដល់សុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ រហូតដល់បាត់បង់អាយុជីវិត រៀងរាល់ថ្ងៃ យ៉ាងអណោចអធម។

*សម្តេចមានប្រសាសន៍ថា "យើងទាំងអស់គ្នាប្តេជ្ញាចិត្តធ្វើសកម្មភាពរួមគ្នា និងបន្តពង្រីកការផ្សព្វផ្សាយតាមរយៈការអប់រំតាមបែបសាសនា ដល់សាសនិកគ្រប់និកាយ សាសនាទាំងអស់ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឲ្យយល់ដឹង អំពីអំពើជួញដូរមនុស្ស ផលប៉ះពាល់ ល្បិចកលជនល្មើស និងនាំគ្នាលុបបំបាត់ទាសភាពសម័យទំនើបនេះ ឲ្យអស់ពីទឹកដីកម្ពុជា"។*

សម្តេចបន្តថា ជំនឿសាសនា គឺជាឱសថដែលព្យាបាលជំងឺផ្លូវចិត្ត ជាមាគ៌ាតម្រង់ផ្លូវឲ្យមនុស្សដើរទៅតាមផ្លូវសុចរិត ជាច្បាប់កម្រិតឲ្យមនុស្សជៀសវាងនូវកំហុសក្នុងការកសាងបាបកម្ម និងឧក្រិដ្ឋកម្មនានា ឲ្យមនុស្សចេះរស់នៅមានភាព សុខដុមរមនា ក្នុងកិត្តិយស និងសេចក្តីថ្លៃថ្នូរ ចេះគោរពខ្លួនឯង និងគោរពគ្នាទៅវិញទៅមក មានន័យថា "សាសនា គឺជាប្រភពនៃសេចក្តីសុខ" របស់មនុស្ស។ ជាងនេះទៅទៀត រដ្ឋមន្ត្រីមហាផ្ទៃ មានជំនឿយ៉ាងមុតមាំថា តាមរយៈ វេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី៣ នឹងជួយរួមចំណែកដល់សកម្មភាពបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឈានទៅបញ្ចប់ទាសភាពសម័យទំនើបយ៉ាងពិតប្រាកដ។

ចំណែក លោក ហ៊ឹម ឆែម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួង ធម្មការ និងសាសនា បានលើកឡើងថា ភាគីពាក់ព័ន្ធទាំងអស់ត្រូវប្រឆាំងដាច់ខាតអំពើជួញដូរ កេងប្រវ័ញ្ចគ្រប់រូបភាព លើមនុស្ស និងបញ្ចប់ឲ្យបាននូវទាសភាពសម័យទំនើបដ៏អមនុស្សធម៌នេះ ដើម្បីសេចក្តីសុខរបស់ប្រជាជនកម្ពុជា និងមនុស្សទូទៅក្នុងពិភពលោក។

សូមរំលឹកថា ក្នុងឆមាសទី១ ឆ្នាំ២០១៩ ក្រុមសមត្ថកិច្ចចំរុះមកពីអគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាល រាជធានី-ខេត្ត ទាំង១៩ បានតាមដានស្រាវជ្រាវ បង្រ្កាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទបាន៧៨ករណី និងឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន៩៧ ក្នុងនោះស្រី២២នាក់ អនីតិជន៩នាក់ ជនបរទេស១៤នាក់ដែល មានជនជាតិចិន១២នាក់ និងអាមេរិក២នាក់៕ ដោយ ៖ អេង ប៊ូឆេង

## សម្តេចក្រឡាហោម ស ខេង បង្ហាញអំពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា

http://www.freshnewsasia.com/ 2019-08-14

**(ភ្នំពេញ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅរសៀលថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩នេះ បានបង្ហាញអំពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ចប់ការធ្វើទាសភាពសម័យទំនើបនៅក្នុងប្រទេសកម្ពុជា។

ការបង្ហាញនូវអ្វីដែលជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ពីសំណាក់សម្តេចក្រឡាហោម ស ខេង ត្រូវបានធ្វើឡើងតាមរយៈ វេទិកាជាតិ អន្តរសាសនា លើកទី៣ «ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប» ដែលបានរៀបចំធ្វើឡើងនៅមជ្ឈមណ្ឌល និងពិពណ៌កោះពេជ្រ។ សម្តេចក្រឡាហោម ស ខេង បានគូសបញ្ជាក់ថា នេះគឺជាលើកទី៣ហើយ ដែលទិវាអន្តរសាសនាថ្នាក់ជាតិដ៏មហោឡារឹកនេះ បានប្រារព្ធធ្វើឡើងក្នុងកម្ពុជា ដោយមានការឯកភាពគ្នារវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃរាជរដ្ឋាភិបាលកម្ពុជា និងមេដឹកនាំសាសនាធំៗ ទាំងឡាយនៅកម្ពុជា។ បើតាមសម្តេច ស ខេង វេទិកានេះធ្វើឡើង ដើម្បីបញ្ជាក់អំពីការប្តេជ្ញាចិត្តរួមគ្នារវាងរាជរដ្ឋាភិបាល ស្ថាប័នសាសនា អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រជាពលរដ្ឋទាំងអស់ក្នុងប្រទេសកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាអំពើដ៏ឃោរឃៅ អមនុស្សធម៌ និងជាអំពើបាបយ៉ាងធ្ងន់ធ្ងរ ដែលជនល្មើសបានប្រព្រឹត្តទៅលើជនរងគ្រោះជាមនុស្សគ្រប់វ័យ ទាំងទារក កុមារ យុវ័យ និងមនុស្សចាស់គ្រប់ភេទ ឥតរើសមុខ ដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ បាត់បង់សិទ្ធិជាមនុស្ស បាត់បង់សេចក្តីសុខក្នុងគ្រួសារ ខូចខាតដល់សុខ ភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ រហូតដល់បាត់បង់អាយុជីវិតរៀងរាល់ថ្ងៃ យ៉ាងអណោចអធ័ម។

សម្តេចក្រឡាហោម ស ខេង បានគូសបញ្ជាក់យ៉ាងដូច្នេះថា **«យើងទាំងអស់គ្នាប្តេជ្ញាចិត្ត ធ្វើសកម្មភាពរួមគ្នា និងបន្តពង្រីកការផ្សព្វផ្សាយតាមរយៈការអប់រំតាមបែបសាសនា ដល់សាសនិកគ្រប់និកាយសាសនាទាំងអស់ ដែលមាន**

**នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឲ្យយល់ដឹង អំពីអំពើជួញដូរមនុស្សផលប៉ះពាល់ ល្បិចកលជនល្មើស និងនាំគ្នាលុបបំបាត់ ទាសភាពសម័យទំនើបនេះ ឲ្យអស់ពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា»។**

ប្រមុខដឹកនាំក្រសួងមហាផ្ទៃ ក៏បានលើកឡើងទៀតថា នេះជាសកម្មភាពដ៏កម្រមួយ ដែលបង្ហាញអំពីភាពសុខដុមរមនានៃសាសនា នៅក្នុងប្រទេសកម្ពុជា ដែលមានគោលដៅរួមគ្នា គឺការបង្កើតឲ្យមានសេចក្តីសុខ ផ្លូវកាយ ផ្លូវចិត្តដល់មនុស្ស មិនបៀតបៀនគ្នា មិនប្រឈមមុខដាក់គ្នា ព្រមទាំងរួមគ្នាអប់រំកាយចិត្ត តាមបែបជំនឿសាសនារៀងៗខ្លួន ដល់សាសនិកទាំងឡាយ ឲ្យលើកកម្ពស់សីលធម៌ក្នុងការរស់នៅ និងជួយជាស់តឿនក្រើន រំលឹកគ្នាមិនឲ្យធ្វើនូវអំពើការការគេងប្រវ័ញ្ច រំលោភបំពាន ដែលនាំឲ្យមនុស្សជទៃ និងខ្លួនឯងរងទុក្ខវេទនា។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា, សម្តេចក្រឡាហោម ស ខេង បានសម្តែងនូវការកោតសរសើរអស់ពីដួងចិត្ត និងសូមគាំទ្រសកម្មភាពនេះ ឲ្យមានជារៀងរហូតនៅកម្ពុជា ដើម្បីជាគ្រឹះដ៏រឹងមាំ នៃសីលធម៌ក្នុងការរស់នៅ ដែលនាំមកនូវសេចក្តីសុខ សន្តិភាពផ្លូវកាយ ផ្លូវចិត្តរបស់មនុស្សក្នុងសង្គម ជាសេចក្តីត្រូវការចាំបាច់ មិនអាចខ្វះបាន ក្នុងជីវិតរស់នៅប្រចាំថ្ងៃ ក៏ដូចជាដើម្បីលើកកម្ពស់វប្បធម៌អារ្យធម៌ដ៏ល្អផូរផង់របស់កម្ពុជា ដែលធ្លាប់មានតាំងពីយូរលង់មកហើយ។

សម្តេចក្រឡាហោម ស ខេង បានអះអាងថា តាមរយៈ «វេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី៣» ដែលបាន និងកំពុងតែប្រព្រឹត្តទៅក្នុង ព្រះរាជាណាចក្រកម្ពុជា នាពេលនេះ នឹងជួយរួមចំណែកដល់សកម្មភាពបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឈានទៅបញ្ចប់ទាសភាពសម័យទំនើបយ៉ាងពិតប្រាកដ។ មិនតែប៉ុណ្ណោះ សកម្មភាពនេះ បាននិងកំពុងក្លាយទៅជាកម្លាំងសាមគ្គីភាពដ៏រឹងមាំក្នុងសង្គមជាតិកម្ពុជា និងជាសកម្មភាពដ៏រស់រវើក ដែលនឹងធ្វើឲ្យជ្រួតជ្រាបទៅដល់ប្រជាពលរដ្ឋគ្រប់ច្រកល្ហក ឲ្យរួមគ្នាបង្ការទប់ស្កាត់ និងការពារគ្នាទៅវិញទៅមកពីអំពើជួញដូរមនុស្ស ដោយមិនប្រកាន់និន្នាការ និងជំនឿសាសនាណាមួយឡើយ ដើម្បីឈានទៅបញ្ចប់ទាសភាពសម័យទំនើបដ៏ឃោរឃៅនេះ៕

## ការជួញដូរមនុស្ស ជាអំពើឃោរឃៅ អមនុស្សធម៌ និងជាអំពើបាបយ៉ាងធ្ងន់ធ្ងរ ដែលជនល្មើសបានប្រព្រឹត្តទៅលើជនរងគ្រោះ

http://www.cen.com.kh/archives/ August 15, 2019

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា ជំនឿសាសនាគឺជាឱសថដែលព្យាបាលជំងឺផ្លូវចិត្ត និងជាគ្រឹះដ៏រឹងមាំនៃសីលធម៌ក្នុងការរស់នៅ ដើម្បីកាត់បន្ថយ និងឈានទៅការលុបបំបាត់អំពើជួញដូរមនុស្ស។ សម្តេចក្រឡាហោមបានលើកឡើងបែបនេះ ក្នុងឱកាសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងវេទិការជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស និងទាសភាពសម័យទំនើបលើកទី៣ នារសៀលថ្ងៃពុធ ទី១៤ ខែសីហា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានមានប្រសាសន៍លើកឡើងថា ជំនឿសាសនា គឺជាឱសថដែលព្យាបាលជំងឺផ្លូវចិត្ត ជាមាគ៌ាតម្រង់ផ្លូវឱ្យមនុស្សដែលទៅតាមផ្លូវសុចរិត ជាច្បាប់កម្រិតអោយមនុស្សជៀសវាងនូវកំហុសក្នុងការកសាងបាបកម្ម និងឧក្រឹដ្ឋកម្មនានា ឲ្យមនុស្សចេះរស់នៅមានភាពសុខុនរមនា ក្នុងកិត្តិយស និងសេចក្តីថ្លៃថ្នូរ ចេះគោរពខ្លួនឯង និងគោរពគ្នាទៅវិញទៅមក ដែលនេះមានន័យថា សាសនា គឺជាប្រភពនៃសេចក្តីសុខរបស់មនុស្ស ដែលនេះជាហេតុផលក្នុងការកាត់បន្ថយ និងឈានទៅការលុបបំបាត់អំពើជួញដូរមនុស្សក្នុងសង្គមកម្ពុជាផងដែរ។

សម្តេចក្រឡាហោម បានបន្តថា ការជួញដូរមនុស្ស គឺជាអំពើឃោរឃៅ អមនុស្សធម៌ និងជាអំពើបាបយ៉ាងធ្ងន់ធ្ងរ ដែលជនល្មើសបានប្រព្រឹត្តទៅលើជនរងគ្រោះជាមនុស្ស គ្រប់វ័យ ទាំងទារក កុមារ យុវវ័យ និងមនុស្សចាស់គ្រប់ប្រភេទ ឥតរើសមុខ ដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួនធ្វើឲ្យប៉ះពាល់ដល់កិត្តិយសសេចក្តីថ្លៃថ្នូរ បាត់បង់សិទ្ធិជាមនុស្ស

បាត់បង់សេចក្តីសុខក្នុងគ្រួសារខូចខាតដល់សុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ រហូតដល់បាត់បង់អាយុជីវិតរៀងរាល់ថ្ងៃ។ សម្តេចក្រឡាហោមបានបន្ថែមថា ការរួមគ្នាក្នុងសកម្មភាពពង្រីកការផ្សព្វផ្សាយតាមរយៈការអប់រំតាមបែបសាសនាដល់សាសនិកគ្រប់និកាយសាសនាទាំងអស់ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺដើម្បីឲ្យយល់ដឹងអំពីអំពើជួញដូរមនុស្ស ផលប៉ះពាល់ ល្បិចកលជនល្មើសនិងនាំគ្នាលុបបំបាត់ទាសភាពសម័យទំនើបនេះ ឲ្យអស់ពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

ថ្លែងក្នុងឱកាសនោះ លោកទេសរដ្ឋមន្រ្តី ហ៊ឹម ឆែម រដ្ឋមន្រ្តីក្រសួងធម្មការ និងសាសនា បានលើកឡើងថា ដើម្បីចូលរួមចំណែកបន្ត ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សវេទិការ អន្តរសាសនាថ្នាក់ជាតិលើកទី៣នេះ គឺរៀបចំឡើងក្នុងគោលបំណងសំខាន់ៗ រួមមាន ដើម្បីផ្សព្វផ្សាយ បង្កើនការយល់ដឹង នៃអំពើជួញដូរមនុស្ស និងតួនាទីសំខាន់ៗ របស់ថ្នាក់ដឹកនាំសាសនាទាំងឡាយ ក្នុងការអប់រំប្រជាជន ក្នុងការការពារ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលុបបំបាត់ទាសភាពសម័យទំនើប។ ដើម្បីពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័នពាក់ព័ន្ធជាពិសេសស្ថាប័នសាសនា ក្នុងការងារអប់រំផ្សព្វផ្សាយអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើបនៅតាមវត្តអារាម ព្រះវិហារ និងតាមពិធីសាសនានានា និងដើម្បីឲ្យសំឡេង នៃការសូត្រធម៌អធិដ្ឋាននេះ ផ្តល់នូវក្តីសង្ឃឹមដល់ជនរងគ្រោះ អ្នកដែលរងទុក្ខដោយសារអំពើជួញដូរមនុស្ស និងសូមឲ្យពួកគាត់ឆាប់បានទទួលនូវសេរីភាពឡើងវិញ។ ទេសរដ្ឋមន្ត្រី ហ៊ឹម ឆែម បានគូសបញ្ជាក់ទៀតថា វេទិកាអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺមិនត្រឹមតែជាវេទិកាគំរូថ្នាក់ជាតិមួយប៉ុណ្ណោះទេ គឺសម្រាប់ថ្នាក់តំបន់ និងពិភពលោកទាំងមូល។ វេទិកានេះ គឺជាសក្ខីភាពមួយ បង្ហាញអំពីភាពសុខដុមរមនា នៃសាសនាទាំងឡាយនៅប្រទេសកម្ពុជា។ មិនត្រឹមតែប៉ុណ្ណោះ វេទិកានេះបញ្ជាក់ពីការប្តេជ្ញាចិត្ត និងការចាប់ផ្តើមអនុវត្តន៍រួមគ្នាមួយរវាងសាសនាធំទាំងអស់ លើទស្សនៈវិស័យតែមួយ គឺប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ការលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការកសាងសន្តិភាព និងសុខុមរមនារបស់មនុស្សក្នុងសង្គមជាតិកម្ពុជាទាំងមូល។

តាមរបាយការណ៍របស់លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជរដ្ឋាភិបាល បានប្រឹងប្រែងជម្នះគ្រប់ឧបសគ្គ ក្នុងការបង្ការទប់ស្កាត់ បង្ក្រាប សង្គ្រោះ ផ្តន្ទាទោស និងការពារជនរងគ្រោះ យ៉ាងសកម្ម។

ដោយឡែក ក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០១៩នេះ ការអប់រំផ្សព្វផ្សាយ និងសកម្មភាពបង្ការទប់ស្កាត់ ត្រូវបានយកចិត្តទុកដាក់ និងធ្វើឡើងតាមគ្រប់រូបភាព ទាំងកិច្ចការពារផ្លូវច្បាប់ ការអប់រំផ្សព្វផ្សាយដោយផ្ទាល់ដោយប្រយោល តាមប្រព័ន្ធព័ត៌មាននានា ឲ្យបានដល់មនុស្ស រាប់លាននាក់ ដាក់ស្តែងវេទិកាអន្តរសាសនាថ្នាក់ជាតិ នាពេលនេះ ក៏ជាមធ្យោបាយមួយ ដើម្បីរួមចំណែកដល់ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើបផងដែរ។

បើតាមលោកស្រី ជូ ប៊ុនអេង ក្រសួង ស្ថាប័ន អង្គភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានធ្វើការបង្ការទប់ស្កាត់តាមជំនាញរៀងៗខ្លួន ដើម្បីគ្រប់គ្រងស្ថានភាពមិនឲ្យធ្លាក់ចូលក្នុងភាពរងគ្រោះ ដោយបទល្មើសជួញដូរមនុស្ស។ ចំពោះការងារបង្ក្រាប សមត្ថកិច្ចនគរបាលយុត្តិធម៌ បានធ្វើការស៊ើបអង្កេត ស្រាវជ្រាវ និងឈានដល់ការបង្ក្រាប សរុបបាន៧៨ករណី បើប្រៀបធៀបរយៈពេលដូចគ្នា ក្នុងឆ្នាំ២០១៨ មាន៦២ករណី (គឺកើនឡើង ១៦ករណី ស្មើនឹង២៥%) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៩៧នាក់លើ៨៥នាក់ (កើន១២នាក់ ស្មើនឹង ១៤%) ក្នុងនោះស្រី២២នាក់ អនីតិជន៩នាក់ ជាជនបរទេស ១៨នាក់ (សញ្ជាតិចិន ១២នាក់ និងអាមេរិក ២នាក់)៕ ដោយៈកូឡាប

## សម្តេច ស ខេង ៖ អ្នកជួញដូរមនុស្សសុទ្ធតែជាអ្នកមាន ហើយមានក្តីលោភលន់មិនចេះគ្រាន់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៩ ម៉ោង ១០:៥៦ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ ដោយក្តីលោភលន់មិនចេះគ្រប់គ្រាន់អ្នកជួញដូរមនុស្ស សុទ្ធតែអ្នកមាន ដែលធ្វើការបោកបញ្ឆោតមនុស្សយកទៅលក់ ។ នេះបើតាមសម្តេច ស ខេង ឧបកនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ថ្លែងក្នុងវេទិកាជាតិ អន្តរសាសនានៅកម្ពុជាលើកទី៣ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅរសៀលថ្ងៃទី១៤ ខែសីហានេះ នៅសាលសន្និសិទកោះពេជ្រ ។ សម្តេចស ខេង បានអះអាងថា ជនទុច្ចរិតដែលរកស៊ីជួញដូរមនុស្ស មិនមែនអ្នកក្រនោះ គឺអ្នកមានទ្រព្យសម្បត្តិ ប៉ុន្តែលោភលន់មិនចេះចប់ចេះហើយ ។ គេប្រើមធ្យោបាយរបស់គេដែលមានទៅបោកបញ្ឆោតអ្នកដែលគ្មានលទ្ធភាព អ្នកគ្មានការចេះដឹង ឬការអប់រំ ឬជីវភាពខ្សត់ខ្សោយ ។ ដើម្បីលុបបំបាត់ ឬចាប់អ្នកដែលជួញដូរមនុស្ស សម្តេច ស ខេង បញ្ជាក់ថា ៖«វិធានការរបស់យើង គឺយើងកំពុងនាំគ្នាប្រមូលកម្លាំងសរុប ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ ។ កម្លាំងសរុប គឺនៅទីនេះចាត់ទុកជាការប្រមូលកម្លាំងសរុបហើយ ។ «...» មិញនេះទាំងពុទ្ធសាសនា និងឥស្លាមសាសនាបានសម្តែងការគាំទ្រយ៉ាងពេញទំហឹងដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធការជួញដូរមនុស្ស ដូច្នេះគឺកម្លាំងមួយហើយ។ អ្វីដែលយើងត្រូវធ្វើ គឺផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះឲ្យបានយល់និងដឹងអំពីបែបផែនរបស់ជនទុច្ចរិតក្នុងការលោមលោងដើម្បីធ្វើការជួញដូរ» ។

សម្តេច ស ខេង ក៏បានលើកឡើង ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះដែរ គឺត្រូវធ្វើចលនាក្នុងការផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីសកម្មភាពដែលជនទុច្ចរិតធ្វើសកម្មភាពផងដែរ ។ សម្តេចក៏បានលើកឡើងថា មិនត្រូវតែពឹងតែទៅលើគណៈកម្មការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនោះទេ ។ ដោយសារគណៈកម្មការនេះ គ្រាន់តែស្នូល ឬជាបង្គោលដែលដាក់ចេញគោលការ និងវិធានការដើម្បីអនុវត្ត ។ ទន្ទឹមនឹងនេះយើងមិនអាចប្រើប្រាស់វិធានការអប់រំតែមួយមុខបានទេ យើងត្រូវប្រើវិធានការច្បាប់ថែមទៀតទើបមានប្រសិទ្ធភាព ។ សម្តេចបញ្ជាក់ថា ៖«បើយើងអប់រំមានប្រសិទ្ធភាព គឺជាការល្អ ប៉ុន្តែយើងប្រើវិធានការច្បាប់ថែមទៀតកាន់តែល្អ» ។ ជាមួយគ្នានោះដែរ សម្តេច ស ខេង ក៏បានឲ្យដឹងថា លទ្ធផលនៃការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សឆ្នាំ២០១៨កន្លងមកទទួលបានជោគជ័យ ប៉ុន្តែបើប្រៀបធៀបឆ្នាំ២០១៧ គឺធ្លាក់ចុះដែលក្រសួងការបរទេសអាមេរិកបានវាយតម្លៃថា កម្ពុជារាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ហើយរាជរដ្ឋាភិបាលទទួលបានលទ្ធផលល្អ ប៉ុន្តែមិនគ្រប់គ្រាន់នៅមានបញ្ហាខ្លះត្រូវបន្តតាមដានបន្តទៀត ។ កម្ពុជាជាប្រទេសជាប់ដំលាប់ថ្នាក់លេខ២ ក្នុងការលុបបំបាត់ការជួយដូរមនុស្ស ។ តែយើងក៏ត្រូវបន្តលុបបំបាត់ទាំងស្រុង ដើម្បីឲ្យក្លាយជាប្រទេសដែលស្ថិតក្នុងចំណាត់ថ្នាក់ល្អជាងនេះទៀត ៕ កែសម្រួលដោយ ៖ សុឃាក់

## ជនជាតិចាមថា ការឃុំខ្លួនលោក អះម៉ាត់ យ៉ះយ៉ា គឺជារឿងអយុត្តិធម៌

https://www.rfa.org/khmer/news/ ដោយ ទីន ហ្សាការីយ៉ា 2019-08-13

តុលាការបេបក្រុងភ្នំពេញបានសម្រេចផ្តន្ទាទោស អះម៉ាត់ យ៉ះយ៉ា អតីតរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចរយៈពេល ១៥ឆ្នាំ និងបញ្ជូនទៅខ្លួនភ្លាមៗ នៅពន្ធនាគារព្រៃសក្រោយសវនាការបានបញ្ចប់នៅថ្ងៃទី១៣ សីហា ពាក់ព័ន្ធករណីជួញដូរមនុស្សជាង ៣០០នាក់ទៅប្រទេសអារ៉ាប់។

ជនជាតិចាមបានចាត់ទុកការចោទប្រកាន់របស់តុលាការក្រុងភ្នំពេញបែបនេះថា ជារឿងអយុត្តិធម៌ និងមិនអាចទទួលយកបានចំពោះករណីលោក អះម៉ាត់ យ៉ះយ៉ា និងក្មួយប្រុសលោកនោះឡើយ។ ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៣ ខែសីហា អនុប្រធានតុលាការ លោក កូយ សៅ ក្រុងភ្នំពេញ បានសម្រេចផ្តន្ទាទោសលោក អះម៉ាត់ យ៉ះយ៉ា និងក្មួយប្រុសរបស់ឈ្មោះ អ៊ីស្មាអែល ពិនឧស្មាន ឱ្យជាប់ពន្ធនាគារក្នុងម្នាក់ៗ រយៈពេល ១៥ឆ្នាំ និងពិន័យជាប្រាក់រួម

គ្នាចំនួន ២០០លានរៀល ប្រមាណ ៥ម៉ឺនដុល្លា ទៅឲ្យជនរងគ្រោះពីរនាក់ បន្ទាប់ពីតុលាការរកឃើញថា អ្នកទាំងពីរជាប់ពាក់ព័ន្ធករណីជួញដូរមនុស្សទៅប្រទេសអារ៉ាប់។

ជនជាតិចាមម្នាក់ឈ្មោះ សុខ គ្រី ដែលបានចូលរួមក្នុងសវនាការនៅថ្ងៃទី១៣ សីហា ប្រាប់អាស៊ីសេរីថា តុលាការមិនបានបង្ហាញភស្តុតាងណាមួយរឹងមាំមកដាក់បន្ទុកទៅលើជនសង្ស័យទាំងពីរនោះទេ។ លោកបានថ្លែងការពារថា លោក អះម៉ាត់ យ៉ះយ៉ា គឺជាមនុស្សស្អាតស្អំ និងមិនជាប់ពាក់ព័ន្ធនឹងករណីជួញដូរមនុស្សទេ៖ «លោក អះម៉ាត់ យ៉ះយ៉ា មិនមែនសម្រាប់ខ្លួនខ្ញុំទេ គឺសម្រាប់ជនជាតិចាមនៅទូទាំងប្រទេសទាំងអស់ គឺចាត់ទុកគាត់ជាមនុស្សល្អដោយសារអី? ដោយសារគាត់ជាមនុស្សដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជាដែលមានគំនិតផ្តួចផ្តើមដល់កូនខ្មែរអ្នកកាន់សាសនាឥស្លាមទាំងអស់បានរៀនសូត្រខាងចំណេះដឹងទូទៅ ហើយសរុបកូនសិស្សដែលគាត់ជួយហ្នឹងបានជាង ១.០០០នាក់ហើយ គឺឲ្យបណ្ដុះបណ្ដាលឱ្យចប់មានការងារធ្វើល្អ អ្នកខ្លះបានធ្វើជាឯកឧត្តមអីច្រើនណាស់តាមរយៈគាត់ហ្នឹង»។

លោក អ៊ីស្មាអែល ពិនឧស្ម័ន ត្រូវជាក្មួយបង្កើតលោក អះម៉ាត់ យ៉ះយ៉ា ត្រូវកម្លាំងនគរបាល នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចាប់ខ្លួនកាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨ សង្ស័យថា ជាប់ពាក់ព័ន្ធករណីនាំពលករទៅធ្វើការខុសច្បាប់ នៅប្រទេស អារ៉ាប់ប៊ី សាអូឌីត៕

## កម្ពុជាបញ្ជូនពលករចំនួន៣២នាក់ បន្ថែមទៀតទៅធ្វើការនៅប្រទេសកូរ៉េ

http://kampucheathmey.com/ 13/8/2019 8:42 Pm

ភ្នំពេញ ៖ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជូនពលករចំនួន ៣២នាក់ ស្រី២នាក់ បន្ថែមទៀតទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូងខណៈបច្ចុប្បន្នមានពលករខ្មែរកំពុងធ្វើការនៅទីនោះជាង៤ម៉ឺននាក់លើវិស័យឧស្សាហកម្ម សេវាកម្ម សំណង់និងកសិកម្ម។

ថ្លែងប្រាប់អ្នកសារព័ត៌មានកាលពីរសៀលថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញលោក ហេង សួរ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍ថា ការបញ្ជូនពលករចំនួន៣២នាក់ ធ្វើការនៅកូរ៉េនេះគឺជាផ្នែកមួយនៃកូតាសម្រាប់ឆ្នាំ២០១៩ដែលភាគីកូរ៉េផ្តល់ឲ្យកម្ពុជាពី៤ពាន់ទៅ៤៥០០នាក់។ លោក ហេង សួរ បានបន្តថា ពលករធ្វើការនៅកូរ៉េទទួលបានការគាំពារយ៉ាងខ្លាំងពីសំណាក់ភាគីកូរ៉េព្រោះនៅកូរ៉េមានកន្លែងគាំពារពលករបរទេសមិនតិចជាង៤០កន្លែងទេ ដែលនៅតាមកន្លែងនីមួយៗមានអ្នកចេះភាសាទៅតាមប្រទេសនីមួយៗរួមទាំងភាសាខ្មែរផងនៅពេលដែលពលករមានបញ្ហាអ្វីមួយ។ ក្រៅពីនេះក្រសួងក៏បានដាក់មន្ត្រីចំនួន២នាក់ដោយមានភ្ជាប់ទំនាក់ទំនងលេខទូរស័ព្ទនៅស្ថានទូតកម្ពុជាប្រចាំនៅប្រទេសកូរ៉េផងដែរ ដើម្បីរង់ចាំជួយដោះស្រាយបញ្ហាផ្សេងៗរបស់ពលករយើង។ ជាងនេះទៅទៀតដើម្បីបង្កលក្ខណៈងាយស្រួលដល់ការធ្វើដំណើររបស់ពលករកម្ពុជាដដែលទៅធ្វើការនៅប្រទេសកូរ៉េ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តែងតែចាត់តាំងមន្ត្រីមួយរូប ដើម្បីសម្របសម្រួលមធ្យោបាយគ្រប់បែបយ៉ាង តាំងពីពេលឡើងយន្តហោះនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ រហូតដល់ដៃសមាគមនិយោជកនៅប្រទេសកូរ៉េ។

លោកបានបន្ថែមថា ពលករដែលធ្វើការនៅកូរ៉េមានជីវភាពធូរធារដោយសារទទួលបានប្រាក់បៀវត្សរ៍ខ្ពស់ ហើយនៅពេលត្រឡប់មកវិញ ទទួលបាននូវជំនាញបច្ចេកទេសថ្មីៗពិសេសភាសាកូរ៉េ ដែលអាចឲ្យគាត់មានលទ្ធភាពក្នុងការរកការងារធ្វើ ឬ ប្រកបមុខរបរខ្លួនឯងបាន។ នៅក្នុងឱកាសនោះលោកហេងសួរបានផ្តាំផ្ញើឲ្យប្អូនៗទាំង៣២នាក់ដែលចាកចេញទៅបម្រើការនៅកូរ៉េត្រូវចេះថែរក្សាសុខភាពឲ្យបានល្អ ខិតខំធ្វើការងារឲ្យមានការទទួលខុសត្រូវដើម្បីកសាងកេរ្តិ៍ឈ្មោះដ៏ល្អមួយសម្រាប់ពលករកម្ពុជានិងបង្កើតក្តីស្រលាញ់ពីភាគីនិយោជកកូរ៉េព្រោះថានៅពេលថៅកែចូលចិត្តគេនិងបង្កើន តម្រូវការពលករខ្មែរបន្ថែមទៀត។

ចំណែកលោក អូ ណាក់យ៉ុង ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជាមានប្រសាសន៍ថា បច្ចុប្បន្ននេះមានពលករបរទេសទេសធ្វើការនៅកូរ៉េចំនួន១៦ប្រទេស ក្នុងនោះមានទាំងកម្ពុជាផង។ ប៉ុន្តែក្នុងចំណោមពលករទាំងនោះពលករខ្មែរ ត្រូវបាននិយោជកកូរ៉េមានការកោតសរសើរថា មានចរិតស្លូតបូត រួសរាយរាក់ទាក់ ឧស្សាហ៍ព្យាយាមក្នុងបំពេញការងារដែលធ្វើឲ្យមាននិយោជកកូរ៉េទទួលយកពលករខ្មែរជាបន្តបន្ទាប់ទៀត។ យ៉ាងណាក៏ដោយលោកនឹងខិតខំប្រឹងប្រែង ដើម្បីជំរុញឲ្យមានការបន្ថែមកូតាដល់ពលករខ្មែរឲ្យបានច្រើនថែមទៀតពិសេសពលករគំរូដើម្បីឲ្យពួកគាត់ធ្វើការនៅទីនោះយ៉ាងតិចឲ្យបាន១០ឆ្នាំដែរដើម្បីលើកស្ទួយដល់ជីវភាពរស់នៅកាន់តែប្រសើរ។ លោក អូ ណាក់យ៉ុង បានណែនាំឲ្យពលករខ្មែរត្រូវប្រឹងប្រែងបំពេញការងារឲ្យបានត្រឹមត្រូវ ពិសេសត្រូវខិតខំក្រេបយកចំណេះជំនាញទាំងឡាយ ដើម្បីអាចបង្កើតការងារ ឬមុខរបរណាមួយសម្រាប់ខ្លួន ក្រោយពេលត្រលប់មកមាតុភូមិកម្ពុជាវិញ។ លោកបានផ្តាំផ្ញើទៀតថា ក្នុងពេលបំពេញការងារនៅប្រទេសកូរ៉េខាងត្បូង ប្រសិនបើមានបញ្ហាណាមួយ សូមពលករទាំងអស់ទំនាក់ទំនងទៅកាន់ក្រុមការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ដែលប្រចាំការនៅទីនោះ ឬអាចទំនាក់ទំនងទៅកាន់មជ្ឈមណ្ឌល ដើម្បីដោះស្រាយបញ្ហានានា ដែលកើតមាននៅពេលធ្វើការនៅកូរ៉េ។

ប្អូនស្រី រឹក ឆេងលី មកពីខេត្តកណ្តាលធ្វើការខាងវេចខ្ចប់សាច់គោនៅប្រទេសកូរ៉េបានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលកូរ៉េពិសេសក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានផ្តល់ឱកាសការងារ និងគាំពារដល់ពលករខ្មែរទៅធ្វើការនៅកូរ៉េបានល្អ ដែលធ្វើឲ្យជីវភាពរស់នៅរបស់ពលករបានល្អប្រសើរជាងមុន ដោយសារទទួលបានប្រាក់ខែខ្ពស់។

ចំណែកប្អូនស្រី អន កែវមុនីរ័ត្ន មកពីខេត្តកំពង់ស្ពឺធ្វើការនៅរោងចក្រធ្វើសាច់ទានៅប្រទេសកូរ៉េបាននិយាយថា ពលករខ្មែរទៅធ្វើការនៅកូរ៉េពិតជាល្អប្រសើរណាស់ពោលគឺមិនត្រឹមតែទទួលបានប្រាក់ខែសមរម្យប៉ុណ្ណោះទេថែមទាំងការរស់នៅសណ្តាប់ធ្នាប់ គោរពសិទ្ធិលក្ខខណ្ឌការងារនិងច្បាប់ការងារបានល្អប្រសើរទៀតផងដែលធ្វើឲ្យជីវភាពគ្រួសារបានល្អប្រសើរ។ ប្អូនស្រីបានបន្តថា «ខ្ញុំចង់ឲ្យយុវជនខ្មែរទៅធ្វើការនៅកូរ៉េឲ្យបានច្រើនដើម្បីទទួលបានប្រាក់ចំណូលច្រើនយកមកដោះស្រាយជីវភាពគ្រួសារនិងលើកស្ទួយដល់សេដ្ឋកិច្ចជាតិផងដែរ»។

គួរបញ្ជាក់ថា គិតត្រឹមថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ កម្ពុជាបានបញ្ជូនពលករទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េ សរុបចំនួន ៦៥,២២៥នាក់ (ស្រី ១៣,៥៩៥នាក់)ក្នុងនោះមានពលករខ្លះបានវិលត្រឡប់មកវិញដោយត្រូវចប់អាណត្តិការងារ៕ សំអឿន

## ទីផ្សារកូរ៉េបន្តបើកសម្រាប់ពលករកម្ពុជា ខណៈកូតាឆ្នាំ២០១៩កូរ៉េទទួលពលករកម្ពុជាជាង ៤ពាន់នាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៩ ម៉ោង ០៨:៥០ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ កូរ៉េនៅតែបើកទីផ្សារទទួលយកកម្លាំងពលកម្មពីប្រទេសកម្ពុជា ដើម្បីបម្រើការងារតាមបណ្តារោងចក្រនានានៅក្នុងប្រទេសខ្លួន ខណៈដែលឆ្នាំ២០១៩នេះប្រកាសកូតាយកកម្លាំងពលកម្មពីកម្ពុជាប្រមាណជាង៤ពាន់នាក់ ។ នេះបើតាមឯកអគ្គរដ្ឋទូតកូរ៉េប្រចាំនៅកម្ពុជា ។

លោកអូ ណាក់យ៉ុង ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា បានលើកឡើងក្នុងពេលជូនដំណើរពលករកម្ពុជាផ្នែកឧស្សាហកម្មចំនួន៣២នាក់ (ស្រី២នាក់) ចេញទៅធ្វើការនៅសាធារណរដ្ឋកូរ៉េ កាលពីថ្ងៃរសៀលថ្ងៃទី១៣ ខែសីហា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំ ពេញ បានអះអាងថា ភាពអត់ធ្មត់ព្យាយាមនឹងការងារគួបផ្សំនឹងអត្តចរិតល្អរបស់ពលករកម្ពុជាដែលទៅធ្វើការនៅសាធារណរដ្ឋកូរ៉េទទួលបាននូវការកោតសរសើរយ៉ាងពេញទំហឹងពីសំណាក់និយោជក និងថ្នាក់ដឹកនាំកូរ៉េថែមទៀតផង ។ នាឱកាសសំណេះសំណាលជាមួយពលករកម្ពុជាលោក អូ ណាក់យ៉ុង បានផ្តាំផ្ញើថា ក្នុងពេលបំពេញការងារនៅសាធារណរដ្ឋកូរ៉េ ប្រសិនបើមានបញ្ហាណាមួយ សូមពលករទាំង អស់

ទាក់ទងទៅកាន់មជ្ឈមណ្ឌលគាំពារពលករបរទេសដែលប្រចាំការនៅទីនោះស្រាប់ ដើម្បីដោះស្រាយបញ្ហានានាដែលកើតមាននៅពេលធ្វើការនៅកូរ៉េ ។

លោក ហេង សួរ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក៏មានមតិផ្តាំផ្ញើទៅកាន់ពលករទាំង ៣២នាក់នោះត្រូវប្រឹងប្រែងតស៊ូអត់ធ្មត់នឹងការងារ ប្រសិនបើចង់ផ្លា ស់ប្តូរការងារត្រូវជួបប្រឹក្សាយោបល់ជាមួយមជ្ឈមណ្ឌលគាំពារពលករបរទេសដែលនៅជិតកន្លែងការងារ ពីព្រោះបើផ្លាស់ប្តូរការងារដោយចិត្តឯងអាចឈានដល់ការប្រព្រឹត្តខុសកិច្ចព្រមព្រៀងក៏ដូចជា អាចប្រឈមនឹងបញ្ហានានាផងដែរ ។ លោករដ្ឋលេខាធិការ បានបង្ហាញការសង្ឃឹមជឿជាក់ថា ពលករកម្ពុជាទាំងអស់នឹងរក្សាបាននូវភាពថ្លៃថ្នូសម្រាប់ប្រជាជាតិកម្ពុជាទាំងមូល និងត្រូវយកចិត្តទុកដាក់ថែរក្សាសុខភាព អនាម័យ សុវត្ថិភាពក្នុងការរស់នៅ និងការធ្វើដំណើរទៅកាន់ទីកន្លែងផ្សេងៗ ។ ជាមួយគ្នានោះដែរលោក ហេង សួរ ក៏បានឲ្យដឹងថា មកដល់ពេលបច្ចុប្បន្នកម្ពុជាបានបញ្ជូនពលកររបស់ខ្លួនទៅធ្វើការនៅសាធារណរដ្ឋកូរ៉េប្រមាណជាង៦ម៉ឺននាក់ភាគច្រើនធ្វើការលើផ្នែកឧស្សាហកម្ម បន្ទាប់មកមានផ្នែកកសិកម្ម និងសំណង់ ។ លោកបានបញ្ជាក់ថា៖ «បើតាមកូតាដែលសាធារណរដ្ឋកូរ៉េផ្តល់ឱ្យកម្ពុជា ឆ្នាំ២០១៩នេះ យើងទទួលបានកូតាចន្លោះពី៤,០០០នាក់ ទៅ ៤,៥០០នាក់បន្ថែមទៀត» ។ លោកបានបញ្ជាក់ទៀតថា នៅសាធារណរដ្ឋកូរ៉េមានប្រព័ន្ធគ្រប់គ្រងពលករបរទេសយ៉ាងល្អ ដោយសារនៅទីនោះមានមជ្ឈមណ្ឌលគាំពារពលករបរទេសមិនតិចជាង៤០កន្លែងឡើយ ហើយនៅក្នុងមជ្ឈមណ្ឌលទាំងនោះតែងតែមានអ្នកចេះភាសារបស់ពលករនៃប្រទេសនីមួយៗ តួយ៉ាងសម្រាប់ពលករកម្ពុជា គឺមានអ្នកចេះភាសាខ្មែរនៅប្រចាំការក្នុងមជ្ឈមណ្ឌលទាំងនោះផងដែរ នៅពេលដែលពលករមានបញ្ហាណាមួយពលករអាចទំនាក់ទំនងតាមលេខទូរស័ព្ទពួកគេនឹងទទួលបានការជួយដោះស្រាយតែម្តង ៕ កែសម្រួលដោយ ៖ សុឃាក់

## ពលករកម្ពុជានៅតែទទួលបានការកោតសរសើរពីថៅកែ និងមន្ត្រីកូរ៉េថាល្អទាំងចរិកនិងការងារ

http://www.rasmeinews.com/ August 14, 2019, 2:57 PM

*ដោយៈដេប៉ូ/ភ្នំពេញ ៖* ពលករកម្ពុជាដែលបានទៅធ្វើការនៅប្រទេសសាធារណរដ្ឋកូរ៉េ នៅតែទទួលបាននូវការកោតសរសើរពីសំណាក់ និយោជក និងថ្នាក់ដឹកនាំកូរ៉េថាជាពលករ ប្រកបដោយចរិកល្អ និងការប្រកបការងារអត់ធ្មត់យកចិត្តទុកដាក់ខ្ពស់។ ការលើកឡើងបែបនេះធ្វើឡើងដោយ លោក អ៊ូ ណាក់យ៉ុង ឯក អគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា ក្នុងពេលជូនដំណើរពលករកម្ពុជាផ្នែកឧស្សាហកម្មចំនួន ៣២នាក់(ស្រី ២នាក់) ចេញទៅធ្វើការនៅប្រទេសសាធារណរដ្ឋកូរ៉េ នារសៀលថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ក្នុងពេលជួបសំណេះសំណាលជាមួយពលករកម្ពុជា លោក អ៊ូ ណាក់យ៉ុងឯក អគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ បានផ្តាំផ្ញើដល់ពលករកម្ពុជាថា ក្នុងពេលបំពេញការងារនៅសាធារណរដ្ឋកូរ៉េ ប្រសិនបើមានបញ្ហាណាមួយ សូមឱ្យពលករទាំងអស់ទាក់ទងទៅកាន់មជ្ឈមណ្ឌលគាំពារពលករបរទេស ដែលប្រចាំការនៅទីនោះស្រាប់ ដើម្បីដោះស្រាយបញ្ហានានា ដែលកើតមាននៅពេលធ្វើការនៅកូរ៉េ។ លោក ឯក អគ្គរដ្ឋទូត កូរ៉េ បានបញ្ជាក់ថា" បើតាមមតិភាគច្រើនពីនិយោជកកូរ៉េចំពោះពលករកម្ពុជា គឺពួកគេពិតជាមានការពេញចិត្តចំពោះសមត្ថភាពការងារ និងភាពអត់ធ្មត់នឹងការងាររបស់ពលករកម្ពុជាយ៉ាងខ្លាំង"។

នាឱកាសនោះដែរ លោក ហេង សួរ ក៏បានធ្វើការផ្តាំផ្ញើទៅកាន់ពលករទាំងអស់ ត្រូវប្រឹងប្រែងតស៊ូអត់ធ្មត់នឹងការងារ ប្រសិនបើចង់ផ្លាស់ប្តូរការងារ ត្រូវជួបប្រឹក្សាយោបល់ជាមួយមជ្ឈមណ្ឌលគាំពារពលករបរទេស ដែលនៅជិតកន្លែងការងារ ពីព្រោះបើផ្លាស់ប្តូរការងារដោយចិត្តឯង អាចឈានដល់ការប្រព្រឹត្តខុសកិច្ចព្រមព្រៀង ក៏ដូចជាអាចប្រឈមនឹងបញ្ហានានាណាមួយកើតឡើង។ ព្រមជាមួយគ្នានេះរដ្ឋលេខាធិការ បានបង្ហាញការសង្ឃឹមជឿជាក់ថា ពល

ករកម្ពុជាទាំងអស់នឹងរក្សាបាននូវភាពថ្លៃថ្នូរ សម្រាប់ប្រជាជាតិកម្ពុជាទាំងមូល និងត្រូវយកចិត្តទុកដាក់ថែរក្សាសុខភាព អនាម័យ សុវត្ថិភាពក្នុងការរស់នៅ និងការធ្វើដំណើរទៅកាន់ទីកន្លែងផ្សេងៗ។ លោកថា "បើតាមកូតាដែលសាធារណរដ្ឋកូរ៉េផ្តល់ឱ្យកម្ពុជា ឆ្នាំ២០១៩នេះ យើងទទួលបានកូតាចន្លោះពី ៤,០០០នាក់ ទៅ ៤,៥០០នាក់ បន្ថែមទៀត"។ បញ្ជាក់ប្រាប់បណ្ដាញសារព័ត៌លោក ហេង សួរ បានឲ្យដឹងថា គិតរហូតមកដល់ពេលបច្ចុប្បន្ន កម្ពុជាបានបញ្ជូនពលករ ទៅធ្វើការនៅសាធារណរដ្ឋកូរ៉េ ប្រមាណជាង ៦ម៉ឺននាក់ដែលក្នុងចំណោមនេះ ភាគច្រើនធ្វើការលើផ្នែកឧស្សាហកម្ម បន្ទាប់មកមានផ្នែកកសិកម្ម និងសំណង់៕B/

## នគរបាលខណ្ឌដូនពេញ បន្តចុះបង្ក្រាបស្ត្រីរកស៊ីផ្លូវភេទឃាត់ខ្លួនបាន២នាក់

http://nokorwatnews.com/ 14-08-2019

ភ្នំពេញ៖ ដោយអនុវត្តន៍តាមការណែនាំរបស់លោកសុខ ពេញវុធ អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង១០យប់ កំលាំងជំនាញខណ្ឌ សហការជាមួយប៉ុស្ដិ៍នគរបាលវត្តភ្នំ បានចុះបង្រ្កាបករណីស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគកជេរ(អ្នកចាប់ម៉ូយ) ស្ថិតនៅចំណុចផ្លូវលេខ ៩២. ៩៤. ៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ ។

មន្ត្រីនគរបាលខណ្ឌដូនពេញ បានឲ្យដឹងថា ក្នុងប្រតិបត្តិការបង្រ្កាបនេះកម្លាំងជំនាញ បានបញ្ចប់នៅវេលាម៉ោង២រំលងអាធ្រាតចូលថ្ងៃទី១៤ ខែសីហា ជាលទ្ធផលនៃកិច្ចប្រតិបត្តិការនេះ សមត្ថកិច្ចប្រមូលបានសរុបរួមចំនួន២នាក់ស្រី ។ ចំពោះមុខ អធិការដ្ឋានបានបញ្ជូនស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគកជេរខាងលើទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ហើយកិច្ចប្រតិបត្តិការនេះសមត្ថកិច្ចយើងនឹងបន្តអនុវត្តន៍ជាប់ជាប្រចាំ ៕ ស រស្មី

## វេទិកាផ្សព្វផ្សាយច្បាប់ស្តីពីការបង្ការទប់ស្កាត់ អំពើជួយដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងការចំណាកស្រុកដោយគ្មានសុវត្ថិភាព

https://www.khi-news.com/ ចេញផ្សាយ ថ្ងៃទី14 ខែសីហា ឆ្នាំ2019

(ស្វាយរៀង): នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ លោកស្រី ឯក សុវណ្ណភារៈ អភិបាលរងខេត្ត បានអញ្ជើញជាអធិបតីក្នុង វេទិកាផ្សព្វផ្សាយច្បាប់ស្តីពីការបង្ការទប់ស្កាត់ អំពើជួយដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងការចំណាកស្រុកដោយគ្មានសុវត្ថិភាព នៅស្រុករមាសហែក និងមានការចូលរួមពីលោកអភិបាលស្រុករមាសហែក លោក លោកស្រី ប្រធាន-អនុប្រធានមន្ទីរខេត្ត កងកម្លាំង លោកស្រីនាយករងរដ្ឋបាលខេត្ត និងលោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស នៅវិទ្យាល័យជ្រៃធំ ជាច្រើនអ្នកទៀត ដែលកម្មវិធីរៀបចំដោយលេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការឆាលហ្វានកម្ពុជា ។ លោកស្រី ឯក សុវណ្ណភារៈ អភិបាលរងខេត្តបានថ្លែងថា: រាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់កាន់តែខ្លាំងក្លាក្នុងការការពារប្រជាពលរដ្ឋពីភាពរងគ្រោះដោយចំណាកស្រុកគ្មានសុវត្ថិភាព ពិសេសក្រុមឧក្រិដ្ឋកម្មជួញដូរមនុស្សដែលបានបង្កអោយមានវិនាសកម្មជាថ្មីដល់មនុស្សជាតិ ហើយបានឹងកំពុងក្លាយជាទាសភាពទំនើបគួរឲ្យភ័យខ្លាច និងស្អប់ខ្ពើមបំផុត ។

លោក ស៊ូ ម៉ុល អភិបាលស្រុករមាសហែក បានអោយដឹងថា: ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាពគឺជាបញ្ហាប្រឈមដល់គ្រួសារនិងសង្គម ហើយក៏ជាបរិបទសកលដែលនៅតែបន្តកើតមានអាស្រ័យលើកត្តា៣យ៉ាងគឺ:ការអប់រំសង្គម, ការអនុវត្តច្បាប់, ការឆក់ឱកាសពីជនល្មើស ។ ដែលវាជារូបភាពនៃអំពើជួញដូរមនុស្សមិនត្រឹមតែជាការជួញដូរ ឬកេងកម្លាំងពលកម្ម និងផ្លូវភេទប៉ុណ្ណោះទេ តែក៏មានបាតុភូតមួយចំនួនទៀត ដែលមានទំនោរទៅរកការជួញដូរសរីរាង្គ និងបទល្មើសរត់ពន្ធ ឬជួញដូរទារកឆ្លងដែនជាដើម ។

លោក ហាស់ ប៊ុនធី ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអោយដឹងដែលថា: នៅបច្ចុប្បន្ននេះ ស្ថានភាពកម្លាំងពលកម្មក្នុងប្រទេសកម្ពុជាក៏ដូចជាក្នុងតំបន់ និងសកលលោកសម្បូរណ៍ទៅដោយពលករវ័យក្មេង រួមផ្សំជាមួយនិងការពង្រីកទីក្រុងនិងការកើនឡើងយ៉ាងឆាប់រហ័សនូវសកម្មភាពពាណិជ្ជកម្ម វិនិយោគបាន និងកំពុងជំរុញអោយមានកំណើននៃចលនាកម្លាំងពលកម្មចេញពីជនបទចូលទៅទីក្រុង ក៏ដូចជាចលនាកម្លាំងពលកម្មឆ្លងប្រទេសដើម្បីស្វែងរកការងារធ្វើ ។ បើតាមរបាយការណ៍ឆ្នាំ២០១៨របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេសមានចំនួន ១.២៣៥.៩៩៣នាក់ នៅក្នុងនោះប្រទេសថៃ ១.១៤៦.៦៨៥នាក់, ប្រទេសកូរ៉េ ៤៩.០៩៩នាក់, ប្រទេសម៉ាឡេស៊ី ៣០.១១៣នាក់, ប្រទេសសិង្ហបុរី ៨៣១នាក់, ប្រទេសហុងកុង ៥៤នាក់, ប្រទេសអារ៉ាប៊ីសាអ៊ូឌីត ១៦នាក់ ។

លោកស្រី ទុំ សារ៉ានី ប្រធានមន្ទីរកិច្ចការខេត្ត បានអោយដឹងថា: ចំពោះការកំណត់ក្រុមជនងាយរងគ្រោះនិងមធ្យោបាយនៃការបំពានផ្លូវភេទគឺមាន ជនគ្រប់រូបពេញវ័យ កុមារកំព្រា ស្ត្រីក្រីក្រ ក្មេងអនាថា អ្នកបម្រើតាមផ្ទះ កុមារមានឪពុកចុង ស្ត្រីផ្សព្វផ្សាយស្រាបៀរ។ល។ ហើយការដោះស្រាយអំពើបំពានផ្លូវភេទគឺសុទ្ធសឹងជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវដោះស្រាយតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន គឺតាមរយៈការដាក់ពាក្យបណ្តឹងទៅកាន់នគរបាលយុត្តិធម៌ ឬទៅព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត ដើម្បីដំណើរការតាមនីតិវិធីច្បាប់ផងដែរ ៕

## ក្នុងឆមាសទី១ មានសាកសពពលករខ្មែរ៧១នាក់ បញ្ជូនមកកម្ពុជាវិញ

https://thmeythmey.com/ 14, Aug 2019 , 10:59 pm

ភ្នំពេញ៖ ក្នុងឆមាសទី១ មានពលករខ្មែរ៧១នាក់ ដែលទៅធ្វើការនៅក្រៅប្រទេស បានបាត់បង់ជីវិត។ សពពលករទាំងនោះ បានបញ្ជូនមកកម្ពុជាជាផ្លូវការ ធ្វើបុណ្យតាមប្រពៃណី។ នេះបើតាមរបាយការណ៍ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើបលើកទី៣នៃក្រសួងមហាផ្ទៃ ដែលចេញផ្សាយនៅថ្ងៃទី១៤ ខែសីហា ។

របាយការណ៍ បានបង្ហាញថា មានពលករខ្មែរជាង២ម៉ឺននាក់ ដែលបានបញ្ជូនត្រឡប់មកខ្មែរវិញ ដោយសារតែពួកគេជួបនឹងបញ្ហាផ្សេងៗក្នុងអំឡុងពេលបំពេញការងារ។ ដំណើរវិលត្រឡប់របស់ពលករខ្មែរទាំងនោះ មានការជួយជ្រោមជ្រែងពីក្រសួងបរទេស ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានសង្គ្រោះទាន់ពេលវេលា។ បើតាមរបាយការណ៍ដដែល មានពលករកម្ពុជា២១.៧៤៦នាក់ ស្រី ៩.៤២៥នាក់ ដែលបានវិលត្រឡប់មកខ្មែរវិញ ក្នុងនោះមានពលករខ្មែរ២១.៦៥៨នាក់ ត្រូវបានបញ្ជូនមកពីប្រទេសថៃ។ របាយការណ៍ដដែលបានបន្ថែមថា ក្នុងមួយឆមាសកន្លងទៅនេះ មានពលករកម្ពុជាដែលជួបគ្រោះថ្នាក់បង់បាត់ជីវិត ចំនួន៧១សាកសព ក្នុងនោះស្រី១២នាក់ និងកុមារម្នាក់ ត្រូវបានបញ្ជូនមកមាតុភូមិវិញ ដោយមិនគិតពីសាកសពដែលត្រូវបានបូជា ឬមិនបានរាយការណ៍នៅប្រទេសគោលដៅទេ។

គួរបញ្ជាក់ថា កាលពីឆមាសទីមួយ ឆ្នាំ២០១៨ អាជ្ញាធរបរទេសបានបញ្ជូនពលករខ្មែរខុសច្បាប់ជិត២ម៉ឺននាក់ពីប្រទេសចំនួន១៨។ ក្នុងនោះអាជ្ញាធរថៃបានបញ្ជូនពលករខ្មែរខុសច្បាប់សរុប១៩,៣៧៩នាក់៕

## ថៃបញ្ជូនពលករខ្មែរ ចំនួន០៦នាក់ មកស្រុកវិញ ពាក់ព័ន្ធនឹងករណីស្នាក់នៅ លើសការកំណត់

https://www.dap-news.com/ ByID:112 Posted on 15 August 2019 | 07:52

ភ្នំពេញ៖ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារ ព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៦នាក់ ពាក់ព័ន្ធនឹងករណីស្នាក់ នៅលើសការកំណត់ ។ នេះបើយោងតាម អគ្គនាយកដ្ឋាន អន្តោប្រវេសន៍។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៦នាក់នេះ មានស្រុកកំណើតនៅខេត្ត

កំពត ០១នាក់ ស្រី ០១នាក់, ខេត្តបាត់ដំបង ០២នាក់ ស្រី ០១នាក់, ខេត្តកំពង់ចាម ០១នាក់ ស្រី ០១នាក់, ខេត្តកំពង់ស្ពឺ ០១នាក់, ខេត្តតាកែវ ០១នាក់ ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 14-08-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់ នាវេលាម៉ោង ១៧និង៣០នាទី ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ជួបគ្រោះអកុសលពលករម្នាក់ស្លាប់ និងម្នាក់ទៀតរបួសធ្ងន់លើទឹកដីថៃ

https://news.kohsantepheapdaily.com.kh/ By mony koh August 13, 2019

ខេត្តបន្ទាយមានជ័យ ៖ ពលករ២នាក់ជួបគ្រោះអកុសល ម្នាក់ស្លាប់នៅនឹងកន្លែង ម្នាក់ទៀតរងរបួសធ្ងន់ដោយសារ ធ្លាក់ពីលើគ្រឿងចក្រលើកដាក់អីវ៉ាន់ក្នុងក្រុមហ៊ុនមួយនៅខេត្តស្រះកែវ ប្រទេសថៃ កាលពីព្រឹកថ្ងៃទី១២ សីហា ២០១៩។ សពរងគ្រោះក្នុងករណីនេះត្រូវបានភាគីថៃ បញ្ជូនឲ្យសាច់ញាតិតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតរសៀលថ្ងៃទី១៣ សីហា។

## អាជ្ញាធរថៃ បញ្ជូនពលរដ្ឋខ្មែរ២នាក់ មកកម្ពុជាវិញ ពាក់ព័ន្ធករណីឆ្លងដែនកាប់ឈើគ្រញូង

http://nokorwatnews.com/ 14-08-2019

ខេត្តឧត្តរមានជ័យ ៖ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ នាវេលាម៉ោង១២និង២០នាទី អាជ្ញាធរថៃ បានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន០២នាក់ តាមច្រកអន្តរជាតិជាំ មាន៖ ១,ឈ្មោះ ហៀន រិន ភេទប្រុស អាយុ៤១ឆ្នាំ រស់នៅភូមិចារ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ២,ឈ្មោះ អ៊ុំ សំបូរ ភេទប្រុស អាយុ៤៨ឆ្នាំ រស់នៅភូមិត្រាំប៉ោង ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ អ្នកទាំង២ ត្រូវបានថៃចាប់ខ្លួនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៧ ពីបទឆ្លងដែនកាប់ឈើ ចូលតាមច្រកចាក់ច្រែង ជាប់គុកនៅស្រុកខាន់ថាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ។ បច្ចុប្បន្ន សមត្ថកិច្ច នៅនឹងមាត់ច្រកអន្តរជាតិជាំ បានអប់រំរួច ក៏បានឲ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ ៕ ប៉ែន នួន

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៣នាក់

https://www.facebook.com/GDIOfficial/ General Department of ImmigrationGDI August 13 at 3:59 PM

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៣នាក់ នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ពីបទឆ្លងដែនស្នាក់នៅ និងធ្វើការខុសច្បាប់ នៅប្រទេសថៃ ដែលចេញតាមច្រកចាក់ច្រែង ខេត្តព្រះវិហារ៕

# ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៩

## ជំនឿសាសនា ជាឱសថព្យាបាលជំងឺផ្លូវចិត្ត និងជាគ្រឹះដ៏រឹងមាំនៃសីលធម៌ ដើម្បីកាត់បន្ថយ និងឈានទៅការលុបបំបាត់អំពើជួញដូរមនុស្ស

https://grandnewsasia.com/detail/ 15-08-2019

លោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានមានប្រសាសន៍លើកឡើងថា ជំនឿសាសនា គឺជាឱសថដែលព្យាបាលជំងឺផ្លូវចិត្ត ជាមាគ៌ាតម្រង់ផ្លូវឱ្យមនុស្សដែលទៅតាមផ្លូវសុចរិត ជាច្បាប់កម្រិតអោយមនុស្សជៀសវាងនូវកំហុសក្នុងការកសាងបាបកម្ម និងឧក្រឹដ្ឋកម្មនានាឲ្យមនុស្សចេះរស់នៅមានភាពសុខុនរមនាក្នុងកិត្តិយស និងសេចក្តីថ្លៃថ្នូរ ចេះគោរពខ្លួនឯង និងគោរពគ្នាទៅវិញទៅមក ដែលនេះមានន័យថា សាសនា គឺជាប្រភពនៃសេចក្តីសុខរបស់មនុស្ស ដែលនេះជាហេតុផលក្នុងការកាត់បន្ថយ និងឈានទៅការលុបបំបាត់អំពើជួញដូរមនុស្សក្នុងសង្គមកម្ពុជាផងដែរ។ លោក បានលើកឡើងបែបនេះក្នុងឱកាសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងវេទិកាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស និងទាសភាពសម័យទំនើបលើកទី៣ នារសៀលថ្ងៃពុធ ទី១៤ ខែសីហា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ។

លោក ស ខេង បានបន្តថា ការជួញដូរមនុស្ស គឺជាអំពើឃោរឃៅ អមនុស្សធម៌ និងជាអំពើបាបយ៉ាងធ្ងន់ធ្ងរដែលជនល្មើសបានប្រព្រឹត្តទៅលើជនរងគ្រោះជាមនុស្សគ្រប់វ័យ ទាំងទារក កុមារ យុវវ័យ និងមនុស្សចាស់គ្រប់ប្រភេទ ឥតរើសមុខ ដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួនធ្វើឲ្យប៉ះពាល់ដល់កិត្តិយសសេចក្តីថ្លៃថ្នូរ បាត់បង់សិទ្ធិជាមនុស្ស បាត់បង់សេចក្តីសុខក្នុងគ្រួសារខូចខាតដល់សុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ រហូតដល់បាត់បង់អាយុជីវិតរៀងរាល់ថ្ងៃ។ លោក ស ខេង បានបន្ថែមថា ការរួមគ្នាក្នុងសកម្មភាពពង្រីកការផ្សព្វផ្សាយតាមរយៈការអប់រំតាមបែបសាសនាដល់សាសនិកគ្រប់និកាយសាសនាទាំងអស់ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុ ជាគឺដើម្បីឲ្យយល់ដឹងអំពីអំពើជួញដូរមនុស្ស ផលប៉ះពាល់ ល្បិចកលជនល្មើសនិងនាំគ្នាលុបបំបាត់ទាសភាពសម័យទំនើបនេះឲ្យអស់ពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា៕

## ក្រសួងបង្ហាញតួលេខពលករខ្មែរ ដែលរងគ្រោះពីការធ្វើទេសន្តរប្រវេសន៍ការងារនៅក្រៅប្រទេស

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 15 August 2019 | 11:07 ICT

**ភ្នំពេញៈ** កម្ពុជាទទួលបានមកវិញនូវសាកសពចំនួន ៧១ ក្នុងចំណោមប្រជាជនកម្ពុជាចំនួន ២១ ៧៤៦ នាក់បានធ្វើទេសន្តរប្រវេសន៍ការងារនៅក្រៅប្រទេស ហើយបានប្រឈមមុខភាពរងគ្រោះនៅក្នុងរយៈពេល ៦ ខែ ដើមឆ្នាំ ២០១៩ នេះ។ ទោះយ៉ាងណាក៏ដោយនៅក្នុងរបាយការណ៍របស់ក្រសួងមហាផ្ទៃមិនបានបញ្ជាក់ពីមូលហេតុដែលបណ្តាលឲ្យស្លាប់នោះទេ។ នេះបើយោងតាមលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលបានថ្លែងក្នុងវេទិកាជាតិ អន្តរសាសនា លើកទី៣ «ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប» នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រកាលពីថ្ងៃម្សិលមិញ ដែលមានមន្ត្រីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងធម្មការ និងសាសនា និងអង្គការការពារសិទ្ធិកម្ពុជា ថ្នាក់ដឹកនាំ សាសនារួមមាន ព្រះពុទ្ធសាសនា អ៊ិស្លាមសាសនា កាតូលិក និង គ្រិស្តបរិស័ទ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជាចូលរួមក្រោមអធិបតីភាពលោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

លោកស្រី ជូ ប៊ុនអេង ថ្លែងថា ក្នុងរយៈពេល ៦ ខែដើមឆ្នាំនេះ មានប្រជាជនកម្ពុជាចំនួន ២១ ៧៤៦ នាក់ ដែលបានធ្វើទេសន្តរប្រវេសន៍ការងារនៅក្រៅប្រទេសត្រូវបានប្រឈមនឹងភាពរងគ្រោះ និងត្រូវបញ្ជូនមកកម្ពុជាវិញ ដោយមូលហេតុផ្សេងៗ។ លោកស្រី ថ្លែងថា៖ «ក្រសួងការបរទេសបានជួយសម្របសម្រួលផ្ដល់ឯកសារដើម្បីបានវិលត្រឡប់មកកម្ពុជាវិញ។ ភាគច្រើនជាពលករដែលត្រូវបញ្ជូនត្រឡប់ពីប្រទេស ថៃ ប្រមាណជា ២១ ៦៥៨ នាក់។ ក្នុងរយៈពេលមួយឆមាសកន្លងទៅនេះដែរ ក៏មានការបញ្ជូនសាកសពត្រឡប់វិញផ្លូវការចំនួន ៧១ (ស្រី ១២ នាក់ កុមារ ១ នាក់) ដោយមិនគិតពីសាកសពដែលត្រូវបានបូជា ឬមិនបានរាយការណ៍នៅប្រទេសគោលដៅទេ»។ លោកស្រី ក៏បានឲ្យដឹងដែរថា អំពើជួញដូរមនុស្ស គឺជាទម្រង់នៃឧក្រិដ្ឋកម្មមួយដែលមានបណ្ដាញចាត់តាំងយ៉ាងទូលំទូលាយភាគច្រើន ជាឧក្រិដ្ឋកម្មឆ្លងដែន ហើយមានរូបភាព និងទ្រង់ទ្រាយខុសៗគ្នានៅកម្ពុជា ក្នុងតំបន់ និងក្នុងពិភពលោក។

លោកស្រី បញ្ជាក់ថា៖ «រៀងរាល់ថ្ងៃ មានមនុស្សក្មេងចាស់ ប្រុស ស្រី រាប់លាននាក់ក្នុងតំបន់ និងរាប់រយលាននាក់ក្នុងពិភពលោក ដែលត្រូវបានគេជួញដូរ កេងប្រវ័ញ្ចដូចសត្វធាតុ ហើយមនុស្សទាំងនោះ បានខូចខាត និងបាត់បង់សិទ្ធិសេរីភាព សុខភាពផ្លូវកាយ ផ្លូវចិត្ត រងនូវការលំបាកវេទនា ខាតបង់ទ្រព្យធនពេលវេលា បាត់បង់ទំនាក់ទំនងផ្សារភ្ជាប់មនោសញ្ចេតនារវាងស្វាមីភរិយា ឪពុកម្ដាយ បងប្អូន ញាតិមិត្ត សាច់សាលោហិត ឬរងនូវការធ្វើទារុណកម្ម ដោយការងារធ្ងន់ធ្ងរគ្រោះថ្នាក់ និងមួយចំនួនបានក្លាយជាជនពិការរាងកាយ វិកលចរិត និងរហូតដល់បាត់បង់អាយុជីវិតថែមទៀត»។ លោកស្រីថ្លែងថា ជារឿយៗជនរងគ្រោះត្រូវបានរកឃើញ និងសង្គ្រោះដើម្បីផ្ដល់សេវាគាំពារទាំងការធ្វើមាតុភូមិនិវត្តន៍ ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម ការផ្ដល់សេវាផ្លូវ ច្បាប់ដើម្បីទាមទារយុត្តិធម៌ និងសំណងប៉ះប៉ូវការខូចខាត ការផ្ដល់ជំនាញវិជ្ជាជីវៈ ការងារ និងមុខរបរ។ តែទោះបីជាយ៉ាងនេះក្ដី ក៏នៅមានជនរងគ្រោះជាច្រើនទៀតដែលគ្មានភ័ព្វសំណាង បានទទួលសេវាទាំងអស់នេះទេ ព្រោះពួកគេត្រូវបានគេបង្ខាំងទុក ឬត្រូវបានបាត់បង់អាយុជីវិតទៅហើយ។

លោក គឹម រតនា នាយប្រតិបត្តិអង្គការកាកីតាសកម្ពុជាបានឲ្យដឹងថា បើទោះបីជាមានការខិតខំប្រឹងប្រែង និងសម្រេចបាននូវលទ្ធផលជាច្រើនឥតគណនាពីសំណាក់រដ្ឋាភិបាល អង្គការជាតិ អន្តរជាតិនានា លើការអប់រំផ្សព្វផ្សាយ ការបង្ការទប់ស្កាត់ ការបង្ក្រាប និងដាក់ទោសទណ្ឌដល់ជនល្មើសយ៉ាងណាក៏ដោយ ក៏ប៉ុន្តែអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើបនេះនៅមិនទាន់មានភាពប្រសើរនៅឡើយ ទាំងនៅក្នុងតំបន់ក៏ដូចជានៅព្រះរាជាណាចក្រកម្ពុជា។ លោកថ្លែងថា៖ «ដូច្នេះកិច្ចការនេះទាមទារឲ្យមានការប្តេជ្ញាចិត្ត និងការចូលរួមចំណែកបន្ថែមទៀតពីសំណាក់គ្រប់ភាគីពាក់ព័ន្ធទាំងអស់វាគឺជាបញ្ហារបស់យើងរាល់គ្នា ដូច្នេះយើងរួមគ្នាផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងទប់ស្កាត់បញ្ឈប់ឲ្យបាននូវទាសភាពសម័យទំនើប ព្រមទាំងយកចិត្តទុកដាក់ការពារ និងថែរក្សាជនរងគ្រោះឲ្យរស់នៅក្នុងក្ដីសង្ឃឹម»៕

## កម្ពុជាបញ្ជូនពលករទៅធ្វើការជាង៦ម៉ឺននាក់ ខណៈកូរ៉េត្រៀមផ្តល់កូតាថ្មីប្រមាណ៤ពាន់នាក់បន្ថែម

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៩ ម៉ោង ០៨:១០ ឡុង សារ៉េត

រាជធានីភ្នំពេញ៖ មន្ត្រីជាន់ខ្ពស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានឱ្យដឹងថា គិតមកដល់បច្ចុប្បន្ន ប្រទេសកម្ពុជាបានបញ្ជូនពលករទៅធ្វើការនៅប្រទេសកូរ៉េ មានជាង៦ម៉ឺននាក់ ហើយភាគច្រើនធ្វើការនៅលើផ្នែកឧស្សាហកម្ម កសិកម្មនិងសំណង់ ហើយនៅឆ្នាំ២០១៩ នេះប្រទេសកូរ៉េបានផ្តល់កូតាថ្មី បន្ថែមប្រមាណ៤,៥៣ពាន់នាក់ថែមទៀត។

លោក ហេង សួរ រដ្ឋលេខាធិការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រាប់ក្រុមអ្នកសារព័ត៌មានកាលពីថ្ងៃទី១៣សីហា ក្នុងឱកាសចូលរួមជូនដំណើរពលករខ្មែរធ្វើការ ផ្នែកឧស្សាហកម្មនៅប្រទេសកូរ៉េថា មកដល់

ពេលបច្ចុប្បន្ន កម្ពុជាបានបញ្ជូនពលករបស់ខ្លួនទៅធ្វើការនៅសាធារណរដ្ឋកូរ៉េ ប្រមាណជាង ៦ម៉ឺននាក់ ហើយភាគច្រើនធ្វើការលើផ្នែកឧស្សាហកម្ម បន្ទាប់មកមានផ្នែកកសិកម្ម និងសំណង់។ លោក ហេង សួរ គូសបញ្ជាក់ថា «បើតាមកូតាដែលសាធារណរដ្ឋកូរ៉េផ្តល់ឱ្យកម្ពុជា ឆ្នាំ២០១៩នេះ យើងទទួលបានកូតាចន្លោះពី ៤,០០០នាក់ ទៅ ៤,៥០០នាក់ បន្ថែមទៀត»។ លោករដ្ឋលេខាធិការបានលើកឡើងបន្តទៀតថា នៅសាធារណរដ្ឋកូរ៉េ មានប្រព័ន្ធគ្រប់គ្រងពលករបរទេសយ៉ាងល្អ ដោយសារនៅទីនោះមានមជ្ឈមណ្ឌលគាំពារពលករបរទេសមិនតិចជាង ៤០កន្លែងឡើយ ហើយនៅក្នុងមជ្ឈមណ្ឌលទាំងនោះតែងតែមានអ្នកចេះភាសារបស់ពលករនៃប្រទេសនីមួយៗ តួយ៉ាងសម្រាប់ពលករកម្ពុជាគឺមានអ្នកចេះភាសាខ្មែរនៅប្រចាំការក្នុងមជ្ឈមណ្ឌលទាំងនោះផងដែរ នៅពេលដែលពលករមានបញ្ហាណាមួយ ពលករអាចទំនាក់ទំនងតាមលេខទូរស័ព្ទ ពួកគេនឹងទទួលបានការជួយដោះស្រាយតែម្តង។ ក្រៅពីមជ្ឈមណ្ឌលគាំពារពលករនេះ កម្ពុជាក៏មានទីប្រឹក្សាការងារទទួលបន្ទុកពលករចំនួន ២នាក់ នៅប្រចាំការអមស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ ព្រមជាមួយមន្ត្រីនៃគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រង់ចាំទទួលប្រឹក្សា និងជួយដោះស្រាយបញ្ហាការងារនៅសាធារណរដ្ឋកូរ៉េ។

ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា លោក អូ ណាក់យ៉ុង មានប្រសាសន៍បញ្ជាក់ថា «តាមមតិភាគច្រើនពីនិយោជកកូរ៉េចំពោះពលករកម្ពុជា គឺពួកគេពិតជាមានការពេញចិត្តចំពោះសមត្ថភាពការងារ និងភាពអត់ធ្មត់នឹងការងាររបស់ពលករកម្ពុជាយ៉ាងខ្លាំង»។ បើតាមឯកអគ្គរដ្ឋទូតរូបនេះបានឲ្យដឹងថា ស្ថានទូតសាធារណរដ្ឋកូរ៉េប្រចាំនៅកម្ពុជា នឹងខិតខំជំរុញរដ្ឋាភិបាលកូរ៉េរបស់លោក ឱ្យជួយបង្កើនកូតាទទួលពលករកម្ពុជាឱ្យទៅធ្វើការនៅសាធារណរដ្ឋកូរ៉េបន្ថែមឱ្យបានកាន់ច្រើន។ មកដល់ពេលបច្ចុប្បន្ន ពលករបរទេសដែលធ្វើការនៅសាធារណរដ្ឋកូរ៉េមានចំនួន ១៦ប្រទេស ក្នុងនោះចំនួនពលករកម្ពុជាពិតជាមានកើនឡើងកាន់តែច្រើន ក្នុងចំណោមពលករបរទេសដទៃទៀត។ ក្នុងឱកាសនោះលោក អូ ណាក់យ៉ុង បានផ្តាំផ្ញើទៅពលករកម្ពុជាថា ក្នុងពេលបំពេញការងារនៅសាធារណរដ្ឋកូរ៉េ ប្រសិនបើមានបញ្ហាណាមួយ សូមពលករទាំងអស់ទាក់ទងទៅកាន់មជ្ឈមណ្ឌលគាំពារពលករបរទេស ដែលប្រចាំការនៅទីនោះស្រាប់ ដើម្បីដោះស្រាយបញ្ហានានា ដែលកើតមាននៅពេលធ្វើការនៅកូរ៉េ។ ខណៈមន្ត្រីជាន់ខ្ពស់ក្រសួងការងារផ្តាំផ្ញើរថា ត្រូវប្រឹងប្រែងតស៊ូអត់ធ្មត់នឹងការងារ ប្រសិនបើចង់ផ្លាស់ប្តូរការងារ ត្រូវជួបប្រឹក្សាយោបល់ជាមួយមជ្ឈមណ្ឌលគាំពារពលករបរទេស ដែលនៅជិតកន្លែងការងារ ពីព្រោះបើផ្លាស់ប្តូរការងារដោយចិត្តឯង អាចឈានដល់ការប្រព្រឹត្តខុសកិច្ចព្រមព្រៀង ក៏ដូចជាអាចប្រឈមនឹងបញ្ហានានា។ កែសម្រួលដោយ ៖ សុឃាក់

## មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន សរុបចំនួន ១០៦នាក់

https://www.facebook.com/ អគ្គនាយកដ្ឋានការងារ General Department of Labour 15-08-2019

នាថ្ងៃព្រហស្បតិ៍ ១៥កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន សរុបចំនួន១០៦នាក់ (ស្រី៤៨នាក់)។

វគ្គសិក្សានេះរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងដល់កម្មសិក្សាការី ឱ្យមានការយល់ដឹងអំពី៖

១-ការរៀបចំខ្លួន ដើម្បីធ្វើការនៅប្រទេសជប៉ុន
២-ភូមិសាស្ត្រ បរិស្ថាន និងវប្បធម៌នៅប្រទេសជប៉ុន
៣-ការធ្វើដំណើរតាមផ្លូវ និងការទៅដល់ប្រទេសជប៉ុន
៤-ការធ្វើការងារ និងការរស់នៅក្នុងប្រទេសជប៉ុន
៥-ការគ្រប់គ្រងប្រាក់
៦-សុខភាព និងអនាម័យ
៧-ការធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ
៨-សុវត្ថិភាព និងសេវាគាំទ្រ។

ក្រុមហ៊ុនដែលបានបញ្ជូនកម្មសិក្សាការី ទទួលការបណ្តុះបណ្តាលក្នុងវគ្គនេះមានចំនួន៧ គឺ

១. Ung Rithy Group Co., LTD
២. Asia Recruit Staffing ( A.R.S ) Co., LTD
៣. Axel Asia Human Resources Co., LTD
៤. Big Bi Imex Group Co., LTD
៥. Global Employment Service Co., LTD
៦. JNN International Economic and Technical Cooperation Co., LTD
៧. Kakehashi International & Business Co., Ltd

## ស្ថានអគ្គកុងស៊ុល ៖ កាលពីប្រមាណ៤ខែមុន មិនមានពលករខ្មែរណា ត្រូវបានអាជ្ញាធរថៃចាប់ខ្លួននៅអារញ្ញប្រាថេតនោះទេ

http://kampucheathmey.com/ 15/8/2019 1:36 Pm

ភ្នំពេញ ៖ ស្ថានអគ្គកុងស៊ុលខ្មែរប្រចាំនៅខេត្តសាកែវ ឬស្រះកែវ ប្រទេសថៃ បានអះអាងថា កាលពីប្រមាណ៤ខែមុន មិនមានពលករខ្មែរណា ត្រូវបានអាជ្ញាធរថៃចាប់ខ្លួននៅអារញ្ញប្រាថេតនោះទេ ហើយរាល់ពលករខ្មែរ ដែលត្រូវចាប់ខ្លួន មិនមានអ្នកណាត្រូវបានបង្អត់បាយបង្អត់ទឹកនោះទេ គឺមានបាយទឹកហូបមួយថ្ងៃ៣ពេល ហើយរឿងក្តីសុទ្ធតែត្រូវបានរៀបចំសំណុំរឿងឡើងតុលាការតាមនីតិវិធី និងមានមេធាវីស្ម័គ្រចិត្តការពារក្តីជូនផងដែរ។ ស្ថានអគ្គកុងស៊ុលខ្មែរប្រចាំនៅខេត្តសាកែវ ឬស្រះកែវ ប្រទេសថៃ អះអាងបែបនេះ តាមរយៈសារ messenger កាលពីថ្ងៃទី១៤ សីហា និងបន្ទាប់ពីមានសារជាសម្លេងមួយត្រូវបានគេបញ្ជូនមកកាន់បណ្តាញសារព័ត៌មានកាលពីថ្មីៗនេះ ដោយអះអាងថា មានពលករខ្មែរប្រមាណជាង៦០នាក់ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន កាលពីប្រមាណ៤ខែមុន នៅអារញ្ញប្រាថេត ហើយនៅមិនទាន់ដោះលែងនៅឡើយ ថែមទាំងអត់បាយអត់ទឹកទៀតផង។

ស្ថានអគ្គកុងស៊ុលបានឲ្យដឹងថា ដោយសារករណីខាងលើនេះ មិនមានកាលបរិច្ឆេទច្បាស់លាស់ ស្ថានអគ្គកុងស៊ុលមិនហ៊ានសន្និដ្ឋានយ៉ាងណាទេ ប៉ុន្តែពលរដ្ឋខ្មែរ ដែលត្រូវអាជ្ញាធរថៃចាប់ខ្លួននៅស្រុកអារញ្ញ ខេត្តសាកែវ ឬស្រះកែវ កន្លងមក មិនមានអ្នកណាត្រូវបង្អត់បាយបង្អត់ទឹកទេ គឺមានបាយទឹកហូបមួយថ្ងៃ៣ពេល ហើយរឿងក្តីសុទ្ធតែត្រូវបានរៀបចំសំណុំរឿងឡើងតុលាការតាមនីតិវិធី និងមានមេធាវីស្ម័គ្រចិត្តការពារក្តីជូនទាំងអស់។ បើតាមស្ថានអគ្គកុងស៊ុលខ្មែរ កាលពី៤ខែមុន គ្មានរឿងចាប់ពលរដ្ឋខ្មែរជាង៦០នាក់ នៅអារញ្ញប្រាថេតនោះទេ។ ជាមួយគ្នានោះ ស្ថានអគ្គកុងស៊ុល បានស្នើឲ្យជួយរកកាលបរិច្ឆេទជាក់លាក់ នៃរឿងខាងលើ ដើម្បីតាមដាន និងដោះស្រាយបន្ទាន់ ពីព្រោះស្ថានអគ្គកុងស៊ុល មិនដែលទុកបណ្តោយឲ្យពលរដ្ឋខ្មែរត្រូវចាប់ឃុំដោយគ្មានដំណោះផ្លូវច្បាប់យូរយ៉ាងនេះទេ។

ទាក់ទងបញ្ហានេះ លោក កេត សោផាន់ អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានថ្លែងថា លោកមិនដឹងថា ករណីនេះ ដូចគ្នា ឬយ៉ាងណានោះទេ តែមានករណីមួយ ឯកអគ្គរដ្ឋទូតឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសថៃ បានធ្វើលិខិតតវ៉ាចំនួនពីរដងរួចមកហើយ ដើម្បីឲ្យអាជ្ញាធរថៃដោះលែង។ ជាមួយគ្នានោះ ខាងឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំនៅប្រទេសថៃក៏បានចុះទៅមើលប្រជាពលរដ្ឋខ្មែរ ដែលជាប់ទោសនៅផងដែរ។ តាមលោក កេត សោផាន់ ករណីនេះ មានពលការខ្មែរប្រមាណ៨០នាក់ ហើយការធ្វើលិខិតតវ៉ាចំនួនពីរលើក ដើម្បីឲ្យអាជ្ញាធរថៃដោះលែងនោះ អាជ្ញាធរថៃមិនបានដោះលែងមកវិញនោះទេ ដោយសារតែក្រុមទាំងនោះ បានជាប់ពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស។ មានន័យថា ពួកគេគឺជាក្រុមមេខ្យល់។ លោក កេត សោផាន់ បានឲ្យដឹងដែរថា ករណីនេះ ខាងឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំនៅប្រទេសថៃ ក៏បានចុះទៅមើលប្រជាពលរដ្ឋខ្មែរ ដែលជាប់ទោសនោះផងដែរ ហើយចំពោះព័ត៌មានថា អត់បាយអត់ទឹកនោះ មិនជាការពិតទេ គឺមន្ត្រីទូតបានទៅមើលជាក់ស្តែង៕ ដោយ៖ កោះកែវ

## ពលរដ្ឋខ្មែរម្នាក់ ត្រូវទាហានថៃ បាញ់បាក់ជើង ព្រោះឆ្លងដែនខុសច្បាប់ទៅបេះផ្កាអ័រគីដេ

https://mediakhmer.club/ August 15, 2019

(ព្រះវិហារ)៖ ប្រជាពលរដ្ឋខ្មែរម្នាក់ ក្នុងចំណោមប្រជាពលរដ្ឋខ្មែរចំនួន ៥នាក់ ត្រូវបានក្រុមទាហានថៃ បាញ់ឲ្យរបួសបាក់ជើង ខណៈដែលពួកគាត់ បានឆ្លងដែនខុសច្បាប់ ចូលក្នុងទឹកដីរកបេះផ្កាអ័រគីដេ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩។ លោកវរសេនីយ៍ទោ ឳ សេង អធិការនគរបាលស្រុកជាំក្សាន្ត ខេត្តព្រះវិហារ បានថ្លែងប្រាប់តាមទូរសព្ទឲ្យភ្នាក់ងារ Fresh News ដឹងនៅរសៀលថ្ងៃទី១៥ ខែសីហានេះថា មុនពេលកើតហេតុ កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ ប្រជាពលរដ្ឋចំនួន ៥នាក់ រស់នៅភូមិអូក្សាន្ត ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ បានឆ្លងដែនចូលក្នុងទឹកដីថៃ តាមភ្នំច្រកដំណាក់ជ្រៃ ដើម្បីរកបេះផ្កាអ័រគីដេ និងខ្លះទៀតបេះផ្លែសម្រង ដើម្បីយកមកលក់ដោះស្រាយជីវភាព។ ប៉ុន្តែចៃដន្យអាក្រក់ បានជួបនឹងក្រុមទាហានថៃ ដែលកំពុងដើរល្បាត ត្រូវក្រុមទាហានថៃបាញ់រះមកបណ្តាលឲ្យរត់ចែកជើងគ្នា ត្រឡប់មកដីខ្មែរវិញ និងរងរបួសត្រូវជើងម្នាក់ផងដែរ។

លោកអធិការស្រុកបានបន្តថា ជនរងគ្រោះត្រូវទាហានថៃបាញ់មានឈ្មោះ ឈិន ឡាង ភេទប្រុស អាយុ២៦ឆ្នាំ រស់នៅនៅភូមិឃុំខាងលើ គឺបាញ់ត្រូវកជើងខាងស្តាំ ត្រូវបានក្រុមក្រុមគ្រួសារបញ្ជូន ទៅធ្វើការសង្គ្រោះនៅមន្ទីរពេទ្យបង្អែក ១៦មករា ខេត្តព្រះវិហារហើយ។ ជាមួយគ្នានោះដែរ លោកអធិការស្រុក បានធ្វើការអំពាវនាវឲ្យប្រជាពលរដ្ឋ ដែលរស់នៅជាប់ព្រំដែន ត្រូវបញ្ឈប់ការឆ្លងដែន ដោយខុសច្បាប់តទៅទៀត។ លោកថា ជាទូទៅការឆ្លងដែនខុសច្បាប់ របស់ប្រជាពលរដ្ឋខ្មែរ មិនដែលទទួលបានលទ្ធផលល្អទេ អ្នកខ្លះត្រូវជាន់មីនបណ្តាលឲ្យស្លាប់ និងរបួស ខ្លះត្រូវទាហានថៃចាប់ដាក់គុក រាប់ខែឆ្នាំនៅស្រុកគេ និងខ្លះទៀត ត្រូវទាហានថៃបាញ់បណ្តាលឲ្យរបួសពិការទៀតផង៕

## លោកអគ្គកុងស៊ុល ហ៊ុន សារឿន និងសហការី បានចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោកប្រធានសាលាដំបូងខេត្តស៊ីសាកេត និងលោកស្រីប្រធានសាលាដំបូងកាន់ថាឡាក់

https://www.facebook.com/ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ / 15-08-2019

សាលាដំបូងខេត្តស៊ីសាកេត, ថ្ងៃព្រហស្បតិ៍ 15កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី 15 ខែសីហា ឆ្នាំ2019។ លោកអគ្គកុងស៊ុល ហ៊ុន សារឿន និងសហការី បានចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោកប្រធានសាលាដំបូងខេត្តស៊ីសាកេត និងលោកស្រីប្រធានសាលាដំបូងកាន់ថាឡាក់ ដោយមានការអញ្ជើញចូលរួមពីសំណាក់លោកចៅក្រម ព្រះរាជអាជ្ញាអមសាលាដំបូងទាំងពីរ និងក្រុមមេធាវីថៃស្ម័គ្រចិត្តការពារក្តីជូនបងប្អូនប្រជាពលរដ្ឋខ្មែរចំនួន 3រូប។

ក្រៅពីថ្លែងស្វាគមន៍យ៉ាងកក់ក្តៅ ប្រកបដោយមនោសញ្ចេតនាមិត្តភាព ភាពជាអ្នកជិតខាងល្អ លោកនិងលោកស្រីប្រធានសាលាដំបូងទាំងពីរ បានធ្វើបទឧទ្ទេសនាមអំពីប្រព័ន្ធការងាររបស់សាលាដំបូងទាំងពីរដោយសង្ខេប និងបានជម្រាបដោយសង្កត់ធ្ងន់ជូនលោកអគ្គកុងស៊ុលថា កន្លងមកសាលាដំបូងទាំងពីរកាត់ក្តីដោយឈរលើគោលការណ៍មនុស្សធម៌ យុត្តិធម៌ មិនរើសអើងប្រកាន់ពូជសាសន៍ មិនប្រកាន់អ្នកមានអ្នកក្រ និងស្មើសិទ្ធិចំពោះមុខច្បាប់។ ជនជាប់ចោទទាំងអស់សុទ្ធតែត្រូវបានផ្តល់សិទ្ធិក្នុងការស្វែងរកមេធាវីការពារក្តី ទទួលបានការថែទាំក្នុងអំឡុងពេលឃុំខ្លួនរង់ចាំការកាត់ក្តីដូចជាផ្តល់អាហារទទួលទានគ្រប់គ្រាន់។ ចំពោះជនជាប់ចោទដែលជាពលរដ្ឋបរទេស ដែលពុំចេះភាសាថៃ និងគ្មានលទ្ធភាពរកមេធាវីការពារក្តី គឺតុលាការតែងតែរៀបចំអ្នកបកប្រែភាសា និងមេធាវីស្ម័គ្រចិត្តការពារក្តីជូនដោយមិនចាំបាច់ចំណាយថ្លៃចាយវាយអ្វីទាំងអស់។ កន្លងមកជនជាប់ចោទជាពលរដ្ឋខ្មែរសុទ្ធតែទទួលបានសេវា និងការអនុវត្តដូចគ្នានឹងជនជាប់ចោទជាពលរដ្ឋថៃ និងសាសន៍ដទៃដែរ។

លោកអគ្គកុងស៊ុលបានថ្លែងអំណរគុណចំពោះលោក លោកស្រីប្រធានសាលាដំបូងទាំងពីរ ដែលបានអនុញ្ញាតអោយចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ព្រមទាំងចែករំលែកព័ត៌មានដ៏មានសារៈសំខាន់ជូនប្រតិភូស្ថានអគ្គកុងស៊ុល។ លោកអគ្គកុងស៊ុលក៏បានជម្រាបជូនអង្គប្រជុំអំពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដោយមានក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិដែលមានឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិជាសេនាធិការ ជានិច្ចកាលតែងបានណែនាំស្ថានតំណាងកម្ពុជានៅបរទេសទាំងអស់យកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់បងប្អូនខ្មែរនៅបរទេសទាំងអស់។

លោកអគ្គកុងស៊ុលក៏បានឆ្លៀតជំរាបជូនអង្គប្រជុំអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃបានយ៉ាងជោគជ័យ និងកិច្ចប្រឹងប្រែងរបស់អាជ្ញាធរពាក់ព័ន្ធសមត្ថកិច្ចក្នុងខេត្តជាប់ព្រំដែនកម្ពុជា-ថៃក្នុងការផ្សព្វផ្សាយអប់រំមិនអោយពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ។ ទន្ទឹមនេះក៏បានជម្រាបជូនអង្គប្រជុំអំពី កំណើនសេដ្ឋកិច្ចយ៉ាងលឿនរហ័ស និងកំណើនការងារយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់ពលរដ្ឋខ្មែរនៅកម្ពុជាផងដែរ។ ទីបញ្ចប់លោកអគ្គកុងស៊ុលបានថ្លែងអំណរគុណចំពោះលោក លោកស្រីប្រធានសាលាដំបូង លោកចៅក្រមនិងលោកមេធាវីអមសាលាដំបូង ព្រមទាំងមន្ត្រីពាក់ព័ន្ធក្នុងសាលាដំបូងទាំងពីរដែលកន្លងមកបានជួយ បានយោគយល់ បានបន្ធូរបន្ថយទោស និងបានផ្តល់យុត្តិធម៌ជូនបងប្អូនជនជាប់ចោទខ្មែរទាំងអស់ដែលត្រូវឡើងតុលាការនៅទីនេះ ព្រមទាំងស្នើសុំអ្នកទាំងអស់ខាងលើមេត្តាបន្តជួយ និងអនុគ្រោះចំពោះជនជាប់ចោទជាពលរដ្ឋខ្មែរ តាមនីតិវិធីតទៅទៀត៕

## ក្រុមការងាររបស់អង្គការបណ្តាញលើកកម្ពស់គុណភាពជីវិតពលករ(LPN)ក្នុងប្រទេសថៃ ចុះអប់រំបណ្តុះបណ្តាលចំណេះដឹង អំពីសិទ្ធិការងារដល់ពលករកម្ពុជាចំនួន 30នាក់

https://www.facebook.com/PheakTraLiveOfficial/ Pheak Tra 16/08/19

16/08/19 យើងខ្ញុំ និងក្រុមការងាររបស់អង្គការបណ្តាញលើកកម្ពស់គុណភាពជីវិតពលករ(LPN)ក្នុងប្រទេសថៃ ចុះអប់រំបណ្តុះបណ្តាលចំណេះដឹង អំពីសិទ្ធិការងារដល់ពលករថៃចំនួន 30នាក់ ដែលកំពុងធ្វើការនៅរោងចក្រ CPF នៅ ខេត្តសារាក់បុរី ប្រទេសថៃ ។ ចំណុចសំខានក្នុងការអប់រំដោយផ្តោតសំខាន់ទៅលើរឿងការទប់ស្កាត់អំពើជួញដូរមនុស្សនិងសិទ្ធិការងារទូទៅ។

## ក្រុមការងាររបស់អង្គការបណ្តាញលើកកម្ពស់គុណភាពជីវិតពលករ(LPN)ក្នុងប្រទេសថៃ ចុះអប់រំបណ្តុះបណ្តាលចំណេះដឹង អំពីសិទ្ធិការងារដល់ពលករកម្ពុជា ចំនួន ៥០នាក់

https://www.facebook.com/PheakTraLiveOfficial/ Pheak Tra 16/08/19

15/08/19 យើងខ្ញុំ និងក្រុមការងាររបស់អង្គការបណ្តាញលើកកម្ពស់គុណភាពជីវិតពលករ(LPN)ក្នុងប្រទេសថៃ ចុះអប់រំបណ្តុះបណ្តាលចំណេះដឹង អំពីសិទ្ធិការងារដល់ពលករកម្ពុជា ចំនួន ៥០នាក់ ដែលកំពុងធ្វើការនៅរោងចក្រ CPF នៅតំបន់ក្វ៉ាតស្ថិតនៅស្រុកធូកថៃ ខេត្តណាខនរាជស៊ីម៉ា ប្រទេសថៃ ។ ចំណុចសំខានក្នុងការអប់រំដោយផ្តោតសំខាន់ទៅលើរឿងសិទ្ធិការងាររបស់ពលករដែលត្រូវទទួល ព្រមទាំងសារៈសំខាន់ផ្សេងទៀតដែលពលករត្រូវយល់ដឹង។

# ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៩

## ខុទ្ទកាល័យ លោកទេសរដ្ឋមន្ត្រី អូស្មាន ហាស្សាន់ បានបដិសេធចំពោះខ្លឹមសារ ដែលបានចុះផ្សាយនៅលើគេហទំព័រ និងវិទ្យុអាស៊ីសេរី ករណីចាប់លោក អះម៉ាត់ យ៉ះយ៉ា

http://www.cen.com.kh/ August 19, 2019

ភ្នំពេញ ៖ ខុទ្ទកាល័យ លោកទេសរដ្ឋមន្ត្រី អូស្មាន ហាស្សាន់ បានបដិសេធចំពោះខ្លឹមសារ ដែលបានចុះផ្សាយនៅលើគេហទំព័រ និង វិទ្យុអាស៊ីសេរី កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ជុំវិញការចាប់ខ្លួនលោកអះម៉ាត់ យ៉ះយ៉ា ដែលបានលើកឡើងដោយបំភ្លៃខុសពីការពិតនិង មានចរិតមួលបង្កាច់ អុជអាល បង្កចលាចលធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និង សេចក្តីថ្លៃថ្នូរបស់លោក អូស្មាន ហាស្សាន់ ដោយបានដកស្រង់សម្តីលោក អះម៉ាត់ យ៉ះយ៉ា ថា អ្នកដែលរៀបចំគម្រោងចាប់លោកដាក់ពន្ធនាគារនេះគឺ លោក អូស្មាន ហាស្សាន់ ដោយសារតែលោក និង ពលរដ្ឋជំទាស់នឹងគម្រោងចង់ធ្វើផ្លូវពុះដីវិហារបឹងកក់។

នៅថ្ងៃទី១៧ ខែ តុលា ឆ្នាំ២០១៨ ខុទ្ទកាល័យ លោកទេសរដ្ឋមន្ត្រី អូស្មាន ហាស្សាន់ សូមបដិសេធយ៉ាងដាច់អហង្ការ ចំពោះខ្លឹមសារដែលបានចុះផ្សាយនៅលើគេហទំព័រ និង វិទ្យុអាស៊ីសេរី កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ដែលបានលើកឡើងដោយបំភ្លៃខុសពីការពិត និង មានចរិតមួលបង្កាច់ អុជអាល បង្កចលាចល ធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរបស់ លោក អូស្មាន ហាស្សាន់ ដោយបានដកស្រង់សម្តីលោក អះម៉ាត់ ប៉ះយ៉ាថាអ្នកដែលរៀបចំគម្រោងចាប់លោកដាក់ពន្ធនាគារនេះគឺ លោក អូស្មាន ហាស្សាន់ ដោយសារតែលោក និងពលរដ្ឋជំទាស់នឹងគម្រោងចង់ធ្វើផ្លូវពុះដីវិហារបឹងកក់។

ខុទ្ទកាល័យ សូមបញ្ជាក់ថា ការផ្តន្ទាទោសលោក អះម៉ាត់ យ៉ះយ៉ា ដាក់ពន្ធនាគារ ជាសមត្ថកិច្ចរបស់តុលាការទាំងស្រុង ។ នេះគឺជារឿងឯកជនរបស់លោក អះម៉ាត់យ៉ះយ៉ា ដែលត្រូវបានតុលាការរកឃើញថា បានបញ្ជូនពលករដោយខុសច្បាប់ទៅបម្រើការងារនៅប្រទេសអារ៉ាប៊ីសាអូឌីត ដោយបោះបង់ចោលអស់រយៈពេលជាង ១២ ឆ្នាំ ហើយត្រូវបាន ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ជួយសង្គ្រោះមកដល់កម្ពុជាវិញ ដែលជនរងគ្រោះឈ្មោះ ម៉ាត់ សាណាស់ បានមកដល់កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ និង ឈ្មោះ អេង ពៅ បានមកដល់កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ បន្ទាប់មកពួកគេបានប្តឹងទៅសមត្ថកិច្ច ហើយត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ១៥ ឆ្នាំ និងបង្គាប់ឲ្យសងប្រាក់ ទៅជនរងគ្រោះចំនួន ២០០ លានរៀលពីបទជួញដូរមនុស្សដោយខុសច្បាប់ ករណីនេះមិនមានពាក់ព័ន្ធនឹង គម្រោងធ្វើផ្លូវរបស់ សាលារាជធានីភ្នំពេញកាត់ដីវិហារបឹងកក់នោះឡើយ៕ ដោយៈកូឡាប

## ជនបរទេសជិត៣០០នាក់ គ្មានសៀវភៅការងារ ត្រូវក្រុមចម្រុះចល័តលើការងារអធិការកិច្ចហត្ថពលកម្មបរទេស ផាកពិន័យ

http://nokorwatnews.com/archives/ 17/08/2019

ខេត្តបន្ទាយមានជ័យ៖ រយៈពេល២ថ្ងៃ នៅថ្ងៃទី១៥ និង១៦ ខែសីហានេះ ជនបរទេសជិត៣០០នាក់ ដែលសម្ងំធ្វើការងារគ្មានសៀវភៅការងារ នៅក្រុងប៉ោយប៉ែត ត្រូវក្រុមការងារចម្រុះចល័តលើការងារអធិការកិច្ច ហត្ថពលកម្មបរទេស ចុះពិនិត្យផាកពិន័យ ដែលនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩នេះ កំពុងតែបន្តការងារត្រួតពិនិត្យ នៅអគារចុងស្រល់ ក្រុមហ៊ុនកាស៊ីណូ ហ្គោឌិនក្រោន នៅក្នុងភូមិក្បាលស្ពាន១ សង្កាត់.ក្រុងប៉ោយប៉ែត ។

ក្រុមការងារចម្រុះចល័តនេះ និងចុះពិនិត្យលើប័ណ្ណ រួមទាំងសៀវភៅការងារជនបរទេស តាមសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្តឹមកំសាន្ត អាជីវកម្មរណប អាជីវកម្មពុំមាននាមករណ៍ អាជីវកម្មពេលរាត្រី អាជីវកម្មចល័ត អាជីវកម្មលើផ្ទៃទឹក និងអាជីវកម្មផ្សេងៗទៀតទូទាំង២៥រាជធានី/ខេត្ត ។ ក្រុមការងារចម្រុះចល័តនេះ ដឹកនាំដោយ លោកឧត្តមសេនីយ៍ឯក ចុង សុវណ្ណនី អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងលោកឧត្តមសេនីយ៍ឯក កែម សារិន

ប្រធាននាយកដ្ឋានជនបរទេសអន្តោប្រវេសន៍ ដើម្បីត្រួតពិនិត្យពលករបរទេស ដែលប្រើប្រាស់ Visa E, ប័ណ្ណការងារ, ពលករបរទេសដែល ទើបចូលមកធ្វើការនៅកម្ពុជា និងពលករបរទេស ដែលគ្មានប័ណ្ណការងារ ដើម្បីផាកពិន័យ ។ សមត្ថកិច្ចបានបញ្ជាក់ថា៖ ការចុះប្រត្តិបត្តិការត្រួតពិនិត្យរយៈពេលមួយថ្ងៃម្សិលមិញ និងមកទល់និងរសៀលម៉ោង៣ ថ្ងៃទី១៦ ខែសីហានេះ គឺបានចំនួន២៦០នាក់ហើយ ដែលពលករបរទេសទាំងនោះ មានប៉ាស្ព័រ និងវិសារការងារត្រឹមត្រូវ តែខ្វះប័ណ្ណការងារប៉ុណ្ណោះ ដែលពលករបរទេសទាំងនោះ មានជនជាតិចិន ជនជាតិឥណ្ឌូនេស៊ី និងជនជាតិថៃផងដែរ ។

សមត្ថកិច្ចបញ្ជាក់បន្ថែមថា៖ ពលករបរទេសដែលពុំមានប័ណ្ណការងារនោះ ត្រូវបានក្រុមការងារចម្រុះចល័តផាកពិន័យ ជាថវិកា៥០ម៉ឺនរៀល និងទុកពេលឲ្យពលករបរទេសទាំងនោះរយៈពេល១ខែ ដើម្បីធ្វើបណ្ណការងារ បើលើសពី១ខែនិងផាកពិន័យជាបន្តទៀត ហើយការធ្វើប័ណ្ណការងារនេះមានសុពលភាព១ឆ្នាំ គឺពលករបរទេសទាំងនោះ អាចធ្វើតាមរយៈក្រុមហ៊ុនដែលខ្លួន កំពុងធ្វើការ ៕ វណ្ណា

## កម្ពុជា-ថៃសម្រេចកសាងមជ្ឈមណ្ឌលសំចតទី១ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត នាចុងឆ្នាំ២០១៩

http://freshnewsasia.com/ 2019-08-17

**(ភ្នំពេញ)៖** កម្ពុជា-ថៃ បានសម្រេចកសាងមជ្ឈមណ្ឌលសំចត សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត នៅអំឡុងចុងឆ្នាំ២០១៩ ខាងមុខនេះ។ ភាគីទាំង២ បានអះអាងបន្ថែមថា ការកសាងមជ្ឈមណ្ឌលនេះ មានលក្ខណៈជាប្រវត្តិសាស្ត្រ និងសម្រាប់ការប្រារព្ធពិធីគំរប់ខួប៧០ឆ្នាំ នៃសម្ព័ន្ធភាពថៃ-កម្ពុជាផងដែរ។ ការសម្រេចរួមគ្នានេះបានធ្វើឡើងក្នុងជំនួបពិភាក្សារវាងប្រតិភូកម្ពុជា និងថៃ ដែលភាគីកម្ពុជា ដឹកនាំដោយលោក ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំណែកភាគីថៃដឹកនាំដោយលោកស្រី សាស៊ីថន វង្សរៀវ៉ាធុតឃីត អគ្គនាយករងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិថៃ (TICA) នៃក្រសួងការបរទេសថៃ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ នាទីស្តីការក្រសួងសង្គមកិច្ច។

ការសម្រេចកសាងមជ្ឈមណ្ឌលសំចតទី១ និងដំបូងបង្អស់ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត នាពេលនេះ គឺបានបង្ហាញពីចំណុចចាប់ផ្តើមជាវិជ្ជមានរបស់កម្ពុជា-ថៃ លើការពង្រឹង និងគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និង សមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស (SOP) នៅក្នុងប្រទេសថៃ ដែលកម្ពុជា និងថៃបានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។ ភាគីកម្ពុជា និងភាគីថៃ បានចុះហត្ថលេខា (SOP) ដើម្បីបង្កើតគោលការណ៍ណែនាំរួមស្តីពី ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងពង្រឹងបទដ្ឋានប្រតិបត្តិអនុលោម ទៅតាមការអនុវត្តជាលក្ខណៈអន្តរជាតិ, កំណត់តួនាទី និងការទទួលខុសត្រូវ នៃអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋភាគីទាំង២ នៅក្នុងដំណើរការមាតុភូមិនិវត្តន៍ និងសមាហរណកម្ម, ប្រើប្រាស់ជាឯកសារយោងពាក់ព័ន្ធ និងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម និងជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

ការចុះហត្ថលេខាកាលនោះ គឺរដ្ឋភាគីទាំង២ ត្រូវផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងពេញលេញ ដើម្បីធានានូវការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ជាប្រព័ន្ធប្រកបទៅដោយសុវត្ថិភាព និងនិរន្តរភាព ក្រោមវិសាលភាព នៃកិច្ចសហប្រតិបត្តិការរួមមាន៖

ទី១៖ ការផ្លាស់ប្តូរព័ត៌មានពីជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

ទី២៖ ការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

ទី៣៖ ការសម្របសម្រួលក្នុងកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

ទី៤៖ ការតាមដានត្រួតពិនិត្យ និងការប៉ាន់ប្រមាណលទ្ធផល នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

ក្រោយមានការចុះហត្ថលេខា ភាគីកម្ពុជា-ថៃ ក៏បានបង្ហាញជំហររួមគ្នាអនុវត្ត លើកិច្ចព្រមព្រៀងលុបបំបាត់ និងទប់ស្កាត់អំពើជួញដូរមនុស្ស ឲ្យនៅមានតិចតួចបំផុត ហើយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នឹងត្រូវបានលើកតម្កើង និងឲ្យមានសមភាព កុំឲ្យមានភាពរើសអើង ហើយក៏ដើម្បីជួយឲ្យជីវិតរបស់ជនរងគ្រោះ មានភាពល្អប្រសើរជាងមុន៕

## អាជ្ញាធរថៃ បានបញ្ជូនប្រជាពលរដ្ឋខ្មែរ ០១នាក់ មកឲ្យព្រះរាជាណាចក្រកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI August 17 at 5:06 PM

នៅច្រកទ្វារតំបន់ព្រំដែនអានសេះ នាល្ងាចថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ អាជ្ញាធរថៃ បានបញ្ជូនប្រជាពលរដ្ឋខ្មែរ ០១នាក់ មកឲ្យព្រះរាជាណាចក្រកម្ពុជាវិញ។ សមត្ថកិច្ចបានឲ្យដឹងថា ប្រជាពលរដ្ឋខ្មែរ ០១នាក់នេះ មានឈ្មោះ ផៃ សល់ ភេទប្រុស អាយុ ៤៣ឆ្នាំ មានទីលំនៅភូមិកៀរ៉ានី ឃុំរុងរឿង ស្រុកថ្មង ខេត្តកំពង់ស្ពឺ ដែលអាជ្ញាធរថៃចាប់ខ្លួន កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧ ពីបទឆ្លងដែនខុសច្បាប់។ សមត្ថកិច្ចបានធ្វើការអប់រំ ហើយឲ្យវិលត្រឡប់ទៅមូលដ្ឋានវិញនៅថ្ងៃដដែល៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/ General Department of Immigration - GDI August 16 at 5:48 PM

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់ នាវេលាម៉ោង ១៦និង៥៥នាទី ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## កម្លាំងសមត្ថកិច្ចខេត្តឈៀងរ៉ាយថៃ ឃាត់ខ្លួនពលរដ្ឋខ្មែរ ចំណាក់ស្រុកខុសច្បាប់ជាង 30 នាក់ ព្រមទាំងមេខ្យល់និងបក្សពួកមួយចំនួន

https://www.facebook.com/PheakTraLiveOfficial/ Pheak Tra Live August 17 at 1:42 PM

កម្លាំងសមត្ថកិច្ចខេត្តឈៀងរ៉ាយថៃ ឃាត់ខ្លួនពលរដ្ឋខ្មែរ ចំណាក់ស្រុកខុសច្បាប់ជាង 30នាក់ ព្រមទាំងមេខ្យល់និងបក្សពួកមួយចំនួន។ ការឃាត់ខ្លួនពលរដ្ឋខ្មែរជាង30នាក់ ដែលចំណាក់ខុសច្បាប់ ចូលប្រទេសថៃ នេះ បានធ្វើឡើងកាលពីយប់ថ្ងៃទី15 ខែសីហា ឆ្នាំ2019 កន្លងទៅ បច្ចុប្បន្នពលរដ្ឋខ្មែរទាំង កំពុងស្ថិតនៅក្នុងការសាកសួរពីសមត្ថកិច្ចចំរុះ ស្រុកប៉ាដែត ខេត្តឈៀងរ៉ាយ ប្រទេសថៃ ។

## ពលករខ្មែរម្នាក់ ធ្វើការនៅរោងចក្រមួយកន្លែងក្នុងខេត្តសមុតប្រាកាន បន្ទាប់ពីរូបគាត់ត្រូវខាងរោងចក្រដកហូតឯកសារលិខិតឆ្លងដែន អស់រយៈពេលជាច្រើនខែ ដោយមិនអោយគាត់កាន់

https://www.facebook.com/PheakTraLiveOfficial/ Pheak Tra Live August 16 at 8:31 PM

16/08/19 ថ្ងៃនេះខ្ញុំទទួលបានដំណឹងល្អ ពីពលករខ្មែរម្នាក់ធ្វើការនៅរោងចក្រមួយកន្លែង ក្នុងខេត្តសមុតប្រាកាន បន្ទាប់ពីរូបគាត់ត្រូវខាងរោងចក្រដកហូតឯកសារលិខិតឆ្លងដែន អស់រយៈពេលជាច្រើនខែ ដោយមិនអោយគាត់កាន់ ក្រោមលក្ខខណ្ឌ (បើចង់កាន់លិខិតត្រូវមានប្រាក់3000฿យកទៅបញ្ចាំ) ដោយឃើញភាពអយុត្តិធម៌ដូច្នេះគាត់បានទំនាក់ទំនងសុំអោយខ្ញុំជួយ ខ្ញុំបាននាំគាត់ទៅសរសេរពាក្យបណ្តឹងនៅ នាយកដ្ឋានក្រសួងការងារថៃ ផ្ទាល់កាលពីចុងខែកក្កដាកន្លងទៅ រហូតមកដល់ល្ងាចម្សិលមិញខាងរោងចក្រ បានកោះហៅ ពលករខ្មែរ ទាំងអស់មកប្រជុំ ដោយខាងរោងចក្របានប្រគល់លិខិតឆ្លងដែន និងប្រាក់ប្រកាន់មួយចំនួនជូនពលករទាំងអស់។ គាត់សប្បាយចិត្តខ្លាំងណាស់ក្រោយពីទទួលបានកាន់លិខិតឆ្លងដែនរបស់ខ្លួន និងទទួលបានប្រាក់កាន់មួយចំនួនដែលគេកាត់មកវិញ ពួកគាត់បានទូស័ព្ទមកអរគុណដល់ក្រុមការងារយើងដែលជួយជ្រោមជ្រែងរហូតដល់គាត់ទទួលបានឯកសាររបស់ខ្លួន។

គាត់ធ្លាប់ប្រាប់យើងខ្ញុំថាកន្លងមកខាងរោងចក្រមិនដែលអោយពួកគាត់កាន់ឯកសាររបស់ខ្លួនឡើយ ពេលទៅណាម្តងៗត្រូវដើរខ្ចីលុយគេដើម្បីប្រកាន់ យកលិខិតឆ្លងដែនមកកាន់ដើម្បីធ្វើដំណើរទៅផ្ទះឬទៅធ្វើធុរៈអ្វីមួយ តែថ្ងៃនេះគាត់ទទួលបានសិទ្ធិរបស់គាត់ពេញលេញហើយ ព្រមទាំងអរគុណយ៉ាងខ្លាំងដល់ក្រុមការងារយើងទៀត។

គួររំលឹកផងដែរថា ច្បាប់ប្រទេសថៃ បានហាមឃាត់មិនឲ្យថៅកែឬរោងចក្រ ដកហូតឬរឹបអូសឯកសារស្គាល់ខ្លួនរបស់ពលករជាដាច់ខាត់មិនករណីអ្វីក៏ដោយ ការដកហូតឯកសារសម្គាល់ខ្លួនរបស់ពលករ គឺជាអំពើជួញដូរមនុស្សខុសច្បាប់។ ក្នុងករណីខាងលើនេះខ្ញុំសូមចូលរួមសម្តែងការត្រេកអរចំពោះប្អូនដែលមានភាពក្លាហានចេញមកទាមទារភាពអយុត្តិធម៌របស់ខ្លួនរហូតដល់ទទួលបានជោគជ័យ តាមអ្វីដែលខ្លួនត្រូវបានទទួលតាមច្បាប់ការងារ ។ ហើយខ្ញុំសូមចូលរួមសម្តែងក្តីរីករាយដល់ពលករខ្មែរជាច្រើននាក់ទៀតដែលធ្វើការក្នុងរោងចក្រនេះ ដែលទទួលបានសិទ្ធិសេរីភាពទាំងអស់គ្នា។

## ជាហូរហែថៃបញ្ជូនពលរដ្ឋខ្មែរដែលចំណាកស្រុកខុសច្បាប់ ចូលប្រទេសថៃ អោយវិលត្រឡប់ទៅប្រទេសខ្លួនវិញ

https://www.facebook.com/PheakTraLiveOfficial/ Pheak Tra Live 17/08/2019

តើអ្នកមានដឹងថា ពលករខុសច្បាប់ដែលត្រូវសមត្ថកិច្ចថៃបញ្ជូនអោយវិលត្រឡប់ទៅស្រុកកំណើតវិញនោះត្រូវជាប់ឈ្មោះក្នុងបញ្ជីខ្មៅរបស់អគ្គស្នងការដ្ឋានអត្តសញ្ញាណកម្ម ប្រទេសថៃ ត្រូវហាមមិនអោយចូលមកធ្វើការក្នុងប្រទេសរយៈពេល 2ឆ្នាំ ។ ដូច្នេះប្រសិនបងប្អូនមានបំណងចង់ចូលមកធ្វើការក្នុងប្រទេសថៃ ដោយស្របច្បាប់នោះត្រូវទំនាក់ទំនងការិយាល័យស្វែងរកការងារនៅក្រៅប្រទេស ឬក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ដែលមានការទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងប្រទេសកម្ពុជា។ ត្រូវជៀសវាងការលួងលោមរបស់មេខ្យល់ ដែលបោកបញ្ឆោតនាំទៅធ្វើការនៅប្រទេសថៃ តាមរយៈខុសច្បាប់ ឬលួងលោមនាំទៅធ្វើការនៅលើទូកនេសាទត្រី នៅប្រទេសម៉ាឡេស៊ី,ឥណ្ឌូណេស៊ីជាដើម។ ត្រូវចងចាំថា ប្រទេសថៃគ្មានគោលនយោបាយបើកអោយពលករខុសច្បាប់ចុះឈ្មោះ ឬធ្វើឯសារស្រប់ដល់ពលករខុសច្បាប់ទៀតឡើយ ប្រសិនមានបុគ្គលណាមួយធបោកដូចករណីខាងលើ សូមប្រញាប់រាយការណ៍ ទៅសមត្ថកិច្ចពាក់ព័ន្ធដើម្បីចាត់វិធានការណ៍ មុននឹងលង់ខ្លួនក្លាយទៅជាជនរងគ្រោះនៅបរទេស។

## តួរីស ព្រលះរថយន្តសណ្តោង ពេលទៀបភ្លឺ នៅខេត្តស្រះកែវ ស្លាប់ពលករចំណាកស្រុក ១១ នាក់

http://kampucheathmey.com/ 18/8/2019 3:21 Pm

ប្រទេសថៃ ៖ ពលករចំណាកស្រុកចំនួន ១១ នាក់ បានស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ ក្នុងចំណោមពលករសរុបចំនួន ១៥ នាក់ ដោយ ៤ នាក់ ទៀតរងរបួសយ៉ាងធ្ងន់ធ្ងរ ខណៈដែលពួកគេកំពុងជិះលើរថយន្តឈ្នួលទៅរ៉ៃត្រាបន្តច្បាប់នៅខ្សែបន្ទាប់ព្រំដែន ក៏ត្រូវប៉ះទង្គិចជាមួយនឹងរថយន្តសណ្តោង។

យោងតាមព័ត៌មានរបស់កាសែតថៃ បានបញ្ជាក់ថា ហេតុការណ៍ដ៏រន្ធត់មួយនៃករណីគ្រោះថ្នាក់ចរាចរណ៍ បានកើតឡើងនៅវេលាម៉ោង ៤ និង ១៥ នាទីទៀបភ្លឺ ព្រឹកថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៩ តាមបណ្តោយផ្លូវពីស្រះកែវ ទៅច័ន្ទបុរី ក្បែផ្លូវចូលទៅសាលាស្រុក ក្នុងស្រុកវ៉ាំងសុំប៊ូន ខេត្តស្រះកែវ ប្រទេសថៃ។ នៅត្រង់ចំណុចកើតហេតុ ក្រោយពេលក្រុមតម្រួតថៃទៅដល់ គេសង្កេតឃើញថា មានរថយន្ត តួរីសមួយគ្រឿង ពាក់ស្លាកលេខលឿង បាងកក ៣៤-០៤០៥ របស់ លោក ណារីន ត្រាវ៉ែល បានរេឆ្លងខ្សែបន្ទាត់ទ្រូងថ្នល់ទៅបុកនឹងរថយន្តសណ្តោង ប្រភេទ កង់ ១៨ ពាក់ស្លាកលេខ ៧០-១២៣៤ និង ៧០-១២៣៥ ដែលកំពុងធ្វើដំណើរច្រាសទិសគ្នា ក្នុងតំបន់កំពុងស្ថាបនាផ្លូវថ្នល់ ពី ២ ខ្សែ ទៅ ៤ ខ្សែ បណ្តាលអោយរថយន្តតួរីសរួញមួយកំណាត់ខាងមុខ។

នៅក្នុងហេតុការណ៍នោះដែរ សមត្ថកិច្ចថៃបានបញ្ជាក់ថា ជនរងគ្រោះទាំងអស់មានចំនួន ១៤ នាក់ ដែលបានធ្វើដំណើរទៅកាន់ព្រំដែនត្រង់ចំណុច ច្រកអន្តរជាតិបានឡែម ( ច្រកអន្តរជាតិដូង ជាប់នឹងស្រុកកំរៀង ) ដើម្បីរ៉ៃត្រាបំពេញឯកសារក្នុងការរស់នៅបន្តក្នុងប្រទេសថៃ ដែលពលករចំណាកស្រុកទាំងអស់នោះ សុទ្ធសឹង ជាពលករមកពីប្រទេសឡាវ។ ក្រោយពីមានការជួយសង្គ្រោះរួចមក គឺមានពលករស្លាប់ចំនួន ១១ នាក់ ( ប្រុស៥នាក់ និង ស្រី ៦ នាក់ ) ក្នុងនោះមានអ្នកបើកបររថយន្តផងដែរ និង ៤ នាក់ទៀតរងរបួសធ្ងន់ ដែលត្រូវបានបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ វ៉ាំងសុំប៊ូន។ ដោយប៉ូលិសបានសន្និដ្ឋានបឋមថា បញ្ហានេះគឺបណ្តាលមកពីអ្នកបើកបររយន្តតួរីសដេកលក់ ទើបធ្វើអោយរេចង្កូតបែបនេះ៕ **ដោយ ៖ សោ និយមរ័ត្ន**

# ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៩

## បង្ក្រាបសេវាបម្រើផ្លូវភេទ របស់ជនជាតិចិនមួយកន្លែង នៅក្រុងកំពត

https://www.chnchannel.com/ អត្ថបទដោយ Kongkea Leuk កាលបរិច្ឆេទ ថ្ងៃទី 20 ខែ សីហា ឆ្នាំ 2019

**កំពត៖** ទីតាំងលួចបើកបង្កប់សេវាបម្រើផ្លូវភេទ របស់ជនជាតិចិនមួយកន្លែង នៅក្នុងសង្កាត់ក្រាំងអំពិល ក្រុងកំពត ត្រូវកម្លាំងសមត្ថកិច្ចចុះបង្ក្រាប នៅយប់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩។ នៅព្រឹកថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ នេះ ស្នងការនគរបាលខេត្តកំពត លោកឧត្តមសេនីយ៍ទោ ម៉ៅ ច័ន្ទមធុរិទ្ធ បានឲ្យដឹងថា ប្រតិបត្តិការនៅយប់មិញនេះ ស្ថិតក្រោមការសម្របសម្រួលពី ព្រះរាជអាជ្ញារង លោក ខា ដែនណា។ បើតាមលោកឧត្តមសេនីយ៍ស្នងការ ប្រតិបត្តិការនេះ កម្លាំងនគរបាលជំនាញរបស់លោក បានធ្វើការឃាត់ខ្លួនជនជាតិចិនចំនួន៩នាក់ ស្រី៥នាក់ និងវត្ថុតាងខិតផ្សព្វផ្សាយ ព្រមទាំងស្រោមអនាម័យមួយចំនួន។ ក្រោយឃាត់ខ្លួនជនសង្ស័យ ត្រូវបានបញ្ជូនទៅការិយាល័យជំនាញដើម្បីចាត់ការបន្តតាមច្បាប់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/ General Department of Immigration - GDI 19/08/2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់ នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកចាក់ប្រែង ខេត្តព្រះវិហារ៕

## ពលករកម្ពុជាធ្វើការនៅក្នុងប្រទេសថៃនាំកូនតូចៗ របស់ខ្លួនទៅធ្វើលិខិតបញ្ជាក់ម្ដាយនិងកូន

https://www.facebook.com/PheakTraLiveOfficial/ Pheak Tra Live 19-08-2019

19/08/19 ពលករកម្ពុជាធ្វើការនៅក្នុងប្រទេសថៃនាំកូនតូចៗរបស់ខ្លួនទៅធ្វើលិខិតបញ្ជាក់ម្ដាយ និងកូននៅស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកកប្រទេសថៃយ៉ាងច្រើនកុះករ។ ប្រភពពីពលករខ្មែរម្នាក់ធ្វើការតំបន់បាងណានៃខេត្តសាមុតប្រាកានប្រទេសថៃ បានអោយដឹងថារូបគាត់ និងភរិយាបានកូនប្រុស ស្រីពីរនាក់ ធ្វើលិខិតបញ្ជាក់ម្ដាយ និងកូន នៅស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកក ដើម្បីអោយកូនរបស់គាត់រស់នៅដោយស្របច្បាប់ប្រទេសថៃ ។

## សាច់ញាតិពលករខ្មែរជាប់ឃុំនៅថៃទទូចដល់អាជ្ញាធរឱ្យជួយធ្វើអន្តរាគមន៍ទៅភាគីថៃដោះលែងកូនៗ របស់ពួកគាត់វិញ

https://www.rfa.org/khmer/news/ ដោយ ទីន ហ្សាការីយ៉ា 2019-08-19

ឪពុកជនរងគ្រោះនៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ លោក គង់ សុផាត ប្រាប់អាស៊ីសេរី នៅថ្ងៃទី១៨ សីហាថា កូនរបស់លោក២នាក់ និងអ្នកជិតខាងនៅស្រុកម៉ាឡៃ ៣នាក់ទៀត ជាប់គុកនៅស្រុកអារញ្ញ ខេត្តស្រះកែវ (Srakaeo) ប្រមាណ ៤ខែហើយ។ លោកបន្តថា ពួកគាត់ប្រមាណ ៣០នាក់ជាអាណាព្យាបាលត្រៀមឆ្លងដែលទៅស្រុកអារញ្ញ ដើម្បីទៅសួរសុខទុក្ខកូនដល់ទីកន្លែង នៅថ្ងៃទី១៨ សីហា ប៉ុន្តែបានអាក់ខានវិញ បន្ទាប់ពីកូនទូរស័ព្ទពីពន្ធនាគារប្រទេសថៃមកថា អាជ្ញាធរខេត្តបន្ទាយមានជ័យគ្រោងទៅសួរសុខទុក្ខពួកគេនៅថ្ងៃទី១៩ សីហា៖ «ខ្ញុំម្រេចចាំមើលស្អែកទៀតមកបើមិនកើតទេពួកខ្ញុំនឹងនាំគ្នាទៅព្រំដែនប៉ោយប៉ែតទៀត ព្រោះបើយើងធ្វើតែម្នាក់ឯងមិនមានប្រសិទ្ធភាពទេ តែបើយើងដាក់ពាក្យប្ដឹងជុំគ្នាមានប្រសិទ្ធភាពជាង។

កន្លងមកដំណឹងអីក៏ដោយចេញមកពីគុកមកវិញ មិនដែលមានអាជ្ញាធរណាមកប្រាប់សាច់ញាតិទេ ហើយមន្ត្រីពាក់ព័ន្ធក៏គេមិនដែលទាក់ទងមកម៉ែឪផង ឃើញតែអ្នកនៅក្នុងគុកទូរស័ព្ទមកប្រាប់ឪពុកម្ដាយវិញ»។ លោកបន្តថា ពួកលោកជាឪពុកម្ដាយមានការអាណិតអាសូរដល់កូនៗ ជាខ្លាំង ដែលត្រូវជាប់គុកនៅស្រុកគេដោយសារតែជីវភាពក្រីក្រប៉ូលិសថៃបានចាប់ពលករខ្មែរជាង ៨០នាក់ ដាក់គុក កាលពីថ្ងៃទី២៦ មេសាកន្លងទៅ បន្ទាប់ពីពួកគេបានចាញ់បោកមេខ្យល់ឆ្លងដែនទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់។ លោក គង់ សុផាត អះអាងថា ក្នុងចំណោមពលករ ៨០នាក់នោះ មានប្រមាណ ៦០នាក់ ប៉ូលិសថៃបញ្ជូនមកដាក់គុកក្នុងស្រុកអារញ្ញ ក្រោយពីពួកគេជាប់គុកនៅទីក្រុងបាងកកជាង២ខែ ស្របពេលពលករជាង ២០នាក់ ទៀត កំពុងជាប់ឃុំនៅទីក្រុងបាងកកនៅឡើយ។ លោកបន្តថា អ្នកជាប់ឃុំទាំងនោះ មានកុមារតូចៗជាច្រើននាក់ជាប់គុកជាមួយឪពុកម្ដាយ។ លោកឱ្យដឹងទៀតថា ក្រុមពលករដែលកំពុងជាប់ឃុំតែងតែទូរស័ព្ទទៅក្រុមគ្រួសារទាំងទឹកភ្នែកជារៀងរាល់ថ្ងៃ និងមានពលករខ្លះបានដួលសន្លប់ក្នុងពន្ធនាគារ ដោយសារហូបអាហារមិនគ្រប់គ្រាន់ធ្វើឱ្យពួកគេធ្លាក់ខ្លួនឈឺជាច្រើននាក់។

កាលពីថ្ងៃទី១៥ សីហា កន្លងទៅ គ្រួសារពលករដែលកំពុងជាប់ឃុំនៅស្រុកអារញ្ញ បានលើកគ្នាទៅសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅព្រំដែនអន្តជាតិប៉ោយប៉ែតម្ដងរួចមកហើយ ដើម្បីឱ្យជួយនិយាយជាមួយភាគីថៃ ឱ្យដោះលែងកូនៗរបស់ពួកគាត់ឱ្យបានឆាប់។ ក៏ប៉ុន្តែ ប៉ូលិសព្រំដែនបានប្រាប់ពួកគាត់ឱ្យត្រឡប់ទៅផ្ទះវិញ ដើម្បីធ្វើលិខិតពីអាជ្ញាធរមូលដ្ឋានបញ្ជាក់ទីលំនៅរបស់ពលករទាំងនោះ ដើម្បីបញ្ជូនទៅស្ថានកុងស៊ុលខ្មែរនៅស្រុកអារញ្ញ ឱ្យជួយអន្តរាគមន៍ដោះលែងពួកគេ៕

## អគ្គនាយកអន្តោប្រវេសន៍ បានដឹកនាំគណៈប្រតិភូអគ្គនាកដ្ឋានអន្តោប្រវេសន៍កម្ពុជា ចូលរួមពិធីបើកកិច្ចប្រជុំអគ្គនាយកអន្តោប្រវេសន៍ និងប្រធានកុងស៊ុលអាស៊ានលើកទី២៣

https://www.facebook.com/ General Department of Immigration - GDI 19-08-2019

ណៃពិដោះ ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍ បានអញ្ជើញដឹកនាំគណៈប្រតិភូអគ្គនាកដ្ឋានអន្តោប្រវេសន៍កម្ពុជា ចូលរួមពិធីបើកកិច្ចប្រជុំអគ្គនាយកអន្តោប្រវេសន៍ និងប្រធានកុងស៊ុលអាស៊ានលើកទី២៣ (23rd DGICM) និងកិច្ចប្រជុំពាក់ព័ន្ធ ប្រព្រឹត្តទៅនៅព្រឹកថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៩ នៅរដ្ឋធានីណៃពិដោរ សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ដោយមានការអញ្ជើញចូលរួមពីគ្រប់បណ្តាអគ្គនាយកអន្តោប្រវេសន៍ និប្រធានកុងស៊ុលអាស៊ាន នៅសណ្ឋាគារហីលតុន នាទីក្រុងណៃពីដ សាធារណរដ្ឋ សហភាពមីយ៉ាន់ម៉ា ។

គណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំក្នុងវេទិកាប្រធានច្រកទ្វារអន្តោប្រវេសន៍អាស៊ានលើកទី៣ (3rd AMICF) ពិភាក្សាលើការងារគ្រប់គ្រងច្រកទ្វារអន្តោប្រវេសន៍ នៃបណ្តាប្រទេសជាសមាជិកអាស៊ាន ដើម្បីបង្ការ និងទប់ស្កាត់បទល្មើសឧក្រិដ្ឋកម្មឆ្លងដែនគ្រប់រូបភាព នៅក្នុងតំបន់។ វេទិកានេះផ្នែកមួយនៃកិច្ចប្រជុំអគ្គនាយកអន្តោប្រវេសន៍ និងប្រធានកុងស៊ុលអាស៊ានលើកទី២៣ (23th DGICM) ដែលប្រារព្ធឡើងនៅរដ្ឋធានី ណៃពិដោ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ពីថ្ងៃទី ១៩ ដល់ថ្ងៃ ២១ ខែសីហា ឆ្នាំ២០១៩ នេះ៕

## ពលករខ្មែរ ចំនួន ០៦នាក់ បានចាញ់បោកបុគ្គលក្នុងរូបភាព ថាអាចនាំចូលធ្វើការក្នុងរោងចក្រល្អ បាន ដោយតម្រូវឱ្យពលករបង់លុយមុនម្នាក់៣០០០បាត

https://www.facebook.com/PheakTraLiveOfficial/ Pheak Tra Live 20-08-2019

បងប្អូនពលករខ្មែរធ្វើការក្នុងប្រទេសថៃ ប្រយ័ត្នចាញ់បោក បុគ្គលដែលបោកប្រាស់ ថាអាចនាំចូលការនៅក្នុងរោងចក្រនានា ក្នុងប្រទេសថៃ បានដោយយកចូលថ្លៃបង់ចូលធ្វើការរោងចក្រល្អៗម្នាក់ ៣០០០បាត។ ករណីនេះពលករខ្មែរ ចំនួន ០៦នាក់ បានចាញ់បោកបុគ្គលក្នុងរូបភាព ថាអាចនាំចូលធ្វើការក្នុងរោងចក្រល្អ បាន ដោយតម្រូវឱ្យពលករបង់លុយមុនម្នាក់៣០០០បាត តែចុងក្រោយត្រូវបុគ្គលរូបនោះដឹកយកទៅដាក់ចោលក្នុងបន្ទប់ជួលអស់រយៈពេលជាង ១០ថ្ងៃ តែមិនមានការងារអោយធ្វើ នៅពេលពលករ ទាក់ទងសសុំលុយវិញ ត្រូវបុគ្គលរូបនោះកុហកព្រឹក កុហកល្ងាច ថែមទៀតាំង គំរាមប្តឹងតម្រួតចាប់ទៀត ។ ចុងក្រោយពលករគ្មានជម្រើសននាំគ្នាវិលត្រលប់ទៅប្រទេសខ្មែរវិលអស់លុយក៏អស់ ការងារក៏គ្មានធ្វើ ព្រមទាំងក្លាយជាពលករខុសច្បាប់ទៀត ។

ក្នុងករណីខាងលើនេះខ្ញុំសូមរំលឹកអោយបងប្អូនដឹងថា សូមកុំជឿលើបុគ្គលណាមួយ ដែលសន្យាថាអាចរកការងារល្អក្នុងរោងចក្រក្នុង ប្រទេសថៃ អោយពលករខុសច្បាប់ ឬខុសថៅកែ ធ្វើបាន នោះទេ នេះជាល្បិចបោកប្រាស់ពេលគេឃើញយើង នៅខុសច្បាប់ គេតែងប្រើវិធីបែបនេះ ដើម្បីបោកពលករខុសច្បាប់និងខុសថៅកែ ។ សូមប្រយ័ត្នចាញ់បោកដូចករណីពលករខ្មែរ យើងខាងលើនេះ.!។

## ពលករខ្មែរម្នាក់ជួបគ្រោះថ្នាក់ត្រូវសសរគៀបបាក់ភ្លៅ និងបែកប្រអប់ភ្នែកជើង ខណៈពេលកំពុងបំពេញការងារ

https://www.facebook.com/PheakTraLiveOfficial/ Pheak Tra Live 20-08-2019

ករណីបុរសខ្មែរ ឈ្មោះ សាន រ៉ាវី អាយុ ២៥ឆ្នាំ ស្រុកកំណើត រស់នៅខេត្តកំពង់ចាម ជួបគ្រោះថ្នាក់ត្រូវសសរគៀបបាក់ភ្លៅ និងបែកប្រអប់ភ្នែកជើង ខណៈពេលកំពុងបំពេញការងារ ក្រៅម៉ោងកាលពីថ្ងៃសៅរ៍ ទី១៧ ខែសីហា ឆ្នាំ ២០១៩ កន្លងទៅ បច្ចុប្បន្នជនរងគ្រោះកំពុងសំរាកព្យាបាលនៅ មន្ទីរពេទ្យបាងណា ប្រទេសថៃ ។ ប្រភពពីះភរិយាជនរងគ្រោះ ឈ្មោះ ហាន ខេន ២៤ឆ្នាំ បានប្រាប់ក្រុមការងារយើងតាមរយៈទូស័ព្ទ អោយដឹងប្តីរបស់កំពុងសម្រាក

ព្យាបាលនៅមន្ទីរពេទ្យមុំបាងណា បច្ចុប្បន្នកំពុងចូលវះកាត់ជើងជាលើកទីពីរ ហើយខាងថៅកែ បានទិញទឹកដោះគោរចូលមកសួរសុខទុក្ខរៀនរាល់ថ្ងៃ ។ ចំណែកឯថ្លៃព្យាបាលពួកគាត់មិនបានអស់ប្រាក់នោះទេព្រោះគាត់មានប្រកាន់សង្គម ចំណែកឯរឿងផ្សេងទៀតគាត់មិនទានគិតគូរនៅឡើយទេ ព្រោះរងចាំអោយប្តីរបស់គាត់ធូរសាសន៍ ស្មើយសិន ដូច្នេះ សូមបងប្អូននៅក្នុងសង្គមហ្វេសប៊ុកជ្រាបជាពត៌មាន។

## សមត្ថកិច្ចអន្តោប្រវេសន៍ថៃចាប់ខ្លួនម្ចាស់ផ្ទះ និងធ្វើការចោទប្រកាន់ពីបទជួញដូរមនុស្ស

https://www.facebook.com/PheakTraLiveOfficial/ Pheak Tra Live 19-08-2019

កុមារីជនជាតិឡាវម្នាក់ វ័យ ១៤ឆ្នាំ បានចំណាកស្រុកចេញពីប្រទេសរបស់ខ្លួន ដោយខុសច្បាប់ មកធ្វើការតាមផ្ទះនៅក្នុងខេត្តសាមុតប្រាកាន ប្រទេសថៃ តតាំងពីឆ្នាំ២០១៧ ដោយម្ចាស់ផ្ទះ ផ្តផ្តល់ប្រាក់ខែជូននាង ចំនួន ៣០០០បាត ក្នុងមួយខែ ហើយខែដំបូងប្រាក់ខែនាងត្រូវថៅកែកាត់អស់ ដោយបង់ថ្លៃធ្វើដំណើរ ហើយប្រាក់ខែ ខែទីពីរ ត្រូវថៅកែវេរទៅអោយបញ្ជីធានាគាររបស់ឪពុកម្តាយនាង។ អស់រយៈពេល ២ឆ្នាំ ដែលនាងធ្វើការផ្ទះជាមួយថៅកែរូបនោះ នាងតែងត្រូវម្ចាស់ផ្ទះដែលជាថៅកែវាយធ្វើបាប និងប្រើកន្ត្រៃកាត់ផ្កាចាក់លើខ្លួនប្រាណនាង ឡើងដំបៅពេញខ្លួនប្រាណនាង នៅក្រោយពេលនាងត្រូវថៅកែវាយធ្វើបាប មានស្លាកស្នាមដំបៅលើខ្លួនប្រាណ នាងបានទៅរកពេទ្យដើម្បីព្យាបាលឡើយ ដោយបានត្រឹមលេបថ្នាំប៉ារ៉ា ហើយបណ្តោយអោយស្នាមដំបៅជាទៅតាមធម្មជាតិខ្លួនឯងប៉ុណ្ណោះ។ ពីមុនមកនាងធ្លាប់គិតថា ចង់រត់ចេញពីកន្លែងធ្វើការនេះដែរប៉ុន្តែត្រូវថៅកែនេះ គំគំរាមកំហែងបើហានរត់ទៅនឹងត្រូវតម្រួតចាប់ឬមិនដូច្នោះទេ នឹងត្រូវគេចាប់កោសក់អោយក្បាលត្រងោល។

ដោយសារតែទ្រាំនឹងស្ថានភាពថៅកែនេះ វាយធ្វើបាបរាល់ថ្ងៃមិនបាន នាងក៏សម្រេចចិត្ត រត់ចេញពីកន្លែងធ្វើការ ហើយក្លាយជាក្មេងអនាថា តាមចិញ្ចើមផ្លូវ ក្រោយមកនាង ជួបបុរសជនជាតិថៃ ម្នាក់ដែលអាងខ្លួនជាមនុស្សល្អបោកបញ្ឆោតយកទៅនៅជាមួយ ប៉ុន្តែនាងបែរជាត្រូវបុរសរូបនោះរំលោភបំពានផ្លូវភេទលើរូបនាង រហូតដល់អ្នកជិតខាងទ្រាំនឹងទង្វើបុរសរូបនោះលែងបាន ក៏ជួយនាំខ្លួននាងមកប្រគល់ជូនសមត្ថកិច្ចអន្តោប្រវេសន៍ខេត្តសាមុតប្រាកានដើម្បីបញ្ជូននាងអោយទៅស្រុកកំណើតវិញ ។ ប៉ុន្តែសមត្ថកិច្ចបានសង្កេតឃើញខុសប្រក្រតីលើខ្លួនប្រាណនាងមានស្លាកស្នាមដំបៅពេញខ្លួន បានសាកសួរ ទើបបែកធ្លាយដឹងថានាងត្រូវថៅកែមុន វាយធ្វើបាប និងត្រូវបុរសអាងធ្វើជាមនុស្សល្អរំលោភបំពានផ្លូវភេទថែមទៀត។ បន្ទាប់ពីដឹងមូលហេតុសមត្ថកិច្ចអន្តោប្រវេសន៍ បានសហការជាមួយអាជ្ញាធរពាក់ព័ន្ធ សាកសួររឿងហេតុរហូតឈានដល់ការចាប់ខ្លួន បុរសដែលខ្លែងខ្លួនជាមនុស្សល្អ ហើយរំលោភបំពានផ្លូវភេទលើរូបនាង ។ វេលាបន្តបន្ទាប់សមត្ថកិច្ចបានស្រាវជ្រាវបន្ថែមឈានទៅដល់ការចាប់ថៅកែដើម ដែលធ្វើទារុណកម្មវាយធ្វើបាបលើខ្លួនប្រាណនាង ថៅកែដើមត្រូវជាម្ចាស់ផ្ទះ ត្រូវសមត្ថកិច្ចចាប់ខ្លួន និងធ្វើការចោទប្រកាន់ពីបទជួញដូរមនុស្ស ។ ចំណែកឯកុមារីរងគ្រោះត្រូវបានសមត្ថកិច្ចថៃ ជួយទំនាក់ទំនងក្រុមគ្រួសារឪពុកម្តាយ ព្រមទាំងផ្តល់កន្លែងស្នាក់ ដើម្បីការព្យាបាលផ្លូវចិត្តអោយវិលទៅកេសភាពធម្មតាវិញ។

# ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៩

## បច្ចុប្បន្នស្ត្រីខ្មែរជាង៨ពាន់នាក់ បានរៀបការជាមួយបុរសកូរ៉េ

https://www.dap-news.com/ ByID:118 Posted on 21 August 2019 | 13:04

**ភ្នំពេញ៖** ក្នុងជំនួបជាមួយលោក អូ ណាក់យ៉ុង (Oh Nak-young) ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជាចប់អាណត្តិនៅព្រឹកថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានលើកឡើងថា បច្ចុប្បន្នមានស្ត្រីជាជនជាតិខ្មែរជាង៨ពាន់នាក់ បានរៀបការជាមួយបុរសជនជាតិកូរ៉េ ហើយមានប្រមាណ៤០០នាក់ មានភរិយាជាជនជាតិកូរ៉េ ។ ចំណុចនេះ ត្រូវបានសម្តេចនាយករដ្ឋមន្ត្រីបញ្ជាក់ថា “**ដូច្នេះមានន័យថា ទំនាក់ទំនងរវាងប្រជាជន និងប្រជាជនមានការកើនឡើង**” ។

ពាក់ព័ន្ធស្ត្រីខ្មែររៀបការជាមួយបុរសកូរ៉េ សម្តេចតេជោ នាពេលកន្លងមកបានចាត់ទុកកូរ៉េ គឺជាជន្លងដ៏ល្អ ហើយក៏បានស្នើភាគីកូរ៉េជួយមើលការខុសត្រូវ ការពារដល់ស្ត្រីខ្មែរ និងពលករខ្មែរទៅរស់នៅ ក៏ដូចជាធ្វើការនៅកូរ៉េផង ដែរ។ សម្តេចបន្តថា បច្ចុប្បន្នក្នុងកម្រិតទ្វេភាគីឃើញថា ពលកររបស់កម្ពុជាទៅធ្វើការនៅប្រទេសកូរ៉េមានការកើន ឡើងដែលបានជួយដល់ប្រជាពលរដ្ឋមិនត្រឹមតែពលករនៅកូរ៉េប៉ុណ្ណោះទេ ប៉ុន្តែបាននាំចំណូលជាច្រើនដល់គ្រួសារ របស់គាត់ និងជួយសេដ្ឋកិច្ចកម្ពុជាផងដែរ។ ពិសេសពលករកម្ពុជាបានរៀនសូត្រនិងទទួលបទពិសោធន៍ពីកូរ៉េដែល បានបង្កើនសមត្ថភាព។ សម្តេចតេជោក៏ចង់ឃើញនៅពេលខាងមុខនូវការពង្រីកទំនាក់ទំនងរវាងប្រជាជន និងប្រជា ជននៃប្រទេសទាំងពីរ ទំហំពាណិជ្ជកម្ម កំណើនវិនិយោគ និងទេសចរណ៍កូរ៉េផងដែរ។ សម្តេចនាយករដ្ឋមន្ត្រីគ្រោង នឹងអញ្ជើញបំពេញទស្សនកិច្ចនៅកូរ៉េនៅពេលខាងមុខ ប៉ុន្តែមិនទាន់បានកំណត់ពេលវេលាជាក់លាក់នៅឡើយទេ ៕

## កម្ពុជា-ជប៉ុន នឹងពិនិត្យលទ្ធភាព ដោះស្រាយបញ្ហាគ្រឿងញៀន ការសម្អាតប្រាក់ និងជួញដូរមនុស្ស

https://www.dap-news.com/ ByID:117 Posted on 20 August 2019 | 18:08

**ភ្នំពេញ ៖** កម្ពុជា-ជប៉ុន នឹងពិនិត្យមើលលទ្ធភាព រួមគ្នាដោះស្រាយបញ្ហាសំខាន់ៗ ដែលនៅសេសសល់ មួយចំនួនដូចជា ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ការងារប្រយុទ្ធប្រឆាំងជួញដូរមនុស្ស និងការងារប្រឆាំងទៅនឹងការសម្អាតប្រាក់កខ្វក់។ ក្រោយបញ្ចប់ជំនួប ជាមួយរវាងសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោក Hidehisa HORINOUCHI ឯកអគ្គរាជទូតជប៉ុន ចប់អាណត្តិប្រចាំកម្ពុជា ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ លោក ផាត សុផានិត បានថ្លែងប្រាប់អ្នកសារព័ត៌មានថា “**ភាគីទាំងពីរ អាចពិនិត្យលទ្ធភាពពង្រីកនូវកិច្ចសហការលើវិស័យសំខាន់ៗ មួយចំនួនទៀត ដូចជាការងារប្រយុទ្ធប្រឆាំងនិងគ្រឿងញៀន , ការងារប្រឆាំងនិងការជួញដូរមនុស្ស ហើយនិងការងារប្រឆាំង និងការសម្អាតប្រាក់ជាដើម**” ។

សម្តេចបញ្ជាក់ថា បច្ចុប្បន្នទំនាក់ទំនង កម្ពុជា-ជប៉ុន កាន់តែមានភាពប្រសើរឡើង គួរឲ្យមានការកត់សម្គាល់ នេះក៏ដោយសារកើតឡើង ពីឆន្ទៈរបស់ថ្នាក់ដឹកនាំប្រទេសទាំងពីរ។ សម្តេចបន្តថា ក្រសួងមហាផ្ទៃកម្ពុជា ក៏មានកិច្ចសហប្រតិបត្តិការ ជាមួយស្ថាប័នពាក់ព័ន្ធរបស់ជប៉ុនផងដែរ ដូចជាទីភ្នាក់ងារនគរបាលជាតិជប៉ុន និងអង្គភាពប្រឆាំងភេរវកម្ម របស់ជប៉ុនដែលកម្ពុជា-ជប៉ុន បាននិងកំពុងមានទំនាក់ទំនងល្អជាមួយគ្នា។ ក្នុងឱកាសនោះ សម្តេចក៏បានថ្លែងអំណរគុណ ដល់រដ្ឋាភិបាលជប៉ុន ដែលបានផ្តល់លើ កិច្ចសហប្រតិបត្តិការ លើការជួយបណ្តុះបណ្តា ដល់មន្ត្រីរដ្ឋបាលមូលដ្ឋាន របស់កម្ពុជា ដែលនេះគឺជាការឆ្លើយតបមួយនូវ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងពេលរាជរដ្ឋាភិបាលកម្ពុជា កំពុងយកចិត្តទុកដាក់។ លើសពីនេះទៀត សម្តេចក៏បានជំរុញឲ្យ មានកំណើនវិនិយោគ ពាណិជ្ជកម្ម និងទេសចរណ៍រវាងប្រទេសទាំងពីរ ព្រមទាំងជំរុញការផ្លាស់ប្តូរវប្បធម៌ សិល្បៈ កីឡា អប់រំ ជាពិសេសការ ផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន ការផ្លាស់ប្តូររវាងយុវជន និងយុវជនដ៏ទូលំទូលាយ ផងដែរ៕ ដោយៈធី លីថូ

## អាជ្ញាធរខេត្តស្ទឹងត្រែងឲ្យមន្ទីរទេសចរណ៍ណែនាំបន្ថែមការទប់ស្កាត់ការរំលោភបំពានលើកុមារក្នុងវិស័យទេសចរណ៍

https://www.information.gov.kh/ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩

អាជ្ញាធរខេត្តស្ទឹងត្រែងណែនាំឲ្យមន្ទីរទេសចរណ៍បង្កើនការអប់រំបន្ថែមដល់ម្ចាស់អាជីវកម្មជួយពង្រឹងសុវត្ថិភាព ការពារសិទ្ធិកុមារ ដើម្បីធ្វើជាយន្តការទប់ស្កាត់កុំឲ្យកើតមានការរំលោភបំពាន និងការជួញដូរចំពោះកុមារក្នុងវិស័យ ទេសចរណ៍។ ការណែនាំនេះធ្វើឡើងក្នុងពិធីបើកវគ្គផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងច្បាប់ ស្តីពីវិស័យទេសចរណ៍ នៅមន្ទីទេសចរណ៍ខេត្តស្ទឹងត្រែងកាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩។ លោក យ៉ង់ សុវណ្ណនា អភិបាលរងខេត្តមាន

ប្រសាសន៍ថា ការលពីខែមិថុននា ឆ្នាំ២០១៨ អាជ្ញាធរទេសចរណ៍ បានចងក្រងម្ចាស់អាជីវកម្មប្រកបរបរពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ ជាបណ្តាញផ្តល់ព័ត៌មានរួចមកហើយ។ លោកបន្តថា កិច្ចការចំពោះមុខនេះសូមឲ្យបន្តរួមគ្នាធ្វើការអប់រំ និងណែនាំបន្ថែមក្រោមកិច្ចសហការគ្នាលប់បំបាត់រាល់ទម្រង់កម្មភាពជួញដូរ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរផ្លូវភេទចំពោះកុមារ ក្នុងវិស័យទេសចរណ៍ ដើម្បីឈានទៅលើកកម្ពស់តម្លៃវប្បធម៌ជាតិ។

លោក អ៊ុន ប៉ោសឿន ប្រធានមន្ទីរទេសចរណ៍ខេត្ត មានប្រសាសន៍ថា ម្ចាស់អាជីវកម្មទាំងអស់បានស្ម័គ្រចិត្ត ធ្វើជាភ្នាក់ងារសហការបានល្អជាមួយអាជ្ញាធរទេសចរណ៍ ហើយជាងនេះមន្ទីរបានបើកវគ្គអប់រំ និងជំរុញឲ្យម្ចាស់អាជីវកម្មបំពេញតួនាទីចូលរួមលើកកម្ពស់សុវត្ថិភាពកុមារជារៀងរាល់ឆ្នាំ។

លោក វរសេនីយ៍ត្រី ជា រដ្ឋា មន្ត្រីនគរបាលទេសចរណ៍ខេត្ត បានអះអាងថា ប៉ុន្មានឆ្នាំកន្លងមកនេះខេត្តស្ទឹងត្រែងគ្មានករណីកេងប្រវ័ញ្ច និងការជួញដូរកុមារទេ ដោយសារម្ចាស់អាជីវកម្ម និងអាជ្ញាធរពាក់ព័ន្ធបានសហការគ្នាល្អក្នុងការអនុវត្តច្បាប់។

លោកស្រី ឡាយ សំភារ ម្ចាស់អាហារដ្ឋាន១៧៩ នៅក្រុងស្ទឹងត្រែងបានលើកឡើងថា គោលការណ៍ដែលមន្ទីរទេសចរណ៍បានរៀបចំឡើងនេះ ជាចំណុចដែលម្ចាស់អាជីវកម្មកំពុងនាំគ្នាអនុវត្ត ព្រោះប៉ុន្មានឆ្នាំកន្លងមកធ្លាប់មានបណ្តាញព័ត៌មានបានបង្ហាញឲ្យឃើញពីម្ចាស់ហាងលក់ខោអាវបានធ្វើបាបកុមារី ជាខ្ញុំបម្រើ ដែលធ្វើឲ្យប្រជាពលរដ្ឋយើងមានការឈឺចាប់ជំនួស។

សូមបញ្ជាក់ថា ខេត្តស្ទឹងត្រែងមានសណ្ឋាគារចំនួន ៦ ផ្ទះសំណាក់ ៤០ ភោជនីយ៍ដ្ឋាន និងអាហារដ្ឋានចំនួន៣៩កន្លែង ហាងម៉ាស្សា ៩កន្លែង និងហាងខារ៉ាអូខេ ១០កន្លែង មានបុគ្គលិកបម្រើការងារចំនួន ៤៧៧នាក់ ក្នុងនោះស្ត្រីចំនួន ៤១៧នាក់។

## ឯកឧត្តម ហ៊ុយ សារ៉ាវុធ អញ្ជើញជាអធិបតីបិទសិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាព ក្រុមសីលធម៌ និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សដល់ពិធីករ និងអ្នកអានព័ត៌មានវិទ្យុ និងទូរទស្សន៍

https://www.information.gov.kh/ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩

ឯកឧត្តម ហ៊ុយ សារ៉ាវុធ រដ្ឋលេខាធិការក្រសួងព័ត៌មាន តំណាងឯកឧត្តម ខៀវ កញ្ញារិទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានអញ្ជើញជាអធិបតីបិទសិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាពក្រុមសីហធម៌ និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សដល់ពិធីករ និងអ្នកអានព័ត៌មានវិទ្យុ និងទូរទស្សន៍ ដែលមានវាគ្មិនជំនាញសំខាន់ៗមកពីក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងក្រសួងមហាផ្ទៃ អ្នកជំនាញសារព័ត៌មាន និងអ្នកជំនាញខាងអក្សរសាស្ត្រជាតិមកពីរាជបណ្ឌិត្យសភា ដែលពិធីប្រព្រឹត្តទៅនៅសាកលវិទ្យាល័យអន្តរជាតិ ទល់មុខមន្ទីរពេទ្យសែនសុខ ក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ នារសៀលថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩។

## ពលករខ្មែរច្រើននាក់កំពុងជាប់ឃុំលើដីថៃ សាច់ញាតិរត់រកការអន្តរាគមន៍

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ ម៉ោង ១៦:៥៦ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ពលរដ្ឋមួយក្រុមមានជិត២០នាក់ ដែលខ្លះជាឪពុកម្តាយ ខ្លះជាសាច់ញាតិ និងខ្លះទៀតជាតំណាង កាលពីរសៀលថ្ងៃទី១៩ សីហា បានទៅកាន់ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៅក្រុងប៉ោយប៉ែត ដើម្បីឱ្យជួយដល់កូនៗនិងសាច់ញាតិរបស់ពួកគា ត់ដែលកំពុងជាប់ឃុំលើទឹកដីថៃក្រោយត្រូវចាប់ខ្លួន និងជាប់ចោទឆ្លងដែនខុសច្បាប់ ។

ជួបជាមួយស្ត្រីឈ្មោះអិល អៅ អាយុ៥៨ឆ្នាំ រស់នៅភូមិថ្មល់ ឃុំតាសោម ស្រុកអង្គរជុំ ខេត្តសៀមរាប បានប្រាប់តាមទូរស័ព្ទថា កាលពីរសៀល គាត់និងពលរដ្ឋផ្សេងទៀតជិត២០នាក់ បានទៅកាន់ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីពឹងពាក់ដល់មន្ត្រីឲ្យជួយដល់កូននិងសាច់ញាតិ ដែលកំពុងជាប់ឃុំលើទឹកដីថៃ ។ ស្ត្រីដដែលបន្តថា ប្អូនបង្កើតនិងប្អូនជីដូនមួយរបស់គាត់ចំនួន៥នាក់ (ស្រី២ ប្រុស៣) ពេលនេះកំពុងជាប់ឃុំឃាំងនៅក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ។ គាត់បន្តថាប្អូនៗគាត់បានចេញពីកម្ពុជាកាលពីអំឡុងចុងខែមេសា ឆ្នាំ2019 តាមច្រករបៀងមួយ ដើម្បីទៅរកការងារធ្វើលើទឹកដីថៃជាមួយពលករជាច្រើននាក់ តែមិនទាន់បានដល់គោលដៅផង ក៏ត្រូវសមត្ថកិច្ចថៃចាប់ខ្លួនទាំងអស់ ។

ស្ត្រីខាងលើបន្តថា យោងកាសាកសួរពីប្អូនៗតាមទូរស័ព្ទពីប្រទេសថៃ (ទីតាំងជាប់ឃុំ)ប្រាប់ថា ពលករសរុបដែលសមត្ថកិច្ចថៃចាប់នោះមាន៨៥នាក់ ហើយថាពលករខ្លះមានទាំងកូនតូចៗថែមទៀត ។ គាត់បន្តទៀតថា ក្រោយចាប់ឃាត់ខ្លួនពលករចំនួន៦១នាក់ គេបញ្ជូនទៅដាក់ឃុំបណ្ដោះអាសន្ន នៅក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ និងជាង២០នាក់ទៀត គេយកទៅដាក់ឃុំនៅគុកធំ(សួនភ្លូ)ជិតក្រុងបាងកក ។ ពេលសាកសួរថា តើហេតុអ្វីពលករទាំងនេះមិននាំគ្នាស្វែងរកឯកសារស្របច្បាប់មុនចាកចេញពីកម្ពុជាស្ត្រីខាងលើលើកឡើងថា ព្រោះជីវភាពក្រីក្រគ្មានប្រាក់ធ្វើលិខិតឆ្លងដែនម្យ៉ាងគាត់ថា ប្អូនៗនិងជីដូនមួយទាំងនេះ ធ្លាប់ឆ្លងដែនខុសច្បាប់ម្តងរួចទៅហើយៗថាបើលើកទី2នេះជោគជ័យ និងនាំគ្នាយកប្រាក់ធ្វើលិខិតឆ្លងដែនឲ្យបានគ្រប់គ្នាៗ ដើម្បីបញ្ចៀសបញ្ហាកើតឡើងដឹងអីមិនទាន់ដល់គោលដៅផងត្រូវសមត្ថកិច្ចថៃចាប់ខ្លួនបាត់ទៅហើយ ។ (សម្រួលដោយៈ ស្រីណា)

## ពលករខ្មែរ ធ្វើការ នៅក្នុងខេត្តឆាក់ឈើងសៅ ត្រូវជនជាតិថៃ និងបក្សពួកប្រមាណ ៥នាក់ ប្រដាប់ដោយដំបង និងអាវុធ ស្ទាក់វាយធ្វើបាប

https://www.facebook.com/PheakTraLiveOfficial/ Pheak Tra Live 21-08-2019

ពលករខ្មែរ ធ្វើការ នៅក្នុងខេត្តឆាក់ឈើងសៅត្រូវជនជាតិថៃ និងបក្សពួកប្រមាណ ៥នាក់ ប្រដាប់ដោយដំបង និងអាវុធ ស្ទាក់វាយធ្វើបាបបណ្ដាលអោយរងគ្រោះយ៉ាងដំណំហេតុការណ៍នេះបានកើតឡើងកាលពីយប់នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ស្ថិតនៅក្នុងខេត្តឆាក់ឈើងសៅ ប្រទេសថៃ ប្រភពបឋម បានប្រាប់អោយដឹងថា មុនពេលកើតហេតុអ្នកបើកបររថយន្ត បានជេរស្ដីមើលងាយស្ត្រីពលករខ្មែរម្នាក់ ហើយជនរងគ្រោះដែលឃើញហេតុការណ៍ បានចេញទៅហាមប្រាម លុះដល់កើតហេតុចប់ អ្នកបើកបររថយន្ត និងបក្សពួកបានបើករថយន្តមកស្ទាក់វាយធ្វើបាបជនរងគ្រោះយ៉ាងដំណំ ។ ក្រោយពេលកើតហេតុពលករខ្មែរដែលឃើញហេតុការណ៍បានថតរូបភាពរថយន្ត ទូរស័ព្ទហៅតម្រួតថៃមកអន្តរាគមមកន្លែងកើតហេតុ នៅព្រឹកថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ ជនរងគ្រោះនឹងធ្វើដំណើរទៅដាក់ពាក្យបណ្ដឹងនៅអធិការដ្ឋានតម្រួតខេត្តឆាក់ឈើងសៅ ដើម្បីអោយតាមចាប់ខ្លួនជនបង្កយកផ្ដន្ទាទោសតាមផ្លូវច្បាប់។

# ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៩

## សម្តេចតេជោ ហ៊ុន សែន អញ្ជើញជួបពិភាក្សាការងារជាមួយជាមួយ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំនៅកម្ពុជាដែលចប់អាណត្តិ

http://nokorwatnews.com/archives/ 21-08-2019

ភ្នំពេញ៖ នៅវិមានសន្តិភាព នាថ្ងៃពុធ៦រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម អូ ណាក់យ៉ុង (Oh Nak-young) ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំនៅកម្ពុជាដែលចប់អណត្តិ។ នៅក្នុងជំនួបព្រឹកមិញនេះ ឯកឧត្តមអគ្គរដ្ឋទូតសាធារណៈរដ្ឋកូរ៉េ បានអរគុណចំពោះសម្តេច

តេជោនាយករដ្ឋមន្ត្រីដែលអនុញ្ញាតឲ្យចូលជួបសំដែងការគួរសមពិភាក្សាការងារ និងជម្រាបលា។ ឯកឧត្តមអគ្គរដ្ឋទូត បានបានលើកឡើងនូវចំណុចមួយចំនួនដែលពាក់ព័ន្ធជាមួយនឹងទំនាក់ទំនងទ្វេភាគីរវាងកម្ពុជា និងកូរ៉េ ព្រមទាំងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ ឯកឧត្តម អូ ណាក់យ៉ុង បានលើកឡើងនូវចំណុចពីរសំខាន់ ទីមួយគឺទំនាក់ទំនងកិច្ចសហប្រតិបត្តិការប្រទេសទាំងពីរ និងទីពីរ គឺការងារក្នុងក្របខ័ណ្ឌអនុតំបន់ និងការងារតំបន់ ។

ឯកឧត្តម ឯកអគ្គរដ្ឋទូតកូរ៉េ បានបញ្ជាក់ថា ក្នុងទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរមានការរីកចម្រើនយ៉ាងខ្លាំង និងមានការធ្វើទស្សនកិច្ចផ្លូវរដ្ឋរបស់ ឯកឧត្តមប្រធានាធិបតីសាធារណរដ្ឋកូរ៉េមកកម្ពុជានៅក្នុងពេល ឯកឧត្តមធ្វើជាអគ្គរដ្ឋទូតនៅកម្ពុជា គឺបានជំរុញការងារទ្វេភាគីពិសេសលើពាណិជ្ជកម្ម សេដ្ឋកិច្ច ទេសចរណ៍ជាដើម។ ឯកឧត្តម បានបញ្ជាក់ផងដែរថា នៅខែវិច្ឆិកានាពេលខាងមុខ អាស៊ាន និងកូរ៉េនឹងប្រារព្ធខួបនៃទំនាក់ទំនងនឹងគ្នានៅសាធារណរដ្ឋកូរ៉េ គ្រាដែលបច្ចុប្បន្ននេះកម្ពុជាជាប្រទេសសម្របសម្រួលកិច្ចសន្ទនាអាស៊ាន-កូរ៉េ។ ដូច្នេះហើយកម្ពុជាមានតួនាទីសំខាន់នៅក្នុងកិច្ចការងាររវាងអាស៊ាន និងកូរ៉េផងដែរ។ ពាក់ព័ន្ធជាមួយនឹងក្របខ័ណ្ឌអនុតំបន់ គឺមេគង្គ-កូរ៉េ កន្លងមកនេះគឺយើងមានយន្តការថ្នាក់រដ្ឋមន្ត្រីការបរទេសមេគង្គកូរ៉េ ដែលជាការផ្តួចផ្តើមរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលបានស្នើឲ្យយន្តការនេះកើនឡើងមួយកំរិតទៀតអោយយដល់ថ្នាក់កំពូល ហើយសាធារណរដ្ឋកូរ៉េ ទទួលយកនូវសំណើរបស់សម្តេចតេជោផងដែរ។ ហើយឯកឧត្តម បានបញ្ជាក់ដែរថា ទោះបីជាឯកឧត្តមចប់អាណត្តិក៏ដោយ ប៉ុន្តែការងារគឺនៅតែបន្តទៅមុខទៀត ឯកឧត្តមក៏បានលើកឡើងពីការងារអាទិភាពមួយចំនួន ជាពិសេសក្នុងការងារក្របខ័ណ្ឌទន្លេមេគង្គនេះតែម្តង។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានកត់សម្គាល់ដែរថាការវិនិយោគ ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងប្រទេសទាំងពីរក្នុងក្របខ័ណ្ឌទ្វេភាគីមានការរីកចម្រើនមែន នក៏ប៉ុន្តែសម្រាប់ជួយរដ្ឋមន្ត្រីចង់ឃើញនូវទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរមានការកើនឡើងថែមទៀត។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានជំរុញឲ្យភាគីទាំងពីរធ្វើយ៉ាងណាពង្រីក នឹងបង្កើនទំហំពាណិជ្ជកម្មទ្វេភាគីឲ្យបានកាន់តែកើនឡើងថែមទៀត ហើយសម្តេចនាយករដ្ឋមន្ត្រីក៏បានស្នើឲ្យភាគីកូរ៉េបន្តការនាំចូលនូវផលិតផលកសិផលរបស់កម្ពុជា ចូលទៅកាន់ទីផ្សារកូរ៉េ គ្រាដែលកម្ពុជាមានសក្តានុពលជាច្រើនទៅលើផលិតផលកសិកម្មដូចជាស្វាយជាដើម។ ក្នុងនោះ សម្តេចតេជោនាយករដ្ឋមន្ត្រីក៏ចង់ឃើញសាធារណរដ្ឋកូរ៉េ បង្កើនការវិនិយោគមកកាន់ព្រះរាជាណាចក្រកម្ពុជាថែមទៀត។ នៅក្នុងកិច្ចពិភាក្សានេះ សម្តេចតេជោនាយករដ្ឋមន្ត្រីបានលើកនូវចំនុចមួយចំនួនដែលភាគីកម្ពុជា និងកូរ៉េត្រូវតែខិតខំពង្រឹងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការថែមទៀត ដូចជាកម្រិតទ្វេភាគីនៃប្រទេសទាំងពីរ ដោយធ្វើយ៉ាងណាឱ្យមានការបន្តពង្រីក និងពង្រឹងទ្វេភាគីឱ្យកាន់តែខ្លាំងក្លារឹងមាំថែមទៀត។ បច្ចុប្បន្ននេះមានប្រជាពលរដ្ឋខ្មែរជាង ៨ពាន់នាក់ដែលបានរៀបការជាមួយជនជាតិកូរ៉េ ហើយមានប្រមាណ ៤០០នាក់មានភរិយាជាជនជាតិកូរ៉េ ដូច្នេះមានន័យថាទំនាក់ទំនងរវាងប្រជាជន និងប្រជាជនមានការកើនឡើង។ សម្តេចចង់ឃើញទំនាក់ទំនងទ្វេភាគីនេះមិនមែនត្រឹមតែការវិនិយោគសេដ្ឋកិច្ចពាណិជ្ជកម្ម ទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែចង់ឃើញទំនាក់ទំនងល្អរវាងប្រជាជន និងប្រជាជនមានការកើនឡើងថែមទៀត។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានលើកអំពី កិច្ចសហប្រតិបត្តិការផ្នែកអនុតំបន់មេគង្គកូរ៉េ ដែលសម្តេចតេជោនាយករដ្ឋមន្ត្រីបានរីករាយដែលកូរ៉េសម្រេចទទួលយកអនុសាសន៍របស់សម្តេចតេជោ ក្នុងការដំឡើងកម្រិតនៃកិច្ចសហប្រតិបត្តិការនិងយន្តការនេះ។

សម្តេចតេជោបានកត់សម្គាល់ថា កម្ពុជាបានទាញផលប្រយោជន៍ជាច្រើនទាំងកម្រិតទ្វេភាគីផង និងកម្រិតអនុតំបន់ផងដែរ ដោយសារតែកម្រិតអនុតំបន់មានគម្រោងជាច្រើនក្នុងកិច្ចដំណើរការជំរុញការអភិវឌ្ឍនៅក្នុងចំណោមប្រទេសមេគង្គរួមទាំងកម្ពុជាផងដែរ។ អំពីកិច្ចសហប្រតិបត្តិការក្នុងកម្រិតតំបន់រវាងអាស៊ានកូរ៉េវិញ ជាយន្តការដ៏សំខាន់គ្រាដែលកម្ពុជាជាប្រទេសសម្របសម្រួល ដោយសម្តេចតេជោចង់ឃើញការរីតចំណងមិត្តភាពបន្ថែមទៀតនៃការវិនិយោគពាណិជ្ជកម្មដើម្បីឲ្យឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ច និងសង្គមសេដ្ឋកិច្ចអាស៊ានកូរ៉េថែមទៀត។

គួរកត់សម្គាល់ដែរថា បច្ចុប្បន្ននេះ នៅក្នុងកម្រិតទ្វេភាគីយើងឃើញថាពលកររបស់កម្ពុជាយើងដែលទៅធ្វើការនៅប្រទេសកូរ៉េមានការកើនឡើង ដែលបានជួយដល់ប្រជាពលរដ្ឋមិនត្រឹមតែពលករនៅកូរ៉េប៉ុណ្ណោះទេ ប៉ុន្តែបាននាំចំណូលជាច្រើនគ្រួសាររបស់គាត់នៅកម្ពុជានិងជួយដល់សេដ្ឋកិច្ចរបស់កម្ពុជា។ ពិសេសថែមទៀតនោះពលកររបស់កម្ពុជាបានរៀនសូត្រនិងទទួលបទពិសោធន៍ពីប្រទេសកូរ៉េដែលបានបង្កើនសមត្ថភាពពលករខ្មែរ។

សម្តេចតេជោនាយករដ្ឋមន្ត្រីចង់ឃើញនៅពេលខាងមុខ នេះគឺការពង្រីកទំនាក់ទំនងរវាងប្រជាជន និងប្រជាជននៃប្រទេសទាំងពីរ ទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរមានការកើនឡើង កំណើននៃការវិនិយោគរបស់កូរ៉េ និងទេសចរណ៍កូរ៉េផងដែរ។ សម្តេចក៏បានមានប្រសាសន៍បញ្ជាក់ថា សម្តេចគ្រោងនឹងអញ្ជើញបំពេញទស្សនកិច្ចនៅសាធារណរដ្ឋកូរ៉េនៅពេលខាងមុខ ប៉ុន្តែមិនទាន់បានកំណត់ពេលវេលាជាក់លាក់នៅឡើយទេ៕

## ឯកឧត្តម អ៊ុំ រាត្រី ជម្រុញដល់សមត្ថកិច្ចដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវធ្វើការបង្ក្រាបឲ្យបានរាល់បទល្មើសរត់ពន្ធខុសច្បាប់តាមបន្ទាត់ព្រំដែន ពិសេសគ្រឿងញៀន

https://gdlf-kh.com/ 21/08/2019 Kim Sopha

ខេត្តបន្ទាយមានជ័យ ៖ រដ្ឋបាលខេត្តបន្ទាយមានជ័យ បានបើកកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តក្រោមអធិបតីភាពឯកឧត្តម អ៊ុំ រាត្រី អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងជាប្រធានអង្គប្រជុំ ដែលមានការអញ្ជើញចូលរួមពីគណៈអភិបាលរងខេត្ត មន្ទីរ ស្ថាប័ន អង្គភាពពាក់ព័ន្ធ កងកម្លាំងមានសមត្ថកិច្ចជុំវិញខេត្ត អភិបាលក្រុង-ស្រុក ដែលប្រារព្ធធ្វើនៅថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៩ នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ ។ នៅក្នុងកិច្ចប្រជុំ ឯកឧត្តម អ៊ុំ រាត្រី បានមានប្រសាសន៍លើកឡើងពីបញ្ហាតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដើម្បីរក្សាស្ថេរភាពរវាងប្រទេសទាំង២ ឯកឧត្តមអភិបាលខេត្ត បានជម្រុញដល់អាជ្ញាធរសមត្ថកិច្ចដែលឈរជើងនៅតាមបន្ទាត់ព្រំដែន ត្រូវធ្វើការទប់ស្កាត់ឲ្យបានរាល់បទល្មើសរត់ពន្ធតាមបន្ទាត់ព្រំដែន ដូចជា ៖ ការចរាចរណ៍ទំនិញគេចពន្ធ ពលរដ្ឋឆ្លងដែនខុសច្បាប់ ពិសេសការចរាចរណ៍ និងជួញដូរគ្រឿងញៀនចូលមកម្ពុជា ដែលបញ្ហានេះសមត្ថកិច្ច ដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវធ្វើការបង្ក្រាបឲ្យបានជាដាច់ខាត ។ ជាមួយគ្នានោះទាក់ទឹននឹងការបើកអាជីវកម្មល្បែងភ្នាល់តាមអ៊ីនធឺណេតខុសច្បាប់ដែលមាននៅក្នុងខេត្តបន្ទាយមានជ័យ ពិសេសក្រុងប៉ោយប៉ែត ដែលជាច្រកទ្វារសេដ្ឋកិច្ចដ៏សំខាន់រវាងកម្ពុជា-ថៃ ត្រូវតែធ្វើការបង្ក្រាបកុំឲ្យមាន ហើយកន្លងមកយើងបានអនុវត្ត និងឃាត់ខ្លួនបាន និងបានបិទជាបណ្តើរៗនៅទីតាំងបើកល្បែងស៊ីសងភ្នាល់តាមអ៊ីនធឺណេតផងដែរ តែយើងក៏ត្រូវតែខិតខំប្រឹងប្រែងធ្វើយ៉ាងណាបង្ក្រាបបន្តទៀតឲ្យអស់ ពីព្រោះវាជាដើមហេតុធ្វើឲ្យបាត់បង់សន្តិសណ្តាប់ធ្នាប់ បង្កឲ្យកើតមានចោរកម្ម និងអំពើហិង្សាជាដើម ។

ក្នុងនោះដោយយោងតាមសារាចរណែនាំ របស់រាជរដ្ឋាភិបាលលេខ ០៧ សរណន ស្តីពីការពង្រឹងការគ្រប់គ្រប់អាជីវកម្មល្បែងភ្នាល់ស៊ីសងតាមម៉ាស៊ីនអេឡិចត្រូនិច តាមរយៈអ៊ីនធឺណិត ក្នុង និងក្រៅប្រទេសគ្រប់ប្រភេទ និងគ្រប់រូបភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដើម្បីពង្រឹងការគ្រប់គ្រងអាជីវកម្មល្បែងស៊ីសងតាមម៉ាស៊ីនអេឡិចត្រូនិចតាមរយៈអ៊ីនធឺណេត ក្នុង និងក្រៅប្រទេស សំដៅចូលរួមថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសង្គម រដ្ឋាភិបាលបានណែនាំដូចខាងក្រោម ៖ ១-មន្ត្រីនគរបាលយុត្តិធម៌ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវបង្កើនការស្រាវជ្រាវ និងបង្ក្រាបអាជីវកម្ម ល្បែងភ្នាល់តាមម៉ាស៊ីនអេឡិចត្រូនិច តាមរយៈអ៊ីនធឺណេតអនឡាញ ក្នុង និងក្រៅប្រទេសគ្រប់ប្រភេទ និងគ្រប់រូបភាព ដែលធ្វើសកម្មភាពដោយមិនមានមានអាជ្ញាប័ណ្ណពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។ ២-ចំពោះអាជីវកម្មល្បែងភ្នាល់តាមម៉ាស៊ីនអេឡិចត្រូនិក តាមរយៈអ៊ីនធឺណេតក្នុង និងក្រៅប្រទេស ដែលមានអាជ្ញាប័ណ្ណត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពរហូតផុតសុពលភាពបានកំណត់ក្នុងអាជ្ញាប័ណ្ណ។ បន្ទាប់ពីនេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបន្តសុពលភាពនៃអាជ្ញាប័ណ្ណអនុញ្ញាតឲ្យប្រកបអាជីវកម្មល្បែង

ភ្នាល់គ្រប់ប្រភេទបន្តទៀតឡើយ។ ៣-រដ្ឋាភិបាលបញ្ឈប់ការផ្តល់គោលការណ៍ និងអាជ្ញាប័ណ្ណអនុញ្ញាតឲ្យប្រកបអាជីវកម្មភ្នាល់ល្បែងតាមម៉ាស៊ីនអេឡិចត្រូនិកតាមរយៈអ៊ិនធើណេត ក្នុងនិងក្រៅប្រទេសក្នុងព្រះរាជាណាចក្រកម្ពុជាចាប់ពីថ្ងៃចុះហត្ថលេខាលើសារាចរណែនាំនេះតទៅ៕

## ឃាត់ខ្លួនជនបរទេសម្នាក់ ករណីរំលោភផ្លូវភេទលើកុមារាម្នាក់ ក្រោម១៥ឆ្នាំ

http://kampucheathmey.com/ 22/8/2019 10:25 Am

សៀមរាប ៖ ស្ត្រីជាម្តាយ បានប្តឹងទៅសមត្ថកិច្ចឲ្យឃាត់ខ្លួនបុរសជនបរទេសម្នាក់ ដែលបាននាំកូនប្រុសគាត់វ័យ១៤ឆ្នាំទៅបន្ទប់ជួល ដើម្បីរំលោភបំពានផ្លូវភេទ។ ប្រតិបត្តិការនេះធ្វើឡើងនៅម៉ោង១១និង២០នាទីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ តាមបញ្ជា លោក កើត វណ្ណារេត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាប និងកម្លាំងនគរបាលជំនាញ និងអាជ្ញាធរមូលដ្ឋាន។

នគរបាលជាន់ខ្ពស់ នៃខេត្តសៀមរាប បានឲ្យដឹងថា នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ឈ្មោះ សាន់ យៀង ភេទស្រី អាយុ៤១ឆ្នាំ បានមកដាក់ពាក្យបណ្តឹងថា មានជនបរទេសរំលោភបំពានលើកូនប្រុសរបស់គាត់ ឈ្មោះ តេង លាន ភេទប្រុស អាយុ១៤ឆ្នាំ។ សមត្ថកិច្ចបន្តថា ផ្អែកតាមការសម្ភាសន៍ ក្មេងប្រុសឈ្មោះ តេង លាន បានបំភ្លឺថា នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ពេលយប់ ខ្លួនបានដើរសុំទាននៅម្តុំផ្សារចាស់បានជួបនឹងឈ្មោះ សន ជាជនបរទេស ( អឺរ៉ុប) ហើយសុំប្រាក់គាត់តែគាត់មិនឲ្យ បានហៅឡើងជិះម៉ូតូជាមួយទៅបន្ទប់ជួលរបស់គាត់ (ចំណាំមិនបាន)ពេលទៅដល់បន្ទប់ជួល គាត់ឲ្យស្រាតខោដេកលើគ្រែ រួចហើយគាត់សាប់ប្រដាប់ភេទខ្លួនឡើងរឹង ទើបគាត់ឲ្យខ្លួនសាប់ប្រដាប់ភេទគាត់វិញរហូតចេញទឹកកាម ហើយដេកនៅទីនោះមួយយប់ ព្រឹកឡើងឈ្មោះសន ឲ្យប្រាក់មកខ្លួន២៥ដុល្លារឲ្យត្រឡប់មកផ្ទះវិញ។ សមត្ថកិច្ចបន្ថែមថា ក្រោយពីសម្ភាសន៍ចប់ យើងបានឲ្យគាត់ចង្អុលបង្ហាញរូបថត ទើបយើងស្គាល់អត្តសញ្ញាណជនសង្ស័យ។

ក្រោយពីទទួលបានព័ត៌មាននេះ យើងបានបើកការស៊ើបអង្កេតបឋមទៅលោកព្រះរាជអាជ្ញា បានដឹកាស៊ើបអង្កេតបឋម ក៏បានកោះហៅឈ្មោះ Robinson Shaun Earl (ហៅ សន រី ហៅ ចន)កាន់លិខិតឆ្លងដែនលេខ ៥៤៥៨២២៨៣៨ អាយុ៤០ឆ្នាំ បានឆ្លើយថា ខ្លួនធ្លាប់ហៅមនុស្សប្រុសទៅដេកលេងហ្គេមនៅផ្ទះជួលតែមិនបានធ្វើអ្វីទេ ចំណែកកុមារមិនបានយកទៅទេ។

ជនសង្ស័យបានឃាត់ខ្លួនតាមបញ្ជា លោក កើត វណ្ណារេត ព្រះរាជអមសាលាដំបូងខេត្តសៀមរាបនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ ម៉ោង១១និង២០នាទី។ នៅវេលាម៉ោង២រសៀល បានចុះទៅឆែកឆេរនៅផ្ទះជនសង្ស័យ ដឹកនាំដោយលោក សំរិទ្ធ សុខុន ព្រះរាជអាជ្ញា រកឃើញវត្ថុតាងមាន ៖១. Ipsy 1 គ្រឿង , អង្គចងចាំ១គ្រឿង,២.ដៃហ្គេមក្មេងលេង៣គ្រឿង,៤.ទឹកថ្នាំអេិល២ដប។ សមត្ថកិច្ចបញ្ជាក់ថា នៅថ្ងៃទី២២សីហានេះ សមត្ថកិច្ចសួរនាំចប់ នឹងបញ្ជូនខ្លួនជនសង្ស័យខាងលើទៅតុលាការដើម្បីចាត់ការបន្តតាមនីតិវិធី៕ **ដោយ ៖ កុសល**

## កម្ពុជា កំពុងដុត ដៃដុតជើង អន្តរាគមន៍ ជួយពលករខ្មែរ ៨៥នាក់ ដែលចាញ់បោកមេខ្យល់ជនជាតិថៃ និងឃុំខ្លួនលើស ការកំណត់

https://www.dap-news.com/ ByID:030 Posted on 21 August 2019 | 19:25

ភ្នំពេញ៖ លោក កេត សោផាន់ អ្នកនាំពាក្យក្រសួងការ បរទេសខ្មែរ បានថ្លែងថា ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ កំពុង តែអន្តរាគមន៍ជួយពលករខ្មែរ ៨៥នាក់ ដែលត្រូវបានអាជ្ញាធរថៃ ចាប់ឃុំខ្លួន បន្ទាប់ពីចាញ់បោក មេខ្យល់ជនជាតិថៃ ឲ្យទៅបម្រើការងារខុសច្បាប់ខណៈពួកគាត់ត្រូវបាន ឃុំខ្លួនលើសការកំណត់ផងដែរ ។

ថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មាន ក្រោយជំនួបរវាងលោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរ និងលោក Norikazu SUZUKI អនុរដ្ឋមន្ត្រីការបរទេស ទទួលបន្ទុកកិច្ចការសភា នៃប្រទេសជប៉ុន នៅរសៀលថ្ងៃទី២១ សីហានេះ លោក កេត សោផាន់ បញ្ជាក់ថា "៨៥នាក់ហ្នឹង ត្រូវបានចាប់ជាយូរខែមកហើយ ហើយចុងក្រោយនេះខាងអគ្គកុងស៊ុលយើង នៅខេត្តស្រះកែវ ក៏ដូចជាស្ថានទូតយើង នៅបាងកក បានដុតដៃដុតជើងណាស់ គឺយើងបានទៅមើលគាត់ដល់កន្លែងឃុំ ឃាំង ។ ពលករ ៦១នាក់ ក្នុងចំណោម ៨៥នាក់ ត្រូវបានយកពីកន្លែងឃុំឃាំងនៅបាងកក ដោយសារកន្លែងចង្អៀត គេយកមកដាក់នៅស្រះកែវ" ។ លោកបន្ថែមថា បើតាមតំណាងស្ថានទូតកម្ពុជានៅទីនោះ បានទៅពិនិត្យមើលដល់កន្លែងឃុំឃាំង ឃើញថា ពួកគាត់មានសុខភាពល្អ មានការទំនុកបម្រុងត្រឹមត្រូវ និងគ្រប់គ្រាន់ ប៉ុន្តែអ្វីដែលជាបញ្ហា គឺពួកគាត់ត្រូវបានអាជ្ញាធរថៃ ឃុំខ្លួន លើសការកំណត់។

បញ្ហានេះលោក កេត សោផាន់ គូសបញ្ជាក់ថា ស្ថានទូតកម្ពុជា កំពុងតែតវ៉ា ហើយភាគីថៃឆ្លើយតបថា ចង់រក្សាទុកពលករទាំង ៨៥នាក់នោះ ដើម្បីជាបន្ទុកក្នុងការឆ្លើយចំពោះមេខ្យល់ថៃ ៧នាក់ ពាក់ព័ន្ធនិងការរត់ពន្ធមនុស្ស ។ លោកថា ទាំងក្រសួងការបរទេស ទាំងស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ កំពុងតែខិតខំធ្វើការងារនេះបន្តទៀត ៕ ដោយៈ ខា ដា

## កម្ពុជានិងវៀតណាមចុះកិច្ចព្រមព្រៀងជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងវិស័យចំនួន២៨

https://khmer.voanews.com/ 22 សីហា 2019

ភ្នំពេញ៖ ប្រទេសកម្ពុជានិងវៀតណាមបានចុះកិច្ចព្រមព្រៀងជាមួយគ្នានៅថ្ងៃពុធនេះដើម្បីជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងវិស័យចំនួន២៨។ កិច្ចព្រមព្រៀងនេះបានធ្វើឡើងនៅទីក្រុងភ្នំពេញក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី១៧នៃគណៈកម្មការចម្រុះកម្ពុជាវៀតណាមផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច ផ្នែកវប្បធម៌ និងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ កិច្ចព្រមព្រៀងក្នុងវិស័យទាំង២៨នោះរួមមាន កិច្ចព្រមព្រៀងបង្កនូវលក្ខខណ្ឌអនុគ្រោះដល់សេដ្ឋកិច្ចទ្វេភាគី កិច្ចព្រមព្រៀងផ្នែកសហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម ពង្រឹងភាពជាដៃគូផ្នែកសន្តិសុខ និងការពារជាតិ កិច្ចព្រមព្រៀងផ្នែកហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ផ្នែកវិស័យរ៉ែ និងថាមពល កិច្ចព្រមព្រៀងលើវិស័យក្សេត្រសាស្ត្រ ផ្នែកព័ត៌មាន និងសារគមនាគមន៍ ផ្នែកសុខាភិបាល ផ្នែកពលករ និងសង្គមកិច្ច កិច្ចសហការផ្នែកវប្បធម៌ កីឡា និងកិច្ចព្រមព្រៀងទេសចរណ៍និងផ្នែកបរិស្ថាន។

យោងតាមទីភ្នាក់ងារសារព័ត៌មានវៀតណាម VNA ភាគីកម្ពុជា និងវៀតណាមប្តេជ្ញានឹងបន្តកិច្ចប្រជុំកម្រិតខ្ពស់និងផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមកក៏ដូចជាយន្តការសហប្រតិបត្តិការទ្វេភាគីផងដែរ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial/ Immigration - GDI 21-08-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់ នាវេលាម៉ោង ១៦និង៣០នាទី ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## សារព័ត៌មានថៃ ៖ ប៉ូលិសចាប់យុវជនខ្មែរម្នាក់ចាញ់បោកមេខ្យល់ចូលកាប់ឈើគ្រញូង

http://nokorwatnews.com/archives/ 21-08-2019

ប៉ោយប៉ែត៖ យោងតាមការចុះផ្សាយរបស់គេហទំព័រក្នុងស្រុករបស់ថៃ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៩ បញ្ជាក់ថា កម្លាំងសមត្ថកិច្ចថៃ បានចាប់ខ្លួន យុវជនខ្មែរម្នាក់ ដែលចាញ់បោកមេខ្យល់ ឲ្យលួចចូលទៅកាប់ឈើគ្រញូង

នៅព្រៃអនុរក្សសត្វព្រៃ ហួយ សាលា ចម្ងាយពីព្រំដែនកម្ពុជា-ថៃ ៥.៥គីឡូម៉ែត្រ ។ ប្រភពបន្តថា នៅតំបន់អនុរក្សសត្វព្រៃហួយ សាលា ស្រុកភូ ស៊ីង ខេត្តស៊ី សះកេត សមត្ថកិច្ចថៃរាយការណ៍ ពីលោក សាធិត ផាន់ធុម៉ាស ប្រធានតំបន់រក្សាសត្វព្រៃហួយ សាលា ថា បន្ទាប់ពីសមត្ថកិច្ចអង្គភាព SMART PATROL បានចេញល្បាតនៅបរិវេណព្រៃទិសខាងត្បូងភ្នំឡែម នៃតំបន់រក្សាសត្វព្រៃហួយ សាលា ក្នុងឃុំផាន់ ទ្រំ ស្រុកខុនហាន ខេត្តស៊ី សះកេត ចម្ងាយពីព្រំដែនកម្ពុជា-ថៃ ប្រមាណ៥.៥គីឡូម៉ែត្រ បានប្រទះឃើញបុរសម្នាក់ជាពលករខ្មែរកំពង់កាប់ឈើគ្រញូង ទើបចូលទៅចាប់ឃុំបាន ។

ក្រោយពីការសួរនាំ ជំហានដំបូងដឹងថា យុវជនកម្ពុជារូបនោះ មានឈ្មោះ ស ណាន អាយុ២២ឆ្នាំ មានទីលំនៅភូមិអូរស្វាយ ឃុំត្រពាំងព្រៃ ស្រុកត្រពាំង ប្រាសាទ ខេត្តឧត្តមានជ័យ ព្រមទាំងវត្ថុតាងរួមមាន ឈើគ្រញូង៦ដុំ ដែលមានតម្លៃ១៣,២៥០បាត(ប្រាក់ថៃ) ឧបករណ៍ប្រព្រឹត្តបទល្មើសរួមមាន: កាំបិតខ្មែរ១ រណាកាត់១ រណាច្រៀក១ និងសម្ភារមួយចំនួនទៀត ទើបសមត្ថកិច្ចអង្គភាពSMART PATROL ចោទប្រកាន់ពីបទបំផ្លាញធនធនធម្មជាតិ បន្ទាប់មកបានបញ្ជូនខ្លួនជនសង្ស័យរួមទាំងវត្ថុតាងទាំងអស់ ទៅប្រគល់ឲ្យសមត្ថកិច្ចជំនាញ ដើម្បីអនុវត្តតាមច្បាប់ ។ នីម វណ្ណា

## អន្តោប្រវេសន៍ ខេត្តអយុធ្យា ប្រទេសថៃ បានឃាត់ខ្លួនពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ ចំនួន០៤នាក់

https://www.facebook.com/PheakTraLiveOfficial/ Pheak Tra Live added 21-08-2019

21/08/19 កម្លាំងអជ្ញាធរអន្តោប្រវេសន៍ ខេត្តអយុធ្យា ប្រទេសថៃ បានឃាត់ខ្លួនពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ ចំនួន០៤នាក់៖

១.ឈ្មោះ យ៉ិន យឿន ភេទប្រុស អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ

២.ឈ្មោះ ហុក មឿន ភេទស្រី អាយុ០៤ឆ្នាំ សញ្ជាតិខ្មែរ

៣.ឈ្មោះ អាន ម៉ៃ ភេទប្រុស អាយុ២០ឆ្នាំ សញ្ជាតិខ្មែរ

៤.ឈ្មោះ យ៉ិន យ៉ា ភេទប្រុស អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរ

ទាំងអស់គ្នាត្រូវកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ ខេត្តអយុធ្យា ប្រទេសថៃ ធ្វើការឃាត់ខ្លួននៅត្រង់ចំណុចផ្លូវសាធារណៈ ស្ថិតភូមិម៉ាកប្លាវ សង្កាត់ហ្សរ ស្រុកអយុធ្យា ខេត្តអយុធ្យា ប្រទេសថៃ កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ បច្ចុប្បន្នពលរដ្ឋខ្មែរទាំងអស់ត្រូវសមត្ថកិច្ចថៃ កសាងសំណុំរឿង ដើម្បីចាត់វិធានការណ៍តាមផ្លូវច្បាប់ ។

# ថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៩

## មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន សរុបចំនួន ៣៧នាក់

https://www.facebook.com/ អគ្គនាយកដ្ឋានការងារ-General Department of Labour 23-08-2019

នាថ្ងៃព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន សរុបចំនួន ៣៧នាក់ (ស្រី ១៥នាក់)។ វគ្គសិក្សានេះរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងដល់កម្មសិក្សាការី ឱ្យមានការយល់ដឹងអំពី៖

១-ការរៀបចំខ្លួន ដើម្បីធ្វើការនៅប្រទេសជប៉ុន ២-ភូមិសាស្ត្រ បរិស្ថាន និងវប្បធម៌នៅប្រទេសជប៉ុន

៣-ការធ្វើដំណើរតាមផ្លូវ និងការមកដល់ប្រទេសជប៉ុន ៤-ការធ្វើការងារ និងការរស់នៅក្នុងប្រទេសជប៉ុន
៥-ការគ្រប់គ្រងប្រាក់ ៦-សុខភាព និងអនាម័យ
៧-ការធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ ៨-សុវត្ថិភាព និងសេវាគាំទ្រ។

ក្រុមហ៊ុនដែលបានបញ្ជូនកម្មសិក្សាការី ទទួលការបណ្តុះបណ្តាលក្នុងវគ្គនេះមានចំនួន៧ គឺ

១. Ung Rithy Group Co., LTD ២. C. Connect World Co., LTD ៣. Hirayama Co., LTD
៤. Metrey HR Co., LTD ៥. NiCam Co., LTD
៦. Phillimore Cambodia Co., LTD ៧. Yakushinkai ( Cambodia ) Co., LTD

## បើកប្រតិបត្តិការចុះប្រមូលស្ត្រី រកស៊ីផ្លូវភេទ រួមទាំងអ្នកគកដេរ ជុំវិញរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រវត្តភ្នំ

https://khmernote.com/news/ 23-08-2019

ភ្នំពេញ៖ គណៈបញ្ជាការឯកភាពខណ្ឌដូនពេញ បន្តចុះប្រមូលស្ត្រីរកសុីផ្លូវភេទ ដែលឈរនៅតាមរបង និងក្រោមដើមឈើ រួមទាំងអ្នកគកដេរ(អ្នកចាប់ម៉ូយ) ជុំវិញរមណីយដ្ឋាន វប្បធម៌ប្រវត្តិសាស្ត្រវត្តភ្នំ ។ ដោយអនុវត្តតាមបទបញ្ជាដ៏មុឺងម៉ាត់របស់លោក សុខ ពេញវុធ អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ នៅថ្ងៃព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី២២ ខែសីហាឆ្នាំ ២០១៩ វេលាម៉ោង ៩ និង ៣០ នាទីព្រឹក កម្លាំងគណៈបញ្ជាការឯកភាពខណ្ឌដូនពេញ បានបើកប្រតិបត្តិការចុះប្រមូលស្ត្រី រកស៊ីផ្លូវភេទ រួមទាំងអ្នកគកដេរ(អ្នកចាប់ម៉ូយ) នៅ ជុំវិញរមណីយដ្ឋាន វប្បធម៌ប្រវត្តិសាស្ត្រវត្តភ្នំ ។

ជាលទ្ធផល នៃការបង្ក្រាបនេះ គណៈបញ្ជាការឯកភាពខណ្ឌដូនពេញ បានធ្វើការប្រមូលស្ត្រីរកស៊ីផ្លូវភេទរួមទាំងអ្នកគកដេរ(អ្នកចាប់ម៉ូយ)សរុបចំនួន១៣នាក់ ប្រុស០៣នាក់ បញ្ជូនមកនៅសាលាខណ្ឌដូនពេញ ដើម្បីឯកសារបញ្ជូនបន្តទៅ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ ៕

## ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវាដល់ជូនបងប្អូនពលករខ្មែរ

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 22-08-2019

នាថ្ងៃព្រហតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវាដល់ជូនបងប្អូនពលករខ្មែរ ឱ្យទទួលបាននៅក្នុងថ្ងៃតែមួយតែម្តង ដើម្បីជួយកាត់បន្ថយការចំណាយក្នុងការធ្វើដំណើររបស់បងប្អូនពលករ និងចំនួនថ្ងៃដែលបងប្អូនពលករត្រូវសុំច្បាប់ឈប់សម្រាកពីនិយោជក/ថៅកែ។ ឆ្លៀតឱកាសនេះផងដែរ មន្ត្រីស្ថានទូតបានពន្យល់ណែនាំដល់បងប្អូនពលករ ដែលមកទទួលសេវានៅស្ថានទូត អំពីច្បាប់ការងារ សិទ្ធិនិងអត្ថប្រយោជន៍ បម្រាម ទោសបញ្ញត្តិ និងការស្នើសុំជំនួយក្នុងករណីបងប្អូនពលករជួបប្រទះបញ្ហាផ្សេងៗក្នុងការស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ។

# ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៩

## លោក ហេង សំរិន បានថ្លែងពីការការពារសិទ្ធិជនជាតិខ្មែរដែលកំពុងធ្វើការចំណាកស្រុកនៅក្រៅប្រទេស

https://grandnewsasia.com/ 27-08-2019

លោក ហេង សំរិន ប្រធានរដ្ឋសភា បានជម្រាបមហាសន្និបាតអន្តរសភាអាស៊ាន ដែលហៅកាត់ AIPA ថា បច្ចុប្បន្នការប្រើប្រាស់កម្លាំងពលកម្មប្រកបដោយប្រសិទ្ធភាព ជាការចាំបាច់ និងជាតម្រូវការប្រទេសនីមួយៗ ដូច្នេះ ប្រទេសក្នុងតំបន់ទាំងអស់ត្រូវយកចិត្តទុកដាក់ ក្នុងការអនុវត្តប្រព័ន្ធគាំពារសង្គម ដើម្បីធានាថាពលករចំណាកស្រុកទាំងអស់ រួមទាំងក្រុមគ្រួសារពួកគេ ត្រូវបានការពារដោយច្បាប់ និងទទួលបានសេវាសាធារណៈ ដោយមិនរើសអើង។ ជាមួយគ្នានេះ លោក បានអរគុណចំពោះប្រទេសជាមិត្ត ដែលបានទទួលយកពលករកម្ពុជា មកបម្រើការងារក្នុងប្រទេសរបស់ខ្លួន។ លោកបានថ្លែងបែបនេះនៅក្នុងកិច្ចប្រជុំពេញអង្គ របស់មហាសន្និបាតអន្តរសភាអាស៊ាន AIPA នៅព្រឹកថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ក្រោមមូលបទ«ការលើកកម្ពស់ភាពជាដៃគូសភា ដើម្បីសហគមន៍ប្រកបដោយចីរភាព»។ លោក ហេង សំរិន ប្រធានរដ្ឋសភា ក៏បានបញ្ជាក់ថា ការងារការទូតសភា និងភាពជាដៃគូ ជាកត្តាសំខាន់មួយក្នុងកាលៈទេសៈបច្ចុប្បន្ន ដើម្បីជំរុញការអភិវឌ្ឍក្នុងតំបន់ និងពិភពលោកប្រកបដោយចីរភាព ហើយគ្មានប្រទេសណាមួយស្ថិតនៅឯកោ ដោយគ្មានទំនាក់ទំនងជាមួយប្រទេសដទៃទៀតឡើយ។

ជាមួយគ្នានេះដែរ លោកប្រធានរដ្ឋសភា បានស្នើដល់AIPA ត្រូវមានគោលជំហររួមមួយ ដែលមាននយោបាយស៊ីសង្វាក់គ្នា សេដ្ឋកិច្ចរួមគ្នាយ៉ាងជិតស្និទ្ធ និងមានការទទួលខុសត្រូវផ្នែកសង្គម រវាងផលប្រយោជន៍ជាតិ និងផលប្រយោជន៍តំបន់។ ការលើកកម្ពស់ពាណិជ្ជកម្ម និងវិនិយោគ ដែលជាកត្តាសំខាន់ចាំបាច់ យើងគួរលើកទឹកចិត្ត និងគាំទ្រដល់រដ្ឋាភិបាលនីមួយៗដើម្បីពន្លឿនការចរចាក្នុងការដាក់បញ្ចូលភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ឱ្យបានឆាប់ និងបន្តលើកកម្ពស់ការចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយដៃគូអន្តរជាតិនានា បន្ថែមទៀត។ នៅក្នុងបរិបទនៃជម្លោះពាណិជ្ជកម្មដែលកំពុងវិវឌ្ឍន៍ថ្មីៗនេះ កម្ពុជា សូមប្រកាន់ជំហរគាំទ្រប្រព័ន្ធពហុភាគីនិយម ផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិដែលផ្តល់ការការពារផលប្រយោជន៍ ដល់បណ្តាប្រទេសទាំងអស់ ដោយផ្អែកលើការគោរពការយោគយល់ និងការគិតគូផលប្រយោជន៍គ្នាទៅវិញទៅមក ដោយមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង អធិបតេយ្យភាព និងបូរណភាពដែនដី គឺជាមូលដ្ឋានគ្រឹះនៃសន្តិភាពប្រកបដោយចីរភាព។

កត្តាសន្តិភាព និងស្ថិរភាព គឺជាមូលដ្ឋានគ្រឹះមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍ ហើយផ្ទុយមកវិញការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងសមធម៌ ជាលក្ខខណ្ឌដ៏ចាំបាច់ក្នុងការធានានូវសុខសន្តិភាព និងស្ថិរភាពសង្គម។ ឈរលើមូលដ្ឋាននៃបទពិសោធន៍នេះ ប្រជាជាតិកម្ពុជាទាំងមូលផ្តល់តម្លៃខ្ពស់បំផុត ចំពោះការខិតខំបន្តថែរក្សាសន្តិភាព និងស្ថិរភាព ព្រមទាំងបន្តជំរុញកិច្ចអភិវឌ្ឍន៍ ប្រកបដោយបរិយាប័ន្ន ដែលបច្ចុប្បន្ននេះ កំពុងហុចផ្លែផ្កា ផ្តល់ផលប្រយោជន៍ ដល់ប្រជាពលរដ្ឋកម្ពុជា នៅគ្រប់ទិសទី។ ក្នុងន័យនេះ ដើម្បីឈានទៅសម្រេចបាននូវក្តីប្រាថ្នាដ៏សំខាន់របស់យើង ក្នុងការជំរុញភាពជាដៃគូ និងការអភិវឌ្ឍប្រកបដោយចីរភាព ដែលជាគោលការណ៍គ្រឹះ និងជាចំណុចស្នូលដ៏សំខាន់របស់អាស៊ាន ដើម្បីសម្រេចបាននូវសហគមន៍មួយ ដែលមានសមាហរណកម្មជិតស្និទ្ធនាពេលអនាគត៕

## ប្រមុខរាជរដ្ឋាភិបាលដាក់ចេញផែនការប្រែក្លាយពលករប្រើកម្លាំងទៅជាពលករដែលមានជំនាញ

https://www.information.gov.kh ចេញផ្សាយថ្ងៃទី 26 ខែសីហា ឆ្នាំ2019 វិទ្យុជាតិកម្ពុជា៖ ដោយ អ៊ី កនិកា

MC៖ ប្រមុខរាជរដ្ឋាភិបាល ដាក់ចេញផែនការប្រែក្លាយពលករប្រើកម្លាំងទៅជាពលករជំនាញ ដើម្បីស្របតាមយុទ្ធសាស្ត្រកំណើនថ្មីរបស់កម្ពុជា និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០។ យោងតាមសារលិខិត សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសប្រារព្ធទិវាអក្ខរកម្មជាតិ ៨កញ្ញា ឆ្នាំ២០១៩ នេះដោយបានណែនាំឲ្យក្រសួងអប់រំយុវជន និងកីឡាត្រូវមានផែនការប្រែក្លាយមជ្ឈមណ្ឌលសិក្សាពេញមួយចំនួន ដូចជាមជ្ឈមណ្ឌលសិក្សានៅតាមរោងចក្រ និងមជ្ឈមណ្ឌលអភិវឌ្ឍយុវជន ឲ្យក្លាយទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។ សារលិខិតបានបន្តទៀតថា ក្រសួងអប់រំយុវជន និងកីឡា ក៏ត្រូវសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដាក់ឲ្យដំណើរការ កម្មវិធីសមមូលកម្រិតអប់រំមូលដ្ឋានតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីផ្តល់ឱកាសសិក្សាដល់កម្មករទាំងនៅក្នុង និងក្រៅប្រទេសឲ្យមានលទ្ធភាពបន្តការសិក្សាតាមបែបអនឡាញ ឬតាមបែបឌីជីថល។ ជាមួយគ្នានេះដែរសមិទ្ធផលនៃការអនុវត្តកម្មវិធីអក្ខរកម្មទាំងនេះបានបង្ហាញឲ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងការចូលរួមគាំទ្រដោយចិត្តស្មោះពីអ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ជាពិសេសកិច្ចខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ មន្ទីរាជការ ព្រះសង្ឃ បញ្ញវន្ត ម្ចាស់រោងចក្រ សហគ្រាស សិស្ស និងនិស្សិតទូទាំងប្រទេស។

សារលិខិតបន្ថែមថា រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តជាផ្លូវការនូវគោលនយោបាយជាតិ ស្តីពីការសិក្សាពេញមួយជីវិតក្នុងគោលបំណង ផ្តល់ឱកាស និងគាំទ្រឲ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការសិក្សាគ្រប់រូបភាព និងប្រើប្រាស់ចំណេះដឹងតាមជំនាញដែលទទួលបាន ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ និងប្រាក់ចំណូលតាមយុគសម័យបច្ចេកវិទ្យា មនោគមន៍ និងព័ត៌មាន និងសង្គមពុទ្ធិ។

សូមបញ្ជាក់ថា នៅឆ្នាំ២០១៩នេះ ទិវាអក្ខរកម្មជាតិ ៨ កញ្ញា ត្រូវប្រារព្ធឡើងក្រោមប្រធានបទ អក្ខរកម្មផ្សារភ្ជាប់នឹងជំនាញមុខរបរ ដែលមានចក្ខុវិស័យអភិវឌ្ឍប្រជាពលរដ្ឋកម្ពុជាគ្រប់រូបឲ្យទទួលបានឱកាសសិក្សាពេញមួយជីវិតគ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់មធ្យោបាយ ប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងគុណសម្បត្តិសម្បទា ដើម្បីរួមចំណែកបង្កើនសេដ្ឋកិច្ចជាតិ និងសុខដុមជីវិតបុគ្គល និងសង្គម។ ទស្សនាទាននៃប្រធានបទនៅឆ្នាំនេះមិនសំដៅត្រឹមតែការរៀនអក្សរ និងលេខនព្វន្តប៉ុណ្ណោះទេ ប៉ុន្តែបានគិតគូរដល់ឱកាសសម្រាប់យុវជនយើងទទួលបានចំណេះដឹងចំណេះធ្វើ សហគ្រិនភាពជំនាញមុខរបរ និងនវានុវត្តន៍គ្រប់ផ្នែក គ្រប់វិស័យ ជាពិសេសអក្ខរកម្មបច្ចេកវិទ្យាដែលសព្វថ្ងៃកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស។

## ពលករត្រៀមទៅជប៉ុនម្នាក់បានដាក់ពាក្យបណ្តឹងឱ្យប៉ូលិសជួយអន្តរាគមន៍ខណៈមេខ្យល់នាំគូដណ្តឹងរបស់ខ្លួនទៅប្រទេសចិនបាត់

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 26/08/2019

ភ្នំពេញ ៖ យុវជនម្នាក់បានមកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍រដ្ឋបាលគីឡូម៉ែត្រលេខ៦ ដើម្បីឱ្យសមត្ថកិច្ចជួយអន្តរាគមន៍ហើយហៅស្ត្រីម្នាក់ដែលគេអះអាងជាបងស្រីរបស់មេខ្យល់ នោះមកសួនាំនៅប៉ុស្តិ៍ផងដែរ បន្ទាប់ពីមានមេខ្យល់ម្នាក់នាំគូដណ្តឹងរបស់ខ្លួនទៅប្រទេសចិនបាត់ ហើយទាក់ទងមិនបានដោយសង្ស័យថា មានមេខ្យល់បាននាំគូដ

ណ្ដឹងរបស់ខ្លួនទៅលក់នៅប្រទេសចិន ។ ហេតុការណ៍នេះផ្ទាក់ផ្អើលឡើងកាលពីម៉ោង១០នឹង៣០នាទីព្រឹកថ្ងៃទី២៤ ខែសីហាឆ្នាំ២០១៩នៅប៉ុស្តិ៍រដ្ឋបាលគីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ ។

បុរសខាងលើមានឈ្មោះ អ៊ុក សុជាតិអាយុ៣៣ឆ្នាំរស់នៅសង្កាត់គីឡូម៉ែត្រលេខ៦ ជាអតីតពលករកូរ៉េនិងកំពុងរៀនភាសារជប៉ុនត្រៀមទៅធ្វើពលករប្រទេសជប៉ុននៅខែ១២ឆ្នាំ២០១៩នេះ ចំណែកមេខ្យល់ដែលរងការចោទប្រកាន់នោះមានឈ្មោះ ថោង ស្រីរ័ត្នភេទស្រីអាយុជាង២០ឆ្នាំស្នាក់នៅមិនពិតប្រាកដ រីឯនារីរងគ្រោះដែលមេខ្យល់នាំទៅបាត់នោះឈ្មោះ ញ៉សុខចន្ទ័ហៅតក់ អាយុ២១ឆ្នាំរស់នៅភូមិអ្នកលឿន ឃុំរ៉ាក់ជ័យស្រុកបាភ្នំខេត្តព្រៃវែង ។ បើតាមការរៀបរាប់របស់បុរសជាពលករនោះ ថាខ្លួនបានស្គាល់នាងសុខច័ន្ទតាមរយៈការលេងហ្វេសប៊ុក ហើយស្រលាញ់គ្នាជាមួយ ញ៉សុខច័ន្ទប្រហែល៣ឆ្នាំមកហើយ ពេលនោះនាងជាកម្មកររោងចក្រចំណែកខ្លួនជាពលករនៅប្រទេសកូរ៉េ ។ ប្រភពបានរៀបរាប់ទៀតថា ក្រោយពីស្រលាញ់គ្នាល្អូកល្អឺនបាត់មុខមិនបាន ពេលមកពីកូរ៉េវិញខ្លួនថានឹងយកនាងជាគូអនាគតហើយចូលដណ្ដឹងនាងកាលពី១ឆ្នាំមុខ ។

ក្រោយមកយើងទាំង២នាក់ក៏បានសម្រេចចិត្តប្រឡងចូលរៀនភាសារជប៉ុនជាប់ទាំ២នាក់ ដើម្បីទៅធ្វើពលករនៅប្រទេសជប៉ុន តែខ្លួនគឺរៀនចប់មុនហើយត្រៀមទៅធ្វើពលករជប៉ុននៅខែ១២ឆ្នាំនេះ ចំណែកនាងសុខច័ន្ទគឺទៅជប៉ុននៅវគ្គបន្ទាប់ ហើយបីឆ្នាំក្រោយពេលត្រឡប់មកស្រុកវិញពួកយើងនឹងចូលតែម្ដង ។ បុរសរូបនោះបានបន្តថាស្រាប់តែគូដណ្ដឹងរបស់ខ្លួនបានទូរសព្ទ័មកតាមរយៈហ្វេសប៊ុក ថាគេកំពុងនៅប្រទេសវៀតណាមហើយអត់ផ្ទះសំណាក់ដេកទេ ដែលគេអះអាងថាទៅវៀតណាមតាំងពីថ្ងៃ២០សីហា ហើយគោលបំណងរបស់នាងគឺទៅប្រទេសចិនជាមួយឈ្មោះ ថោងស្រីរត័្នដើម្បីយកខោអាវមកលក់នៅភ្នំពេញ ប៉ុន្តែរហូតមកដល់ថ្ងៃទី២៤នេះខ្លួនមិនអាចទាក់គូដណ្ដឹងឬមេខ្យល់នោះបានទេ ដោយគេប្លុកហ្វេសប៊ុកខ្លួនចោលអស់ ហើយអ្វីដែលហួសចិត្តនោះដណ្ដឹងរបស់ខ្លួនមុនទៅចិននោះមិនបានប្រាប់ខ្លួនឬក្រុមគ្រួសារឱ្យនោះទេ ពេលទៅដល់វៀតណាមទើបតេប្រាប់រួចក៏បិទទូរសព្ទ័រហូតមកដល់ពេលនេះ ។ ដូច្នេះខ្លួនយល់ថានាងពិតជាចាញ់បោកគេមិនខានឡើយព្រោះនាងទៅនោះគ្មានលុយទេ ហើយហេតុអីគេល្អម្លេះហៅនាងទៅរកស៊ីជាមួយខ្លួនមិនជឿទេ ។ ជាមួយនឹងការដាក់ពាក្យបណ្ដឹងខ្លួនក៏បានស្គាល់ផ្ទះដួលបងស្រីបង្កើតរបស់ថោងស្រីរត័្នជាមេខ្យល់ ហើយក៏សំណូមពរឱ្យប៉ូលិសទៅហៅបងស្រីនោះមកប៉ុស្តិ៍ដើម្បីសួនាំនិងជួយទាក់ទងឱ្យប្អូនស្រីគាត់យកគូដណ្ដឹងរបស់ខ្លួនមកស្រុកវិញផងដែរ ។

តាមប្រភពព័ត៌មានពីអ្នកធ្លាប់ស្គាល់ស្ត្រីឈ្មោះ ថោង ស្រីរត័្ន ថានាងគឺជាអ្នកធ្លាប់រកស៊ីគកដេស្រីក្រមុំៗយកទៅឱ្យតាតាដែលមានលុយ ដើម្បីយុយក្រមុំ ដូច្នេះស្ត្រីឈ្មោះ ថោង ស្រវត័្ន គឺសមាសភាពមិនល្អទេ ទើបគេប្រញ៉ាប់ដាក់ពាក្យបណ្ដឹងឱ្យសមត្ថកិច្ចជួយអន្តរាគមន៍ ។

សមត្ថកិច្ចប៉ុស្តិ៍គីឡូម៉ែត្រលេខ៦ ឱ្យដឹងថា ពិតជាមានគេដាក់ពាក្យបណ្ដឹងរឿងនេះមែន តែរឿងហេតុជាក់ស្តែងយ៉ាងណា សមត្ថកិច្ចនឹងធ្វើការស្រាវជ្រាវបន្ត ៕

## ឃុំខ្លួនបុរសបរទេសម្នាក់ ករណីប្រព្រឹត្តអាស

https://www.postkhmer.com/ គឹម សារុំ | Publication date 26 August 2019 | 15:48 ICT

**សៀមរាបៈ** តុលាការខេត្តសៀមរាបកាលពីថ្ងៃទី ២៣ សីហា បានចោទប្រកាន់និងបញ្ជូនបុរសជាតិអាមេរិកាំងម្នាក់ទៅឃុំនៅពន្ធនាគារខេត្ត បន្ទាប់ពីសមត្ថកិច្ចចាប់ខ្លួនកាលពីថ្ងៃទី ២១ សីហា ពាក់ព័ន្ធអំពើបៀតបៀនផ្លូវភេទលើកុមារាម្នាក់ប្រព្រឹត្តកាលពីយប់ថ្ងៃទី ១៤ សីហានៅក្រុង-ខេត្តសៀមរាប។

លោក យិន ស្រាង អ្នកនាំពាក្យសាលាដំបូងខេត្តសៀមរាបប្រាប់កាលពីម្សិលមិញថា ករណីបុរសជនជាតិអាមេរិកឈ្មោះ Robinson Shaun Earl (ហៅ សន រី ហៅ ចន) អាយុ ៤០ ឆ្នាំដែលពាក់ព័ន្ធអំពើបៀតបៀនផ្លូវភេទលើកុមារា នោះត្រូវបានតុលាការចោទ និងឃុំខ្លួនហើយកាលពីថ្ងៃទី ២៣ សីហា តាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ស្តីពីការ

បង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ លោកថា៖ «ខ្ញុំមិនបានចាំថាចៅក្រមស៊ើបសួរមានឈ្មោះអីទេ ប៉ុន្តែជនជាតិអាមេរិកាំងម្នាក់នោះត្រូវបានចោទប្រកាន់ពីបទអំពើអាសប្រទាំងអនីតិជនក្រោមអាយុ ១៥ ឆ្នាំ តាមសំណើរបស់ព្រះរាជអាជ្ញា»។

បើតាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះ ប្រសិនបើតុលាការរកឃើញកំហុសមែននោះនឹងត្រូវជាប់ពន្ធនាគារពី ១ ឆ្នាំដល់ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀលដល់ ៦ លានរៀល។

បើតាមលោក ជា ហេង ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាល ខេត្តសៀមរាបប្រាប់កាលពីម្សិលមិញថាឈ្មោះ Robinson Shaun Earl ជាអ្នកទេសចរស្នាក់នៅបណ្តោះអាសន្ននៅក្នុងក្រុងសៀមរាប។ លោកបានបន្តថា ជនម្នាក់នេះត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ២១ សីហា ក្រោយពីមានបណ្តឹងពីស្រ្តីឈ្មោះ សាន់ យៀង អាយុ ៤១ ឆ្នាំ ត្រូវជាម្តាយក្មេងប្រុសរងគ្រោះដោយចោទថាបានប្រព្រឹត្តអំពើអាសលើកូនគាត់កាលពីយប់ថ្ងៃទី ១៤ សីហានៅក្នុងបន្ទប់ជួលម្ដុំផ្សារចាស់ក្នុងសង្កាត់ស្លក្រាម និងបានឲ្យលុយ ២៥ ដុល្លារនៅពេលព្រឹកឡើងថ្ងៃទី ១៥ សីហា ហើយឲ្យមកផ្ទះវិញ។ ចំណែកវត្ថុតាងដែលរកឆែកឃើញរួមមាន៖ Ipsy១ គ្រឿង, អង្គចងចាំ ១ គ្រឿង, ដៃហ្គេមក្មេងលេង ៣ គ្រឿង និងទឹកថ្នាំអិល ២ ដប៕

## ឪពុកម្តាយខ្ចីលុយឲ្យកូនធ្វើការនៅជប៉ុន ខណៈការព្រួយបារម្ភអំពីការរំលោភសិទ្ធិការងារនៅតែមាន

https://thmeythmey.com/ 26, Aug 2019 , 7:59 pm

ភូមិបែកពាង ខេត្តកំពង់ចាម ៖ នៅក្នុងភូមិបែកពាងនៃខេត្តកំពង់ចាម ក្រុមគ្រួសារមួយៗចង់ឲ្យកូនទៅធ្វើការនៅប្រទេសជប៉ុន ដោយឃើញកូនៗក្នុងក្រុមគ្រួសារដែលបានទៅ បានផ្ញើលុយមកឲ្យឪពុកម្តាយ និងជីវភាពមានភាពល្អប្រសើរ។ ប៉ុន្តែការជ្រើសរើសពលករទៅធ្វើការនៅប្រទេសជប៉ុននៅតែជាបញ្ហានៅឡើយ។ ភូមិបែកពាង ខេត្តកំពង់ចាម- កញ្ញា ជា សុគន្ធា អាយុ២២ឆ្នាំ និងកញ្ញា ជន ស្រីនាង អាយុ១៨ឆ្នាំ ដែលជាបងប្អូនជីដូនមួយនឹងគ្នា នឹងចេញទៅប្រទេសជប៉ុននៅសប្តាហ៍នេះ ដើម្បីធ្វើការនៅរោងចក្រពងមាន់ និងចម្ការបន្លែ។ រស់នៅក្នុងភូមិបែកពាង ឃុំជាលា ស្រុកបាធាយ ខេត្តកំពង់ចាម ចម្ងាយជាង៥០គីឡូម៉ែត្រពីរាជធានីភ្នំពេញ សុគន្ធាបានថ្លែងប្រាប់ VOA នៅផ្ទះថា នាងចេញទៅប្រទេសជប៉ុននៅថ្ងៃទី២៣ ខែសីហា ដើម្បីទៅធ្វើការនៅរោងចក្រដែលនាងទទួលខុសត្រូវផ្នែករើសពងមាន់ដាក់ក្នុងផៃ។ សុគន្ធាដែលបានឈប់រៀននៅថ្នាក់ទី៨ និងធ្លាប់ជាកម្មការិនីរោងចក្រកាត់ដេរនៅស្រុកកំណើត បាននិយាយថា នាងសម្រេចចិត្តទៅធ្វើការនៅប្រទេសជប៉ុនដោយសារឃើញអ្នកភូមិផ្សេងៗទៀតបានទៅធ្វើការនៅទីនោះ ហើយពួកគេអាចរកចំណូលផ្ញើមកក្រុមគ្រួសារ។

នាងបានថ្លែងថា៖ ព្រោះគិតទៅហ្នឹងវាអាចរកបានច្រើនជាងខ្មែរ។ អ៊ីចឹងអាចរកលុយចិញ្ចឹមម៉ែឪនៅផ្ទះបាន។ នេះជាលើកដំបូងហើយដែលសុគន្ធាចេញទៅក្រៅប្រទេស។ នាងបានបញ្ជាក់ថា៖ «មានអារម្មណ៍ថា រំភើប អត់ដែលនឹកស្មានថា បានទៅ!»។ សុគន្ធាមានគម្រោងធ្វើការថែមម៉ោងឲ្យបានច្រើនដើម្បីអាចរកចំណូលឲ្យក្រុមគ្រួសារបន្ថែមលើប្រាក់ខែជាង១ពាន់ដុល្លារ។ នាងបញ្ជាក់ថា៖ «ចង់ថែមម៉ោងឲ្យច្រើន មូលហេតុចង់បានលុយច្រើន ព្រោះយើងទៅដើម្បីរកលុយ។ ពេលអ៊ីចឹងត្រូវតស៊ូថែមម៉ោងថែមអី»។ បើតាមសុគន្ធា នាងសង្ឃឹមថា នឹងអាចផ្ញើប្រាក់មកផ្ទះយ៉ាងតិច៥០០ដុល្លារក្នុងមួយខែ។

បងប្អូនជីដូនមួយរបស់សុគន្ធាគឺនាង ជន ស្រីនាង ក៏យល់ស្រដៀងគ្នាដែរ។ ស្រីនាង ដែលបានឈប់រៀនថ្នាក់ទី៩ និងជាអតីតកម្មការិនីរោងចក្រកាត់ដេរបាននិយាយថា នាងមិនបារម្ភអំពីសុវត្ថិភាព ឬគិតពីការរំលោភបំពានសិទ្ធិការងារនៅទីនោះទេ ដោយសារពលរដ្ឋនៅក្នុងភូមិរបស់នាងបានទៅធ្វើការនៅទីនោះហើយពួកគេមិនបានបង្ហាញការព្រួយបារម្ភអ្វីទេ។ នៅប្រទេសជប៉ុន ស្រីនាង នឹងធ្វើការក្នុងចម្ការដោយដាំដំឡូងឆ្វា និងឆៃថាវ។ ស្រីនាង បានថ្លែង

ប្រាប់ VOA នៅចំពោះមុខឪពុកម្ដាយ និងយាយរបស់កញ្ញាថា៖ «អាចធ្វើបាន បើសិស្សច្បងខ្ញុំគាត់ឡើងទៅ គាត់ថាស្រួលហ្នឹង ធ្វើហ្នឹងម៉ាស៊ីន»។ បើតាមសុគន្ធា និងស្រីនាង មុនពេលចាកចេញទៅប្រទេសជប៉ុន ពួកគេត្រូវឆ្លងកាត់ការបណ្ដុះបណ្ដាលប្រមាណ៩ខែ ដោយក្រុមហ៊ុនជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស។ ពួកគេបានចំណាយប្រាក់ក្នុងមួយនាក់ចំនួន៣៥០០ដុល្លារអាមេរិក បង់ឲ្យក្រុមហ៊ុនសម្រាប់ការបណ្ដុះបណ្ដាល រៀបចំឯកសារ ទិញសំបុត្រយន្តហោះ និងធ្វើលិខិតឆ្លងដែនជាដើម។

ប្រជាពលរដ្ឋនៅក្នុងភូមិមួយនេះតែងតែចង់ឲ្យកូនទៅធ្វើការនៅប្រទេសជប៉ុនក្រោយដឹងថា អ្នកភូមិមួយចំនួនដែលធ្វើការនៅទីនោះអាចផ្ញើប្រាក់មកគ្រួសាររបស់ពួកគេ និងជីវភាពគ្រួសារមានភាពល្អប្រសើរ។

ឪពុកម្ដាយបានខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុរាប់ពាន់ដុល្លារដើម្បីឲ្យកូនបានចេញទៅក្រៅប្រទេស។ ឪពុករបស់កញ្ញាសុគន្ធាគឺលោកសុខ សាវន អាយុ៤២ឆ្នាំ ធ្វើជាទាហាន និងលក់នំចំណីបន្តិចបន្តួចខាងមុខផ្ទះ។ លោកមានប្រសាសន៍ថា លោកបានយកប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រមាណ៥ពាន់ដុល្លារដើម្បីចំណាយឲ្យកូនរៀបចំទៅប្រទេសជប៉ុន។ លោកត្រូវបង់សងក្នុងរយៈពេលបីឆ្នាំ។ លោកមានប្រសាសន៍ថា លោកទុកចិត្តក្រុមហ៊ុនដែលបញ្ជូនកូនលោកទៅប្រទេសជប៉ុន។ លោកបានថ្លែងថា៖ «យើងបញ្ជាក់នឹងក្រុមហ៊ុនហ្នឹង ហើយសួរម្ដាយមីងដែលនៅហ្នឹងគាត់ថា អត់អីដែរ។ យើងក៏ហ៊ានជានាទុកចិត្តនឹងក្រុមហ៊ុនដែរ»។

ចំណែកលោក ធុយ ឌី អាយុ៤០ ជាឪពុករបស់ ស្រីនាង មានប្រសាសន៍ថា លោកនៅតែបារម្ភអំពីសុវត្ថិភាព និងសុខទុក្ខកូនពេលទៅទីនោះ ព្រោះជាដំណើរចេញទៅក្រៅប្រទេសលើកដំបូងរបស់នាង។ លោកបានថ្លែងប្រាប់ VOA ថា៖ «ព្រួយបារម្ភ! ព្រួយបារម្ភខ្លះដែរហ្នឹង។ ការធ្វើដំណើរ ហើយទៅដល់ប្រទេសគេ មិនដឹងម៉េចម៉ា ព្រោះយើងមិនដែលបានទៅ»។

បច្ចុប្បន្នមានពលករកម្ពុជាធ្វើការនៅប្រទេសជប៉ុនចំនួនជាង ៩.០០០នាក់ ក្រោមកម្មវិធីធ្វើកម្មសិក្សា។ ប្រទេសជប៉ុន និងកូរ៉េខាងត្បូងត្រូវបានគេមើលឃើញថាជាប្រទេសមួយដែលពលករខ្មែរអាចរកចំណូលផ្ញើមកគ្រួសារច្រើនជាងប្រទេសដទៃ។

ប្រជាពលរដ្ឋផ្សេងទៀតនៅក្នុងភូមិបែកពាងនេះ ក៏បានសម្រេចចិត្តឲ្យកូនទៅធ្វើការនៅប្រទេសជប៉ុនផងដែរ ហើយពួកគេបានសល់លុយមួយចំនួនដែលកូនផ្ញើឲ្យ។ អ្នកភូមិម្នាក់លោក សួន គឿន អាយុ៦៩ឆ្នាំ មានប្រសាសន៍ថា ជីវភាពរបស់គ្រួសារមានភាពល្អប្រសើរជាងមុន ក្រោយកូនស្រីពីរនាក់របស់លោកបានទៅធ្វើការនៅប្រទេសជប៉ុន។ លោកបានថ្លែងប្រាប់ VOA នៅផ្ទះរបស់លោកថា៖ «វាមិនធូរណាស់ណាទេ។ វាគ្រាន់ដោះបំណុលគេចាស់បានរួចខ្លះ ហើយការហូបចុកខ្លួនយើង។ ឈឺស្កាត់យប់ព្រលប់អី វាមាននៅក្នុងខ្លួនខ្លះ។ វាមិនពិបាកដូចមុន។ មុនយើងមានការអីយប់ព្រលប់ ឈឺស្កាត់យប់ព្រលប់អី យើងពិបាករត់រកលុយគេក្រៅភ្លាមៗ រត់មិនទាន់ចិត្ត»។ ភរិយារបស់លោក សួន គឿន គឺអ្នកស្រី ឡុង រឿន មានប្រសាសន៍ថា ពីដំបូងឡើយអ្នកស្រីព្រួយបារម្ភខ្លាចកូនត្រូវគេបោកយកទៅលក់ ដោយសារធ្លាប់ឮគេនិយាយពីការធ្វើបាបកម្មករខ្មែរនៅក្រៅប្រទេស។ អ្នកស្រីមានប្រសាសន៍ថា៖ «ពីមុន ខ្ញុំឃាត់អត់ឲ្យទៅមែន! អត់ឲ្យទៅខ្លាច! ដូចថា ខ្លាចគេយកទៅលក់ ទៅដូរអីចឹងណ៎ា។ ដល់ពេលឃើញគេទៅលាន់ៗ អត់អី»

ចំណែកអ្នកភូមិម្នាក់ទៀតគឺអ្នកស្រី សេង ណយ អាយុ៥៨ឆ្នាំ មានកូនស្រីចំនួនពីរនាក់ទៅប្រទេសជប៉ុន។ អ្នកស្រីដែលមានកូន៦នាក់ក៏មានបំណងបញ្ជូនកូន២នាក់ទៀតទៅធ្វើការនៅប្រទេសជប៉ុននៅពេលខាងមុខ ខណៈពួកគេទើបរៀនថ្នាក់ទី១០ និងថ្នាក់ទី៤។ អ្នកស្រីបានថ្លែងថា៖ «ខ្ញុំអត់បង្ខំកូនទេ ប៉ុន្តែកូនវាចង់ទៅខ្លួនវា។ បើមួយៗវាថា ឲ្យតែរៀនចប់ វាទៅហើយ»។

នៅក្នុងភូមិពាងបែក ឃុំជាលា ខេត្តកំពង់ចាម ប្រជាពលរដ្ឋពេញកម្លាំងតែងតែធ្វើជាកម្មករកាត់ដេរ និងកម្មករសំណង់។ ចំពោះចាស់ៗ ពួកគេតែងតែធ្វើស្រែចម្ការសម្រាប់ជីវភាពរបស់ពួកគេ។ ប៉ុន្តែពួកគេត្អូញត្អែរថា ឆ្នាំនេះមិន

អាចធ្វើស្រែបានផលល្អនោះទេ ដោយសារកង្វះទឹក។ ចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសជាជម្រើសសំខាន់មួយសម្រាប់ពលរដ្ឋនៅក្នុងភូមិមួយនេះ។

លោក ជិន លី មេភូមិបែកពាងមានប្រសាសន៍ថា ប្រជាពលរដ្ឋមួយចំនួនបានចំណាកស្រុកទៅប្រទេសផ្សេងៗ ដូចជាប្រទេសកូរ៉េ និងជប៉ុន ហើយពួកគេបានខ្ចីលុយពីមីក្រូហិរញ្ញវត្ថុដើម្បីឲ្យកូនបានទៅប្រទេសជប៉ុន។ លោកបន្តថា ជីវភាពគ្រួសាររបស់ពួកគេមានភាពល្អប្រសើរឡើង ក្រោយមានកូនទៅធ្វើការនៅប្រទេសជប៉ុន។

លោកឌី ថេហូយ៉ា មន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស(Central)មានប្រសាសន៍ថា ការជ្រើសរើសពលករខ្មែរទៅធ្វើការនៅប្រទេសជប៉ុននៅតែជាបញ្ហានៅឡើយ ដោយសារមានករណីខ្លះ សាលាបណ្តុះបណ្តាលភាសាជប៉ុនបានដើរតួនាទីក្នុងការជ្រើសរើសពលករ ហើយមានករណីខ្លះពលករបានចំណាយលុយ ហើយមិនបានចេញទៅប្រទេសជប៉ុន។ លោកបានថ្លែងថា៖ «ក្នុងកាលៈទេសៈនេះ មានក្រុមហ៊ុនមួយចំនួនក៏ដូចជាសាលាមួយចំនួន បន្លំខ្លួនបើកសាលា បន្លំជ្រើសរើស[ពលករ]អីចឹងទៅ។ អ្នកខ្លះយកលុយគេ១ពាន់២ពាន់ដុល្លារ គ្នាមិនបានទៅអីជាដើម»។ លោកបន្តថា នៅឆ្នាំនេះ អង្គការរបស់លោកក៏ទទួលបានករណីដែលពលរដ្ឋខ្មែរជាង១០០បានរងគ្រោះដោយសារក្រុមហ៊ុនមិនបានបញ្ជូនទៅប្រទេសជប៉ុនតាមការសន្យា។

កាលពីចុងឆ្នាំ២០១៧ កាសែតភ្នំពេញប៉ុស្តិ៍បានចេញផ្សាយអត្ថបទមួយថា ប្រជាជន១១នាក់ បានចេញមុខតវ៉ា ដោយពួកគេអះអាងថា ត្រូវបានក្រុមហ៊ុនយកលុយរាប់ពាន់ដុល្លារ ហើយពួកគេមិនបានចេញទៅប្រទេសជប៉ុនតាមការសន្យា។

បើតាមលោកឌី ថេហូយ៉ា តម្លៃក្នុងការជ្រើសរើសពលករទៅធ្វើការនៅប្រទេសជប៉ុនក៏នៅថ្លៃនៅឡើយគឺរហូតដល់៦ពាន់ដុល្លារ ដែលលោកថា ពលរដ្ឋខ្មែរបានបង្ខំចិត្តខ្ចីប្រាក់គេដើម្បីរៀបចំឲ្យកូនទៅធ្វើការនៅប្រទេសជប៉ុន។

បើតាមទិន្នន័យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះខែសីហា ឆ្នាំ២០១៩ ទីភ្នាក់ងារឯកជនដែលមានសិទ្ធិជ្រើសរើសពលករទៅធ្វើការនៅប្រទេសជប៉ុនមានចំនួន១០២ក្រុមហ៊ុន។

កន្លងទៅ រដ្ឋាភិបាលជប៉ុនក៏បានរកឃើញក្រុមហ៊ុនដែលយកពលករទៅធ្វើការនៅប្រទេសនានា បានរំលោភសិទ្ធិការងារ ក្នុងនោះមានបង្ខំឲ្យធ្វើការជាច្រើនម៉ោង ការផ្តល់ប្រាក់កម្រៃតិចជាងកម្រិតអប្បបរមាដែលច្បាប់តម្រូវ បង្ខំឲ្យធ្វើការលើសម៉ោង និងកន្លែងធ្វើការមិនត្រូវតាមនិយាមសុវត្ថិភាព។

កាលពីខែមីនា ឆ្នាំ២០១៩ ប្រទេសកម្ពុជា និងជប៉ុនបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការបញ្ជូនពលករជំនាញទៅធ្វើការដោយស្របច្បាប់ និងជាការបង្កើនទីផ្សារការងារ និងឱកាសដល់ពលករកម្ពុជា។ ពលករជំនាញទាំងនោះនឹងធ្វើការនៅផ្នែកថែទាំមនុស្សចាស់ សម្អាតអគារ ផលិតគ្រឿងបន្លាស់ គ្រឿងរថយន្ត គ្រឿងអគ្គិសនី និងសំណង់ជាដើម។

កញ្ញា សុគន្ធា ដែលសម្រេចចិត្តទៅធ្វើការនៅប្រទេសជប៉ុន និយាយថា កញ្ញាមិនព្រួយបារម្ភអ្វីនោះទេ បើទោះជាមិនធ្លាប់ទៅក្រៅប្រទេស ហើយចាត់ទុកថា នេះជាការចេញដំណើរទៅធ្វើការងាររកលុយដើម្បីដោះបំណុលគ្រួសារ។ កញ្ញាបានបញ្ជាក់ថា៖ «មើលទៅអត់ផង! មានសិស្សច្បងនៅហ្នឹង! គាត់អត់មានអីផង! គាត់ថាធ្វើការនៅហ្នឹងស្រួល ហើយថៅកែក៏ស្រួលដែរ។ ពេលអ៊ីចឹង អត់មានអារម្មណ៍ថា ភ័យផង»៕

## បង្ក្រាបហាងស្រាក្រឡុក ប៉ាន់នីបារ បង្កប់សេវាផ្លូវភេទនៅសង្កាត់វត្តភ្នំ ឃាត់ខ្លួន១១នាក់

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 27 August, 2019

ភ្នំពេញ ៖ កម្លាំងនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន បានសហការជាមួយកម្លាំងនគរបាលមូលដ្ឋានខណ្ឌដូនពេញ ចុះបង្ក្រាបទីតាំងបារ លួចលាក់បង្កប់សេវាកម្មផ្លូវភេទ(ឃីហោ ប៉ាន់នី បារ) ដោយធ្វើការឃាត់ខ្លួនមនុស្សប្រុស-ស្រី១១នាក់ (ក្នុងនោះមាននារីបម្រើភ្ញៀវជាស្រីក្មេង៨នាក់ មេការ២នាក់ (ស្រី-ប្រុស)និងថៅកែហាង១នាក់។

ក្នុងប្រត្តិបត្តិការណ៍ខាងលើនេះ បានធ្វើឡើងកាលពីវេលាម៉ោង៨ និង៣០នាទីយប់ ថ្ងៃ២៦ ខែសីហា ឆ្នាំ២០១៩ នៅចំណុច បារមួយកន្លែង (យីហោ បាន់នី បារ) ផ្ទះលេខ៩E០ ផ្លូវលេខ១០៤ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ការប្រត្តិបត្តិការនេះដឹកនាំទី១/ដោយលោក ឧត្តមសេនីយ៍ទោ សំបូរ មាណ្ណារិទ្ធ អនុប្រធាននាយកដ្ឋានប្រឆាំការជួញដូរមនុស្ស។ ទី២ /វីរសេនីយ៍ឯក ជាន វុធ នាយការិយាល័យប្រឆាំការជួញដូរមនុស្សក្នុងប្រទេស។ ទី៣/អនុសេនីយ៍ឯក ឡាង ណារី អ្នកកតត្រា។ ទី៤/អនុសេនីយ៍ទោស ឃឹម មករា នាយរងប៉ុស្តិ៍វត្តភ្នំ។ ទី៥/លោក សេង គីមឡាក់ ព្រះរាជអាជ្ញារង។ ទី៦/ លោក ចេង សុផាត ក្រឡាបញ្ជី។ ទី៧/លោកស្រី នួន គន្ធា ប្រធានក្រុម៨។ និងទី៨/ លោក ឈុស សុធី ចៅសង្កាត់រងទី២។

បើតាមមន្រ្តីនគរបាល ដែលចុះបង្រ្កាបផ្ទាល់ដែលនោះ បានឲ្យដឹងថា មុនឈានដល់ការចុះបង្រ្កាប គឺមានការរាយការណ៍ដោយសម្ងាត់ ពីបងប្អូនប្រជាពលរដ្ឋប្រាប់ថា (ទីតាំងបារដែលមាន យីហោ បាន់នី បារ ) ខាងលើមានលួចបើកសេវាកម្មបម្រើផ្លូវភេទ និងមានបុគ្គលិកជា អនិតិជន(អាយុក្រោម១៥ឆ្នាំ)បម្រើការងារ ។ ទើបកម្លាំងនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន បានចុះធ្វើការស៊ើបអង្កេតអស់រយះពេលជាយូរមកហើយ ទើបនៅថ្ងៃកើតហេតុ បានសហការជាមួយកម្លាំង សមត្ថកិច្ចមូលដ្ឋាន បើកការបង្រ្កាបតែម្តង ។ ក្នុងប្រតិបត្តិការបង្រ្កាប និងឆែកឆេរ ទីតាំង លួចលាក់ បង្កប់ សេវាផ្លូវ ភេទ នេះ ជាលទ្ធផលជាក់ស្តែង កម្លាំងនគរបាលបាន ធ្វើការ ឃាត់ខ្លួនមនុស្សសរុបចំនួន១១នាក់ ក្នុងនោះមាននារីចំនួន៩នាក់ និងបុរសបរទេស២នាក់មេការ១នាក់ ក្នុងនោះមាន ម្ចាស់ហាង មានឈ្មោះ ចន អាយុ៧១ឆ្នាំ១នាក់។

បច្ចុប្បន្ន ក្រោយពេលបង្រ្កាប ជនប្រុសស្រីទាំង១១នាក់នាក់ ដោយនារីបម្រើការងារ៩នាក់ មេការ១នាក់ និងម្ចាស់ទីតាំងម្នាក់ ត្រូវបានឃាត់ខ្លួននិងបញ្ជូនទៅ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន ដើម្បីរងចាំធ្វើការសាកសួរ បន្តតាមនីតិវិធី ៕

## នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បើកវគ្គបណ្តុះបណ្តាលស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

http://cambodiapolice.com/policekh/ 12:47 pm 26 សីហា 2019

**ភ្នំពេញ ៖** ក្រោមការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានបើកវគ្គបណ្តុះបណ្តាលស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នាព្រឹកថ្ងៃចន្ទ ១១រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។

មានប្រសាសន៍ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនេះដែរ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានមានប្រសាសន៍ថា ក្នុងវគ្គបណ្តុះបណ្តាលនេះ មានការទាក់ទង នឹងការស៊ើបអង្កេតទូទៅ និងការស៊ើបអង្កេតប្រមូលភស្តុតាង ការកសាងសំណុំរឿង ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីកសាងសំណុំរឿងទៅតុលាការ។ ឯកឧត្តម បានបន្តថា វគ្គបណ្តុះបណ្តាលនេះ ត្រូវបានឧទ្ទេសនាមដោយគ្រូដែលអញ្ជើញមកពីសហរដ្ឋអាមេរិច ដែលគាត់មានចំណេះដឹង និងបទពិសោធន៍ច្រើន ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសការសង្គ្រោះជនរងគ្រោះពីអំពើរំលោភបំពានផ្លូវភេទលើកុមារ ក៏ដូចជាអំពើធ្វើអាជីវកម្មផ្លូវភេទ ហេតុដូចនេះហើយវាគឺជាបទពិសោធន៍ ដែលត្រូវចែករំលែកទៅវិញទៅមកក្នុងរយៈពេលក្នុងវគ្គបណ្តុះបណ្តាលនេះ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់ដែរថា ការចូលរួមចែករំលែកបទពិសោធន៍ និងចំណេះដឹងតាមរយៈការបណ្តុះបណ្តាលនេះ អាចនឹងយកទៅបម្រើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីក្នុងគោលបំណងតែមួយគឺ ចាប់ជនប្រព្រឹត្តបទល្មើសយកមកផ្តន្ទាទោសតាមច្បាប់ និងកាត់បន្ថយអំពើជួញដូរមនុស្សក្នុងប្រទេសកម្ពុជា ព្រមទាំងអាចធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រទេសពាក់ព័ន្ធក្នុងតំបន់ ក៏ដូចជានៅលើពិភពលោក។ ឯកឧត្តម ក៏បានសំណូមដល់សិក្ខាកាមទាំងអស់ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ សូមយកចិត្តទុកដាក់ស្តាប់ ចូលរួមចែករំលែកបទពិសោធន៍ទៅវិញទៅមក ក្នុងគោលបំណងដើម្បីទទួលបានចំណេះដឹង ចំណេះធ្វើ ហើយអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ។ ឆ្លៀតក្នុងឱកាសនេះដែរ ឯកឧត្តមប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក៏បានថ្លែងអំណរគុណដល់អង្គការ DR ដែលបានឧបត្ថម្ភគាំទ្រ និងផ្តួចផ្តើមឲ្យមានវគ្គបណ្តុះបណ្តាលនេះលើកទីមួយ ហើយនឹងសង្ឃឹមមានការវគ្គបណ្តុះបណ្តាលនេះបន្តទៀត ជាពិសេសបើមានវគ្គបណ្តុះបណ្តាលសូមបន្ថែមលើបទល្មើសតាមប្រព័ន្ធ Online ផងដែរ៕

## ចាប់ខ្លួនជនជាតិអាមេរិកម្នាក់ ពីបទរំលោភបំពានផ្លូវភេទលើកុមារ នៅទីក្រុង Los Angeles រដ្ឋកាលីហ្វូញ៉ា

http://cambodiapolice.com/policekh/ 11:54 am 26 សីហា 2019

**ភ្នំពេញ** ៖ កម្លាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយកម្លាំងនាយកដ្ឋានស៊ើបការខាងក្រៅ និងបច្ចេកទេស និងកម្លាំងការិយាល័យសន្តិសុខប្រចាំតំបន់របស់ស្ថានទូតសហរដ្ឋអាមេរិក (RSO) នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៩ បានអនុវត្តដីការដ្ឋកាលីហ្វូញ៉ា ចាប់ខ្លួនជនល្មើសឈ្មោះ Karl Von Boenninghausen ភេទប្រុស ជនជាតិអាមេរិក កើតថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៥៣ កាន់លិខិតឆ្លងដែនលេខ 566522458 ពីបទរំលោភបំពានផ្លូវភេទលើកុមារ នៅទីក្រុង Los Angeles រដ្ឋកាលីហ្វូញ៉ា សហរដ្ឋអាមេរិក។

លោកវរសេនីយ៍ឯក លៅ លីន នាយការិយាល័យការពារអនីតិជន បានប្រាប់គេហទំព័រ និងព័ត៌មានអគ្គស្នងការដ្ឋាននគរបាលជាតិ នៅព្រឹកថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩នេះ ថា កម្លាំងនាយកដ្ឋានស៊ើបការខាងក្រៅ និងបច្ចេកទេស បានឃាត់ខ្លួនជនល្មើសឈ្មោះ Karl Von Boenninghausen នៅផ្ទះសំណាក់ happy ស្ថិតនៅក្បែរវត្តសារាវ័ន្ត ខណ្ឌដូនពេញ រាជធានីភ្នំពេញ រួចបញ្ជូនមក នាយកដ្ឋានប្រឆាំងជួញដូរមនុស្សនិងការពារអនីតិជន ហើយប្រតិបត្តិការនេះ ធ្វើឡើងដោយមានការសម្របសម្រួលពីព្រះរាជអាជ្ញា នៃសាលាដំបូងរាជធានីភ្នំពេញ។

បច្ចុប្បន្ននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កំពុងបន្តអនុវត្តនីតិវិធីបញ្ជូនជនល្មើស និងសម្ភារៈដកហូតទាំងអស់ទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីអនុវត្តនីតិវិធីបន្ត៕

## កម្ពុជា-វៀតណាម-ឡាវ បន្តជំរុញអភិវឌ្ឍន៍ តំបន់ត្រីកោណ ដើម្បីទប់ស្កាត់បញ្ហាអសកម្មមួយចំនួន

https://www.dap-news.com/archives/ ByID:112 Posted on 27 August 2019 | 11:07

ភ្នំពេញ ៖ គណៈកម្មការជំនាញ របស់រដ្ឋសភា នៃប្រទេសកម្ពុជា-វៀតណាម និងឡាវ ព្រមទាំងភាគីពាក់ព័ន្ធបានបន្តជំរុញឲ្យមានការអភិវឌ្ឍ តំបន់ត្រីកោណ ដើម្បីចែករំលែក និងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ពីគ្នាទៅវិញទៅមក ដើម្បីដោះស្រាយឲ្យបានទាន់ពេល និងមានប្រសិទ្ធភាពនូវបញ្ហា មិនប្រក្រតីមួយចំនួន។ បញ្ហាទាំងនោះរួមមាន បញ្ហាសន្តិសុខ ការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស ការលាងលុយកខ្វក់ និងការកាប់បំផ្លាញព្រៃឈើខុសច្បាប់ជាដើម ។ ក្នុងនោះក៏ត្រូវបន្តខិតខំស្វែងរក និងលើកទឹកចិត្តដើម្បីទាក់ទាញ វិនិយោគទុនបរទេស និងកៀរគរមូលនិធិបន្ថែមទៀត ពីដៃគូអភិវឌ្ឍន៍នានា ដើម្បីអភិវឌ្ឍន៍តំបន់ត្រីកោណលើហេដ្ឋារចនា

សម្ព័ន្ធរឹងនិងទន់ ជាពិសេសការអភិវឌ្ឍធនធានមនុស្ស និងបណ្តាញគមនាគមន៍ ។ នេះបើតាមការលើកឡើង របស់តំណាងប្រទេសទាំង៣ ក្នុងកិច្ចប្រជុំលើកទី៤រវាងគណៈកម្មការ-គណៈកម្មាធិការការពារជាតិ និងសន្តិសុខរបស់រដ្ឋសភា នៃប្រទេសកម្ពុជា ឡាវ និងវៀតណាម នៅសណ្ឋាគារសុខា នាព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩។

ក្នុងឱកាសនោះ លោកបណ្ឌិត ងួន ញ៉ិល ប្រធានស្តីទីរដ្ឋសភា បានបញ្ជាក់ថា វិស័យសន្តិសុខ និងការពារជាតិ មានសារៈសំខាន់ និងចាំបាច់បំផុតក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ នៅគ្រប់កាលៈទេសៈ។ លោកបណ្ឌិតក៏ឲ្យបន្តពង្រឹង លើកកម្ពស់តាមដានត្រួតពិនិត្យការអនុវត្តច្បាប់ និងគោលនយោបាយពាក់ព័ន្ធនានា ដើម្បីរួមចំណែកដល់ការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ សំដៅទប់ស្កាត់រាល់បទឧក្រិដ្ឋឆ្លងដែននានា ធានាបាននូវសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋ វិនិយោគិន និងធុរៈជនទាំងឡាយ ព្រមទាំងលើកកម្ពស់កម្រិតជីវភាព យុត្តិធម៌ សង្គមឲ្យប្រជាពលរដ្ឋនៅតំបន់ត្រីកោណអភិវឌ្ឍន៍។ លោកក៏បន្តជំរុញលើកទឹកចិត្ត និងគាំទ្រដល់រដ្ឋាភិបាលនៃប្រទេសទាំង៣ ពង្រឹងចំណងមិត្តភាព សាមគ្គីភាព និងសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ក្នុងការកៀរគរធនធានដើម្បីពន្លឿនការអភិវឌ្ឍតំបន់ត្រីកោណ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាជន និងដើម្បីប្រជាជន។

លោកបណ្ឌិត ងួន ញ៉ិល ក៏បានលើកទឹកចិត្តដល់តំណាងរាស្ត្រ ជាពិសេសតំណាងរាស្ត្រនៃខេត្តទាំង១៣ នៅតំបន់ត្រីកោណអភិវឌ្ឍន៍ដែលជាអ្នកនៅផ្ទាល់ជាមួយប្រជាពលរដ្ឋបន្តពង្រឹង និងបង្កើនទំនាក់ទំនងរវាងគ្នាឲ្យកាន់តែជិតស្និទ្ធថែមទៀត ដើម្បីលើកកម្ពស់តួនាទីភាពជាតំណាង ក្នុងការពាំនាំនូវបញ្ហាប្រឈម និងក្តីកង្វល់នានាដែលប្រជាពលរដ្ឋ នៅទីនោះបានកំពុងជួបប្រទះ សំដៅអន្តរាគមន៍ និងដោះស្រាយទាន់ពេលវេលា៕

## មន្ទីរឈប់ទទួលស្គាល់ មជ្ឈមណ្ឌលបង្រៀនពលករនៅធ្វើការនៅជប៉ុនមួយ

https://www.postkhmer.com/ ខន សាវិ | Publication date 27 August 2019 | 10:33 ICT

**ភ្នំពេញៈ** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញបានសម្រេចកាលពីថ្ងៃទី ២១ ខែ សីហា ដោយឈប់ទទួលស្គាល់មជ្ឈមណ្ឌលបណ្តុះបណ្តាលការងារកម្ពុជាអន្តរជាតិ (ជំនួយហត្ថា) ដែលបានចុះបញ្ជិកាជាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកាលពីខែ ធ្នូ ឆ្នាំ ២០១៧ និងសាខាផ្សេងៗទៀត ដោយសារធ្វើសកម្មភាពមិនបានសុំការអនុញ្ញាតពីក្រសួង។ សេចក្តីសម្រេចនេះបន្តថា មជ្ឈមណ្ឌលនេះត្រូវតែបញ្ឈប់សកម្មភាពបណ្តុះបណ្តាល និងឃោសនាផ្សេងៗ ដើម្បីជ្រើសរើស និងបញ្ជូនសិក្ខាកាមទៅប្រទេសជប៉ុន។ លើសពីនេះ មជ្ឈមណ្ឌលក៏ត្រូវទទួលខុសត្រូវដោះស្រាយរាល់សំណងទាំងអស់ទៅឱ្យសិក្ខាកាមវិញគ្រប់ចំនួន ទៅតាមចំនួនជាក់ស្តែងផងដែរ។ សេចក្តីសម្រេចនេះបញ្ជាក់ថា៖ «ប្រធានការិយាល័យរដ្ឋបាលបុគ្គលិក និងផែនការ ប្រធានការិយាល័យបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់អង្គភាពពាក់ព័ន្ធ និងនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលការងារកម្ពុជាអន្តរជាតិ (ជំនួយហត្ថា) ត្រូវមានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ»។

លោក ជួន វុឌ្ឍី ប្រធានមន្ទីរការងាររាជធានីភ្នំពេញបានប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា ការបិទមជ្ឈមណ្ឌលនេះគឺដោយសារបានធ្វើសកម្មភាពដោយមិនសុំច្បាប់ទៅក្រសួងការងារជាមុន ប៉ុន្តែលោកថា មជ្ឈមណ្ឌលនេះអាចដំណើរការឡើងវិញ ប្រសិនបើទៅសុំការអនុញ្ញាតពីក្រសួង។ លោកថា៖ «ដោយសារមិនសុំគោលការណ៍ពីក្រសួង ដូច្នោះក្រសួងបញ្ជាឱ្យបិទជាបន្ទាន់ ហើយបើគាត់ចង់តវ៉ាអីគាត់ទៅតវ៉ានៅក្រសួង»។

ទោះយ៉ាងណាលោក ហង្ស សម្បត្តិ នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលការងារកម្ពុជាអន្តរជាតិ(ជំនួយហត្ថា) កាលពីម្សិលមិញបានបដិសេធចំពោះការអះអាងដែលថា ការបើកមជ្ឈមណ្ឌលរបស់លោកមិនបានសុំច្បាប់ ហើយថាលោកមិនដែលបានបោកប្រាក់លុយកាក់សិក្ខាកាមម្តងណាឡើយ។ លោកបន្តថាមជ្ឈមណ្ឌលនេះបានដំណើរការ ៦ ឆ្នាំមកហើយ ដោយបណ្តុះបណ្តាលរហូតសិក្ខាកាមអាចប្រឡងជាប់ទៅធ្វើការងារនៅជប៉ុនគឺក្នុងម្នាក់ត្រូវបង់លុយចំនួន ១៥០ ដុល្លារ។ លោកបានអះអាងថា មជ្ឈមណ្ឌលនេះគ្រាន់តែមានសិទ្ធិបណ្តុះបណ្តាលភាសាជប៉ុនប៉ុណ្ណោះ

និងគ្មានអាជ្ញាប័ណ្ណសម្រាប់បញ្ជូនពលករទៅក្រៅប្រទេសទេ ប៉ុន្តែសិក្ខាកាមគឺមានក្រុមហ៊ុនធំៗជាដៃគូចាំទទួល និងជាអ្នករៀបចំឯកសារ ឬការប្រឡងដើម្បីចេញទៅធ្វើការនៅប្រទេសជប៉ុន។ លោក ហង្ស សម្បត្តិ ចាត់ទុកការឈប់ទទួលមជ្ឈមណ្ឌលនេះថាជារឿងអយុត្តិធម៌ ប៉ុន្តែលោកថានេះដោយសារមានក្រុមហ៊ុននាំពលករខ្លះប្រណែនទើបរកវិធីប្រាប់ទៅក្រសួងឱ្យឈប់ទទួលស្គាល់បែបនេះ។ លោកបញ្ជាក់ថា៖ «សួរទៅមន្ទីរទៅ តើខ្ញុំមានច្បាប់អត់ ហើយម៉េចបានថា អត់? ហើយសួរឱ្យច្បាស់ទៅអ្នកណាចេញច្បាប់ និង certificate។ ...អូនឯងមិនបាច់ទៅរកយុត្តិធម៌ទេ ហើយទៅបញ្ជាក់ជាមួយគាត់ (ជូន វុឌ្ឍី) ឱ្យច្បាស់សិនទៅ»។

យោងតាមបញ្ជីរបស់ក្រសួងការងារមួយចុះថ្ងៃទី ១ ខែសីហា ឆ្នាំនេះ បញ្ជាក់ថាទីភ្នាក់ងារឯកជនដែលមានសិទ្ធិជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងកម្មសិក្សាទៅប្រទេសជប៉ុនមាន ១០២ ក្រុមហ៊ុន។ រីឯទីភ្នាក់ងារឯកជនគ្មានឈ្មោះក្នុងបញ្ជីនេះគឺខុសច្បាប់។

លោក មឿង តុលា នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សបានថ្លែងថា មជ្ឈមណ្ឌលបណ្តុះបណ្តាលការងារកម្ពុជាអន្តរជាតិ (ជំនួយហត្ថា) ពិតជាទទួលបានអាជ្ញាប័ណ្ណដើម្បីបណ្តុះបណ្តាលភាសាជប៉ុនមែន ប៉ុន្តែលោកថា កន្លងមកមជ្ឈមណ្ឌលនេះធ្លាប់មានសិក្ខាកាមរាប់រយនាក់ប្តឹងពីបទឆបោកប្រាក់ពី ៣០០ ដុល្លាររហូតដល់ ៦ ពាន់ដុល្លារ ដោយសារបានផ្សព្វផ្សាយកុហកសិក្ខាកាមខ្លួនថា ជាភ្នាក់ងារបញ្ជូនពលករទៅធ្វើការនៅជប៉ុន។ លោកថា៖ «សាលាអស់ហ្នឹងទទួលបានអាជ្ញាប័ណ្ណគឺតួនាទីមួយត្រឹមបណ្តុះបណ្តាលជំនាញខ្លីៗទេ ប៉ុន្តែដល់ពេលគាត់ដើរតួនាទីគឺដើរលើសអាហ្នឹង។ គាត់ដើរតួលើសម៉េច គឺដើរតួជាភ្នាក់ងារជ្រើសរើស បណ្តុះបណ្តាល និង បញ្ជូន...»។

កាលពីខែកុម្ភៈ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ថាពលករខ្មែរដែលធ្វើការនៅជប៉ុនមានជាង ៩ ពាន់នាក់ ដោយបម្រើការក្នុងផ្នែកកសិកម្ម ចំណីអាហារ គ្រឿងសង្ហារិម គ្រឿងម៉ាស៊ីន សំណង់ តម្បាញ និងដេរផ្នែកឧស្សាហកម្ម និងផ្នែកមើលថែទាំមនុស្សចាស់ជាដើម៕

## អាជ្ញាធរថៃបញ្ជូនពលកររួចផុតទោស មកកម្ពុជាវិញ តាមច្រកអន្តរជាតិជាំ

http://nokorwatnews.com/ 26-08-2019

ខេត្តឧត្តរមានជ័យ៖ ពលករខ្មែរឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់នៅក្នុងទឹកដីថៃចំនួនពីរូប រួចផុតទោសត្រូវបានអាជ្ញាធរថៃបានបញ្ជូនមកកម្ពុជាវិញ កាលថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ តាមច្រកទ្វារអន្តរជាតិជាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

សមត្ថកិច្ចបានឲ្យដឹងថា៖ ប្រជាពលរដ្ឋខ្មែរចំនួន២នាក់ ដែលថៃជូនមកតាមច្រកអន្តរជាតិជាំ ១,ឈ្មោះ ប៊ុន មៀន ភេទប្រុស អាយុ៣៧ឆ្នាំ រស់នៅភូមិរការខ្នោ ឃុំបុស្សខ្នោ ស្រុកចំការលើ ខេត្តកំពង់ចាម ។ ចាប់ខ្លួនថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ពីបទឆ្លងដែនកាប់ឈើ ចូលតាមច្រកចាក់ប្រែង ជាប់គុកនៅខេត្តស៊ីសាកេត ប្រទេសថៃ ។ ២,ឈ្មោះ ជា តេវ ភេទប្រុស អាយុ២៥ឆ្នាំ រស់នៅភូមិ៩៥ ឃុំត្រែងតាយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ចាប់ខ្លួនថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៨ ពីបទឆ្លងដែនកាប់ឈើ ចូលតាមច្រកចាក់ប្រែង ជាប់គុក នៅខេត្តស៊ីសាកេត ប្រទេសថៃ ។ ក្រោយសមត្ថកិច្ចអប់រំរួចក៏បានឲ្យវិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន ៕ ប៉ែននួន

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរពីថៃចំនួន ០៦នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI August 24 at 4:32 PM

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៦នាក់ នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្មាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

# ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៩

## ការជួយសង្គ្រោះជនរងគ្រោះពីការរំលោភផ្លូវភេទ កើនជិត ១៥០%

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 28 August 2019 | 08:43 ICT

**ភ្នំពេញ:** នៅក្នុងរយៈពេល ៦ ខែ ដើមឆ្នាំ ២០១៩ នេះសមត្ថកិច្ចបានជួយសង្គ្រោះជនរងគ្រោះពីការរំលោភបំពានផ្លូវភេទបានចំនួន ២៦៣ នាក់ គឺមានការកើនឡើងរហូតដល់ជិត ១៥០ ភាគរយ បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនដែលបញ្ហានេះបានធ្វើឲ្យមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ និងសង្គមស៊ីវិលបានសម្ដែងក្ដីបារម្ភ ខណៈដែលជនរងគ្រោះក្នុងអំពើរំលោភបំពានផ្លូវភេទទាំងនោះភាគច្រើនគឺជាកុមារ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងនៅក្នុងសិក្ខាសាលាស្ដីអំពី «កិច្ចបង្ការ និងការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍» កាលពីម្សិលមិញថា ក្នុងវិស័យទេសចរណ៍ កម្ពុជាបានទទួលភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិរាប់លាននាក់ក្នុង ១ ឆ្នាំៗ ដែលនៅក្នុងនោះមានជនឆ្លៀតឱកាសមួយចំនួនបានប្រើប្រាស់វិស័យនេះក្នុងការកេងចំណេញផ្លូវភេទលើកុមារស្របពេលដែលកុមារកម្ពុជាមួយចំនួនធំខ្វះភាពកក់ក្ដៅ ខ្វះការគ្រប់គ្រង និងការថែទាំដែលធ្វើឲ្យមានការបណ្ដែតបណ្ដោយក្នុងការស្វែងរកប្រាក់ចំណូលតាំងពីវ័យកុមារ។ បើទោះជាបែបនេះលោកស្រីលើកឡើងថាតាមកិច្ចខិតខំប្រឹងប្រែងរបស់សមត្ថកិច្ចពាក់ព័ន្ធក្នុងរយៈពេល ៦ ខែ ក្នុងឆ្នាំនេះការទប់ស្កាត់អំពើជួញដូរមនុស្សមានការកើនឡើងគួរឲ្យកត់សម្គាល់ដែលការបង្ក្រាបបទល្មើសមានចំនួន៧៨ ករណី ធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៨ មានការកើនឡើងចំនួន ២៥ ភាគរយ។

ប៉ុន្តែលោកស្រី ប៊ុន អេង ថ្លែងថាចំនួននៃជនរងគ្រោះក៏មានការកើនឡើងគួរឲ្យមានការព្រួយបារម្ភផងដែរដែលទាមទារឲ្យមានការចូលរួមទប់ស្កាត់ទាំងអស់គ្នា ខណៈដែលជនរងគ្រោះភាគច្រើនគឺជាកុមារ។ លោកស្រីបានបញ្ជាក់ថានៅដើមឆ្នាំ ២០១៩ នេះសមត្ថកិច្ចបានចាប់ឃាត់ខ្លួនជនសង្ស័យ ចំនួន ៩៧ នាក់ ខណៈដែលរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៨ បានចាប់ឃាត់ខ្លួន ៨៥ នាក់។ លើសពីនេះសមត្ថកិច្ចបាន «ឈានដល់ការជួយសង្គ្រោះជនរងគ្រោះបានចំនួន ២៦៣ នាក់បានន័យថាជនរងគ្រោះកើនខ្លាំងមែនទែន ខណៈឆ្នាំមុនជនរងគ្រោះមាន ១០៦ នាក់។ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៨ គឺកើនរហូតដល់ទៅ ១៤៨ ភាគរយ»។ លោកស្រីបន្ត៖ «ប៉ុន្តែអ្វីដែលយើងចាប់អារម្មណ៍គឺអនីតិជនក្នុងចំណោមជនរងគ្រោះទាំងនោះដែលមានអាយុក្រោម ១៥ ឆ្នាំមានរហូតដល់ទៅ ៧០ នាក់ និងចន្លោះពី ១៥ ទៅ ១៨ ឆ្នាំមាន ៣១ នាក់។ អ៊ីចឹងគ្រាន់តែជនរងគ្រោះជាអនីតិជនមានដល់ទៅ ១០១ នាក់ដែលជាតួលេខខ្ពស់ក្នុងការសង្គ្រោះជនរងគ្រោះរបស់យើងក្នុងដំណាក់កាលបង្ក្រាបនេះ»។ បើតាមលោកស្រី ជូ ប៊ុនអេង វិស័យទេសចរណ៍នៅកម្ពុជាមានការរីកចម្រើនដោយក្នុងឆ្នាំ ២០១៨ មានភ្ញៀវទេសចរប្រមាណ៦ លាននាក់ ហើយចំនួននេះនឹងកើនឡើងរហូតដល់ ១២ លាននាក់ នៅឆ្នាំ ២០៥០ ខាងមុខ ដែលការកើនឡើងនេះក៏នាំឲ្យមានការកើនឡើងនូវហានិភ័យនៃអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារផងដែរ។ បើតាមក្រសួងមហាផ្ទៃមានភ្ញៀវទេសចរប្រមាណ ១៥ ម៉ឺននាក់ ក្នុង ១ ឆ្នាំៗបានធ្វើដំណើរមកកម្ពុជាក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមទីសាធារណៈ និងសហគមន៍តាមគ្រឹះស្ថានកម្សាន្តតាមរយៈអង្គការសង្គមស៊ីវិល និងតាមរយៈការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត។

លោក សំលៀង សីលា នាយកប្រតិបត្តិអង្គការ APLE ថ្លែងថា ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍បានក្លាយជាបញ្ហាសកល និងជាទម្រង់នៃការកេងប្រវ័ញ្ចមួយដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់កុមារកម្ពុជាស្របពេលមានរបាយការណ៍ជាច្រើនបង្ហាញថា ជនល្មើសបានធ្វើដំណើរមកប្រទេសកម្ពុជាក្នុងគោលបំណងស្វែងរកសេវាផ្លូវភេទលើកុមារស្របពេលប្រព័ន្ធការពារកុមារនៅមានកម្រិតទាប និងការមិនបានការពារកុមារពីអាណាព្យាបាល។ លោកបញ្ជាក់ថា៖ «កំណើនតម្រូវការសេវាផ្លូវភេទទាំងក្មេងប្រុសក្មេងស្រី បានធ្វើឲ្យកំណើនស្វែងរកសេវាផ្លូវភេទក្នុងវិស័យទេសចរណ៍បានរងគ្រោះក្នុងអំពើបោកបញ្ឆោត លួងលោម និងជួញដូរដើម្បីផ្គត់ផ្គង់តម្រូវការផ្លូវភេទទាំងនោះ»។ លោក សំលៀង សីលា ក៏អះអាងដែរថា ក្រៅពីវិស័យទេសចរណ៍ការសិក្សាថ្មីៗនេះក៏បង្ហាញដែរថា ការដាក់បញ្ចូលរូបអាសអាភាសកុមារកម្ពុជារាប់លានសន្លឹកលើប្រព័ន្ធអ៊ីនធឺណិត ដែលមានលក្ខណៈរីកសុះសាយហើយវាបានធ្វើឲ្យការ

រំលោភបំពានលើកុមារមានការកើនឡើងផងដែរ និងរឹតតែសាហាវ ស្របពេលកំណើននៃការប្រើប្រាស់អ៊ីនធឺណិតរបស់កុមារមានចំនួនច្រើនដែលទាមទារការទប់ស្កាត់ឲ្យបានទាន់ពេលវេលា៕

## ក្រសួងមហាផ្ទៃ ជំរុញអ្នកប្រើប្រាស់ ប្រព័ន្ធបច្ចេកវិទ្យា ទាំងអស់ ប្រើប្រាស់ឲ្យ បានត្រឹមត្រូវ និងមានប្រយោជន៍ដល់សង្គម

https://www.dap-news.com/ ByID:112 Posted on 27 August 2019 | 14:58

ភ្នំពេញ ៖ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានជំរុញឲ្យអ្នកប្រើ ប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ទាំងអស់ ត្រូវចូលរួមប្រើប្រាស់ប្រព័ន្ធ បច្ចេកវិទ្យានេះ ឲ្យបានត្រឹមត្រូវ និងមានប្រយោជន៍ ដល់សង្គមជាតិ ជៀសវាងការប្រើប្រាស់ ដើម្បីកេងប្រវ័ញ្ច ឬអំពើមិនសមរម្យ ណាមួយទៅលើផ្លូវភេទកុមារ ។ នេះយោងតាមបណ្តាញ ទំនាក់ទំនងសង្គមហ្វេសប៊ុក របស់ក្រសួងមហាផ្ទៃ។ ក្នុងសិក្ខាសាលាស្តីអំពី កិច្ចបង្ការ និងការ ឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ នាទីស្តីការក្រសួងមហាផ្ទៃ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩លោកស្រីជូ ប៊ុនអេងបានថ្លែងថា ការកើនឡើងនូវរូបភាពអាសអាភាស នៅតាមគេហទំព័រនានាកំពុងតែកាន់តែរីកសាយភាយយ៉ាងច្រើន ដែលនេះក៏ជាកត្តាមួយ ក្នុងការ បង្កើត ឲ្យមានអំពើរំលោភបំពាន ផ្លូវភេទលើកុមារ ។ លោកស្រីបន្តថា ˝ បច្ចុប្បន្នយើងសង្កេតថា ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានានា ពិសេសបណ្តាញទំនាក់ទំនង សង្គមកំពុងពេញនិយមប្រើប្រាស់នូវគ្រប់មជ្ឈដ្ឋាន ដូច្នេះប្រសិនបើអ្នកប្រើ ប្រាស់ មិន ត្រឹមត្រូវ និងក្នុងបំណងទុច្ចរិតណាមួយនោះវានឹងបង្កអោយមានបទល្មើស និងជនរងគ្រោះដែលជាអនិតិជន កាន់តែច្រើនតាមរយៈប្រព័ន្ធបច្ចេកវិទ្យានេះ˝ ។

លោកស្រីរដ្ឋលេខាធិការបញ្ជាក់ថា ក្នុងរយៈកាលកន្លងទៅ ដើម្បីទប់ស្កាត់ និងបង្ការបញ្ហានេះ ក្រសួងមហាផ្ទៃបានបង្កើតនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា។ ក្នុងឱកាសនោះលោកស្រី ក៏បានអំពាវនាវដល់អ្នកពាក់ព័ន្ធពិសេសអាណាព្យាបាល ត្រូវបង្កើន ការយកចិត្តទុកដាក់ បន្ថែមទៀត ព្រោះថាការងារនេះ ត្រូវមានការចូលរួមពីគ្រប់ស្ថានប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ផ្សេងៗ ដើម្បី បំពេញ នូវអ្វីដែលខ្វះខាត ដើម្បីឈានដល់ការលុបបំបាត់អំពើកេងប្រវ័ញ្ចលើកុមារ។ លោកស្រី បញ្ជាក់បន្ថែមថា បច្ចុប្បន្នក្រសួងមហាផ្ទៃ ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការលើការងារនេះ បានដាក់ចេញនូវវិធានការ ចំពោះមុខចំនួន៣ ចំណុចសំខាន់ៗ រួមមាន៖ ១-ការប៉ាន់ប្រមាណទៅលើទំហំ នៃការហូរចូលរបស់ភ្ញៀវទេសចរ (ទាំងទេសចរណ៍ខ្មែរ និងបរទេស) ដែលមាននិន្នាការលើអំពើពេស្យាចារ, ២-ត្រូវមានភាពជឿនលឿនផ្នែកបច្ចេកវិទ្យា ក៏ដូចជាផ្លាស់ប្តូរឥរិយាបថ របស់មនុស្សនៅក្នុងសង្គម, និង៣-ត្រូវបង្កើនការស្រាវជ្រាវ ដាក់ការសង្ស័យជាមុនដើម្បីត្រៀមបង្ការ ទប់ស្កាត់ ជាមុន ដោយមិនត្រូវទុកឲ្យរូបភាពនោះមកដល់នោះទេ។ ជាក់ស្តែង គណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរ មនុស្ស បានដាក់ខេត្តចំនួន៥ ដែលជាខេត្តមុខព្រួញ ត្រូវតែបង្កើនប្រព័ន្ធការពារលើកុមារ ដែលងាយរង គ្រោះក្នុងនោះរួមមាន ខេត្តកំពត, សៀមរាប, ព្រះសីហនុ និងរាជធានីភ្នំពេញ៕ ដោយ៖ធី លីថូ

## ក្រសួងមហាផ្ទៃ បង្ហាញការព្រួយបារម្ភចំពោះបទល្មើសផ្លូវភេទលើកុមារ ព្រោះតែបច្ចេកវិទ្យាជឿនលឿន ខណៈគេហទំព័រអាសអាភាសកាន់តែរីកសាយ

http://www.freshnewsasia.com/ 2019-08-27

**(ភ្នំពេញ)៖** ក្រសួងមហាផ្ទៃ តាមរយៈគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបង្ហាញនូវការព្រួយបារម្ភចំពោះបទល្មើសផ្លូវភេទ ដែលកើតឡើងនៅលើកុមារកម្ពុជា ក្នុងរូបភាពកាន់តែសាហាវ និងព្រៃផ្សៃជាទីបំផុត បន្ទាប់បច្ចេកវិទ្យាកាន់តែជឿនលឿន ហើយគេហទំព័រអាកាសអាភាសកាន់តែរីកសាយភាយ។ ទន្ទឹមនឹងការព្រួយបារម្ភនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ

«APLE» នៅព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ បានរៀបចំសិក្ខាសាលាមួយស្ដីពី «កិច្ចការបង្ការ និងការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍» ដែលពិធីនេះ ត្រូវបានធ្វើឡើងនៅទីស្ដីការក្រសួងមហាផ្ទៃ។ សិក្ខាសាលានេះធ្វើឡើងក្នុងគោលបំណងដើម្បីបង្កើនការយល់ដឹងអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ និងស្វែករកធាតុចូល ដើម្បីកំណត់យុទ្ធសាស្ត្រ និងសកម្មភាពគន្លឹះក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ។

ថ្លែងក្នុងឱកាសនោះ លោកស្រី ជូ ប៊ុនអេង បានគូសបញ្ជាក់ថា កន្លងទៅដើម្បីទប់ស្កាត់ និងបង្ការបញ្ហានេះ ក្រសួងមហាផ្ទៃ ក៏បានបង្កើតនូវនាយកដ្ឋានមួយ គឺនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ប៉ុន្តែទន្ទឹមនឹងការបង្កើនយន្តការច្បាប់បែបនេះ ក្រសួងក៏អំពាវនាវដល់អ្នកពាក់ព័ន្ធ ពិសេសអាណាព្យាបាល ត្រូវតែបង្កើនការយកចិត្តទុកដាក់បន្ថែមទៀត។ លោកស្រីបានថ្លែងយ៉ាងដូច្នេះថា «យើងចង់ឲ្យការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានេះឲ្យមានផលប្រយោជន៍ ជៀសជាងបានយកប្រព័ន្ធបច្ចេកវិទ្យានេះ ទៅធ្វើជាឧបករណ៍ សម្រាប់ការកេងប្រវ័ញ្ច ឬមួយក៏ធ្វើអំពើមិនគប្បីចំពោះកុមារ ដោយយើងដឹងស្រាប់ហើយថា កុមារ ឬក្មេងតូចៗ គ្នាអត់ដឹងអីទេ ហើយឥលូវនេះ អ្វីដែលជាការរំលោភបំពានហាក់ដូចកាន់តែស្រួចស្រាលទៅ ដែលក្មេងរងគ្រោះកាន់តែធ្ងន់ធ្ងរដែរ ដោយសារតែភាពប្រព្រឹត្តទៅលើកុមារ កាន់តែសាហាវ»។

ឆ្លើយតបនឹងបញ្ហានេះ លោកស្រី ជូ ប៊ុនអេង អះអាងថា សម្រាប់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មិនអាចធ្វើការងារនេះ ម្នាក់ឯងពេញលេញនោះទេ ពោលគ្រប់ស្ថានពាក់ព័ន្ធ ត្រូវតែរួមគ្នាគិតជាមួយដៃគូរអភិវឌ្ឍន៍ផ្សេង ដើម្បីបំពេញនូវអ្វីដែលខ្វះខាត ដើម្បីឈានដល់ការលុបបំបាត់អំពើកេងប្រវ័ញ្ចលើកុមារ។ លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់ទៀតថា បច្ចុប្បន្នក្រសួងមហាផ្ទៃ ដែលមានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាសេនាធិការលើការងារនេះ បានដាក់ចេញនូវវិធានការចំពោះមុខ៣ចំណុចសំខាន់ៗ៖ ទី១៖ ការប៉ាន់ប្រមាណទៅលើទំហំ នៃការហូរចូលរបស់ភ្ញៀវទេសចរ (ទាំងទេសចរណ៍ខ្មែរ និងបរទេស) ដែលមាននិន្នាការលើអំពើពេស្យាចារ, ទី២៖ ត្រូវមានភាពជឿនលឿនផ្នែកបច្ចេកវិទ្យា ក៏ដូចជាផ្លាស់ប្ដូរឥរិយាបថរបស់មនុស្សនៅក្នុងសង្គម និងទី៣៖ ត្រូវបង្កើនការស្រាវជ្រាវ និងដាក់ការសង្ស័យជាមុនដើម្បីត្រៀមបង្ការ ទប់ស្កាត់ជាមុន ដោយមិនត្រូវទុកឲ្យរូបភាពនោះមកដល់នោះទេ។

គួរជម្រាបថា ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ គឺក្លាយជាបញ្ហាសកល និងជាទម្រង់នៃការរំលោភបំពានមួយ ដែលបង្កផលប៉ះពាល់ យ៉ាងធ្ងន់ធ្ងរដល់កុមារ។ របាយការណ៍ស្រាវជ្រាវជាច្រើនបានបង្ហាញថា ជនល្មើសចូលចិត្តធ្វើដំណើរទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ប្រទេសដែលមានប្រព័ន្ធ ការពារកុមារនៅទន់ខ្សោយ និងប្រទេសដែលមានសហគមន៍ងាយរងគ្រោះ ដែលគ្រួសារគិតពីផលប្រយោជន៍ និងលុយកាក់ធំជាងការរក្សាសុវត្ថិភាពកុមារ។ យ៉ាងណាក៏ដោយ រហូតមកដល់ពេលនេះ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ខេត្តចំនួន៥ ដែលជាខេត្តមុខព្រួញ ត្រូវតែបង្កើនប្រព័ន្ធការពារលើកុមារ ដែលមានងាយរងគ្រោះ រួមមាន ខេត្តកំពត, សៀមរាប, ព្រះសីហនុ និងរាជធានីភ្នំពេញ៕

## កម្ពុជា កំពុងរងគ្រោះការកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមរយៈ បណ្ដាញ INTERNET

http://bayontv.com.kh/ 27/08/2019

ភ្នំពេញ ៖ នៅក្នុងថ្ងៃទី២៧ ខែសីហានេះ ក្រសួងមហាផ្ទៃ បានប្រារព្ធបើកសិក្ខាសាលាស្ដីពីកិច្ចបង្ការ និងការឆ្លើយតប នឹងបទល្មើសផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍។ នៅសិក្ខាសាលានោះ លោកជំទាវ ជូ ប៊ុនអេង បានអះអាងថា ភាពងាយរងគ្រោះដោយសារបទល្មើសផ្លូវភេទលើកុមារនៅកម្ពុជា មួយចំនួនធំកើតឡើងដោយសារការអូសទាញ នៃការរីកចំរើនប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍ របស់ពិភពលោក។ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងថា ចាប់ពី

ពេលនេះ តទៅ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងបង្កើនកិច្ចសហការជាមួយ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងទេសចរណ៍ អង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធនានាទៀត ទប់ស្កាត់ប្រព័ន្ធគេហទំព័រមួយចំនួន ដែលបង្កអោយមានបទល្មើសជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទកុមារ។ លោកជំទាវបន្តថា ការទប់ស្កាត់ការផ្សព្វផ្សាយអំពើកេងប្រវ័ញ្ច និងជួញការជួញដូរផ្លូវភេទកុមារតាមរយៈប្រព័ន្ធបច្ចេកវិទ្យារបស់ពិភពលោកនៅកម្ពុជា គឺកំពុងជួបបញ្ហាប្រឈមច្រើន ដោយសារ ការផលិតវីដេអូអាសអាភាសរបស់កុមារ ផ្សព្វផ្សាយលើបណ្តា Website ខុសច្បាប់ គឺវីដេអូទាំងនោះ មិនមានផលិតនៅកម្ពុជា។

តាមរបាយការណ៍ ឆមាសទី១របស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា ក្នុងរយៈពេល៦ខែឆ្នាំ២០១៩នេះ កងសមត្ថកិច្ចបានបង្ក្រាបបទល្មើសជួញដូរមនុស្សបានប្រមាណ៧៨ករណី កើនឡើង១៦ករណី ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅតុលាការប្រមាណ៩៧នាក់ កើនឡើង១២នាក់ និងបានជួយជនរងគ្រោះបានប្រមាណជាងជិត៣០០នាក់ កើនឡើង១៤៨% លើសការរំពឹងទុក។ របាយការណ៍ បានបញ្ជាក់ដែរថា នៅក្នុងចំណោមជនរងគ្រោះដែលសង្គ្រោះបានពីអំពើជួញដូរមនុស្សទាំង៣០០នាក់នោះ គឺមាន កុមារអាយុ១៥ឆ្នាំ មានចំនួន៧៥នាក់ និងអាយុ១៥ដល់១៨ឆ្នាំមាន ចំនួន២៦នាក់ សរុប១០១នាក់។

នាយកប្រតិបត្តិអង្គការ APLE លោក សំនាង សិលា បានថ្លែងថា ការប្រើប្រាស់បច្ចេកទេសព័ត៌មាន និងសារទូរគមនាគមន៍ ឬInternet ជាមធ្យោបាយសំរាប់ធ្វើសកម្មភាពព្រឹត្តិបទល្មើសផ្លូវភេទជាអំពើដែលមានស្មុគស្មាញ និងលំបាកក្នុងការទប់ស្កាត់ហើយអ្នកដែលងាយរងគ្រោះគឺកុមារនិងស្ត្រីទន់ខ្សោយ។ លោក សំនាង សិលា បញ្ជាក់ថា ការកេងប្រវ័ញ្ចផ្លូវភេទដោយភ្ញៀវទេសចរ ភាគច្រើនកើតឡើងទៅលើកុមារ នៅតាមទីសាធារណៈ នៅតាមគ្រឹះស្ថានកំសាន្ត នៅតាមស្ថាប័នកន្លែងធ្វើការងារនានាជាពិសេសមណ្ឌលថែរក្សាកុមារ និងសាលារៀនជាដើម និងការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅតាមប្រព័ន្ធINTERNETជាដើម៕

## គ.ជ.ប.ជ រៀបចំសិក្ខាសាលាពីកិច្ចបង្ការនិងការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍

http://www.nicetvnewsoffice.com/ August 28, 2019

នៅព្រឹកថ្ងៃអង្គារ ទី២៧ ខែសីហា ឆ្នាំ២០១៩ នាទីស្តីការក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានរៀបចំសិក្ខាសាលាស្តីអំពី កិច្ចបង្ការ និងការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ "The Prevention of Sexual Exploitation of Children in travel and Tourism (SECTT)"។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណង ដើម្បីបង្កើនការយល់ដឹងអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ និងស្វែងរកធាតុចូលដើម្បីកំណត់យុទ្ធសាស្ត្រ និងសកម្មភាពគន្លឹះក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ និងការរំលោភបំពានផ្លូវភេទលើកុមារ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ ដោយមានការចូលរួមពី ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ តំណាងក្រសួង អង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធនានា។

សិក្ខាសាលានេះ តម្រូវឲ្យអ្នកទទួលខុសត្រូវមកពី តំណាង ក្រសួង អង្គការ និងស្ថាប័នពាក់ព័ន្ធទាំងអស់ឡើងធ្វើបទបង្ហាញពីបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តការងារកន្លងមក និងលើកជាគោលនយោបាយ វិធានការនានាដើម្បីកំណត់ធាតុចូលក្នុងការរៀបចំយុទ្ធសាស្ត្រសម្រាប់ជាទិសដៅអនុវត្តបន្ត។ ទន្ទឹមនឹងគ្នានេះដែរក៏បើកឲ្យមានការចូលរួមជាសំនួរ ចម្លើយក្នុងន័យស្វែងយល់បន្ថែមពីចំណុចខ្វះខាតលើកត្តាផ្សេងៗ ដើម្បីធ្វើយ៉ាងណាឲ្យសិក្ខាសាលានេះប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ និងទទួលលទ្ធផលល្អ។

ក្រោយបញ្ចប់សិក្ខាសាលានេះអ្នករៀបចំកម្មវិធីរំពឹងថា នឹងទទួលបានលទ្ធផលដូចជា មានការកើនឡើងពីការយល់ដឹងអំពីទម្រង់ហានិភ័យ និងនិន្នាការថ្មីៗនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍។ ទទួលបានធាតុចូល ដើម្បីកំណត់យុទ្ធសាស្ត្រ និងសកម្មភាពជាគន្លឹះក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ និងការរំលោភបំពានលើកុមារ ផងដែរ៕

## គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ខេត្តបន្ទាយមានជ័យ ជម្រុញដល់អ្នកពាក់ព័ន្ធត្រូវសហការគ្នា ទប់ស្កាត់ឲ្យបាននូវអំពើជួញដូរមនុស្ស ឬឆ្លងដែនខុសច្បាប់នៅតាមបន្ទាត់ព្រំដែន

https://gdlf-kh.com/ 27/08/2019 Kim Sopha បន្ទាយមានជ័យ

ខេត្តបន្ទាយមានជ័យ ៖ នៅព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ នាសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ (សាលខ) បានរៀបចំកិច្ចប្រជុំ ស្តីពី ការបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០១៩ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ខេត្ត (គ.ខ.ប.ជ) ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព លោក ជំទាវ ប៉ុក ណាឌី អភិបាលរង នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងជាប្រធានអង្គប្រជុំ ដែលមានការអញ្ជើញចូលរួមពីលោក លោកស្រី ប្រធានមន្ទីរ អង្គភាព អាជ្ញាធរ សមត្ថកិច្ច ពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ។ លោកជំទាវ ប៉ុក ណាឌី ប្រធានអង្គប្រជុំ បានមានប្រសាសន៍ ជម្រុញដល់អ្នកពាក់ព័ន្ធត្រូវសហការជាមួយសមត្ថកិច្ច អង្គការដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវធ្វើការទប់ស្កាត់ឲ្យបានរាល់សកម្មភាពអំពើជួញដូរមនុស្សឆ្លងដែនទៅប្រទេសជិតខាង ពិសេសស្ត្រី និងកុមារជាដើម ។ លោកជំទាវ បន្តថា ៖ អាជ្ញាធរ សមត្ថកិច្ច ពាក់ព័ន្ធ ត្រូវចុះធ្វើការអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាព ធានាបានការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងធ្វើការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ដូចជាក្នុងសិប្បកម្មឡឥដ្ឋ ការដ្ឋានសំណង់ កន្លែងលាងរថយន្ត ម៉ូតូ អូសរទេះ និងសហការជាមួយអង្គការដៃគូរ និងអង្គភាពពាក់ព័ន្ធ ជួយដល់កូនគ្រួសារក្រីក្រ គ្រួសារងាយរងគ្រោះ សង្គ្រោះកុមារឲ្យរួចផុតពីពលកម្មធ្ងន់ ដោយមួយចំនួន បានបញ្ជូនចូលសាលារៀនមួយចំនួនហួសអាយុបានបញ្ជូនទៅសាលាបណ្តុះបណ្តា លវិជ្ជាជីវជាបន្តបន្ទាប់ ។

យោងតាមស្ថិតិពលករចំណាកស្រុកឆ្លងដែនខុសច្បាប់ប្រចាំថ្ងៃ ដែលភាគីថៃបញ្ជូនក្នុងឆមាសទី១ ឆ្នាំ២០១៩ គិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ មានចំនួនសរុប ៦៧៤៣នាក់ ,បុរស៣៧៤៥នាក់, ស្ត្រី ២១៥៣នាក់ , កុមារ៤៥២នាក់ និងកុមារី៣៩៣នាក់ ។ ក្នុងចំណោមពលករចំនួន ៦៧៤៣នាក់ មជ្ឈមណ្ឌលសំចត់ប៉ោយប៉ែត បានធ្វើសម្ភាសន៍ ដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើជួញដូរមនុស្សមានចំនួន១៣០នាក់(បុរស១៤នាក់ ,ស្ត្រី២២នាក់ ,កុមារ២៩នាក់ ,កុមារី៣២នាក់ ) ស្មើនឹង ៧២.២២% ប្រៀបធៀប ផែនការប្រចាំឆ្នាំ២០១៩ (១៨០នាក់) ក្នុងនោះមានពលករដែលមានបញ្ហាសុខភាព ត្រូវបានក្រុមការងារជួយសង្គ្រោះបញ្ជូនទៅមន្ទីរពេទ្យបង្អែកក្រុងប៉ោយប៉ែត ចំនួន០៦នាក់, ស្ត្រី ០៥នាក់ ,បុរស ០១ , កុមារ០១នាក់ និងមន្ទីរពេទ្យបង្អែកស្រុកមង្គលបូរីចំនួន០១ជាស្ត្រី ៕

## អាជ្ញាធរខេត្តជំរុញអ្នកពាក់ព័ន្ធត្រូវសហការគ្នាទប់ស្កាត់ឲ្យបាននូវអំពើជួញដូរមនុស្ស ឬឆ្លងដែនខុសច្បាប់នៅតាមបន្ទាត់ព្រំដែន

http://cambodiapolice.com/ 6:20 pm 27 សីហា 2019

បន្ទាយមានជ័យ ៖ នៅព្រឹកថ្ងៃទី២៧ ខែសីហា នាសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ (សាលខ) បានរៀបចំកិច្ចប្រជុំស្តីពី ការបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០១៩ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ខេត្ត (គ.ខ.ប.ជ) ដែលប្រព្រឹត្តទៅក្រោមអធិបតីភាពលោកជំទាវ ប៉ុក ណាឌី អភិបាលរង នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងជាប្រធានអង្គប្រជុំ ដែលមានការអញ្ជើញចូលរួមពីលោក លោកស្រី ប្រធានមន្ទីរ អង្គភាព អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ បានចូលរួម ។

លោកជំទាវ ប៉ុក ណាឌី ប្រធានអង្គប្រជុំ បានមានប្រសាសន៍ជម្រុញដល់អ្នកពាក់ព័ន្ធត្រូវ ត្រូវសហការជាមួយសមត្ថកិច្ច អង្គការដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវធ្វើការទប់ស្កាត់ឲ្យបានរាល់សកម្មភាពអំពេីជួញដូរមនុស្សឆ្លងដែនទៅប្រទេសជិតខាងពិសេសស្ត្រី និងកុមារជាដើម ។ លោកជំទាវបន្តថា ៖ អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ត្រូវចុះធ្វើការអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាព ធានាបានការចំណាក់ស្រុកប្រកបដោយសុវត្ថិភាព និងធ្វើការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ដូចជាក្នុងសិប្បកម្មឡឥដ្ឋ ការរដ្ឋានសំណង់ កន្លែងលាងរថយន្ត ម៉ូតូ អូសរទេះ និងសហការជាមួយអង្គការដៃគូ និងអង្គភាពពាក់ព័ន្ធ ជួយដល់កូនគ្រួសារក្រីក្រ គ្រួសារងាយរងគ្រោះ សង្គ្រោះកុមារឲ្យរួចផុតពី

ពលកម្មធ្ងន់ ដោយមួយចំនួន បានបញ្ជូនចូលសាលារៀនមួយចំនួនហួសអាយុបានបញ្ជូនទៅសាលាបណ្តុះបណ្តាលវិជ្ជាជីវជាបន្តបន្ទាប់ ។

យោងតាមស្ថិតិពលករចំណាកស្រុកឆ្លងដែនខុសច្បាប់ប្រចាំថ្ងៃ ដែលភាគីថៃបញ្ជូនក្នុងឆមាសទី១ ឆ្នាំ២០១៩ គឺតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា មានចំនួនសរុប៦៧៤៣នាក់ ,បុរស៣៧៤៥នាក់ ,ស្ត្រី ២១៥៣នាក់ ,កុមារា៤៥២នាក់ និងកុមារី៣៩៣នាក់។ ក្នុងចំណោមពលករចំនួន ៦៧៤៣នាក់ មជ្ឈមណ្ឌលសំចត់ប៉ោយប៉ែតបានធ្វេ ីសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សមានចំនួន១៣០នាក់(បុរស១៤នាក់ ,ស្ត្រី២២នាក់ ,កុមារា២៩នាក់ ,កុមារី៣២នាក់) ស្មើនឹង៧២.២២% ប្រៀបធៀបផែនការប្រចាំឆ្នាំ២០១៩ (១៨០នាក់) ក្នុងនោះមានពលករដែលមានបញ្ហាសុខភាព ត្រូវបានក្រុមការងារជួយសង្គ្រោះបញ្ជូនទៅ មន្ទីរពេទ្យបង្អែកក្រុងប៉ោយប៉ែត ចំនួន០៦នាក់, ស្ត្រី៥នាក់ ,ប្រុស១នាក់ ,កុមារ១នាក់ និងមន្ទីរពេទ្យបង្អែកស្រុកមង្គលបូរី ចំនួន១ជាស្ត្រី ៕

## ប្រធានរដ្ឋសភាថៃ អះអាងថា នឹងយកចិត្តទុកដាក់ ចំពោះពលករខ្មែរ

https://www.dap-news.com/ ByID:112 Posted on 27 August 2019 | 16:57

ភ្នំពេញ ៖ លោក ឈួន លីផៃ ប្រធានរដ្ឋសភាថៃ និងជាប្រធានសភា អាយប៉ាលើកទី៤០ បានថ្លែងថា អាជ្ញាធរមានសមត្ថកិច្ចរបស់ថៃ នឹងបន្តយកចិត្តទុក ដាក់លើពលករខ្មែរ ដែលកំពុងរស់នៅ ក៏ដូចជាធ្វើការនៅថៃ ខណៈបច្ចុប្បន្នមានពលរដ្ឋជាច្រើនពាន់នាក់ កំពុងមានវត្តមាននៅថៃ។ នេះបើយោងតាមបណ្តាញ ទំនាក់ទំនង សង្គមហ្វេសប៊ុក រដ្ឋសភាកម្ពុជា។ ក្នុងជំនួបជាមួយ លោក ឈួន លីផៃ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ នៅទីក្រុងបាងកក សម្តេច ហេង សំរិន នៅក្នុងកិច្ចប្រជុំពេញអង្គ AIPA បានស្នើឲ្យមានការយកចិត្តទុកដាក់ និងលើកស្ទួយសិទ្ធិពលករចំណាកស្រុក។ សម្តេចបន្តថា បច្ចុប្បន្នការប្រើប្រាស់កម្លាំងពលកម្មប្រកបដោយប្រសិទ្ធភាព ជាការចាំបាច់ និងជាតម្រូវការប្រទេសនីមួយៗ ដូច្នេះប្រទេសក្នុងតំបន់ទាំងអស់ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តប្រព័ន្ធគាំពារសង្គម ដើម្បីធានាថា ពលករចំណាកស្រុកទាំងអស់ រួមទាំងក្រុមគ្រួសារពួកគេ ត្រូវបានការពារដោយច្បាប់ និងទទួលបានសេវាសាធារណៈដោយមិនរើសអើង។

លោក ឈួន លីផៃ ចាត់ទុកការលើកឡើងរបស់សម្តេចមានសារៈសំខាន់ព្រោះជាបញ្ហារួម ហើយថៃក៏មានបញ្ហានេះ កម្ពុជា និងប្រទេសផ្សេង ក៏មានបញ្ហានេះដូចគ្នា។ ប្រធានរដ្ឋសភាថៃបានជម្រាបសម្តេចថា *"ថៃបានយកចិត្តទុកដាក់ ដល់ពលករកម្ពុជា ដែលកំពុងធ្វើការនៅក្នុងប្រទេសខ្លួន"* ។

ជាមួយគ្នានេះដែរប្រធានរដ្ឋសភាខ្មែរក៏បានអញ្ជើញលោក ឈួន លីផៃ ទៅបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា ក្នុងពេលវេលាសមស្របណាមួយដែមទៀតផង ។ ផ្អែកលើកិច្ចសហប្រតិបត្តិការជាមួយគ្នារវាងកម្ពុជានិងថៃ លើវិស័យការងារ និងវិស័យអប់រំ បណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈ ពិសេសស្ថិតក្នុងរយៈពេល នៃកិច្ចសហប្រតិបត្តិការផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជា ភាគីទាំងពីរ បានរួមគ្នាផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជា បានជាង៣០ម៉ឺននាក់ រួចហើយ ក្នុងចំណោមពលករ ជាង៤០ម៉ឺននាក់ ដែលកំពុងបំរើការងារ ដោយខុសច្បាប់នៅក្នុង ប្រទេសថៃ ។

**ដោយ បាន ធារ៉ូ**

## នាងបានត្រឹមនិយាយថា៖ ត្រូវបានគេយកទៅលក់នៅចិន

https://www.khmerload.com/ Khmerload ៣២ នាទីមុន 10:30 August 28, 2019

រាជធានីភ្នំពេញ ៖ តាមសេចក្តីរាយការណ៍បឋមបានឱ្យដឹងថា ស្ត្រីម្នាក់ដែលបានទៅប្រទេសចិនប្រហែលជា៥ទៅ៦ខែមកហើយ ពេលនេះបានត្រឡប់មកវិញប៉ុន្តែនាងបែរជាមានសតិមិនប្រក្រតី ។ ស្ត្រីរូបនោះមានឈ្មោះ គន់ សោភណ្ឌ អាយុ៣២ឆ្នាំ ។ តាមសេចក្តីរាយការណ៍បន្តថា ស្ត្រីខាងលើបានចុះពីលើយន្តហោះកាលពីវេលាម៉ោង១

យប់រំលងអធ្រាត្រឈានចូលថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ រហូតដល់ព្រឹកមិញនេះទើបកម្លាំងខាងអាកាសយានដ្ឋានបានរាយការណ៍ទៅកាន់សមត្ថកិច្ចនាំទៅធ្វើការសួរនាំនៅប៉ុស្តិ៍កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ ។ ប៉ុន្តែស្ត្រីរូបនោះនៅពេលដែលសួរនាំរកសាច់ញាតិ និងដំណើរដើមទងនាងបានត្រឹមនិយាយរវើរវាយថា នាងត្រូវបានគេយកទៅលក់៥ទៅ៦ខែមកហើយ ថែមទាំងគេធ្វើបាបទៀតផង និងមិនដឹងថាទីលំនៅរបស់ខ្លួនឯងនៅទីណាផងដែរ ៕

## ប៉ូលិសកម្ពុជាត្រៀមបញ្ជូនបុរសអាមេរិកាំងម្នាក់ចេញពីកម្ពុជា ពាក់ព័ន្ធនឹងករណីបំពានផ្លូវភេទកុមារ

https://www.rfa.org/khmer/news/ ដោយ អាស៊ីសេរី 2019-08-27

សមត្ថកិច្ចកម្ពុជាកំពុងបន្តនីតិវិធីបញ្ជូនបុរសម្នាក់ឈ្មោះ ខាល់ វ៉ុន បិននីង ហៅសេន (Karl Von Boenninghausen) អាយុ ៥៦ឆ្នាំ ជាជនជាតិអាមេរិក ទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីអនុវត្តនីតិវិធីបញ្ជូនចេញពីកម្ពុជា។ គេហទំព័រអគ្គស្នងការនគរបាលជាតិចុះផ្សាយនៅថ្ងៃទី២៦ សីហាថា ប៉ូលិសកម្ពុជា បានសហការជាមួយកងកម្លាំងនៃការិយាល័យសន្តិសុខប្រចាំតំបន់របស់ស្ថានទូតសហរដ្ឋអាមេរិក ចាប់ខ្លួន បុរសឈ្មោះ Karl Von Boenninghausen កាលពីថ្ងៃទី២៥ ខែសីហា ពីបទរំលោភបំពានផ្លូវភេទលើកុមារ តាមដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់តុលាការរដ្ឋកាលីហ្វ័រញ៉ា (California)។

នាយការិយាល័យការពារអនីតិជន លោក សៅ លីន ប្រាប់គេហទំព័រអគ្គស្នងការនគរបាលជាតិថា កម្លាំងនាយកដ្ឋានស៊ើបការខាងក្រៅ និងបច្ចេកទេស បានឃាត់ខ្លួនជនល្មើស ឈ្មោះ Karl Von Boenninghausen នៅផ្ទះសំណាក់ យីហោ happy ស្ថិតនៅក្បែរវត្តសារាវ័ន្ត ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការចាប់ខ្លួនបុរសជនជាតិអាមេរិកនេះ សមត្ថកិច្ចដកហូតបានលិខិតឆ្លងដែន (PASSPORT) ចំនួន ៣ក្បាល ដោយ ១ក្បាល ជាលិខិតឆ្លងដែនថ្មី និង ២ក្បាលទៀត ជាលិខិតឆ្លងដែនប្រើអស់សន្លឹក ព្រមទាំងដកហូតបានរបស់របរមួយចំនួនទៀត។ សម្ភារៈដកហូតបានទាំងអស់នេះ ក៏នឹងត្រូវបញ្ជូនចេញពីកម្ពុជាជាមួយបុរសអាមេរិកាំងរូបនោះដែរ៕

## កុមាររងគ្រោះដោយការរំលោភផ្លូវភេទមានការកើនឡើង

https://khmer.voanews.com/ 27 សីហា 2019 កាន់ វិច្ចិកា

ភ្នំពេញ៖ កុមាររងគ្រោះដោយសារការរំលោភផ្លូវភេទមានការកើនឡើង ក្នុងរយៈពេលប្រាំមួយខែដើមឆ្នាំ ២០១៩នេះ។ មូលហេតុដោយសារកំណើននៃភ្ញៀវទេសចរ និងប្រព័ន្ធបច្ចេកវិទ្យាកាន់តែរីកចម្រើននៅកម្ពុជា។ អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ថ្លែងក្នុងសិក្ខាសាលាស្តីអំពីកិច្ចបង្ការ និងការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍នៅថ្ងៃអង្គារនេះថា ក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០១៩នេះ សមត្ថកិច្ចបង្ក្រាបបានបទល្មើសផ្លូវភេទលើកុមារចំនួន ៧៨ករណី ដែលកើនឡើងចំនួន ១៦ករណី ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៨។ ក្នុងនោះសង្គ្រោះជនរងគ្រោះអាយុក្រោម១៨ឆ្នាំបានចំនួន ២៦៣នាក់។ តួលេខនេះបង្ហាញពីការកើនឡើងនៃជនរងគ្រោះចំនួន ១៥៧នាក់។ ក្នុងចំណោមនោះ ជនរងគ្រោះអាយុក្រោម១៥ឆ្នាំមានរហូតដល់ទៅ ៧០នាក់។ អ្នកស្រី ជូ ប៊ុនអេង បន្ថែមថា សមត្ថកិច្ចឃាត់ខ្លួនជនសង្ស័យចំនួន ៩៧នាក់ គឺកើន១២នាក់។ យោងតាម អ្នកស្រី ជូ ប៊ុនអេង ចំនួនអ្នកទេសចរនៅកម្ពុជាកើនឡើងជារៀងរាល់ឆ្នាំនៅក្នុងប្រទេសកម្ពុជា និងការកើនឡើងនូវរូបភាពអាសអាភាសលើគេហទំព័រនានា គឺជាកត្តាក្នុងការបង្កើតឲ្យមានអំពើរំលោភបំពានផ្លូវភេទលើកុមារ។

បើតាមតួលេខរបស់ក្រសួងទេសចរណ៍កម្ពុជា ភ្ញៀវទេសចរប្រមាណជា ៦លាននាក់បានមកទស្សនាប្រទេសកម្ពុជាក្នុងឆ្នាំ២០១៨។ ចំណែកអ្នកប្រើប្រាស់សេវាអ៊ីនធឺណិតមានរហូតដល់ ១០.៩លាននាក់ គិតត្រឹមខែមេសា ឆ្នាំ ២០១៨ ក្នុងចំណោមប្រជាជនសរុបប្រមាណជា ១៦លាននាក់។

អ្នកស្រី ជូ ប៊ុនអេង កត់សម្គាល់ថា កុមាររងគ្រោះកាន់តែមានអាយុក្មេងទៅៗ៖ «កុមារ ឬក្មេងដែលតូចៗហ្នឹង គ្នាអត់ដឹងអីទេ ហើយឥឡូវនេះ អ្វីដែលជាការរំលោភបំពានហ្នឹង ហាក់ដូចជា កាន់តែស្រួចស្រាលទៅ គឺមិនមែនក្មេងអាយុ១២ ១៣ ១៤ឆ្នាំ គឺថា ក្មេងហ្នឹងវ័យកាន់តែក្មេងៗ ហើយរងគ្រោះក៏កាន់តែធ្ងន់ធ្ងរដែរ ដោយសារតែភាពប្រព្រឹត្តលើកុមារកាន់តែសាហាវ»។ អ្នកស្រី ជូ ប៊ុនអេង បានជំរុញឲ្យអ្នកប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទាំងអស់ ចូលរួមប្រើប្រាស់ឲ្យបានត្រឹមត្រូវ និងមានប្រយោជន៍ដល់សង្គមជាតិ ជៀសវៀងការប្រើប្រាស់ដើម្បីកេងប្រវ័ញ្ច ឬអំពើមិនសមរម្យណាមួយពាក់ព័ន្ធនឹងផ្លូវភេទកុមារ។ អ្នកស្រីក៏បានអំពាវនាវដល់អ្នកពាក់ព័ន្ធ ពិសេសអាណាព្យាបាល ត្រូវបង្កើនការយកចិត្តទុកដាក់ដើម្បីឈានដល់ការលុបបំបាត់អំពើកេងប្រវ័ញ្ចលើកុមារ។

លោក អំ សំអាត នាយករងទទួលបន្ទុកផ្នែកឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូ (LICADHO) ប្រាប់ VOA ថា កម្ពុជាជាប្រទេសដែលថ្មីសម្រាប់ប្រព័ន្ធបច្ចេកវិទ្យា ស្របពេលដែលជីវភាព និងចំណេះដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត ជាហេតុធ្វើឲ្យកម្ពុជាក្លាយជាប្រទេសងាយរងគ្រោះពាក់ព័ន្ធនឹងបទល្មើសផ្លូវភេទ។ «បញ្ហាទី១ សីលធម៌នៅក្នុងសង្គមយើងគឺមានការធ្លាក់ចុះ បញ្ហាទី២ បញ្ហាបច្ចេកវិទ្យាទំនើបហ្នឹង គឺបញ្ហាដែលចែកចាយវីដេអូអាសអាភាសតាមប្រព័ន្ធបណ្ដាញសង្គម តាមអនឡាញអីជាដើមហ្នឹង បញ្ហាទី៣ បញ្ហាគ្រឿងញៀន គ្រឿងស្រវឹងអីជាដើម បញ្ហាទី៤ ការអនុវត្តច្បាប់យើងក៏នៅមានកម្រិត»។ លោក អំ សំអាត បន្ថែមថា រដ្ឋាភិបាលគួរតែបង្កើនកិច្ចការការពារពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យា ពង្រឹងការអនុវត្តច្បាប់ សហការជាមួយអន្តរជាតិក្នុងការទប់ស្កាត់ និងអប់រំបន្ថែមដល់ពលរដ្ឋឲ្យយល់ដឹងអំពីករណីនេះ៕

## រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា សំណូមពរព្រះតេជព្រះគុណគ្រប់ព្រះអង្គ យកចំណេះដឹង និងបទពិសោធន៍ផ្សព្វផ្សាយព្រះពុទ្ធោវាទ ប្រពៃណី ទំនៀមទំលាប់ វប្បធម៌ អរិយធម៌ខ្មែរ អប់រំសីលធម៌ ចរិយាធម៌ ដល់មហាជន

http://www.cen.com.kh/ August 28, 2019

ភ្នំពេញ៖ ក្នុងពិធីបិទសិក្ខាសាលាទស្សនាទានព្រះពុទ្ធសាសនា និងពង្រឹងការផ្សព្វផ្សាយព្រះធម៌ នៃក្រសួងធម្មការនិងសាសនា ជាកម្មវិធីអប់រំតាមបែបព្រះពុទ្ធសាសនា គឺមានសារសំខាន់ និងអត្ថន័យធំធេងបំផុតសម្រាប់អប់រំ ទូន្មាន កូនខ្មែរគ្រប់រូប ឲ្យប្រកាន់ខ្ជាប់នូវអំពើល្អ សីលធម៌ គុណធម៌ ចរិយាធម៌ សេចក្តីថ្លៃថ្នូរនៅក្នុងសង្គម ចៀសផុតពីគ្រឿងញៀន គ្រឿងស្រវឹង ពីការជួញដូរមនុស្ស និងចៀសផុតពីអំពើហិង្សាក្នុងគ្រួសារ និងក្នុងសង្គម។

រសៀលថ្ងៃអង្គារ ទី២៧ ខែសីហា ឆ្នាំ២០១៩លោក ហ៊ឹម ឆែម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ជាអធិបតីក្នុងពិធីបិទសិក្ខាសាលាទស្សនាទានព្រះពុទ្ធសាសនា និងពង្រឹងការផ្សព្វផ្សាយព្រះធម៌លើកទី២ ដែលមានសិក្ខាកាមជាព្រះសង្ឃចូលរួមចំនួន១៨០អង្គ ដែលសុទ្ធតែជាព្រះសង្ឃ និងជាធម្មកថិក កំពុងចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព្រះពុទ្ធោវាទ ប្រពៃណី ទំនៀមទំលាប់ វប្បធម៌ អរិយធម៌ខ្មែរ អប់រំសីលធម៌ ចរិយាធម៌ដល់មហាជនតាមរយៈធម្មទេសនារបស់ព្រះអង្គ ក្នុងកម្មវិធីបុណ្យទាននានាផងដែរ។ លោកទេសរដ្ឋមន្ត្រី បានសរសើរចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងធម្មការ និងសាសនា ជាពិសេសនាយកដ្ឋានស្រាវជ្រាវ ផ្សព្វផ្សាយពុទ្ធសាសនាផ្សារភ្ជាប់សង្គម និងអង្គភាពពាក់ព័ន្ធដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ បង្កើតឲ្យមានវិជ្ជា និងរីកចម្រើនថ្មីៗបន្ថែមទៀត ទាក់ទងទៅនឹងការអប់រំយុវជន អំពីសីលធម៌ ចរិយាធម៌ គុណធម៌តាមបែបព្រះពុទ្ធសាសនាឲ្យស្គាល់ពីគុណមាតាបិតា គុណគ្រូ ឲ្យចៀសផុតពីការប្រើប្រាស់គ្រឿងញៀនជាដើម និងការពង្រឹងការគ្រប់គ្រងផ្សព្វផ្សាយព្រះធម៌តាមប្រព័ន្ធផ្សព្វផ្សាយនានា សំដៅរួមចំណែកកសាងធនធានមនុស្ស និងលើកស្ទួយវិស័យព្រះពុទ្ធសាសនា។

កម្មវិធីទស្សនាទានព្រះពុទ្ធសាសនា នៃក្រសួងធម្មការនិងសាសនា ជាកម្មវិធីអប់រំតាមបែបព្រះពុទ្ធសាសនា គឺមានសារសំខាន់ និងអត្ថន័យធំធេងបំផុតសម្រាប់អប់រំ ទូន្មាន កូនខ្មែរគ្រប់រូប រួមមាន៖ ឲ្យប្រកាន់ខ្ជាប់នូវអំពើល្អ សីលធម៌ គុណធម៌ ចរិយាធម៌ សេចក្ដីថ្លៃថ្នូរនៅក្នុងសង្គម។ ចៀសផុតពីគ្រឿងញៀន គ្រឿងស្រវឹង ពីការជួញដូរមនុស្ស។ ចៀសផុតពីអំពើហិង្សាក្នុងគ្រួសារ និងក្នុងសង្គម។ បង្ការគ្រោះថ្នាក់ចរាចរ។ ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ។ រួមចំណែករក្សា ភូមិ ឃុំ មានសុវត្ថិភាព។ អក្ខរកម្មឆ្ពោះទៅរកការសិក្សាពេញមួយជីវិត។ ការចិញ្ចឹមកូនបែបវិជ្ជមាន។ ក្នុងឱកាសនេះផងដែរ លោកទេសរដ្ឋមន្ត្រី បានមានប្រសាសន៍ថា ក្នុងនាមក្រសួងធម្មការ និងសាសនា ដែលជាសេនាធិការ ឱ្យរាជរដ្ឋាភិបាល សូមគាំទ្រនិងយកចិត្តទុកដាក់ ដល់ផែនការសកម្មភាពទាំងឡាយរបស់នាយកដ្ឋានស្រាវជ្រាវ ផ្សព្វផ្សាយពុទ្ធសាសនាផ្សារភ្ជាប់សង្គម និងជំរុញឲ្យមានការបន្តធ្វើសិក្ខាសាលាបែបនេះជារៀងរាល់ឆ្នាំជាបន្តទៀត។ ដោយអនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងធម្មការ និងសាសនា ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្នុងការដឹកនាំវិស័យសាសនា មានតួនាទីភារកិច្ចក្នុងការអនុវត្តកម្មវិធីមុំទី៤ នៃយុទ្ធសាស្ត្រចតុកោណ កំណើនការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឲ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ រួមទាំងការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។ ទោះជាយ៉ាងណាក្ដី ដើម្បីឈានដល់ការសម្រេចបាននូវគោលបំណងខាងលើនេះ គឺតម្រូវឲ្យមានការចូលរួមគាំទ្រយ៉ាងសកម្មពីគ្រប់ភាគី អនុវត្តន៍ និងអ្នកពាក់ព័ន្ធទាំងអស់។

ទន្ទឹមនឹងនេះផងដែរ លោកទេសរដ្ឋមន្ត្រី សូមសំណូមពរព្រះតេជព្រះគុណគ្រប់ព្រះអង្គ សូមព្រះមេត្តាយកចំណេះដឹង និងបទពិសោធន៍ដែលទទួលបានពីការចូលរួមសិក្ខាសាលានាពេលនេះ និងចំណេះដឹងដែលមានស្រាប់ទៅធ្វើការផ្សព្វផ្សាយ អប់រំ ដល់ពុទ្ធបរិស័ទ ពិសេសយុវវ័យ ឲ្យយល់ដឹងទាំងច្បាប់រដ្ឋ និងច្បាប់សាសនា មានសីលធម៌ សុជីវធម៌ ក្នុងការរស់នៅ ដឹងគុណមាតាបិតា គុណគ្រូ ស្គាល់បុណ្យ ស្គាល់បាប ជៀសផុតពីការសេពគ្រឿងញៀន គ្រឿងស្រវឹង យល់ដឹងពីច្បាប់ចរាចរណ៍ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរជាដើម តាមរយៈការសម្ដែងព្រះធម៌ទេសនាក្នុងកម្មវិធីបុណ្យ និងពិធីជួបជុំនានា៕ ដោយៈបញ្ញាស័ក្ដិ

## ក្រសួងការងារ មិនអនុញ្ញាត ឲ្យជនបរទេស បើកអាជីវកម្ម និងមុខរបរ ចំនួន១០ នៅលើទឹកដីកម្ពុជា

https://www.dap-news.com/archives/ ByID:112 Posted on 28 August 2019 | 11:15

ភ្នំពេញ ៖ យោងតាមការប្រកាស របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជា ស្ដីពីការកំណត់ប្រភេទមុខរបរ និងការងារដែលត្រូវបានហាមឃាត់ ចំពោះជនបរទេសនៅកម្ពុជា នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩នេះ ហាមឃាត់សកម្មភាពស្វ័យនិយោជន៍ដោយជនបរទេស នូវមុខរបរ និងការងារចំនួន១០មុខ។

ការងារទាំង១០នោះរួមមាន ៖ អ្នកបើកបរយានជំនិះគ្រប់ប្រភេទជាលក្ខណៈអាជីវកម្ម , អ្នកលក់ដូរដោយមធ្យោបាយថ្មើជើង ឬយានជំនិះគ្រប់ប្រភេទនៅតាមទីសាធារណៈ , អ្នកម៉ាស្សា ចាប់សរសៃតាមទីសាធារណៈ , អ្នកកាត់សក់ អ៊ុតសក់ និងថែរក្សាសម្ផស្ស , អ្នកផ្ដល់សេវាកម្មដេរ និងសម្អាតស្បែកជើង , អ្នកកាត់ដេរ , អ្នកប៉ះកង់ ជាងជួសជុលយានយន្ត , អ្នកផលិតវត្ថុអនុស្សាវរីយ៍ខ្មែរ , អ្នកផលិតឧបករណ៍ភ្លេងខ្មែរ បាត្រលោក ព្រះពុទ្ធរូប និងជាងទងជាងថ្មៃត្បូងពេជ្រ។ ក្រសួងការងារនឹងមិនផ្ដល់ ឬមិនបន្តសុពលភាពបណ្ណ ឬសៀវភៅការងារដល់ជនបរទេស ដែលកំពុងប្រកបមុខរបរ និងការងារដូចមានកំណត់ក៕

## មន្ត្រីស្ថានអគ្គកុងស៊ុលចូលរួមកិច្ចប្រជុំជាមួយអាជ្ញាធរពាក់ព័ន្ធស្ដីពីការទូទាត់ប្រាក់សំណង ជូនសាច់ញាតិពលករនេសាទខ្មែរ 2 នាក់

https://www.facebook.com Consulate General in Sa Kaeo 28-08-2019

ថ្ងៃអង្គារ ១២រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី 27 ខែសីហា ឆ្នាំ2019។ មន្ត្រីស្ថានអគ្គកុងស៊ុលចូលរួមកិច្ចប្រជុំជាមួយអាជ្ញាធរពាក់ព័ន្ធ ស្ដីពីការទូទាត់ប្រាក់សំណងជូនសាច់ញាតិពលករនេសាទខ្មែរ 2 នាក់ដែលគ្រោះថ្នាក់ស្លាប់កាលពីថ្ងៃទី18 មិថុនា 2019 និងការប្រគល់ប្រាក់ឈ្នួលនៅសេសសល់ជូនពលករខ្មែរម្នាក់។ មន្ត្រីស្ថានអគ្គកុងស៊ុល រួមមាន លោក ណុប វង្ខា កុងស៊ុល លោក ចាន់ សៅរ័ត្ន ភ្នាក់ងារកុងស៊ុល និងលោក យន់ យ៉េន ជំនួយការអគ្គកុងស៊ុល បានចូលរួមក្នុងកិច្ចប្រជុំជាមួយអាជ្ញាធរពាក់ព័ន្ធកម្ពុជា-ថៃ នៅសាលាខេត្តត្រាត ស្ដីអំពីការប្រគល់ប្រាក់ឈ្នួលដែលនៅសេសសល់របស់ពលករឈ្មោះ យ៉ាត ចាន់នី និងការទូទាត់ប្រាក់សំណងគ្រោះថ្នាក់ការងារដល់ក្រុមគ្រួសារសពពលករខ្មែរពីរនាក់ឈ្មោះ កែវ ប៊ុនថៃ និង នី នាង ដែលបានស្លាប់ក្នុងហេតុការណ៍លិចទូកនេសាទថៃមួយគ្រឿងនៅខេត្ត ត្រាត កាលពីថ្ងៃទី ១៨ មិថុនា ២០១៩។

លទ្ធផលនៃកិច្ចប្រជុំនេះ គឺ

- ពលករឈ្មោះ យ៉ាត ចាន់នី ទទួលបានប្រាក់សេសសល់ចំនួន 2500បាត។

- សាច់ញាតិសពពលករនេសាទខ្មែរទាំងពីរ ទទួលបានប្រាក់សំណងគ្រោះថ្នាក់ការងារ ដូចខាងក្រោម៖

១. ម្ដាយសពពលករ កែវ ប៊ុនថៃ គឺអ្នកស្រី យឹម រិន ទទួលបានចំនួន ៨៤០.០០០ បាត (ប្រហែល ២៧.០០០ ដុល្លាអាមេរិក)។

២. ម្ដាយសពពលករ នី នាង គឺអ្នកស្រី រស់ ខេង ទទួលបាន ២៨០.០០០បាត។ ចំណែកប្រពន្ធសពពលករ នី នាង គឺ អ្នកស្រី ស្រីន ចាន់ថេត និងកូនឈ្មោះ នាង សេងហ៊ន ទទួលបាន ២៨០.០០០ ក្នុងម្នាក់ៗ សរុប ៥៦០.០០០បាត។ ប្រាក់ទាំងនេះនឹងប្រគល់ជាពីរដំណាក់កាល គឺលើកទី១ ចំនួន៥០ភាគរយ និងលើកទី២គឺរយៈពេល 5ឆ្នាំក្រោយ ចំនួន៥០ភាគរយទៀត។

-សាច់ញាតិពលករខ្មែរពីរនាក់ខាងលើ អាចបើកប្រាក់សំណងគ្រោះថ្នាក់ការងារទាំងនោះ ពីស្ថានទូតថៃនៅទីក្រុងភ្នំពេញ ក្នុងចុងខែ កញ្ញា ឆ្នាំ២០១៩៕

# ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៩

## សមត្ថកិច្ចកំពុងសួរមនុស្ស ១១ នាក់ រឿងលួចបម្រើផ្លូវភេទក្នុងបារ៍

https://www.postkhmer.com/ សុទ្ធ គឹមសឿន | Publication date 28 August 2019 | 14:37 ICT

**ភ្នំពេញៈ** មន្ត្រីនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃកាលពីម្សិលមិញបាន និងកំពុងសួរមនុស្សប្រុសស្រីចំនួន ១១ នាក់ បន្ទាប់ពីឃាត់ខ្លួនពេលចុះបង្ក្រាបនៅបារ៍មួយកន្លែងដែលមានឈ្មោះ «បាន់នីបារ៍» កាលពីយប់ថ្ងៃទី ២៦ ខែ សីហា ក្នុងសង្កាត់វត្តភ្នំ ខណ្ឌដូនពេញរាជធានីភ្នំពេញដោយបានរកឃើញមានបង្កប់សេវាបម្រើផ្លូវភេទ។

លោក ស ថេត ស្នងការនគរបាលរាជធានីភ្នំពេញបានថ្លែងថា ករណីនេះកម្លាំងរបស់លោកគ្រាន់តែសហការជាមួយមន្ត្រីការិយាល័យជួញដូរមនុស្ស និងការពារអនីតិជនប៉ុណ្ណោះ រីឯរបាយការណ៍ផ្សេងៗត្រូវបានប្រគល់ជូនការិយាល័យនោះទាំងអស់។ «យើងប្រគល់របាយការណ៍ឲ្យគេហើយគឺខាងការិយាល័យជួញដូរមនុស្ស និងការពារអនីតិជនជាអ្នកធ្វើការងារនេះ»។ ស្រដៀងគ្នានេះដែរមន្ត្រីនគរបាលខណ្ឌដូនពេញម្នាក់សុំមិនបញ្ចេញឈ្មោះបានឲ្យដឹងថាក្រុមការងារលោកគ្រាន់តែចូលរួមសហការទេ ក៏ប៉ុន្តែ «រឿងរបាយការណ៍ ឬគេចាត់ចែង និងសាកសួរអ្វីបន្តទៀត ខ្ញុំអត់ដឹងទេ»។

ដោយឡែកលោក អ៊ុន សំអាត នាយប៉ុស្តិ៍នគរបាលសង្កាត់វត្តភ្នំបានថ្លែងពីម្សិលមិញថាលោកបានចូលរួមក្នុងប្រតិបត្តិការនេះ ប៉ុន្តែលោកមិនដឹងពីនីតិវិធីរបស់មន្ត្រីជំនាញទេ «ខ្ញុំគ្រាន់តែទៅចូលរួមសហការជាមួយកម្លាំងការិយាល័យជួញដូរមនុស្ស និងការពារអនីតិជនហើយគេធ្វើយ៉ាងណាទៀតគឺរឿងគេទេ»។

កាលពីម្សិលមិញលោក ឡៅ លីន ប្រធានការិយាល័យជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃមិនបានធ្វើអត្ថាធិប្បាយជុំវិញករណីនេះទេ នៅមុនពេលលោកផ្តាច់ទូរស័ព្ទ។ ប៉ុន្តែលោក សំបូរ មាណ្ណារិទ្ធ អនុប្រធាននាយកដ្ឋានមន្ទីរប្រឆាំងការជួញដូរមនុស្ស និងអនីតិជននៃក្រសួងមហាផ្ទៃត្រូវបានសារព័ត៌មានរស្មីកម្ពុជាដកស្រង់សម្តីកាលពីថ្ងៃទី ២៦ សីហា ថា ការចុះបង្ក្រាបនេះបានឃាត់ខ្លួននារីរងគ្រោះចំនួន ៨ នាក់។ លោកបញ្ជាក់ថា ក្នុងនោះមានអនីតិជន (ក្រោមអាយុ ១៨ ឆ្នាំ) និងថៅកែប្រុសស្រី ២ នាក់រួមទាំងមេការម្នាក់ទៀតសរុបចំនួន ១១ នាក់។ ថៅកែស្រីជាជនជាតិខ្មែរ និងថៅកែប្រុសជាជនជាតិអូស្ត្រាលីឈ្មោះ ចន អាយុ ៧១ ឆ្នាំ។ ចំណែកមេការជាជនជាតិបរទេសដែលមិនប្រាប់ឲ្យស្គាល់អត្តសញ្ញាណ។ លោកបន្តថាក្រោយឃាត់ខ្លួននារីរងគ្រោះ សមត្ថកិច្ចក៏បានរកឃើញស្រោមអនាម័យមួយចំនួនធំ ទាំងប្រើរួច និងមិនទាន់ប្រើ ហើយត្រូវបាននាំយកទៅមន្ទីរប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនដើម្បីអប់រំ។ ដោយឡែកជនសង្ស័យជាថៅកែ និងមេការត្រូវបានបញ្ជូនមកសាកសួរនៅនាយកដ្ឋានមន្ទីរប្រឆាំងការជួញដូរមនុស្ស និងអនីតិជនដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការបន្តតាមនីតិវិធីច្បាប់។ រីឯទីតាំងនោះត្រូវបានសមត្ថកិច្ចបិទទ្វារបណ្តោះអាសន្ន៕

## សមត្ថកិច្ចសាកសួរមនុស្ស៤នាក់ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្ម

https://www.rfa.org/khmer/ ដោយ អាស៊ីសេរី 2019-08-28

សមត្ថកិច្ចជំនាញនៃក្រសួងមហាផ្ទៃ សាកសួរជនសង្ស័យ៤នាក់ ក្នុងនោះមានស្រីជនជាតិខ្មែរ២នាក់ និងបុរសជនជាតិបរទេស២នាក់ ក្រោយពីសង្ស័យថា ពួកគេ អាចជាប់ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចកម្លាំងមនុស្ស ៨នាក់នៅវង្គសាលមួយឈ្មោះ "បាន់នី" (Bunny) ក្នុងសង្កាត់វត្តភ្នំ រាជធានីភ្នំពេញ។

ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ លោក ជីវ ផល្លី ប្រាប់អាស៊ីសេរី នៅថ្ងៃទី២៨ ខែសីហា ថា សមត្ថកិច្ចនិងព្រះរាជអាជ្ញារងសាលាដំបូងរាជធានីភ្នំពេញ កំពុងសាកសួរជនសង្ស័យទាំង៤នាក់ ក្នុងនោះមានបុរសជនជាតិអូស្ត្រាលីវ័យ ៧១ឆ្នាំម្នាក់ ជាម្ចាស់វង្គសាល។

កាលពីថ្ងៃទី២៦ សីហា សមត្ថកិច្ចខណ្ឌដូនពេញ សហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានចុះឆែកឆេរវង្គសាល "បាន់នី" ដោយឃាត់ខ្លួនមនុស្ស១២នាក់។មុនការចាប់ខ្លួននេះ សមត្ថកិច្ចជំនាញនៃក្រសួងមហាផ្ទៃ បានចុះស៊ើបអង្កេតវង្គសាលមួយនេះជាច្រើនដង ក្រោយពីទទួលបានដំណឹងពីប្រជាពលរដ្ឋនៅមូលដ្ឋានប្រាប់ថា វង្គសាលដែលមានម្ចាស់ជនជាតិអូស្ត្រាលីនេះ មានបង្កប់សេវាផ្លូវភេទ និងប្រើក្មេងមិនទាន់គ្រប់អាយុ ឱ្យបម្រើការក្នុងហាង៕

## កិច្ចជំនួបផ្តល់បទសម្ភាសន៍ស្តីពី ការវិភាគស្ថានភាពកុមាររងគ្រោះដោយការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារដោយជនបរទេស

https://www.facebook.com/deputygovernoryousophear/ August 22 at 11:19 AM

ខេត្តសៀមរាបៈ នៅព្រឹកថ្ងៃពុធ ទី២១ ខែសីហា ឆ្នាំ២០១៩ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប និងលោកស្រី ឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការរងនគរបាលខេត្ត និងជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបផ្តល់បទសម្ភាសន៍ជាមួយ លោក ផល ឧត្តមសម្បត្តិ ទីប្រឹក្សាស្រាវជ្រាវជាជនជាតិខ្មែរ និងលោក ជែរីត ដាវីស (Jarrett Davis)

ទីប្រឹក្សាស្រាវជ្រាវជាជនបរទេស របស់អង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា។ កិច្ចជំនួបនេះ បានផ្តោតសំខាន់ទៅលើស្ថានភាពនៃការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទកុមារ ក្នុងវិស័យទេសចរណ៍។

នៅក្នុងកិច្ចជំនួបនេះ ផងដែលអ្នកស្រាវជ្រាវទាំងជនខ្មែរ និងបរទេស បានស្នើសុំឲ្យលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ធ្វើការចែករំលែកអំពីបទពិសោធន៍ក្នុងការបង្ការ ទប់ស្កាត់ ក៏ដូចជាការបង្ក្រាបបទល្មើសរំលោភបំពានលើកុមារដោយជនបរទេស នៅក្នុងខេត្តសៀមរាប។ ឆ្លើយតបទៅការស្នើសុំខាងលើ លេខាធិការដ្ឋានបានបង្ហាញអំពីយន្តការនៃការអនុវត្តសកម្មភាព និងកិច្ចសហប្រតិបត្តិការពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិដែលមានអាជ្ញាធរពាក់ព័ន្ធពីថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន និងមានអង្គការចូលរួមពីដៃគូនានាក្នុងខេត្តផងដែរ។ ដើម្បីឲ្យកិច្ចការពារកុមារពីការរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្លូវភេទពីជនបរទេស ឬពីអ្នកទេសចរណ៍ តាមរូបភាពឧត្តម្ភដល់កុមារ និងគ្រួសារកុមារ អ្នកស្ម័គ្រចិត្ត តាមរយៈសាសនានិងរូបភាពផ្សេងៗទៀត លេខាធិការដ្ឋាន បានស្នើសុំឲ្យមានកិច្ចសហការបន្ថែមទៀតពីបណ្តាអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីរួមគ្នាការពារកុមារ។

## ថៃបញ្ជូនពលករខ្មែរ ១៥នាក់ មកកម្ពុជាវិញ ពាក់ព័ន្ធករណី លួចឆ្លងដែន និងស្នាក់នៅខុសច្បាប់

https://www.dap-news.com/ ByID:030 Posted on 28 August 2019 | 19:28

ភ្នំពេញ៖ កម្លាំងសមត្ថកិច្ច ថៃសហការជាមួយ កម្លាំងនគរបាលកម្ពុជា បានបញ្ជូននិងទទួលពលករខ្មែរ ចំនួន ១៥នាក់ តាមច្រកអន្តរជាតិចាំយាម និងច្រកទ្វារព្រំដែនអន្តរជាតិដូង មកកម្ពុជាវិញ ពាកព័ន្ធករណីលួចឆ្លងដែន និងស្នាក់នៅខុសច្បាប់។ យោងតាមការចុះផ្សាយ របស់អគ្គនាយកដ្ឋាន អន្តោប្រវេសន៍កម្ពុជា បានឲ្យដឹងថា "កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារ ព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៨នាក់ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩នេះ"។ ក្រោយពីបានធ្វើការអប់រំណែនាំរួច កម្លាំងនគរបាលប៉ុស្តិ៍ បានអនុញ្ញាតពលករទាំងអស់ ឲ្យត្រឡប់ទៅផ្ទះវិញ។

ចំណែក កម្លាំងប៉ុស្តិ៍នគរបាលច្រក ទ្វារព្រំដែនអន្តរជាតិដូង ក៏បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៧នាក់ ផងដែរ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ពាកព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍ បានឲ្យដឹងថា ពលករខ្មែរទាំង ០៧នាក់នេះ មានស្រុកកំណើតនៅខេត្តតាកែវ ០១នាក់ ស្រី ០១នាក់, ខេត្តបាត់ដំបង ០៤នាក់ ស្រី ០១នាក់, ខេត្តសៀមរាប ០១នាក់ ស្រី ០១នាក់ និងខេត្តកំពត ០១នាក់ ៕ដោយ បាន ធារ៉ូ

## តំណាងស្ថានទូតបានជួបពិភាក្សាការងារជាមួយ ស្នងការអន្តោប្រវេសន៍សួនភ្លូ ទីក្រុងបាងកកករណីពលរដ្ឋខ្មែរ ៨៥នាក់

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 28-08-2019

នៅរសៀលថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ តំណាងស្ថានទូតបានជួបពិភាក្សាការងារជាមួយ Pol Lt Gen. Sompong Chingduang ស្នងការអន្តោប្រវេសន៍សួនភ្លូទីក្រុងបាងកកពាក់ព័ន្ធករណីពលរដ្ឋខ្មែរ ៨៥នាក់ បានស្នើឲ្យដោះលែង និងបានបញ្ជូនពួកគាត់ត្រឡប់ទៅកម្ពុជាវិញនៅថ្ងៃទី២៨ សីហា ២០១៩ នេះ។

## ពលករខ្មែរខុសច្បាប់៨៥នាក់ ត្រូវសមកិច្ចថៃបញ្ជូនខ្លួនអោយមានសេរីភាពវិញហើយ

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន 29-08-2019

ពលករខ្មែរខុសច្បាប់៨៥នាក់ត្រូវសមកិច្ចថៃបញ្ជូនខ្លួនអោយមានសេរីភាពវិញហើយ ម៉ោងជិត៥ល្ងាច ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ក្រោយពីពលករខ្មែរជាប់ឃុំ៤ខែ៣ថ្ងៃនៅក្នុងប្រទេសថៃ។ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន)

## ពលរដ្ឋខ្មែរ៨៥នាក់ ត្រូវបានអាជ្ញាធរថៃដោះលែង ក្រោយមានកិច្ចអន្តរាគមន៍ពីកម្ពុជា

https://www.facebook.com/ Ministry of Foreign Affairs and International Cooperation 29-08-2019

អាជ្ញាធរប្រទេសថៃ បានសម្រេចដោះលែងពលរដ្ឋខ្មែរចំនួន៨៥នាក់ ដែលត្រូវបានសមត្ថកិច្ចថៃ ចាប់ឃាត់ខ្លួន នៅជាយទីក្រុងបាងកក កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩កន្លងទៅពីបទឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់។ ការដោះលែងនេះ ធ្វើឡើង ក្រោយពីមានកិច្ចអន្តរាគមន៍ស្នើសុំជាបន្តបន្ទាប់របស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ និងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ។ អាជ្ញាធរថៃបានបញ្ជាក់ថា ថ្មីៗនេះ ប្រទេសថៃបានចេញច្បាប់ថ្មី ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ដែលត្រូវឱ្យមានការស៊ើបអង្កេតយ៉ាងតឹងរឹងដើម្បីតាមចាប់មេខ្យល់ ទើបបណ្តាលឱ្យមានការឃាត់ខ្លួនពលរដ្ឋខ្មែរទាំង៨៥នាក់ ក្នុងរយៈពេលយូរបែបនេះ។ មន្ត្រីស្ថានទូត តែងតែជួបសួរសុខទុក្ខជាប្រចាំជាមួយពលរដ្ឋខ្មែរទាំង៨៥នាក់ ក្នុងអំឡុងពេលជាប់ឃុំខ្លួននោះ។

សូមបញ្ជាក់ថា ពលរដ្ឋខ្មែរទាំង៨៥នាក់ បានត្រលប់មកដល់កម្ពុជាវិញហើយ នៅរសៀលថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ក្រោមការសម្របសម្រួលរបស់ស្ថានទូតកម្ពុជានៅទីក្រុងបាងកក ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ជាមួយនឹងអាជ្ញាធរថៃ៕

## ចាប់ខ្លួន២នាក់ប្តី-ប្រពន្ធ លក់ទារកទើបនឹងកើតទៅឲ្យឈ្មួញចិន

https://kbn.news/ August 29, 2019

វៀតណាម ៖ កម្លាំងសមត្ថកិច្ចបានបង្ក្រាបសកម្មភាពជួញដូរមនុស្ស ក្នុងនោះបានឃាត់ខ្លួនជនសង្ស័យ២នាក់ ប្តី-ប្រពន្ធ ដែលជាប់ពាក់ព័ន្ធនឹងករណីលក់ទារកទើបនឹងកើតទៅឱ្យឈ្មួញដែលជាជនជាតិចិន នៅព្រំដែន វៀតណាម-ចិន កាលពីពេលថ្មីៗកន្លងមកនេះ ។

សមត្ថកិច្ច បានបញ្ជាក់ថា ជនសង្ស័យដែលមានវ័យ២២ឆ្នាំ និង២៨ឆ្នាំ ត្រូវបានឃាត់ខ្លួន នៅច្រកព្រំដែន Chi Ma ក្នុងស្រុក Loc Binh ខេត្ត Lang Son ភាគខាងជើងប្រទេសវៀតណាម នៅពេលពួកគេព្យាយាមឆ្លងចូលទៅចិន ។ ចំណែកទារកដែលទើបនឹងកើត មិនមែនជាកូនបង្កើតរបស់ជនសង្ស័យទាំងពីរនាក់ឡើយ ពោលគឺ ពួកគេទទួលបានទារកពីស្ត្រីម្នាក់ទៀត ដែលធ្វើការនៅមន្ទីរពេទ្យមួយកន្លែង នៅខេត្ត Dong Nai ភាគខាងត្បូងប្រទេសវៀតណាម ។ សមត្ថកិច្ចបញ្ជាក់បន្ថែមទៀតថា បន្ទាប់មកពួកគេទទួលបានទារក ជនសង្ស័យបានផ្តល់ប្រាក់១០លានដុង ប្រមាណជា៤៣០ដុល្លារអាមេរិក ឱ្យស្ត្រីរូបនោះ ដើម្បីយកទៅធ្វើសំបុត្រកំណើតក្លែងក្លាយ ។ ក្រុមជនសង្ស័យមានគម្រោងលក់ទារកនោះទៅឱ្យឈ្មួញចិនម្នាក់( មិនស្គាល់អត្តសញ្ញាណ ) ក្នុងតម្លៃ២,១៥០ដុល្លារ ក្នុងទារកម្នាក់ ។

សូមជម្រាបថា បច្ចុប្បន្ន ករណីត្រូវបានបញ្ជូនទៅកាន់តុលាការវៀតណាម ចាត់ការតាមនីតិវិធីច្បាប់ ខណៈទារកខាងលើ ត្រូវបានបញ្ជូនទៅកាន់មន្ទីរសង្គមកិច្ចខេត្ត Lang Son ។ មកទល់ពេលនេះគេមិនទាន់ដឹងថា ក្រុមជនសង្ស័យធ្លាប់ធ្វើសកម្មភាពល្មើសនេះប៉ុន្មានលើកមកហើយទេ ៕

# ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៩

## ក្រសួងការងារ បន្តចុះយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងសិប្បកម្មផលិតឥដ្ឋនៅខេត្តកណ្តាល

https://www.facebook.com/mlvt.gov.kh/ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ 30-08-2019

(កណ្តាល)៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតែបន្តយុទ្ធនាការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅតាមសិប្បកម្មផលិតឥដ្ឋជាបន្តបន្ទាប់ ដើម្បីផ្សព្វផ្សាយ និងទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងតាមដានការអនុវត្តលក្ខខណ្ឌការងារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ នៅទីតាំងសិប្បកម្មផ

លិតឥដ្ឋនានាក្នុងខេត្តកណ្តាល។ ថ្នាក់ដឹកនាំក្រសួងបានបញ្ជាក់ថា វិធានការលើកនេះ គឺជាវិធានការក្តៅគគុកចំពោះម្ចាស់សិប្បកម្មណា ដែលនៅតែគគ្លើនប្រើប្រាស់ពលកម្មកុមារនៅក្នុងសិប្បកម្មខ្លួន ដោយមិនលើកលែង និងគ្មានការយោគយល់ឡើយ។

យុទ្ធនាការនេះបានចាប់ផ្តើមឡើងចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ក្រោមការដឹកនាំរបស់លោក វ៉េង ហៀង ប្រធាននាយកដ្ឋានការងារកុមារ នៃក្រសួងការងារ និងលោក ធុល នាង ប្រធានមន្ទីរការងារខេត្តកណ្តាល អមដោយមន្ត្រីអធិការការងារថ្នាក់ជាតិ និងខេត្តកណ្តាល។ លោក វ៉េង ហៀង បានបញ្ជាក់ថា ស្ថានភាពទូទៅនៃលក្ខខណ្ឌការងារនៅសិប្បកម្មផលិតឥដ្ឋនៅស្រុកមុខកំពូល ដែលមានចំនួន២០សិប្បកម្មនោះ ឃើញថាមានវឌ្ឍនភាពគួរកត់សម្គាល់។ លោកបានបន្តថា លក្ខខណ្ឌការងារនៅក្នុងសិប្បកម្មឥដ្ឋទាំងនោះមានភាពល្អប្រសើរ ដោយសារការប្រើប្រាស់ម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ និងស្វ័យប្រវត្តិដែលកាត់បន្ថយគ្រោះថ្នាក់ការងារ ទំហំផលិតកម្មមានការកើនឡើង ២-៣ដងបើធៀបនឹងឆ្នាំ២០១៦ គ្មានការបំពុលបរិស្ថានដោយផ្សែង ដោយសារដុតឧស និងអង្កាមនៅក្នុងឡកម្តៅ ដែលកន្លងមកមានឡកម្តៅឥដ្ឋខ្លះដុតក្រណាត់ដូចកាលពីឆ្នាំ២០១៦ និងការអនុវត្តច្បាប់ស្តីពីការងារមានលក្ខណៈកាន់តែល្អប្រសើរ កំណើនប្រាក់ឈ្នួល និងការបង់របបបេឡាជាតិសន្តិសុខសង្គមដោយនិយោជក។

ក្រុមការងារក៏បានជួបសម្ភាសន៍ជាមួយនិយោជក និយោជិត និងក្រុមគ្រួសាររស់នៅបរិវេណសិប្បកម្មផលិតឥដ្ឋ ដើម្បីតាមដានការយល់ដឹងស្តីពីការទប់ស្កាត់ពលកម្មកុមារ ការលើកកម្ពស់ឱកាសអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់កុមារងាយរងគ្រោះ និងកម្មករនិយោជិតវ័យក្មេង ជាពិសេសការវាយតម្លៃស្ថានភាពបំណុលនៃក្រុមគ្រួសារដែលចូលរួមសកម្មភាពផលិតឥដ្ឋ។

សូមជម្រាបថា ក្រសួងការងារ បានកំណត់ទិសដៅលុបបំបាត់ពលកម្មកុមារនៅតាមសិប្បកម្មផលិតឥដ្ឋឱ្យបានត្រឹមឆ្នាំ២០២០ ហើយយុទ្ធនាការខាងលើនេះ គឺជាការចូលរួមជំរុញទិសដៅនេះផងដែរ៕

## ពលករ ខ្មែរ 85 នាក់ ដែលត្រូវសមត្ថកិច្ចថៃឃាត់ខ្លួននៅទីក្រុងបាងកក កាលពីថ្ងៃ ទី 26 ខែមេសា ឆ្នាំ 2019 ត្រូវ បានដោះលែង និងជូនវិលត្រឡប់ទៅកម្ពុជាវិញកាលពីរសៀល ថ្ងៃទី 28 ខែសីហា ឆ្នាំ 2019 តាមច្រកអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/ Consulate General in Sa Kaeo 29-08-2019

ថ្ងៃ ពុធ ១៣រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី28 ខែសីហា ឆ្នាំ 2019 ពលករខ្មែរទាំង85 នាក់ខាងលើត្រូវបានមេខ្យល់នាំឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ កាលពីថ្ងៃទី25 ខែមេសា ឆ្នាំ2019 ដើម្បីមកធ្វើការនៅក្នុងខេត្តក្បែរទីក្រុងបាងកក។ ពេលធ្វើដំណើរពីព្រំដែនកម្ពុជា-ថៃ ទៅកាន់ខេត្តគោលដៅ ឆ្លងកាត់ទីក្រុងបាងកក នៅថ្ងៃទី26 ខែមេសា ឆ្នាំ 2019 ពលករទាំង 85 នាក់ ក៏ត្រូវបានសមត្ថកិច្ចទីក្រុងបាងកកចាប់ឃាត់ខ្លួន និងឃុំខ្លួននៅប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍សួនភ្លូ ទុកធ្វើជាសាក្សីដើម្បីប្តឹងដាក់បន្ទុកលើមេខ្យល់និងបក្សពួកជាជនជាតិថៃសរុប 7 នាក់ ពីបទជួញដូរមនុស្ស។

នៅថ្ងៃទី 10 ខែកក្កដា ឆ្នាំ2019 សមត្ថកិច្ច នគរបាល សួនភ្លូ ទីក្រុងបាងកក បានបញ្ជូនពលករចំនួន 61 នាក់មកផ្ញើឃុំខ្លួនបន្តនៅប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍អារញ្ញប្រាថេត ខេត្តសាកែវ (ស្រះកែវ ) ។ ស្ថានអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំខេត្តសាកែវ និងស្ថានទូតកម្ពុជានៅទីក្រុងបាងកក បានប្រឹងប្រែងអន្តរាគមន៍តាមផ្លូវច្បាប់ដោះស្រាយជាមួយអាជ្ញាធរថៃ ដើម្បីដោះលែងបងប្អូនពលករទាំង85 នាក់អោយមានសេរីភាពឡើងវិញ និងជូនវិលទៅកម្ពុជាវិញនៅរសៀលថ្ងៃទី 28 ខែសីហា ឆ្នាំ 2019។

ស្ថានអគ្គកុងស៊ុល សូមអំពាវនាវចំពោះបងប្អូនខ្មែរ ជាពិសេសបងប្អូនដែលមានបំណងមកធ្វើការនៅប្រទេសថៃ មេត្តាកុំជឿមេខ្យល់ ឬជនណានាំឆ្លងដែនដោយខុសច្បាប់ ព្រោះនឹងរងគ្រោះដូចករណីខាងលើ ត្រូវជាប់ឃុំ

ខាតពេល និងបាត់បង់ចំណូលដែលអាចរកបានប្រចាំថ្ងៃមុនពេលត្រូវសមត្ថកិច្ចថៃចាប់ខ្លួន។ បងប្អូនគួរស្វែងរកក្រុមហ៊ុនស្របច្បាប់ ដើម្បីរៀបចំជូនបងប្អូនបានមកធ្វើការដោយស្របច្បាប់នៅប្រទេសថៃ។ ការធ្វើការគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវ ប្រឈមនឹងការចាប់ខ្លួន ពុំទទួលបានការថែទាំសុខភាព និងពុំទទួលបានសំណងក្នុងករណីជួបគ្រោះថ្នាក់ការងារ៕

## ពលករខ្មែរ៨៥នាក់ដែលថៃចាប់ដាក់ឃុំ ប្រឈមនឹងបញ្ហាបំណុល ក្រោយត្រូវបានដោះលែងមកវិញ

https://vodhotnews.com/ លោក ត្រាន់ តិចសេង| ២៩ សីហា ២០១៩ ម៉ោង ៥:២៧ ល្ងាច

ពលករខ្មែរដែលឆ្លងដែនខុសច្បាប់ចំនួន ៨៥នាក់ ត្រូវបានដោះលែង និងបានវិលត្រឡប់មកដល់ផ្ទះសម្បែងរបស់ពួកគេវិញហើយកាលពីថ្ងៃម្សិលមិញនេះ ប៉ុន្តែ ពលករទាំងនោះកំពុងជួបបញ្ហាជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ។ យោងតាមទំព័រ Facebook ផ្លូវការរបស់ក្រសួងការបរទេស ការដោះលែងនេះ គឺធ្វើឡើងក្រោយពីមានកិច្ចអន្តរាគមន៍ស្នើសុំជាបន្តបន្ទាប់ពីស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ និងស្ថានកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ។

ប្រភពដដែលឱ្យដឹងថា ការដែលអាជ្ញាធរថៃទើបតែដោះលែងពលករខ្មែរទាំងនោះ គឺដោយប្រទេសក្បែរខាងរបស់កម្ពុជាមួយនេះ បានដាក់ចេញច្បាប់ថ្មីក្នុងការទប់ស្កាត់ការជួញដូរមនុស្ស ដែលទាមទារការស៊ើបអង្កេតម៉ត់ចត់ដើម្បីឈានទៅចាប់ខ្លួនមេខ្យល់។

ពលរដ្ឋរស់នៅភូមិឃ្លាយ ឃុំតាគង់ ស្រុកម៉ាឡៃ លោក គង់ សុផាត ឱ្យដឹងថា កូនគាត់ពីរនាក់ប្តីប្រពន្ធ បានត្រឡប់មកផ្ទះវិញហើយនៅព្រឹកនេះ ហើយថា គាត់កំពុងជួបបញ្ហាវិលសំបំណុលមីក្រូហិរញ្ញវត្ថុ ដោយសារកូនៗត្រូវជាប់ឃុំ និងមិនអាចចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃបាន។ លោក សុផាត លើកឡើងថា៖ **«កម្ពុជាយើងរាល់ថ្ងៃហ្នឹង សំខាន់ទៅលើធ្វើការចំណាកស្រុកដើម្បីយកប្រាក់មកផ្គត់ផ្គង់ក្រុមគ្រួសារ។ ដល់ពេលគ្នាជាប់ឃុំនេះ គ្នាខាតប្រាក់ច្រើន ដោះបំណុលគេរហូតដល់ម្នាក់ ៣ម៉ឺនបាតទៅ ៤ម៉ឺនបាតអីណោះ ព្រោះអ្នកជំពាក់គេ បានបង្ខំទៅរកស៊ីចំណាកស្រុក។ ពេលគ្នាទៅចំណាកស្រុកនោះខុសច្បាប់ទៀត ដល់គេចាប់ហឹត[រឹត]ខាតទៀត។ បើអត់មានប៉ះពាល់នឹងគេចាប់គេអី ទៅដល់កន្លែងគេធ្វើលាក់បំបាំងចេះតែបានលុយបន្តមកចិញ្ចឹមជីវភាពគ្រួសារ និងជួយដោះបំណុលមីក្រូហិរញ្ញវត្ថុ»**។

លោក ផ្លុង ជាតិ ពលរដ្ឋរស់នៅភូមិមុខពែន ឃុំមុខពែន ស្រុកពួក ដែលមានប្អូនថ្លៃ និងប្អូនជីដូនមួយស្ថិតក្នុងចំណោមពលករទាំង ៨៥នាក់នោះ បានឱ្យដឹងថា ប្អូនជីដូនមួយនិងប្អូនថ្លៃរបស់លោក កំពុងជួបបញ្ហាមិនអាចដោះបំណុលដែលពួកគេបានខ្ចីសម្រាប់ការធ្វើចំណាកស្រុក។ លោក ផ្លុង ជាតិ ប្រាប់ថា៖ **«យើងមិនមានលុយមានកាក់ ទំល។ អីចឹងទៅ យើងមានតែខ្ចីអ្នកជិតខាងទៅ ដើម្បីក្រែងបានទៅដោយសុខស្រួល គ្មានជាប់ជំពាក់នៅកន្លែងណាមួយ។ គ្មានជាប់ជំពាក់ដូចជាកន្លែងគេចាប់បានចាប់អីពួ។ នឹកឃើញយើងទៅបានសុខបានស្រួលនុះ ដល់ពេលទៅជួបឧបសគ្គអីចឹង ដូចគ្នាខ្ចីប្រាក់អ្នកជិតខាងផង គ្នាមកវិញគ្នាបានអីសង»**។

ពលរដ្ឋម្នាក់ទៀត រស់នៅស្រុកព្រះនេត្រព្រះ កញ្ញា សំឡី ពៅ ដែលជាប្អូនស្រីពលករដែលត្រូវបានអាជ្ញាធរថៃចាប់ដាក់ឃុំផងដែរនោះ បានឱ្យដឹងដែរថា ខ្លួនកំពុងប្រឈមបញ្ហាដោះបំណុលជំនួសបងប្រុស ដែលទើបត្រូវគេចាប់បញ្ជូនត្រឡប់មកវិញ។ កញ្ញា ពៅ បន្ថែមថា បងប្រុសកញ្ញាគ្មានលុយធ្វើលិខិតឆ្លងដែន ក៏សម្រេចទៅដោយខុសច្បាប់ដើម្បីអាចធ្វើការរកលុយធ្វើលិខិតស្របច្បាប់នៅទីនោះ។

លោក ស៊ុំ ចន្ទគា មន្ត្រីឃ្លាំមើលសិទ្ធិមនុស្សនៃសមាគមអាដហុកប្រចាំខេត្តបន្ទាយមានជ័យ ដែលបានចូលរួមអន្តរាគមន៍ជាមួយអាជ្ញាធរកម្ពុជាឱ្យដោះលែងពលករទាំង ៨៥នាក់នោះ បានរិះគន់អាជ្ញាធរកម្ពុជា ដែលមិនអាចទប់ស្កាត់ការឆ្លងដែនខុសច្បាប់ដែលនាំឱ្យមានការចាប់ខ្លួនពីតម្រួតថៃជាបន្តបន្ទាប់។ លោក ស៊ុំ ចន្ទគា មានប្រសាសន៍ថា៖ **«រដ្ឋាភិបាលយើងច្រើនអាណត្តិមកហើយ មិនទាន់បានធ្វើអ្វីដែលដើម្បីឱ្យខ្មែរលែងជាប់គុកទេ និយាយឱ្យចំ។ យើង**

មានកម្លាំងទៅលក់ទីផ្សារនៅថៃ ប៉ុន្តែ មិនដែលបានសម្រួលធ្វើម៉េចឱ្យថៃហ្នឹងជួយខ្មែរកុំឱ្យជាប់គុកបានរហូតដល់រាល់ថ្ងៃហ្នឹង»។

អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាលោក កេត សោផាន់ បដិសេធបកស្រាយបន្ថែមជុំវិញបញ្ហានេះនៅថ្ងៃនេះ។ ពលករខ្មែរ ៩០នាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនកាលពីថ្ងៃទី២៦ ខែមេសាកន្លងមក អំឡុងពេលពួកគេឆ្លងដែនស្វែងរកការងារធ្វើនៅប្រទេសថៃ ប៉ុន្តែ ពលករ ៥នាក់ ត្រូវបានដោះលែងវិញដោយសារពួកគេមានឯកសារឆ្លងដែនត្រឹមត្រូវ៕

## លោក សុខ ទូច៖ ពលរដ្ឋចំណាកស្រុក រត់ទៅធ្វើការនៅថៃ ភាគច្រើនខ្ចីលុយធនាគារ ជាច្រើនកន្លែង ក្នុងពេលតែមួយ

https://www.dap-news.com/ ByID:112 Posted on 29 August 2019 | 12:49

ភ្នំពេញ ៖ ក្នុងសន្និសីទសារព័ត៌មានស្តីពី មីក្រូហិរញ្ញវត្ថុ និងផលប៉ះពាល់នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ នាទីស្តីការគណៈរដ្ឋមន្ត្រី លោក សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បានថ្លែងអះអាងថា ប្រជាពលរដ្ឋខ្មែរធ្វើការចំណាក់ស្រុក រត់ទៅធ្វើការនៅថៃភាគច្រើន ដោយសារពួកគេបានខ្ចីលុយធនាគារជាច្រើន កន្លែងក្នុងពេលតែមួយ ហើយបង់លុយធនាគារ មិនទាន់អស់៕ ដោយ ធី លីថូ

## កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនាំឲ្យកសិករបាត់បង់ផ្ទះ ដី និងគ្រួចចំណាកស្រុក

https://khmer.voanews.com/ 30 សីហា 2019 ខាន់ សុគុំមនោ ផន បុប្ផា

ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប៖ កាលពីពីរឆ្នាំមុន អ្នកស្រី ផែល ហឿន ដែលមានកូនប្រាំនាក់ បានសម្រេចចិត្តយកប្លង់ដីផ្ទះ ដែលអ្នកស្រីកំពុងរស់នៅសព្វថ្ងៃទៅតម្កល់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធនាគារភូមិដើម្បីខ្ចីប្រាក់ចំនួន៨០០០ដុល្លារ។ អ្នកស្រី ផែល ហឿន ដែលមានវ័យ៤៧ឆ្នាំ ធ្លាប់ជាអ្នកធ្វើការឲ្យគេ។ ចំណូលប្រចាំថ្ងៃរបស់អ្នកស្រីគឺអាស្រ័យទៅលើតម្រូវការអតិថិជនដែលត្រូវការកម្លាំងពីអ្នកស្រី។ អ្នកស្រីយកប្រាក់ដែលខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅទិញដីទំហំបួនហិកតា ក្នុងបំណងដាំដំឡូងមី ជាដំណាំដែលប្រជាជនភាគច្រើននៅក្នុងស្រុកអង្គរជុំនិយមដាំ។ បច្ចុប្បន្នអ្នកស្រីនិងក្រុមគ្រួសារពុំអាចដាំដំឡូងមីបាន ដោយសារពួកគេត្រូវចំណាយពេលធ្វើការដើម្បីរកចំណូលប្រចាំថ្ងៃមកផ្គត់ផ្គង់ការចាយវាយផ្សេងៗ និងសម្រាប់បង់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រចាំខែដែលសរុបប្រហែល៤០០ដុល្លារ។ ក្នុងខែមិថុនាកន្លងទៅនេះ អ្នកស្រីបានលក់ដីចំនួន២ហិកតាគឺពាក់កណ្តាលនៃដីដែលអ្នកស្រីបានទិញគ្រោងដាំដំឡូងមីនោះ។ អ្នកស្រីលក់ដីនោះបានជាង៣០០០ដុល្លារ ដើម្បីសងបំណុលម្ចាស់បំណុលឯកជននៅក្នុងភូមិដែលអ្នកស្រីបានខ្ចីដើម្បីយកទៅសងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ អ្នកស្រីមានប្រសាសន៍យ៉ាងដូច្នេះថា៖ «លក់២ហិកតាហើយ។ មើលទៅវាត់មិនរួច»។ សព្វថ្ងៃនេះ អ្នកស្រីត្រូវសងលុយចំនួន៦០០០ដុល្លារទៀតទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធនាគារភូមិ ដែលបានដូរឈ្មោះមកជា LOLC។ ដើម្បីជួយដោះបំណុល ដែលអ្នកស្រីត្រូវបង់ជាង២០០ដុល្លារជារៀងរាល់ខែ ប្តីរបស់អ្នកស្រី ផែល ហឿន ត្រូវចាកចេញទៅធ្វើការឲ្យគេនៅក្នុងស្រុកក្បែរៗនោះ។ ប្តីរបស់អ្នកស្រីរកបានប្រហែល២ម៉ឺនរៀលក្នុងមួយថ្ងៃ។ រីឯកូនស្រីរបស់អ្នកស្រីបានចាកចេញទៅធ្វើការនៅប្រទេសថៃ ហើយរកប្រាក់បានចាប់ពី៣ទៅ៤ម៉ឺនរៀលក្នុងមួយថ្ងៃ។

សមាជិកគ្រួសាររបស់អ្នកស្រីចូលរួមចំណែកជួយគ្រួសារទៅតាមសមត្ថភាពរបស់ពួកគេ នៅពេលដែលពួកគេមានប្រាក់។ ឥឡូវនេះ គ្រួសារអ្នកស្រីត្រូវបង់ជាង២០០ដុល្លារក្នុងមួយខែ ហើយចំនួននេះនឹងចុះជាប្រចាំពីមួយខែទៅមួយខែរយៈពេលបួនឆ្នាំខាងមុខ រហូតដល់អ្នកស្រីសងបំណុលអស់។ អ្នកស្រី ផែល ហឿន មានបងប្អូនចំនួនប្រាំពីនាក់។ ពួកគាត់ទាំងអស់សុទ្ធតែខ្ចីលុយពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រួមទាំងកូនពីរនាក់របស់អ្នកស្រីផងដែរ។ ពួកគេប្រើប្រាស់

ប្រាក់ទាំងនោះសម្រាប់ការចំណាយផ្សេងៗ ដូចជាធ្វើចម្ការសាងសង់ផ្ទះ ការចំណាយទៅលើថ្នាំសង្កូវ និងការចំណាយប្រចាំថ្ងៃផ្សេងទៀតផងដែរ។ គ្រួសារផ្សេងៗទៀតប្រហែល៣៥០០គ្រួសារនៅក្នុងឃុំគោកដូងរស់នៅដោយពឹងផ្អែកទៅលើការដាំដំឡូងមី និងប្រាក់ពីសមាជិកគ្រួសារដែលចាកចេញទៅប្រទេសថៃដើម្បីរកប្រាក់សងបំណុល។

វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាកំពុងតែនាំឲ្យគ្រួសារជាច្រើនជាប់បំណុលដែលនាំឲ្យមានការបង្ខំឲ្យលក់ដី ការចាកចេញពីប្រទេសដើម្បីទៅធ្វើការនៅក្នុងប្រទេសផ្សេងទៀតនិងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ។ នេះបើយោងទៅតាមការរកឃើញរបស់អង្គការធ្វើការដើម្បីសិទ្ធិមនុស្ស (Licadho) និងសមាគមជាងត្នោត។ វិស័យមីក្រូហិរញ្ញវត្ថុទាក់ទាញការចាប់អារម្មណ៍នៅអំឡុងទសវត្សរ៍១៩៧០ ដែលកាលនោះ ធនាគារ Grameen Bank បានផ្តល់ប្រាក់កម្ចីខ្នាតតូចដល់ប្រជាជននៅប្រទេសបង់ក្លាដេស។ នៅតាមតំបន់ជាច្រើននៅក្នុងពិភពលោក ប្រាក់កម្ចីដែលមានការប្រាក់ទាប ឬគ្មានការប្រាក់ ហើយមានចំនួនតិចតួចចាប់ពី២០ទៅ១០០ដុល្លារគឺល្មមនឹងអាចចាប់ផ្តើមអាជីវកម្ម ឬចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ចដទៃៗទៀត ដូចជាការទិញដីធ្លីបន្ថែមដែលអាចប្រែក្លាយជាកសិដ្ឋាន បង្កើតប្រាក់កម្រៃផ្គត់ផ្គង់ខ្លួនឯង។ ដើមឡើយអង្គការផ្តល់ប្រាក់កម្ចីជាច្រើនគឺជាអង្គការដែលមិនយកកម្រៃដោយគិតពីផលប្រយោជន៍សង្គម។ ប៉ុន្តែសព្វថ្ងៃ ភាពចម្រូងចម្រាស់បានធ្វើឲ្យវិស័យនេះរងការប៉ះពាល់។ អ្នករិះគន់ចោទសួរថា តើការផ្តល់ប្រាក់កម្ចីបែបផែនតូចនេះជួយសម្រាលទុក្ខលំបាកប្រជាជនក្រីក្រ ឬធ្វើឲ្យពួកគេកាន់តែក្រទៅៗ ដោយសារតែមធ្យោបាយទាក់ទាញអតិថិជនតាមវិធីសាស្ត្រគ្រប់បែបយ៉ាង ដោយមិនខ្វល់លទ្ធភាពដែលគេអាចសងបាន បូករួមទាំងការប្រាក់ដ៏ខ្ពស់។

អ្នកភូមិនៅក្នុងឃុំគោកដូង គឺជាផ្នែកតូចមួយនៃចំនួនមនុស្សចំនួន២,៤លាននាក់ក្នុងប្រទេសកម្ពុជាដែលបានយកប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ប្រាក់កម្ចីទាំងអស់មានចំនួន៨ពាន់លានដុល្លារ ដែលជាចំនួនប្រាក់កម្ចីច្រើនលើសលប់។នេះបើយោងតាមរបាយការណ៍អង្គការទាំងពីរ។ របាយការណ៍នេះបានឲ្យដឹងថាប្រទេសកម្ពុជាមាន«អត្រាមធ្យមភាគខ្ពស់ជាងគេបង្អស់នៅលើពិភពលោកក្នុងការខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ»។

លោកមេឃុំ កែម ហាំ ដែលបានយកលុយកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែរនោះបានឲ្យដឹងថា ប្រហែលពាក់កណ្តាលនៃចំនួនគ្រួសារនៅក្នុងឃុំគោកដូង ជំពាក់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហើយអ្នកភូមិប្រហែល១០០០នាក់បានចាកចេញទៅធ្វើការនៅប្រទេសថៃ។ លោកនិយាយថា អ្នកភូមិខ្ចីប្រាក់ពីពីរទៅបីកន្លែងដើម្បីទិញដីធ្វើចម្ការ និងធ្វើអាជីវកម្មតូចធំ និងសាងសង់ផ្ទះ។ លោកបានប្រាប់វីអូអេថា នៅក្នុងឆ្នាំនេះ អ្នកខ្ចីលុយពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីរនាក់បានរត់ចោលស្រុកដោយសារពួកគេគ្មានលទ្ធភាពសងប្រាក់។ មិនមែនមានតែពួកនោះទេដែលប្រឈមនឹងការលំបាកនេះ ព្រោះកូនបំណុលនៅកម្ពុជាម្នាក់ៗជាប់បំណុលជាមធ្យមចំនួន៣៣៧០ដុល្លារ ខណៈកំណើនផលិតផលក្នុងស្រុកសរុបមានចំនួន១៣៨៤ដុល្លារក្នុងឆ្នាំ២០១៧។ នេះបើយោងតាមរបាយការណ៍អង្គការពីរនេះ។

## មានករណីផ្ទាំងស៊ីម៉ង់រលំធ្លាក់សង្កត់បុរសពលករខ្មែរម្នាក់ បណ្តាលឲ្យស្លាប់ភ្លាមៗ នៅកន្លែងកើត

https://www.facebook.com/ Pheak Tra Live 29-08-2019

29/08/19 មានករណីផ្ទាំងស៊ីម៉ង់រលំធ្លាក់សង្កត់បុរសពលករខ្មែរម្នាក់ ឈ្មោះ UO Satuot អាយុ ២៨ឆ្នាំ បណ្តាលឲ្យស្លាប់ភ្លាមៗ នៅកន្លែងកើត ។ ហេតុការណ៍នេះបានកើតឡើងកាលពីវេលាម៉ោង ១១:០០ ថ្ងៃត្រង់ត្រូវ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ នៅការដ្ឋានសំណង់សាងសង់អាគារមួយកន្លែងម្តុំ( Soi) អេិកការផៃ ១៣៩ សង្កាត់បាងណាមជឹត ស្រុកម៉ឿង ខេត្តសាមុតសាខន ប្រទេសថៃ ។ បច្ចុប្បន្ន សាកសព ជនរងគ្រោះត្រូវបានសមត្ថកិច្ចថៃ ប៉ុស្តិ៍បាងណាមជឹតបញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យក្នុងតំបន់កើតហេតុ ។

## ស្ថានទូតកម្ពុជាប្រចាំ ប្រទេសថៃ បានជួយសម្រួលឯកសារជូនសាច់ញាតិសពពលករខ្មែរ ឈ្មោះ អ៊ូ សារួត ដើម្បីយក ទៅធ្វើបុណ្យតាមប្រពៃណីនៅស្រុកកំណើត

https://www.facebook.com/ Pheak Tra Live 30/08/19

ករណីពលករខ្មែរ ឈ្មោះ អ៊ូ សារួត បានស្លាប់បាត់បង់ជីវិត ក្នុងហេតុការណ៍ រលំផ្ទាំងស៊ីម៉ង់ត៍សង្កត់ស្លាប់ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ នៅក្នុងការដ្ឋានសំណង់សាងសង់អាគារមួយកន្លែង ម្តុំ(Soi)អើកការធៃ ១៣៩ សង្កាត់បាងណាមជឹត ស្រុកមឿងខេត្តសាមុតសារខន ប្រទេសថៃនៅព្រឹកថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលឯកសារជូនសាច់ញាតិ ដើម្បីយកសពទៅធ្វើបុណ្យតាមប្រពៃណីនៅស្រុកកំណើត ។ ក្នុងនោះដែរស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ចូលរួមថវិកាបុណ្យសពមួយចំនួន និងសម្តែងការសោកស្តាយដល់ក្រុមគ្រួសារសាច់ញាតិ ពលករខ្មែរ ដែលស្លាប់បាត់បង់ជីវិត នៅហេតុការណ៍ខាងលើនេះ។

## កម្លាំងសមត្ថកិច្ចថៃ ឃាត់ខ្លួន ពលរដ្ឋ ខ្មែរ ចំនួន ០៩នាក់ ចំណាក់ស្រុកខុសច្បាប់

https://www.facebook.com/ Pheak Tra Live 29-08-2019

ការឃាត់ខ្លួនពលរដ្ឋខ្មែរខាងលើនេះបានធ្វើឡើងកាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ នៅម្តុំចំណតរថភ្លើងក្នុងខេត្តណាខនប៉ាធុម ប្រទេសថៃ យោងតាមរបាយការណ៍របស់ សមត្ថកិច្ចថៃបានអោយដឹងថា ពលរដ្ឋខ្មែរទាំងអស់ធ្វើដំណើរពីប្រទេសម៉ាឡេស៊ី ទៅប្រទេសកម្ពុជា តាមរយៈរថភ្លើងពីខេត្តបាតតានី ប៉ុន្តែពលរដ្ឋខ្មែរទាំងអស់គ្មានលិខិតស្នាមស្គាល់ខ្លួនឡើយ។ ក្រោយការសាកសួរស្រាវជ្រាវសមត្ថកិច្ចថៃបានធ្វើការចោទប្រកាន់ MSS. YANARIMAS SCN អាយុ 45ឆ្នាំ ពីបទនាំជនបរទេសគ្មានលិខិតស្នាមចូលប្រទេសថៃ។
ពលរដ្ឋខ្មែរ ដែលត្រូវសមត្ថកិច្ចថៃឃាត់ខ្លួនមានដូចខាងក្រោម៖

1. MSS. YANARIMAS SCN អាយុ 45ឆ្នាំ
2.MR.LACH SOKHEAN អាយុ 45 ឆ្នាំ
3.MR.SIN SENAN អាយុ 45 ឆ្នាំ
4.MR.SOK KHIMYUM អាយុ 45 ឆ្នាំ
5.MR.NON REM អាយុ 45 ឆ្នាំ
6.MISS.HIM BATRE អាយុ 45 ឆ្នាំ
7.MISS YOU ARIYAS อายุ 45 ឆ្នាំ
8.MISS KHON MOM អាយុ 45 ปี
9.MISS NH PERY អាយុ 45 ឆ្នាំ